

ការរីកចម្រើននៃវិទ្យាសាស្ត្រដែលជួយឱ្យមនុស្សបង្កើតស្នាដៃយ៉ាងអស្ចារ្យគ្រប់វិស័យដូចសព្វថ្ងៃនេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងទស្សនវិជ្ជា។ ប៉ុន្តែ ដោយសារពេលវេលាដើរទៅមុខកាន់តែលឿន មនុស្សភាគច្រើនភ្លេចគិតថា ទស្សនវិជ្ជាស្ថិតនៅក្នុងចំណោមដើមកំណើតនៃចំណេះដឹងដែលជួយធ្វើឱ្យមនុស្សអភិវឌ្ឍគំនិតរបស់ខ្លួន។ វិទ្យាសាស្ត្រមិនអាចកាត់ផ្ដាច់ចេញពីទស្សនវិជ្ជាបានទេ ហើយអនាគតក៏មិនអាចគ្មានអតីតកាលជាមូលដ្ឋានដែរ។

នៅក្នុងវណ្ណកម្មនេះ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន នាំអ្នកអានទៅក្នុងពិភពនៃគំនិតដែលលាតសន្ធឹងលើពេលវេលាជាង២៦០០ឆ្នាំ និងបង្ហាញប្រព័ន្ធពុទ្ធិរបស់ទស្សនវិទូជាង៤០រូបដែលបានចូលរួមចំណែកក្នុងវិភាគទានដើម្បីយល់ដឹងពិភពលោក និងដំណើរជីវិតមនុស្សឱ្យកាន់តែប្រសើរឡើង។

ISBN: 978 99243 40 40 9

សិក្សាសង្ខេបស្ដីពីទស្សនវិជ្ជា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

# សិក្សាសង្ខេបស្ដីពី

# ទស្សនវិជ្ជា



ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា
Sipar
២០១៨

## សិក្សាសង្ខេបស្ដីពី

# ទស្សនវិជ្ជា

# សិក្សាសង្ខេបស្តីពី

# ទស្សនវិជ្ជា

ដោយ បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**២០១៨**

*រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការSipar*
*© ហង់ជួន ណារ៉ុន*
*រក្សាសិទ្ធិគ្រប់យ៉ាង*

*បោះពុម្ពនៅកម្ពុជាដោយរោងពុម្ពស៊ុន ហ៊ាង*

# មាតិកា

**អារម្ភកថា**..................................................................................... ៩

## ជំពូកទី១
**ទស្សនវិជ្ជាពុទ្ធសាសនា**....................................................................... ១៧

## ជំពូកទី២
**ទស្សនវិជ្ជាក្រិកបុរាណ** ....................................................................... ២១

*១- តាលែស*............................................................................................... ២៥

*២- អេវ៉ាគ្លីត និង ប៉ារមេនីដ*................................................................. ២៧

*៣- ហេរ្យណាង និងពួកអាតូមនិយម*........................................................ ៣១

*៤- ពួកសូហ្វីសត៍*......................................................................................... ៣៣

*៥- សូក្រាត* ................................................................................................ ៣៤

*៦- ប្លាតុង*..................................................................................................... ៤០

*៧- អារីស្តូត* ................................................................................................ ៤៨

*៨- សាលាអេពីគួរ និងសាលាខន្តីនិយម*........................................................ ៥៣

## ជំពូកទី៣
**ទស្សនវិជ្ជាមជ្ឈិមសម័យ**.......................................................................... ៥៧

*៩- សាំង អូហ្គូស្តាំង*...................................................................................... ៥៨

*១០- តូម៉ាស ដាក់កាំង*.................................................................................... ៦០

**ទស្សនវិជ្ជានៃបុនរុត្ថានសម័យ** ....................................................................... ៦៥



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ជំពូកទី៤


**ទស្សនវិជ្ជាសម័យថ្មី** ........................................ ៦៩

១១- ហ្វ្រង់ស៊ីស បេកិន ........................................ ៧១

**ទស្សនវិជ្ជាវិចារណញ្ញាណនិយម** ........................................ ៧៥

១២- រ៉េណេ ដេកាត ........................................ ៧៦

១៣- ស្ពីណូហ្សា ........................................ ៨១

១៤- ឡៃបនិត ........................................ ៨៥

**ទស្សនវិជ្ជាពិសោធនិយម** ........................................ ៨៨

១៥- ចន ឡុក្ក ........................................ ៨៩

១៦- ដេវីដ ហ្យូម ........................................ ៩១

**ទស្សនវិជ្ជាមនោនិយម** ........................................ ៩៤

១៧- អេម៉ាណុយអែល កង់ត៍ ........................................ ៩៤

១៨- ហ្គតលៀម ហ្វិកត៍ ........................................ ១០៦

១៩- ហ្វ្រីឌ្រីច ស្ហែលលីង ........................................ ១០៩

២០- ហ្វ្រីឌ្រីច ហេហ្គែល ........................................ ១១៥


## ជំពូកទី៥


**ទស្សនវិជ្ជាសម័យទំនើប** ........................................ ១២១

២១- អាតួ ស្សូប៉ែនអាវ ........................................ ១២២

២២- លូដវីគ ហ្វួយ័របាក់ ........................................ ១២៦

២៣- អូហ្គុស កុងត៍ ........................................ ១៣០

២៤- អង់រី ប៉ែកសុន ............................................................. ១៣២
២៥- សូរ៉េន គៀរគឺហ្គាដ ..................................................... ១៣៧
២៦- ហ្វ្រីឌ្រីច នីតស៍ ............................................................. ១៤២
២៧- អេដមុន ហ៊ូស្សែរល ......................................................... ១៤៦
២៨- ម៉ាទីន ហៃដឺហ្គ័រ ............................................................. ១៥០
២៩- កាល ហ្យាស្ពែរ ............................................................... ១៥៣
៣០- ហ្សង់-ប៉ូល សាត្រ ............................................................ ១៥៨
៣១- ហាណា អារ៉េន ............................................................... ១៦២

## ជំពូកទី៦

**ទស្សនវិជ្ជាចុងស.វ.ទី២០ និងដើមស.វ.ទី២១** ............... ១៦៧
**ទស្សនវិជ្ជាវិភាគនិយម** ..................................................... ១៦៧
៣២- ប៊ែរត្រង់ រ៉ាស់ស្សែល ........................................................ ១៦៩
៣៣- វីតហ្គែនស្តាញ ................................................................. ១៧១

**ទស្សនវិជ្ជាក្រោយវិជ្ជមាននិយម** ........................................... ១៧៧

**ទស្សនវិជ្ជារចនាសម្ព័ន្ធនិយម** .............................................. ១៨១
៣៤- មីស្សែល ហ្វូកូល ............................................................... ១៨៣

**ទស្សនវិជ្ជាក្រោយទំនើបនិយម** ............................................. ១៨៦
៣៥- ហ្សាក់ ដេរីដា ................................................................. ១៩១
៣៦- ហ្សីល ឌើលូស្ស ............................................................... ១៩៥
៣៧- រ៉ូទី ................................................................................ ១៩៨



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ទស្សនវិជ្ជាស្មារតីនិយម** ........................................ ២០២
*៣៨- ដេនណោត* ........................................ ២០៦
*៣៩- ចន សើល* ........................................ ២១០
*៤០- ភីង់ឃើ*........................................ ២១៥

**ទស្សនវិជ្ជាលទ្ធផលនិយម**........................................ ២២០
*៤១- អាផែល* ........................................ ២២០
*៤២- ហាបើរម៉ាស* ........................................២២៥

**ទស្សនវិជ្ជាចរិយាធម៌និយម**........................................ ២៣០
*៤៣- សីង់ហ្គើរ*........................................ ២៣០

**វាក្យស័ព្ទទស្សនវិជ្ជា**........................................ ២៣៧

**គន្ថនិទ្ទេស**........................................២៤៣

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ........................................ ២៤៩

**ស្នាដៃរបស់អ្នកនិពន្ធ** ........................................ ២៥១



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អារម្ភកថា

*បំណងសរសេរសៀវភៅ* **ប្រវត្តិទស្សនវិជ្ជា** *នេះខ្ញុំមានជាយូរមកហើយ។ ខ្ញុំបានចាប់ចិត្តប្រតិព័ទ្ធជាមួយមុខវិជ្ជាទស្សនវិជ្ជា ដោយសារសាស្ត្រាចារ្យពីររូបគឺ៖ សាស្ត្រាចារ្យ* **ឌីរដា** *(Prof. Dyrda I.) ដែលបង្រៀនមុខវិជ្ជា* **តក្កវិជ្ជា** *នៅឆ្នាំទីមួយនៅមហាវិទ្យាល័យទំនាក់ទំនងអន្តរជាតិ និងច្បាប់អន្តរជាតិនៃសាកលវិទ្យាល័យជាតិទីក្រុងគៀវ (Kiev State University) រដ្ឋអ៊ុយក្រែន សហភាពសូវៀត និងសាស្ត្រាចារ្យ* **ខ្រូសតូវ** *(Prof. Khrustov H.F.) ដែលបង្រៀនមុខវិជ្ជា* **ទស្សនវិជ្ជា** *ដល់និស្សិតថ្នាក់បណ្ឌិតនៅ* **វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិទីក្រុងម៉ូស្គូ** *(Moscow State Institute of International Relations-MGIMO)។ និស្សិតថ្នាក់បណ្ឌិតដែលរៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមនៅសហភាពសូវៀត ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ត្រូវរៀនមុខវិជ្ជាទស្សនវិជ្ជា ដើម្បីប្រឡងថ្នាក់ជាតិ និងប្រឡងមុខវិជ្ជាបីទៀត ទើបអាចការពារនិក្ខេបបទថ្នាក់បណ្ឌិតបាន។ មេរៀនទស្សនវិជ្ជាជំនាន់នោះផ្តោតលើប្រវត្តិទស្សនវិជ្ជា និងទស្សនៈរបស់ទស្សនវិទូធំៗ ពីទស្សនវិទូបុរាណរបស់ក្រិក គឺ* **តាលែស** *(Thalès) និង* **សូក្រាត** *រហូតដល់* **ម៉ាក្ស**។

*ខ្ញុំយល់ឃើញថា ការសិក្សាតក្កវិជ្ជា និងទស្សនវិជ្ជាមានប្រយោជន៍សម្រាប់ឱ្យយុវជនបណ្តុះគំនិតត្រិះរិះពិចារណា ដោះស្រាយបញ្ហា ចេះស្រមើស្រមៃ និងមានគំនិតច្នៃប្រឌិត។ គេតែងតែចាត់ទុក* **សូក្រាត** *ជាបិតានៃទស្សនវិជ្ជា ហើយ* **អារីស្តូត** ( ៣៨៤-៣២២ មុន.គ.ស.) *ជាបិតានៃតក្កវិជ្ជា។ លោកបានរៀបចំជាវិធានសម្រាប់ការវាយតម្លៃដែលហៅថា វិធាន* **ត្រៃយានិយម** *(Syllogisme) ដោយប្រើ* **សព្វឯកាវិធី** *(Déduction) ដែលត្រូវបានគេយកទៅរៀបចំជាប្រព័ន្ធតក្កវិជ្ជាគ្រប់ជ្រុងជ្រោយ។ តក្កវិជ្ជាគឺជា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិទ្យាសាស្ត្រស្តីពីការវាយតម្លៃអំណះអំណាង ដែលរួមទាំងវិធីសាស្ត្រ និង លក្ខណវិនិច្ឆ័យ ដើម្បីឱ្យគេអាចសន្និដ្ឋានថា អំណះអំណាងនេះគួរឱ្យទុកចិត្តបាន។ អំណះអំណាងគឺជាសេចក្តីថ្លែងការមួយចំនួនដែលមានសក្ខីកម្ម ឬជាលក្ខខណ្ឌ និងសេចក្តីសន្និដ្ឋានដែលជាលទ្ធផលនៃការអនុវត្តលក្ខខណ្ឌនេះ។

ឧទាហរណ៍ ៖ (១) ប្រយោគច្បង ៖ មនុស្សទាំងអស់ត្រូវតែស្លាប់

(២) ប្រយោគរង ៖ **សូក្រាត**ក៏ជាមនុស្ស

(៣) ការសន្និដ្ឋាន ៖ ដូច្នេះ **សូក្រាត**ត្រូវតែស្លាប់។

ខ្ញុំតែងតែប្រើប្រាស់នូវចំណេះដឹងខាងផ្នែកទស្សនវិជ្ជានេះក្នុងការងារប្រចាំថ្ងៃរបស់ខ្ញុំ ដូចជាវិធីសាស្ត្របង្រៀនរបស់ **សូក្រាត** ឱ្យចេះចោទសួរជាសំណួរក្នុងគោលដៅស្វែងរកសច្ចធម៌។ **ដេកាត** បានបង្កើតប្រព័ន្ធទស្សនវិជ្ជា **វិចារណនិយម** *(le rationalisme)* ដែលជាវិធីសាស្ត្រគិតមួយដ៏សំខាន់ក្នុងវិស័យតក្កវិទ្យា និងទស្សនវិជ្ជាក្នុងគោលដៅចោទសួរ និងដោះស្រាយបញ្ហាប្រកបដោយវិចារណៈគឺ ៖ (១) ការត្រិះរិះពិចារណាតាមបែប **ឯកសព្វភាព** *(Induction)* ពោលគឺការសិក្សាពីករណីដាច់ដោយឡែកជាច្រើន ដើម្បីធ្វើសេចក្តីសន្និដ្ឋាន និងសំយោគរួម និង (២) ការត្រិះរិះពិចារណាតាមបែប **សព្វឯកភាព** *(Déduction)* ពោលគឺការសិក្សាដោយយកករណីរួម មកញែកជាដុំតូចៗ ដើម្បីធ្វើការវិភាគ។

ទស្សនវិជ្ជាដែលភាសាឡាតាំងហៅថា philosophia នេះអាចបកប្រែជាភាសាខ្មែរថា ការស្រឡាញ់ *(philo)* គតិបណ្ឌិត *(sophia)*។ គេតែងតែនិយាយថា **ទស្សនវិជ្ជា គឺជាវិទ្យាសាស្ត្រនៃវិទ្យាសាស្ត្រ**។ ទស្សនវិទូភាគច្រើនសុទ្ធសឹងតែជាអ្នកប្រាជ្ញខាងផ្នែកវិទ្យាសាស្ត្រ ដូចជា **តាឡែស** និង **ពីតាហ្គ័រ** សុទ្ធសឹងតែជាគណិតវិទូបុរាណ។ ហើយទន្ទឹមនឹងនេះអ្នកប្រាជ្ញមួយចំនួនក៏ជាទស្សនវិទូផងដែរ។ ដូច្នេះហើយទើបអ្នកសិក្សាទស្សនវិជ្ជាតម្រូវឱ្យមានសញ្ញាណស្តីពីវិទ្យាសាស្ត្រពិត ដើម្បីយល់ច្បាស់ពីទស្សនា-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាននៃទស្សនវិជ្ជា។ ទស្សនវិទូនិយាយមិនសូវត្រូវគ្នាទេ។ ទស្សនវិទូក្រោយៗតែងតែអាចបដិសេធទ្រឹស្តីដែលទស្សនវិទូមុនៗបានលើកឡើង។ ថ្វីត្បិតតែយ៉ាងនេះក៏ដោយ ទស្សនវិជ្ជានៅតែជាមុខវិជ្ជាដ៏សំខាន់នៅក្នុងការបណ្តុះបណ្តាលបញ្ញវន្ត ដោយសារតែទស្សនវិជ្ជាបង្រៀនមនុស្សឱ្យចេះគិត ហើយទស្សនវិទូត្រូវតែបង្ហាញថា ទ្រឹស្តីរបស់ខ្លួនមានលក្ខណៈតក្កវិទ្យា។ សាកលវិទ្យាល័យ គឺជាថ្នាលមួយដ៏សំខាន់ក្នុងការស្រាវជ្រាវទស្សនវិជ្ជា។ សាកលវិទ្យាល័យ គឺជាស្ថាប័នដែលអ្នកស្រាវជ្រាវអាចបញ្ចេញមតិរបស់ខ្លួន និងធ្វើការស្រាវជ្រាវដោយសេរី ដើម្បីឱ្យមានវឌ្ឍនភាពខាងផ្នែកវិទ្យាសាស្ត្រ។

យ៉ាងណាមិញ ទស្សនវិជ្ជាចូលរួមចំណែកយ៉ាងខ្លាំងក្លា ក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រ។ លោក **ដេកាត** ដែលជាទស្សនវិទូបារាំងនាពាក់កណ្តាលទី១នៃសតវត្សរ៍ទី១៧ បានបោះផ្សាយស្នាដៃ «**អភិប្រាយស្តីពីវិធីសាស្ត្រ**» ដែលជំរុញឱ្យមានការត្រិះរិះពិចារណា *Je pense, donc je suis* ជាភាសាឡាតាំង Cogito ergo sum និងចូលរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រពិត។ **កង់ត៍** ក៏ជាទស្សនវិទូអាឡឺម៉ង់ដ៏ឆ្នើមម្នាក់ដែរ ហើយដែលមានទម្លាប់គោរពពេលវេលាយ៉ាងខ្លាំងក្លា។ ស្នាដៃរបស់ **កង់ត៍** មានគោលដៅសិក្សាពីវិធីសាស្ត្រក្នុងការបង្កើតនូវវិទ្យាសាស្ត្រថ្មី នៅពេលនោះគឺ រូបវិទ្យា។

នៅកម្ពុជា គេមិនសូវឃើញមានស្នាសរសេរច្រើនលើប្រធានបទទស្សនវិជ្ជាទេ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ មានអ្នកនិពន្ធតែពីរបីរូបប៉ុណ្ណោះដែលបានបោះពុម្ពផ្សាយស្នាដៃទស្សនវិជ្ជាជាខេមរភាសា។ ស្នាទីមួយ គឺបណ្ឌិតសភាចារ្យ **រស់ ចន្ត្រាបុត្រ** ដែលបានធ្វើការសិក្សាស្តីពី «**សូក្រាត**» នៅឆ្នាំ១៩៧២។ ស្នាទីពីរ គឺសាស្ត្រាចារ្យ **សរ សារុន** ដែលបានសរសេរសៀវភៅស្តីពី «**អត្ថាធិប្បាយទស្សនវិជ្ជា**» សម្រាប់ថ្នាក់ទីបញ្ចប់ និងថ្នាក់ឧត្តមសិក្សានៅឆ្នាំ១៩៧៤ដែលផ្តល់នូវសញ្ញាណខ្លះពីទស្សនវិជ្ជា។ សំណេររបស់ព្រះមហាវិរិយបណ្ឌិតោ **ប៉ាង ខាត់** បោះផ្សាយក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទស្សនាវដ្ដី **កម្ពុជសុរិយា** ក្នុងឆ្នាំ១៩៦៩ ផ្ដោតលើ«**ទស្សនវិជ្ជាពុទ្ធសាសនា**»។

ការស្រាវជ្រាវលើប្រធានបទនៃទស្សនវិជ្ជាបានចាប់ផ្ដើមវិញក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ដែលផ្ដោតលើតែទស្សនវិជ្ជាបែបម៉ាក្សនិយម។ ទើបតែក្នុងអំឡុងឆ្នាំ២០០០ ទើបមានអ្នកស្រាវជ្រាវមួយចំនួនចាប់ផ្ដើមសរសេរដើម្បីផ្សព្វផ្សាយទស្សនវិជ្ជា ក្នុងមជ្ឈដ្ឋានសាកលវិទ្យាល័យ។ ស្នាដៃទាំងនោះមាន «**អំណាចទស្សនវិជ្ជាពីលោកធាតុទៅលោកម៉ាក្ស**» របស់លោក **អេវ៉ាន អេស្លី** ក្នុងឆ្នាំ២០១២ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (បោះពុម្ពលើកទី២) «**មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជា**» របស់បណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ក្នុងឆ្នាំ២០០៦ និង «**មូលដ្ឋានរបស់ទស្សនវិជ្ជា**» របស់អ្នកស្រាវជ្រាវមួយក្រុម គឺ **ខ្មៅ សាវន**, **ប៉ាន់ ឧត្ដា**, **ឈត ម៉ុនថន**, **ឈុន ផាវ៉េង** និង **អ៊ុន លាង** ក្នុងឆ្នាំ២០០៨ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ក្នុងឆ្នាំ២០១៣ លោក **វ៉ាន់ឌី ការអុន** ដែលជាអ្នកនិពន្ធចាស់វស្សាមួយរូបបានបោះពុម្ពផ្សាយស្នាដៃរបស់លោកដែលមានចំណងជើងថា «**និន្នាភាពខ្លះៗនៃទស្សនវិជ្ជា**» ចាប់ពីសតវត្សរ៍ទី៦ មុនគ្រិស្ដសករាជមកដល់សព្វថ្ងៃ។ សៀវភៅនេះបញ្ចប់ត្រឹមទស្សនវិជ្ជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ដែលមានជាអាទិ៍គឺលោក **ហ្សង់-ប៉ូល សាត្រ** ដែលជាបវរទស្សនវិជ្ជាអត្ថិភាពនិយម។

នាពេលបច្ចុប្បន្ន ទស្សនវិជ្ជាបានបន្ដរីកចម្រើនដែលបង្កើតជាទស្សនវិជ្ជាថ្មីៗទៀត ដូចជាទស្សនវិជ្ជាវិភាគនិយម ទស្សនវិជ្ជាក្រោយវិជ្ជមាននិយម ទស្សនវិជ្ជារចនាសម្ព័ន្ធនិយម ទស្សនវិជ្ជាក្រោយទំនើបនិយម ទស្សនវិជ្ជាស្មារតីនិយម និងទស្សនវិជ្ជាភាសានិយម។ ដូច្នេះហើយ ទើបមានការចាំបាច់ក្នុងការធ្វើការសិក្សាបន្ត ដើម្បីឱ្យយុវជនខ្មែរបានដឹង និងបានយល់ពីទស្សនវិជ្ជាចុងសតវត្សរ៍ទី២០ និងដើមសតវត្សរ៍ទី២១។ សៀវភៅទស្សនវិជ្ជានេះក៏



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នឹងជួយបំពេញបន្ថែមលើចំណុចទាំងឡាយដែលអ្នកនិពន្ធមុនៗមិនបាន សរសេរ។

គោលដៅនៃការសរសេរសៀវភៅទស្សនវិជ្ជានេះ គឺដើម្បីបណ្តុះឱ្យកូនខ្មែរមានការត្រិះរិះពិចារណា និងត្រៀមខ្លួនរួចជាស្រេចដើម្បីជួបនឹងបញ្ហាប្រឈមដែលបង្កើតឡើងដោយបដិវត្តន៍ឧស្សាហកម្មលើកទីបួន។ ក្នុងបរិការណ៍នៃស្វ័យប្រវត្តិភាវូបនីយកម្ម និងការវិវត្តនៃបច្ចេកវិទ្យាដ៏លឿនដូចព្យុះនេះ យុវជនត្រូវមានបំណិនក្នុងការគិត ការត្រិះរិះពិចារណា ការធ្វើការងារជាក្រុម និងចេះដោះស្រាយបញ្ហា។ ក្នុងន័យនេះ ការរៀនទស្សនវិជ្ជានឹងជួយឱ្យពួកគេមានបំណិនទន់ដែលចាំបាច់សម្រាប់ការងាររបស់ពួកគេក្នុងពេលអនាគត។

ម្យ៉ាងវិញទៀត វិទ្យាសាស្ត្រនៃអនាគត គឺជាការធ្វើសមាហរណកម្មរវាងគណិតវិទ្យា ជីវវិទ្យា រូបវិទ្យា បច្ចេកវិទ្យាព័ត៌មានវិទ្យា បច្ចេកវិទ្យាណាណូ។ ក្នុងបរិការណ៍នេះ អ្នកវិទ្យាសាស្ត្រត្រូវចេះធ្វើការជាមួយគ្នា ដើម្បីកំណត់ទិសដៅនៃការវិវត្តនៃវិទ្យាសាស្ត្រ។ មានតែទស្សនវិទូទេដែលត្រូវចោទសួរនូវសំណួរថា តើនាពេលអនាគតវិទ្យាសាស្ត្រនឹងវិវត្តតាមទិសដៅណាមួយ។

ក្នុងន័យនេះ ការសិក្សាទស្សនវិជ្ជាត្រូវតែចោទសួរពីអ្វីៗទាំងអស់ ហើយមិនត្រូវសន្និដ្ឋានអ្វីទាំងអស់។ ទស្សនវិជ្ជាគឺជាការផ្តល់នូវទឡ្ហីករណ៍ ឬអំណះអំណាង ក្នុងគោលដៅធ្វើសេចក្តីសន្និដ្ឋាន។ ដើម្បីឈានទៅរកសេចក្តីសន្និដ្ឋាន ទស្សនវិទូត្រូវមានសំណើ (premise) សម្រាប់ទឡ្ហីករណ៍ ពោលគឺជាមូលដ្ឋានគ្រឹះដែលត្រូវចាត់ទុកថាជាការពិត។ សំណើនេះត្រូវតែកំណត់ថាពិត ដោយឈរលើមូលដ្ឋាននៃសក្ខីកម្ម ឬទស្សនាទានជាដើម។ ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ទស្សនវិទូតែងតែប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ដូចជាសព្វឯកវិធី (deduction) ឯកសព្វវិធី (induction) ជាដើម។ ដូច្នេះ ទស្សនវិទូត្រូវបន្តដើរតួនាទីឈានមុខក្នុងការសិក្សាពីវិទ្យាសាស្ត្រនៃអនាគត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងស្នាដៃនេះ អ្នកនិពន្ធបានលើកឡើងនូវទ្រឹស្តីទស្សនវិជ្ជាជាច្រើន។ អ្នកអានមិនត្រូវរៀនដោយទន្ទេញចាំមាត់នូវទ្រឹស្តីទាំងនោះទេ ហើយត្រូវចាត់ទុកថា គំនិតដែលលើកឡើង គឺគ្រាន់តែជាគំនិតមួយក្នុងចំណោមគំនិតជាច្រើន។ គ្មានទ្រឹស្តីមួយណាដែលពេញលេញទេ។ ដូច្នេះ ការសិក្សាទស្សនវិជ្ជា គឺបង្រៀនឱ្យអ្នកអានចេះគិត ចេះទិតៀនក្នុងន័យស្ថាបនានូវទស្សនៈផ្សេងៗ ចេះចាប់យកគំនិតល្អៗក្នុងទ្រឹស្តី ហើយត្រូវមើលឱ្យឃើញដោយខ្លួនឯងនូវគំនិតថ្មីផ្សេងទៀត ដែលគេមិនបានសរសេរនៅក្នុងទ្រឹស្តីទាំងឡាយនោះ។ នៅក្នុងប្រព័ន្ធទស្សនវិជ្ជានីមួយៗតែងតែមានគំនិតល្អ និងចំណុចខ្វះខាត ចំណុចខ្លាំង និងចំណុចខ្សោយ។ ពោលគឺការសិក្សាទស្សនវិជ្ជា គឺការបង្រៀនឱ្យចេះគិត ឱ្យចេះធ្វើអំណះអំណាង ឱ្យចេះរកសច្ចធម៌ដោយខ្លួនឯង។

ដូចបានរៀបរាប់ខាងលើ នេះគឺជាមូលហេតុដែលខ្ញុំសម្រេចចិត្តយកសៀវភៅទី២០របស់ខ្ញុំ ដើម្បីឧទ្ទិសដល់ **ទស្សនវិជ្ជា** ដែលជាមុខវិជ្ជាដែលមិនត្រឹមតែខ្ញុំចូលចិត្ត នៅពេលដែលខ្ញុំជានិស្សិតថ្នាក់បណ្ឌិតនៅវិទ្យាស្ថានរដ្ឋទំនាក់ទំនងអន្តរជាតិទីក្រុងម៉ូស្គូ (MGIMO) ប៉ុណ្ណោះទេ តែគឺជាមុខវិជ្ជាមួយដែលជួយឱ្យខ្ញុំធ្វើការវិភាគពីស្ថានការណ៍ផ្សេងៗដែលពាក់ព័ន្ធនឹងការងារប្រចាំថ្ងៃរបស់ខ្ញុំ។ ម្យ៉ាងវិញទៀត គោលដៅដ៏សំខាន់នៃកំណែទម្រង់វិស័យអប់រំ គឺការផ្តល់ឱ្យយុវជនកម្ពុជាមិនត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ តែយុវជនត្រូវមានបំណិនទន់ដែលជាបំណិនក្នុងការគិត ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា និងមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីសម្រេចឱ្យបាននូវសុបិន្តរបស់ខ្លួន។

ខ្ញុំសរសេរសៀវភៅទស្សនវិជ្ជានេះឡើង គឺដើម្បីរំឭកពីអនុស្សាវរីយ៍កាលពីយុវភាពផង ចែករំលែកចំណេះដឹង និងពុទ្ធិដ៏ស្តួចស្តើងនេះជាមួយយុវជនកម្ពុជាផង និងដើម្បីសម្រេចសុបិន្តរបស់ខ្ញុំផងដែលចង់ឱ្យមានការសិក្សាទស្សនវិជ្ជាឡើងវិញនៅតាមវិទ្យាល័យ និងនៅតាមគ្រឹះស្ថានឧត្តម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សិក្សាកម្ពុជា ក្នុងគោលដៅឱ្យយុវជនកម្ពុជាចេះស្រឡាញ់វិទ្យាសាស្ត្រនៃអនាគតកាលនេះ។*

*ថ្ងៃចន្ទ ១៣ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១*
*ភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៨*
**ហង់ជួន ណារ៉ុន**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី១
# ទស្សនវិជ្ជាពុទ្ធសាសនា
**(៥០០ឆ្នាំមុនគ្រិស្តសករាជ)**

*ព្រះពុទ្ធសាសនាមានប្រភពមកពីប្រទេសឥណ្ឌា ក្នុងអំឡុងសតវត្សរ៍ទី៥មុនគ្រិស្តសករាជនៅពេលដែលព្រះសមណគោត្តមទ្រង់ប្រសូតចាកឧទរមាតា ទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណ និងទ្រង់រំលត់ខន្ធចូលកាន់ព្រះបរមនិព្វានដែលពុទ្ធសាសនិកជនតែងតែប្រារព្ធពិធីបុណ្យវិសាខបូជា នាថ្ងៃពេញបូណ៌មី (គឺថ្ងៃ១៥កើត) ខែពិសាខជារៀងរាល់ឆ្នាំ។*

*នៅក្នុងទស្សនាវដ្ដី* **កម្ពុជសុរិយា** *ឆ្នាំ១៩៦៩ ព្រះមហាវីរិយបណ្ឌិតោ* **ប៉ាង ខាត់** *បានចុះផ្សាយនូវអត្ថបទមួយដែលមានចំណងជើងថា «***ទស្សនវិជ្ជាពុទ្ធសាសនា***» ដែលមានខ្លឹមសារសង្ខេបដូចតទៅ ៖*

**ព្រះពុទ្ធជាមនុស្សពិតប្រាកដ** ៖ *ពុទ្ធសាសនាជាបដិបទាផ្លូវប្រតិបត្តិជាកម្មនិយម ឬជាវិធីបំបាត់អវិជ្ជា តណ្ហា ឧបាទានកម្ម។ មនុស្សគ្រប់រូបអាចប្រើសក្ដានុភាពខ្លួន ជាមនុស្សឱ្យបានសម្រេចភាពជាព្រះពុទ្ធបាន បើមានបំណងមាំ និងមានវីរិយភាពធំ។ មនុស្សជាម្ចាស់ខ្លួនឯង ឥតមានអំណាចអ្វីមួយប្រសើរជាងវាសនាខ្លួនជាមនុស្សនេះទេ។ មនុស្សត្រូវកសាងខ្លួនដោយខ្លួនឯង ឱ្យរួចស្រឡះពីចំណងតណ្ហា ដោយវីរិយភាព និងបញ្ញាជារបស់ខ្លួនឯងជាមនុស្ស។ ព្រះពុទ្ធបានត្រឹមត្រាស់ដឹងធម៌ ទេសនាចង្អុលប្រាប់ផ្លូវឱ្យសត្វដើរដោយខ្លួនឯង។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សេរីភាពក្នុងការគិត** ៖ ព្រះសម្ពុទ្ធទ្រង់ប្រទានដល់សាវកព្រះអង្គនូវសេរីភាពក្នុងការគិត ដោយសារអត្តាធិនភាព(ការរំដោះខ្លួន)របស់មនុស្សលោក ស្ថិតនៅក្នុងអភិសម័យ(ការសម្រេចបាន)នៃអរិយសច្ចធម៌ មិនមែននៅក្រោមការប្រោសនៃព្រះអាទិទេព ឬអំណាចនៃបុគ្គលណាមួយឡើយ។ ដូច្នេះ ព្រះពុទ្ធទ្រង់សុំឱ្យសាវកប្រព្រឹត្តតាមនូវអ្វីជាកុសល ជារបស់ប្រសើរ និងវៀរចាកអ្វីជាអកុសល ខុសគន្លងធម៌។

**ការបំបាត់សេចក្ដីមន្ទិលសង្ស័យ** ៖ ក្នុងព្រះពុទ្ធសាសនា **វិចិកិច្ឆា** (សេចក្ដីសង្ស័យ) ជាធម៌រាំងបិទមិនឱ្យយល់អរិយសច្ចធម៌ ឬមិនឱ្យកើតសេចក្ដីចម្រើនគ្រប់ប្រការ។ **វិចិកិច្ឆា**មិនមែនជាអំពើបាបកម្មទេ។ ក្នុងពុទ្ធសាសនាមិនមានបាបកម្មឡើយ។ ឫសគល់នៃបាបកម្ម គឺអវិជ្ជា និង **មិច្ឆាទិដ្ឋិ** (ទស្សនៈខុស)។ ក៏ប៉ុន្តែ ប្រសិនបើមានការជឿងឆ្ងល់ហើយ សេចក្ដីចម្រើនពិតមិនអាចកើតឡើងបានឡើយ។ ព្រះសម្មាសម្ពុទ្ធត្រាស់ទេសនាប្រដៅជានិច្ចថា ត្រូវបំបាត់**វិចិកិច្ឆា** ចោលឱ្យអស់មុនបរិនិព្វាន។

**ខន្តីធម៌ និង មេត្តាប្រោសប្រណី** ៖ ព្រះសម្ពុទ្ធទ្រង់មានព្រះហឫទ័យទូលាយ និងប្រកបដោយខន្តីធម៌ មេត្តាប្រោសប្រណី សន្ដោសសាវក និងប្រទានការយោគយល់ទៅវិញទៅមកទៀតផង។ ទ្រង់ត្រាស់ទូន្មានឱ្យពិចារណាហ្មត់ចត់ ទើបសម្រេចចិត្ត ជាការប្រសើរបំផុត។ អ្នកគ្រប់គ្នាមិនត្រូវលើកដម្កើងសរសើរតែលទ្ធិសាសនារបស់ខ្លួនហើយប្រមាថលទ្ធិសាសនាដទៃទេ។ ត្រូវគោរពលទ្ធិសាសនាដទៃឱ្យដូចជាខ្លួនគោរពសាសនារបស់ខ្លួនដែរ។ សាមគ្គីជាគុណធម៌ប្រសើរណាស់ ហើយព្រះពុទ្ធសូមឱ្យសាវកស្ដាប់វាទៈនៃលទ្ធិសាសនាដទៃផង។

**ហិង្សា** ៖ ការបៀតបៀន (**ហិង្សា** = la violence) ទោះជាបែបណាក៏ដោយ ទាំងហិង្សានិងទារុណកម្មលើរាងកាយ ទាំងហិង្សាដោយប្រើប្រាស់សារធាតុគីមីផ្សេងៗដាក់ក្នុងចំណីអាហារ គ្រឿងភេសជ្ជៈ ការធ្វើទារុណកម្មលើផ្លូវចិត្ត ឬទោះជាប្រើលេសមកបន្ទំក៏ដោយ ក៏សុទ្ធតែផ្ទុយនឹងពុទ្ធវចនៈ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាំងអស់។

**សច្ចធម៌** ៖ អ្នកស្វែងរកសច្ចធម៌មិនមានប្រយោជន៍អ្វីនឹងដឹងថា សច្ចធម៌នេះកើតមកពីណាទេ។ កិច្ចការជាសារវន្ត គឺការរកឃើញធម៌ពិត ហើយបានលុះធម៌នោះដោយប្រពៃ។ ជំនឿក្នុងព្រះពុទ្ធសាសនាជាជំនឿប្រកបដោយហេតុផល (Cause et effet) ជាជំនឿប្រកបដោយវិចារណញ្ញាណ (Raisonnement) ពោលគឺ **សទ្ធា** ដែលជាជំនឿប្រកបដោយបញ្ញា (Confiance=confidence et sagesse)។ ជំនឿពុទ្ធសាសនាសំដៅយកការឃើញច្បាស់ ការដឹងច្បាស់ និងការយល់ច្បាស់។ គោលដៅធំបំផុតក្នុងព្រះពុទ្ធសាសនា គឺការត្រាស់ដឹងអរិសច្ចដែលព្រះសម្ពុទ្ធប្រើពាក្យថា «ធម្មចក្ខុ = ភ្នែកធម៌ ឬមានភ្នែកឃើញធម៌» ឃើញដោយបញ្ញាចក្ខុដោយពិត ពោលគឺ «ភ្នែកកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ»។ ចិត្តដែលជ្រះថ្លាចំពោះអំពើជាកុសល ដោយបានយកបញ្ញាពិចារណាឃើញពិត ដឹងពិត យល់ពិតថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ នេះហៅថា **បសាទសទ្ធា**។

**ធម៌វិន័យ** ៖ **ពុទ្ធវចនៈ** មានអត្ថន័យថានាំសត្វទៅកាន់ **សិវហាន សន្តិវរបទ បរមសុខ ខេមឋាន** ត្រើយត្រានអមតនិព្វានពិតប្រាកដ។ ធម៌វិន័យព្រះអង្គ ពិតជាធម៌នាំសន្តិភាព នាំសេចក្តីសុខមកប្រគល់ឱ្យសត្វលោកដែលកំពុងក្តៅពោលពលដោយភ្លើងទុក្ខ ភ្លើងកិលេសបានយ៉ាងសក្តិសិទ្ធិបំផុត។

**អរិយសច្ចធម៌** ៖ លោក **ស៊ិន សុវណ្ណនិ** ក្នុងសៀវភៅ «**អភិឥស្សរវិជ្ជារបស់ព្រះពុទ្ធ**» បានសរសេរថា **អរិយសច្ចធម៌** បួនប្រការនោះគឺ ៖ ទុក្ខជាសេចក្តីពិត ហេតុដែលនាំឱ្យកើតទុក្ខជាសេចក្តីពិត ការរលត់ទុក្ខជាសេចក្តីពិត មាគ៌ាដែលនាំទៅកាន់រលត់ទុក្ខជាសេចក្តីពិត។ ទុក្ខមានន័យក្នុងទស្សនវិជ្ជាពុទ្ធសាសនាថា ការខ្វះខាត ការមិនទៀងទាត់ ទទេ ឬសូន្យ ការមិនមានខ្លួនប្រាណ។ មាគ៌ាដែលនាំទៅកាន់រលត់ទុក្ខ គឺជា **មជ្ឈិមា**

**បដិបទា** *«ផ្លូវកណ្តាល» ដែលប្រកបដោយអង្គ៨ប្រការដ៏ប្រសើរគឺ ៖* (១) **សម្មាទិដ្ឋិ** *(ការយល់ត្រូវ)* (២) **សម្មាសង្កប្ប** *(ការត្រិះរិះត្រូវ)* (៣) **សម្មាវាចា** *(វាចាត្រូវ)* (៤) **សម្មាកម្មន្ត** *(ការងារត្រូវ)* (៥) **សម្មាអាជីវ** *(ការចិញ្ចឹមជីវិតត្រូវ)* (៦) **សម្មាវាយាម** *(ការព្យាយាមត្រូវ)* (៧) **សម្មាសតិ** *(ការរលឹកត្រូវ)* (៨) **សម្មាសមាធិ** *(ការតម្កល់ចិត្តត្រូវ)*។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី២
# ទស្សនវិជ្ជាក្រិកបុរាណ
## (ជាង៦០០ឆ្នាំមុនគ្រិស្តសករាជ)

មូលហេតុអ្វីបានជាទស្សនវិជ្ជាចាប់បដិសន្ធិនៅប្រទេសក្រិក? ក្រិកបុរាណមានជំនឿទៅលើអាទិទេពច្រើន។ គេតែងតែបន់ស្រន់ និងរៀបចំធ្វើពិធីសក្ការៈបូជាសុំសេចក្ដីសុខពីអាទិទេពទាំងនោះ។ ក្រោយមកប្រជាជនក្រិកជឿលើតែអាទិទេពតែមួយគត់ គឺ ហ្សឺស (Zeus)។ ចាប់ពីអំឡុងទសវត្សរ៍ទី៥មុនគ.ស. ប្រទេសក្រិកជួបនឹងបដិវត្តន៍វប្បធម៌ដែលធ្វើឱ្យមានការផ្លាស់ប្ដូរក្នុងជីវភាពនយោបាយ និងសង្គម និងបង្កើតបានជាចលនាទស្សនវិជ្ជាក្នុងអំឡុងពេលជាច្រើនសតវត្សរ៍។ គេឃើញមានក៏កើតឡើងនូវទីក្រុង(polis-ទីក្រុងជារដ្ឋ) ជាច្រើនដែលប្រណាំងប្រជែងគ្នាក្នុងសកម្មភាពសេដ្ឋកិច្ចនយោបាយ និងយោធា។ នៅទីក្រុងអាតែន ពលរដ្ឋគ្រប់រូបតែងតែយកចិត្តទុកដាក់លើបញ្ហានយោបាយដែល**អារីស្តូត**បានហៅថា មនុស្ស គឺជាសត្តនិករនយោបាយ។

ក្រោយមកទស្សនវិជ្ជាបានលេចជារូបរាងឡើង ហើយនាសម័យបុរាណ យុវជននៃទីក្រុងអាតែននៃប្រទេស ក្រិកបុរាណត្រូវសិក្សាទស្សនវិជ្ជានៅក្នុងសាលាទស្សនវិជ្ជាសិន មុននឹងហ្វឹកហាត់សិល្បៈយោធា។ មុខវិជ្ជាដែលត្រូវរៀនកំណត់ដោយទស្សនវិទូនៃសាលាទស្សនវិជ្ជាទាំងនោះដែលគេមានសេរីភាពក្នុងការបញ្ចេញមតិ។ ប្រការនេះធ្វើឱ្យទីក្រុងអាតែនក្លាយជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រដ្ឋធានីដ៏រីកចម្រើនមួយនៅសម័យបុរាណ និងបង្កើតជាមូលដ្ឋានគ្រឹះនៃគំនិតទស្សនវិជ្ជារបស់លោកខាងលិច។

អ្នកប្រាជ្ញត្រូវបានគេគោរព ហើយទស្សនវិទូ និងគណិតវិទូដ៏ល្បីល្បាយ **ពីតាហ្គ័រ** បានបង្កើតនូវពាក្យទស្សនវិជ្ជានេះឡើង ដើម្បីបង្ហាញផ្តល់គោរម-ងារដល់ជនណាដែលស្រឡាញ់គតិបណ្ឌិត និងពុទ្ធិ។ គេបានបង្កើតសាលាទស្សនវិជ្ជាជាច្រើន ដើម្បីបំពេញតាមត្រូវការក្នុងការបណ្តុះបណ្តាលយុវជនក្រិកឱ្យទទួលបាននូវពុទ្ធិ។ ទស្សនវិទូក៏ចាប់ផ្តើមសិក្សាបញ្ហារូបវិទ្យា ដើម្បីពន្យល់ពីធាតុភូតធម្មជាតិ ដូចជាទឹក ដី ភ្លើង និងខ្យល់។ ក្រោយមក ក៏មានទស្សនវិទូដ៏ល្បីម្នាក់ គឺ **សូក្រាត** ដែលបានចាប់ផ្តើមចោទសួរពីពុទ្ធិមុនៗ ហើយលើកទឹកចិត្តឱ្យមានការចោទសួរ ដើម្បីស្វែងរកការពិត។ ពាក្យស្លោករបស់**សូក្រាត** គឺ «អ្នកត្រូវស្គាល់ខ្លួនដោយខ្លួនឯង»។ ដូច្នេះ ពុទ្ធិចាប់ផ្តើមពីការស្គាល់ខ្លួនឯងសិន មុននឹងសិក្សាធម្មជាតិខាងក្រៅ។ ប្រការនេះបានបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ទស្សនវិជ្ជាដែលផ្សាភ្ជាប់ផ្នែកខាងក្នុង និងផ្នែកខាងក្រៅ ហើយ **សូក្រាត** ត្រូវបានទទួលស្គាល់ថាជាបិតាទស្សនវិជ្ជានៃបស្ចិមប្រទេស។

ទស្សនវិទូនាសម័យកាលចន្លោះ៦០០-៥០០ឆ្នាំមុនគ្រិស្តសករាជត្រូវបានគេចាត់ទុកថា ជា **ទស្សនវិទូមុនសូក្រាត**។ សាលាទស្សនវិជ្ជាទាំងនេះរីកចម្រើននៅប៉ែកខាងកើតនៃអេឡេអាត(éléate) និងនៅក្នុងអាណា-និគមរបស់ក្រិកនៅអ៊ីតាលីខាងត្បូង និងនៅស៊ីស៊ីល។ ទស្សនវិជ្ជានៃសាលាអ៊ីយ៉ូន(école ionienne)ផ្តោតជាសំខាន់លើបទពិសោធ(empirisme) ការពន្យល់ធាតុភូតតាមបែបធម្មជាតិ ពិភពលោករូបធាតុ វេទនារម្មណ៍(sensation) និងលក្ខណៈបន្ទាប់បន្សំនៃបញ្ហាចរិយាសាស្ត្រ(Éthique)។ ទស្សនវិទូមុន **សូក្រាត**យកចិត្តទុកដាក់សិក្សាពីពិភពលោក ពីចក្រវាល។

សាលាទស្សនវិជ្ជាល្បីៗមានសាលានៅមីឡេ(Milet) សាលាពីតាហ្គ័រ (Pythagore) សាលាអេឡេ(Élée) សាលាអាប់ឌែរ(Abdère) សាលាសូហ្វីស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(Sophistes) សាលាសង្ស័យនិយម(Sceptiques)។ល។

សាលានៅមីឡេបង្កើតឡើងដោយលោក **តាលែស** (៦២៤-៥៤៦ មុនគ.ស.)។ ទស្សនៈរបស់ **តាលែស** និងសាវករបស់គាត់ គឺលោក Anaximandre (៦១០-៥៤៦ មុនគ.ស.) និងលោក Anaximène បានបង្កើតជាមូលដ្ឋានសម្រាប់ធម្មជាតិវិទ្យា។ ចំពោះ **តាលែស ទឹក** គឺជាប្រភពនៃអ្វីៗទាំងអស់។

**អេរ៉ាគ្លីត** (Heraclitus of Ephesus) (៥៣៥-៤៧៥ មុនគ.ស.) យល់ឃើញថា អ្វីៗទាំងអស់ក្នុងធម្មជាតិស្ថិតនៅក្នុងស្ថានភាពជាលំហូរជានិរន្តរដែលភ្ជាប់គ្នាដោយរចនាសម្ព័ន្ធតក្កវិជ្ជាដែលគាត់ឱ្យឈ្មោះថា Logos។ **ភ្លើង** គឺជាសារធាតុមួយក្នុងចំណោមសារធាតុទាំងបួនដែលជានាទូវលំហូរជានិរន្តរនេះ។ **ភ្លើង** គឺជាប្រភពនៃអ្វីៗទាំងអស់ដែលបង្កើតឱ្យមានវដ្តវិលចុះវិលឡើងមិនចេះចប់។

លោក **ពីតាហ្គ័រ** (Pythagore) នៅសាម៉ុស (៥៨២-៤៩៦ មុនគ.ស.) បានបង្កើតសាលាទស្សនវិជ្ជាដ៏ល្បីល្បាញនៅក្នុងអំឡុងឆ្នាំ៥៣០ មុនគ្រិស្តសករាជ។ លោកយល់ថា នៅក្នុងធម្មជាតិមានលេខដែលអាចឱ្យគេគិតពីចក្រវាលទាំងមូលជាកន្លែងមួយរួមជាសណ្តាប់ធ្នាប់ និងមានសុខដុមនឹងគ្នា។ សាវករបស់លោកមាន Philolaus (៤៧០-៣៨០ មុនគ.ស.) និង Archytas (៤២៨-៣៤៧ មុនគ.ស.)។

លោក **ប៉ារមេនីដ** (Parménide) (៥១០-៤៤០ មុនគ.ស.) បានបង្កើតសាលាទស្សនវិជ្ជា **អេឡេ** (Élée) ដ៏ល្បីល្បាញនៅសតវត្សរ៍ទី៥មុនគ្រិស្តសករាជ។ នៅក្នុងកំណាព្យដ៏ល្បីរបស់លោក លោកបានរៀបរាប់ពីមូលដ្ឋាននៃគំនិតរបស់លោក តាមរយៈការពិពណ៌នាពីចក្រវាល និងការធ្វើដំណើរទៅរកការពិត។ **ប៉ារមេនីដ** ពន្យល់ពីភាវៈដែលមិនផ្លាស់ប្តូរ ហើយភាវៈប្រៀបបីដូចជាអាទិទេព។ ក្រោយមកទៀត **ហ្សេណុង** ក៏យល់ឃើញថាអ្វីៗមិនប្រែប្រួលឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សាលាទស្សនវិជ្ជា* **អាតូមនិយម** *គឺជាសាលាដែលមានលក្ខណៈជារូបធាតុនិយមដែលបង្កើតឡើងដោយ* **ឡឺសីបពុស** *(Leucippus) (សតវត្សរ៍ទី៥មុនគ.ស.) និងសាវករបស់លោក គឺ* **ដេម៉ូគ្រីត** *(Democritus) (៤៦០-៣៧០ មុនគ.ស.)។ សាលាទស្សនវិជ្ជានេះយល់ឃើញថា អ្វីៗទាំងអស់បង្កើតឡើងដោយអាតូមជាច្រើន ដែលមិនអាចបំបែកបាន មិនចេះបាត់បង់មិនប្រែរូប។*

*ពួក* **សូហ្វីស** *(les sophistes) គឺជាពួកដែលពូកែនិយាយ និងចេះប្រើប្រាស់ពាក្យយ៉ាងស្ទាត់ជំនាញ។ ពួកសូហ្វីសពូកែនិយាយ និងពូកែបកស្រាយ ដើម្បីទាក់ទាញឱ្យល្បីល្បាញ តែមិនមានគោលដៅរកការពិតឡើយ។*

*ពួក***សង្ស័យនិយម** *(les sceptiques) ដែលមានលោក* **ពីរ៉ុន** *(Pyrrhon) ជាអ្នកបង្កើតសាលានេះ យល់ឃើញថា គេមិនអាចទៅដល់តថភាពបានឡើយ ហើយបានសុំឱ្យបោះបង់ចោលនូវទ្រឹស្តីទស្សនវិជ្ជាទាំងអស់នោះ។ ក្នុងការគិត គេត្រូវតែមានការសង្ស័យជាប់ជានិច្ច។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# តាលែស

## (៦០០ឆ្នាំមុនគ្រិស្តសករាជ)

នាសម័យបុរាណ ទស្សនវិទូគឺជាអ្នកប្រាជ្ញដែលសិក្សាពីគណិតវិទ្យា ធរណីមាត្រ និងប្រព័ន្ធព្រះអាទិត្យ ហើយទស្សនវិជ្ជាត្រូវបានគេចាត់ទុកថា ជាវិទ្យាសាស្ត្រនៃវិទ្យាសាស្ត្រ។ សាលាទស្សនវិជ្ជាដ៏ល្បីមួយ គឺសាលានៅមីឡេ(Milet) ដែលបង្កើតឡើងដោយលោក **តាលែស**។ គាត់បានបង្កើតសម្មតិកម្មថា ៖ រង្វង់គឺជាការតភ្ជាប់ចំណុចនៃមុំត្រង់ដែលសង់លើខ្សែបន្ទាត់ត្រង់។ **តាលែស** គឺជាទស្សនវិទូម្នាក់ដ៏ល្បីដែលអាចវាស់កំពូលពីរ៉ាមីដបាន ដោយប្រើចំណោលព្រះអាទិត្យទៅលើបន្ទាត់ត្រង់មួយដើម្បីរកមុំ បន្ទាប់មកគឺប្រើរូបមន្ត $a^2+b^2=c^2$ ដើម្បីគិតកម្ពស់។

សំណួរសំខាន់នៃទស្សនវិជ្ជានៅពេលនោះ គឺ **ការផ្លាស់ប្តូរ**។ ការផ្លាស់ប្តូរបណ្តាលមកពី **ភាវៈ** (L'être) ដែលមាន ដែលផ្លាស់ប្តូរ តែនៅតែជាភាវៈដដែល។ សាលាមីឡេបានចោទសួរថា ៖ នៅក្នុងដំណើរការផ្លាស់ប្តូរនេះ តើសារធាតុអ្វីដែលនៅដដែល?

បើគេដាក់នំប៉័ងមួយដុំលើតុ។ មួយសន្ទុះក្រោយមកនំប៉័ងនៅលើតុដដែល។ នៅពេលដែលគេចោទជាសំណួរ គេមិនមើលឃើញនំប៉័ងដែលនៅលើតុទេ។ អ្វីដែលគេមើលឃើញ គឺការផ្លាស់ប្តូរ ភាពមិនទៀងទាត់ តែនៅពេលជាមួយគ្នានោះ គឺ ភាវៈនៅទីនោះរហូត។ គេចោទជាសំណួរថា ៖ តើមូលដ្ឋានអ្វីដែលនាំឱ្យមានការផ្លាស់ប្តូរនេះ?

សំណួរដែលសាលាមីឡេបានចោទសួរគឺ៖ តើសារធាតុអ្វីដែលនៅសេសសល់នៅក្នុងដំណើរការផ្លាស់ប្តូរនេះ? ទស្សនវិទូនៃសាលាមីឡេបានផ្តល់នូវចម្លើយផ្សេងៗគ្នា ៖ **តាលែស** បាននិយាយថា ៖ សារធាតុដែលជាមូលដ្ឋាននៃអ្វីៗទាំងអស់ ហើយដែលអាចបំប្លែងជាវត្ថុផ្សេងទាំងអស់ គឺទឹក។ ក៏ប៉ុន្តែ ទស្សវិទូនៃសាលាមីឡេខ្លះឆ្លើយថា ខ្យល់។ ខ្លះឆ្លើយថា ភ្លើង

*ហើយខ្លះទៀតឆ្លើយថា អនន្ត។ ដូច្នេះ បើតាម* **តាលែស** *ទឹកគឺជាសារធាតុដែលអាចបំប្លែងជាវត្ថុផ្សេងៗទៀតជាច្រើន រហូតដល់អនន្ត។*

*សរុបមក ទស្សនវិជ្ជារបស់* **តាលែស** *ផ្តោតទៅលើសារធាតុជាមូលដ្ឋាននៃអ្វីៗទាំងអស់ដែល* **តាលែស** *ខ្លួនឯងចាត់ទុកថាជា* **ទឹក**។ *ក៏ប៉ុន្តែ ទស្សនវិទូផ្សេងទៀតចាត់ទុកថា ជាភ្លើង ឬអនន្ត។*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# អេរ៉ាក្លីត
## (៥៥០-៤៨០ឆ្នាំមុនគ្រិស្តសករាជ) និង
# ប៉ារមេនីដ
## (ប្រហែល៥០០ឆ្នាំមុនគ្រិស្តសករាជ)

*នៅប្រទេសក្រិក ប្រមាណជា៥០០ឆ្នាំមុនគ្រិស្តសករាជ មានសាលាទស្សនវិជ្ជាធំពីរគឺ ៖ សាលាអីយ៉ូន(école ionienne) ដែលបង្កើតឡើងដោយ* **អេរ៉ាក្លីត** *(Héraclite) និងសាលាអេឡេអាត(école éléate) ដែលបង្កើតឡើងដោយ* **ប៉ារមេនីដ** *(Parménide) ។ សាលាទាំងពីរសិក្សាពីការផ្លាស់ប្តូររយៈពេល អ្វីដែលជាបណ្តោះអាសន្ន និងអ្វីដែលជាអចិន្ត្រៃយ៍។ បណ្តោះអាសន្នស្ថិតនៅក្នុងពិភពនៃចំនួនច្រើន ចំណែកឯអចិន្ត្រៃយ៍ គឺស្ថិតនៅក្នុងពិភពនៃចំនួនតែមួយ។ តែមួយមានន័យថា មិនផ្លាស់ប្តូរ មិនអនន្ត ពោលគឺអ្វីដែលមិនប្រែប្រួល។ នៅក្នុងគណិតវិទ្យា សមីការគឺមានអញ្ញត្តិពីរសងខាងដែលស្មើគ្នា តាមគោលការណ៍សមីការ ឬគោលការណ៍មិនផ្ទុយគ្នា។ ដូច្នេះប្រសិនបើមានការផ្លាស់ប្តូរ មានន័យថាវាផ្ទុយនឹងគោលការណ៍សមីការហើយ។*

*ទស្សនវិជ្ជារបស់* **អេរ៉ាក្លីត** *ផ្តោតទៅលើ* **ការផ្លាស់ប្តូរ។ អេរ៉ាក្លីត** *ចោតសួរសំណួរដែលលើកឡើងដោយសាលា Milet ថា ៖ តើបន្ទាប់ពីមានការផ្លាស់ប្តូរ គេឃើញមាននៅសល់អ្វី។ ចម្លើយគឺថា ៖ គឺការផ្លាស់ប្តូរខ្លួនឯង។ អ្វីដែលអចិន្ត្រៃយ៍ គឺការផ្លាស់ប្តូរ។ ការផ្លាស់ប្តូរ គឺជាភាវៈនៃអ្វីៗទាំងអស់។*

**អេរ៉ាក្លីត** *យល់ឃើញថា ៖ ការផ្ទុយគ្នា គឺជាលក្ខខណ្ឌនៃអ្វីៗទាំងអស់។ ការប្រយុទ្ធគឺជាបិតានៃអ្វីៗទាំងអស់ ហើយការប្រទាញប្រទង់រវាងការផ្ទុយ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្មានាំឱ្យមានតថភាព។ នេះគឺជាប្រភពដើមនៃវិចារវិទ្យារបស់ **ហេហ្គែល** (Hegel) និង **ម៉ាក** (Marx)។ ដូច្នេះ អ្វីដែលជាសច្ចធម៌ ឬជាតថភាពកើតឡើងពីការប្រយុទ្ធរវាងអ្វីដែលផ្ទុយគ្នា។

**អេរ៉ាក្លីត** សង្កត់ធ្ងន់ទៅលើបទពិសោធន៍នៃការផ្លាស់ប្តូរ ៖ គេមិនអាចមុជទឹកពីរដង នៅក្នុងទន្លេតែមួយបានឡើយ។ នៅពេលដែលគេត្រឡប់មកមុជទឹកម្តងទៀត ទឹកពីពេលមុខហូរទៅឆ្ងាយបាត់ទៅហើយ នៅសល់តែទន្លេផ្សេងមួយទៀត និងទឹកផ្សេងទៀតប៉ុណ្ណោះ។ **អេរ៉ាក្លីត** យល់ឃើញថា ៖ ការប្រយុទ្ធ និងទឹកដែលហូរមិនចេះចប់នេះបានបង្កើតឱ្យមានគោលការណ៍សណ្តាប់ធ្នាប់ និងតុល្យភាព។ ធាតុមួយដ៏សំខាន់នៃដំណើរការនេះ គឺ ភ្លើង។ ភ្លើងនេះមិនមែនភ្លើងដែលដុតទេ តែវាមានន័យថាជាមូលហេតុ តក្កវិទ្យា ច្បាប់ ដែលភាសាក្រិកថាជា logos ដែលនាំឱ្យមានតុល្យភាព។ នៅក្នុងការប្រយុទ្ធរវាងអ្វីដែលផ្ទុយគ្នា អត់មានអ្នកឈ្នះ ហើយក៏អត់មានអ្នកចាញ់ដែរ។ ការប្រយុទ្ធនេះស្ថិតនៅក្រោមច្បាប់តុល្យភាពដែលធ្វើឱ្យអ្វីៗទាំងអស់ត្រឡប់មកក្នុងសភាពភ្លើងដូចមុន គឺ logos។

ដូច្នេះ ទស្សនៈរបស់ **អេរ៉ាក្លីត** ផ្តោតលើអ្វីដែលច្រើន អ្វីដែលផ្ទុយគ្នា ការផ្លាស់ប្តូរ ការប្រយុទ្ធ និងទឹកដែលហូរទៅ។ ហើយសារធាតុតែមួយដែលនៅសល់ គឺការផ្លាស់ប្តូរ។ ហើយអ្វីៗទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់រួមមួយ គឺ logos។

**ប៉ារមេនីដ** (Parménide) គឺជាទស្សនវិទូជំនាន់ **អេរ៉ាក្លីត** ដែរ ហើយក៏ជាគូបដិបក្សរបស់គាត់ផងដែរ។ **ប៉ារមេនីដ** បានបង្កើតសាលាអេឡេអាត (école éléate)។ ទស្សនវិជ្ជារបស់ **ប៉ារមេនីដ** ផ្តោតលើមូលដ្ឋាននៃតក្កវិទ្យាគោលការណ៍ **ភាវៈ**។ គេអាចនិយាយថា៖ គឺ **មានភាវៈ** តែគេមិនអាចនិយាយថា គឺជា **អភាវៈ** (le non-être est) បានឡើយ ដោយសារតែនេះគឺជាការផ្ទុយ(contradiction)។ មូលហេតុនៃការគ្មាន **អភាវៈ** គឺជាការទាមទារនៃពុទ្ធិ **ជីវវត្តវិជ្ជា** (exigence ontologique)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ប៉ារមេនីដ** យល់ឃើញថា អត្ថិភាពមិនមែនជាទស្សនាទានអរូបីទេ។ អត្ថិភាពគឺជានាមមួយដែលមានន័យទូលំទូលាយ មានអាថ៌កំបាំង និងមានពុទ្ធិជ្រៅជ្រះ។ ក៏ប៉ុន្តែ ពិភពលោកយើងផ្លាស់ប្តូរជានិច្ច។ **ប៉ារមេនីដ** បែងចែកវិទ្យាសាស្ត្រដែលជាពុទ្ធិពិតនៃភាវៈ(connaissance vraie de l'être) នៅក្នុងអត្តសញ្ញាណអចិន្ត្រៃយ៍របស់ខ្លួន ពីចំណេះដឹងពីពិភពខាងក្រៅដែលយើងកំពុងរស់នៅ។ **ប៉ារមេនីដ** ហៅចំណេះដឹងពីពិភពខាងក្រៅនេះថាជា **មតិយោបល់** (doxa)។ **ប៉ារមេនីដ** យល់ថា មតិយោបល់មានន័យថា មិនទាន់ដល់កម្រិតនៃ **សច្ចធម៌** (vérité) ឬចំណេះដឹងពិតនៅឡើយ ក៏ប៉ុន្តែ មតិយោបល់ក៏មិនមែនជាអ្វីដែលមិនពិតដែរ ពោលគឺការឈានទៅរកការពិតដើម្បីឱ្យមនុស្សអាចរស់នៅជាក់ស្តែង។ ដូច្នេះ មតិយោបល់(opinion) ស្ថិតនៅចំកណ្តាលរវាងសច្ចធម៌ (vérité) និង ការមិនពិត(erreur)។

**ប៉ារមេនីដ** ចាត់ទុក មតិយោបល់(opinion) ថាជាចំណេះដឹងពីពិភពដែលផ្លាស់ប្តូរ ដែលយើងជួបប្រទះក្នុងបទពិសោធន៍របស់យើង។ ចំពោះពុទ្ធិពិតនៃភាវៈ(connaissance de l'être) គឺឈានដល់កម្រិតមួយដែលដាច់ខាត។

ចំពោះ **ប៉ារមេនីដ** មានការផ្លាស់ប្តូរមានន័យថាមានចន្លោះ មានកន្លែងទទេ។ ចំណែកឯភាវៈវិញ គឺជាសញ្ញាណមួយដែលពេញ មិនអាចមានប្រហោង ឬមានអ្វីក្នុងនោះបានឡើយ។ ប្រសិនបើភាវៈជាសញ្ញាណមួយដែលពេញលេញ ដូច្នេះ វាមិនអាចផ្លាស់ប្តូរបានឡើយ។ ភាពពេញលេញនេះមានរូបរាងជាស្វ៊ែរ។ ចំពោះជនជាតិក្រិកសម័យបុរាណ សភាពមិនអនន្ត ឬដែលមិនអាចកំណត់បាន គ្មានរូបរាងឡើយដែលមិនទាន់ចប់ ឬដែលមិនទាន់ឈានដល់ភាវៈទេ។ នៅក្នុងទស្សនាទានរបស់ **ប៉ារមេនីដ** ស្វ៊ែរ(sphère) គឺជាភាវៈល្អឥតខ្ចោះ(l'être parfait) ដែលទស្សនវិទូយល់ឃើញថា គ្រប់គ្រាន់ដោយខ្លួនឯង **មូលហេតុនៃខ្លួនឯង** (cause de soi) **ដោយខ្លួនឯង** (par soi) ឬ **ក្នុងខ្លួនឯង** (en soi)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សម្រាប់* **ប៉ារមេនីដ** *ភាវៈ (l'être) គឺជាអ្វីដែលប្រដូចទៅនឹងអាទិទេព ប្រៀបដូចជាព្រះដែលបង្កើតលោកដូច្នេះឯង។ នៅក្នុងទស្សនាទាននៃប្រវត្តិគំនិតនាបស្ចិមប្រទេស ភាវៈ(l'être) គឺជាអាទិទេព។ ដូច្នេះហើយ* **ប៉ារមេនីដ** *ត្រូវបានគេចាត់ទុកថាជាទស្សនវិទូ***ម៉ូនីស្ត** *(moniste) ឬមានទស្សនៈតែមួយ ៖ គេអាចនិយាយ ឬគិតបានថា មានតែ* **ភាវៈ** *ប៉ុណ្ណោះ គ្មានទេភាពសូន្យទទេ ឬ* **អភាវៈ** *នោះ (un rien n'est pas)។ ក៏ប៉ុន្តែ ចំពោះ* **អេរ៉ាគ្លីត** *វិញ គេអាចគិតពីភាពល្អឥតខ្ចោះ តាមរយៈភាពមិនល្អឥតខ្ចោះតែប៉ុណ្ណោះ។*

*ចាប់ពីពេលនោះមក គេតែងតែចាត់ទុកទស្សនវិទូដែលមានទស្សនៈដូច* **អេរ៉ាគ្លីត** *(Héraclite) ដូចជា* **ស្ពីណូហ្សា** *(Spinoza) ក្នុងសតវត្សរ៍ទី១៧ ថាជាទស្សនវិទូនៃសាលាអីយ៉ូន (école ionienne) ចំណែកឯទស្សនវិទូដែលមានទស្សនៈដូច* **ប៉ារមេនីដ** *ដូចជា* **ហេហ្គែល** *(Hegel) ក្នុងសតវត្សរ៍ទី១៩ ថាជាទស្សនវិទូនៃសាលាអេឡេអាត(école éléate)។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្សេណុង
## ( ៤៩០-៤៣០ឆ្នាំ មុនគ្រិស្តសករាជ ) និង
# ពួកអាត្មូមនិយម

**ហ្សេណុង** គឺជាសាវកដ៏ចំណានម្នាក់របស់ **ប៉ារមេនីដ**។ លោកជាអ្នកបង្កើត **សូហ្វីស** (sophismes) និង **ប៉ារ៉ាដុក**(paradoxes)។ **សូហ្វូ** (sophos) មានន័យថាអ្នកប្រាជ្ញ (sage)។ **សូហ្វីស** គឺជាការត្រិះរិះពិចារណាដែលមើលទៅដូចជាពិត តែតាមពិតគឺជាការមិនពិត។

**ប៉ារមេនីដ** និយាយថាមានតែ **ភាវៈ** (l'être) ប៉ុណ្ណោះ ចំណែកឯ **អភាវៈ** (le non-être) គ្មានទេ។ **ការផ្លាស់ប្តូរ** (le devenir) និង **ភាពមិនទៀងទាត់** (l'éphémère) គឺជាមតិយោបល់ មិនមែនជា**សច្ចធម៌** (la vérité)ឡើយ។ ទស្សនៈនេះធ្វើឱ្យប៉ះពាល់ដល់បទពិសោធន៍ជាក់ស្តែងប្រចាំថ្ងៃ។ ទោះបីជាចលនា និងការផ្លាស់ប្តូរតែងតែកើតឡើងក្នុងបទពិសោធន៍ប្រចាំថ្ងៃ ក៏ប៉ុន្តែយើងមិនអាចគិតឃើញឡើយ។ ដូច្នេះ ពួកសូហ្វីសបានប្រើប្រាស់វិធីសាស្ត្រសូហ្វីស ដើម្បីបង្ហាញជាកស្តុតាង ប៉ុន្តែមិនមែនក្នុងគោលដៅរកការពិតឡើយ។

ឧទាហរណ៍ អ្នកបាញ់ធ្នូម្នាក់បានបាញ់ធ្នូទៅ។ ធ្នូនេះបាញ់ទៅបង្កើតបានជាគំនូសមួយក្នុងលំហ។ **ហ្សេណុង** សង្កេតឃើញថា ៖ នៅក្នុងពេលកំណត់មួយ ធ្នូស្ថិតនៅលើចំណុច **A** លើគំនូសនេះ។ បន្ទាប់មកធ្នូនេះស្ថិតនៅត្រង់ចំណុច **B**។ នៅចន្លោះចំណុចទាំងពីរ ធ្នូស្ថិតនៅត្រង់ចំណុច **A'** ហើយនៅពេលធ្នូស្ថិតនៅចន្លោះ **A** និង **A'** ធ្នូស្ថិតនៅត្រង់ចំណុច **A''**។ នៅពេលណាមួយ ព្រួញស្ថិតនៅត្រង់ចំណុចពិតប្រាកដមួយ។ **ហ្សេណុង** បង្ហាញថា ថ្វីត្បិតតែយើងឃើញព្រួយហោះ តែយើងមិនអាចកំណត់ចលនា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*របស់បានឡើយ ដោយសារតែគំនិតរបស់យើងផ្ដោតលើអ្វីដែលនៅថេរ* **អនន្ត**។ *ក៏ប៉ុន្តែ យើងរស់នៅក្នុងពិភពមួយដែលមិនទៀងទាត់ដែលផ្លាស់ប្ដូរ និងប្រែប្រួល។*

*ដូច្នេះ នៅក្រិកបុរាណគេមានទស្សនៈពីរ ៖ គឺទស្សនៈរបស់* **អេរ៉ាក្លីត** *គឺអ្វីៗតែងតែផ្លាស់ប្ដូរ និងទស្សនៈរបស់* **ប៉ារមេនីដ** *គឺ* **ភាវៈ** *(l'être) គឺជាអ្វីដែលពេញ ហើយដែលមិនប្រែប្រួល។ ដូច្នេះ ហើយទើបមានសាលា* **អាតូមនិយម** *(école atomiste) ដែលសំយោគទស្សនៈទាំងពីរដោយបង្កើតឱ្យមាន ទី១ ធាតុដែលមិនអាចបំបែកបាន និងដែលមានកំហាប់ តែគ្មាន* **អភាវៈ** *(le non-être) របស់* **ប៉ារមេនីដ** *និង ទី២ ការផ្លាស់ប្ដូរ និងការបម្លែងពីធាតុមួយទៅធាតុមួយទៀតដូចទស្សនៈរបស់* **អេរ៉ាក្លីត**។

**ពួកអាតូមនិយម** *(Atomiste) យល់ឃើញថា ៖ គេមិនចាំបាច់យក* **ភាវៈ** *មកពន្យល់ទេ តែគេអាចប្រើបំណែកតូចៗជាច្រើនរបស់* **ភាវៈ** *ដែលជាបំណែកដ៏តូចមិនអាចបំបែកបាន មិនអាចផ្លាស់ប្ដូរ និងមិនអាចប្រែរូបដែល* **អភាវៈ** *(non-être) មិនអាចជ្រាបចូលបាន។ បំណែកតូចៗដែលពេញលេញ និងមិនអាចបំបែកបាននេះ គឺជាភាវៈមានទំហំតូចៗជាច្រើនរបស់* **ប៉ារមេនីដ** *ដែលគេហៅថា អាតូម(atome)។ អាតូមជាភាសាក្រិកមានន័យថា ៖ គ្មានចន្លោះប្រហោង។ ទ្រឹស្ដីនេះជួយពន្យល់ដល់បាតុភូតធម្មជាតិ និងជួយដល់ការស្រាវជ្រាវវិទ្យាសាស្ត្រ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ពួកសូហ្វីសត៍
## (៤២៧-៣៤៧ឆ្នាំមុនគ្រិស្តសករាជ)

*ពួក* **សូហ្វីសត៍** *(les sophistes) ជាភាសាក្រិកហៅថា អ្នកឯកទេសខាងផ្នែកគតិបណ្ឌិត (sagesse) គឺជាចលនាខាងផ្នែកគំនិតមុនទស្សនវិជ្ជា* **សូក្រាត***បន្តិច។ ពួក* **សូហ្វីសត៍** *គឺជាពួកដែលពូកែនិយាយ និងចេះប្រើវោហាសាស្ត្រយ៉ាងស្ទាត់ជំនាញ។ ពួក* **សូហ្វីសត៍** *ពូកែនិយាយ រិះគិត និងពូកែបកស្រាយ ដើម្បីទាក់ទាញឱ្យល្បីល្បាញ តែមិនមានគោលដៅរកការពិតឡើយ។ ដូច្នេះ ប្រការនេះបង្ហាញពីកំសោយខាងផ្នែកទស្សនវិជ្ជា និងធ្វើឱ្យពួក* **សូហ្វីសត៍** *នេះតែងតែនិយាយផ្ទុយគ្នា។*

*ពួកគេមិនបានពិចារណាពី* **ភាវៈ** *ដូចនៅក្នុងសាលាទស្សនវិជ្ជាអេឡេអាត(école éléate) ឬក៏ត្រិះរិះពី* **ជម្មជាតិ** *ដូចជាទស្សនវិទូរូបនិយមនៃសាលាទស្សនវិជ្ជាអីយ៉ូន(école ionienne)ឡើយ។ ពួកគេតាំងខ្លួនថាជាអ្នកអប់រំប្រកបដោយវិជ្ជាជីវៈ ហើយធ្វើដំណើរទៅគ្រប់ទិសទី ដើម្បីលក់គតិបណ្ឌិត វប្បធម៌ និងសមត្ថភាពរបស់ពួកគេ។ ពួក* **សូហ្វីសត៍** *ខ្វះក៏ជាអ្នកកាន់អំណាចដែលចេះទាក់ទាញចៅក្រម ដឹកនាំបេសកកម្មការទូត រៀបចំច្បាប់ និងដឹកនាំនយោបាយនៅក្នុងទីក្រុងដែរ។ កត្តាសំខាន់គឺពួកគេត្រូវចេះភាសាយ៉ាងស្ទាត់ជំនាញ និងចេះប្រើវោហាសាស្ត្រ។ ពួក* **សូហ្វីសត៍** *ល្បីៗមាន* **ប្រូតាហ្គោរាស់** *Protagoras) (៤៩០-៤២០ មុនគ.ស.)* **ហ្គ័រហ្គីយ៉ាស** *(Gorgias) (៤៨៧-៣៧៦ មុនគ.ស.) និង* **ហីពពីយ៉ាស** *(Hippias) (៤៨៥-៤១៥ មុនគ.ស.)ជាដើម។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្វូក្រាត

## (៤៧០-៣៩៩ឆ្នាំមុនគ្រិស្តសករាជ)

**ស្វូក្រាត** (Socrate) កើតនៅឆ្នាំ៤៧០មុនគ្រិស្តសករាជក្នុងគ្រួសារក្រីក្រមួយនៅក្នុងប្រទេសក្រិកបុរាណ។ ឪពុកលោកជាជាងចម្លាក់ថ្ម ហើយម្តាយជាឆ្មប។ ឪពុកលោកគ្មានពេលគ្រប់គ្រាន់សម្រាប់អប់រំកុមារ **ស្វូក្រាត** ឡើយ។ លុះឈានចូលវ័យជំទង់ លោកបានរៀនទស្សនវិជ្ជា ចំពេលដែលទស្សនវិជ្ជារូបធាតុនិយមកំពុងចាប់ផ្តើមរីកដុះដាល។ **ទស្សនវិជ្ជារូបធាតុនិយម** បកស្រាយអំពីរូបធាតុ ដូចជាសកម្មភាពវត្ថុ ឬរូបធាតុដែលទាក់ទងនឹងសកម្មភាពរបស់មនុស្ស។ លោកស្រេកឃ្លានចំណេះដឹង ហើយរស់នៅយ៉ាងសាមញ្ញ។

**ស្វូក្រាត** មិនបានសរសេរអ្វីទុកសម្រាប់ជនជំនាន់ក្រោយឡើយ។ តែលោកជាបិតានៃទស្សនវិជ្ជាដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើទស្សនវិជ្ជាក្នុងរយៈពេលជាច្រើនសតវត្សរ៍។ គេស្គាល់ **ស្វូក្រាត** តាមរយៈសំណេរនៃសាវករបស់លោកតែប៉ុណ្ណោះ។ **ស្វូក្រាត** ធ្វើការស្រាវជ្រាវកំណាព្យអក្សរសាស្ត្រ វិធីសាស្ត្រសន្ទនា និងដោះស្រាយបញ្ហាចោទឆ្លើយ។

**សច្ចធម៌** ៖ ទស្សនវិជ្ជារបស់ **ស្វូក្រាត** ផ្តោតលើ **សច្ចធម៌**។ **សច្ចធម៌** មិនមែនជាវត្ថុទេ តែគឺជា **សច្ចធម៌** ទស្សនវិជ្ជា។ **ស្វូក្រាត** យល់ឃើញថា **សច្ចធម៌** ត្រូវតែផ្សាភ្ជាប់ជាមួយនឹងអ្នកដែលនិយាយ និងជាមួយនឹងពេលដែលគេនិយាយ។ ប្រហែលជាដូច្នេះហើយទើប **ស្វូក្រាត** មិនដែលសរសេរសៀវភៅ។ **សច្ចធម៌** ទស្សនវិជ្ជា គឺជាសេចក្តីថ្លៃថ្នូររបស់មនុស្សមានទំនួលខុសត្រូវ មានសេរីភាព ជានា **សច្ចធម៌** ហើយធ្វើឱ្យ **សច្ចធម៌** នេះជារបស់ខ្លួន ហើយធ្វើឱ្យវាជា **សច្ចធម៌** តាមរយៈការប្តេជ្ញាចិត្តចំពោះវា។ ចំពោះ **ស្វូក្រាត** **សច្ចធម៌** ទ្រឹស្តីជានិច្ចកាល គឺជា **សច្ចធម៌** ជាក់ស្តែង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយវាអាស្រ័យលើសកម្មភាពរបស់បុគ្គលចំពោះការពិតនេះដែលចង់ឱ្យវាក្លាយជា **សច្ចធម៌** ។

**ខ្ញុំអត់ចេះអ្វីទាំងអស់** ៖ ឃ្លាដ៏ល្បីល្បាញមួយរបស់ **សូក្រាត** គឺ៖ **ខ្ញុំដឹងថា ខ្ញុំអត់ចេះអ្វីទាំងអស់** *(Je sais que je ne sais rien)*។ នេះគឺជាប្រយោគដែល **សូក្រាត** បានថ្លែង ក្រោយពីគ្រូទាយនៅ Pythie បានថ្លែងថា **សូក្រាត** គឺជាមនុស្សម្នាក់ដែលមានប្រាជ្ញាជាងគេនៅក្រុងអាតែន។ ប្រយោគនេះមានន័យថា ខ្ញុំសម្រួចន័យនៃ **សច្ចធម៌** របស់ខ្ញុំឱ្យដល់កម្រិតមួយដែលការទាមទាររបស់ខ្ញុំចំពោះ **សច្ចធម៌** មិនមែនត្រឹមរូបភាពនៃ **សច្ចធម៌** ដែលពេលខ្លះខ្ញុំទទួលបានថាគ្រប់គ្រាន់ប៉ុណ្ណោះទេ។ អ្វីដែលខ្ញុំចាត់ទុកថាជា **សច្ចធម៌** គឺជាការទាមទារការពិតខ្ពស់ជាងនេះ ពោលគឺមិនមែនត្រឹមតែជាការពិតខ្លួនឯងប៉ុណ្ណោះទេ។

**ត្រូវស្គាល់ខ្លួនដោយខ្លួនឯង** ៖ អ្វីដែល **សូក្រាត** ខុសពីទស្សនវិទូមុនលោកដែលជាទស្សនវិទូរូបធាតុនិយម គឺមិនមែនការផ្ដោតទៅលើការពន្យល់ពីពិភពលោក ឬពី **ភាវៈក្នុងខ្លួនឯង** *(être en soi)* ទេ តែផ្ដោតលើមនុស្សដែលស្វែងរក **សច្ចធម៌**។ លោកយល់ថា ទោះបីជារូបធាតុរីកចម្រើនបែបណាក៏មិនអាចកែប្រែពិភពលោកបានដែរ។ មានតែបញ្ញាមនុស្សតែមួយគត់ដែលអាចធ្វើឱ្យពិភពលោកមានការប្រែប្រួល ដូចក្ដីស្រមៃរបស់មនុស្ស។ មនសិការរបស់មនុស្សស្ដីពីពិភពលោកត្រូវតែសួរដោយខ្លួនឯង ហើយត្រូវស្គាល់ខ្លួនដោយខ្លួនឯង *(Connais-toi, toi-même)*។ ខ្ញុំសួរខ្លួនឯងពីពុទ្ធិរបស់ខ្ញុំ ពីគំនិតរបស់ខ្ញុំ ហើយខ្ញុំរកឃើញថា ជារួម **ពុទ្ធិ** *(savoir)* របស់ខ្ញុំ គឺជា **អពុទ្ធិ** *(un non-savoir)* ដើម្បីឱ្យការទាមទាររក **សច្ចធម៌** របស់ខ្ញុំមានកាន់តែខ្លាំងឡើងៗ។ លោកជាទស្សនវិទូទីមួយដែលបង្កើតទស្សនាទានទស្សនវិជ្ជា។ លោកសិក្សាពីគុណធម៌ក្នុងសីលធម៌ និងខិតខំរិះរកបង្កើតអត្ថន័យសាកលមួយ។ សីលធម៌របស់លោក គឺធ្វើដូចម្ដេចឱ្យមនុស្សស្គាល់ខ្លួនឯងឱ្យច្បាស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**រស់នៅប្រកបដោយគតិបណ្ឌិត ៖** *សំណួរសំខាន់របស់* **សូក្រាត** *គឺ ៖ តើត្រូវរស់នៅដូចម្ដេច ដើម្បីឱ្យគេអាចរស់នៅប្រកបដោយគតិបណ្ឌិត (Comment faut-il vivre pour vivre selon le bien?)។ ទស្សនៈសំខាន់របស់* **សូក្រាត** *គឺកាតព្វកិច្ចរបស់មនុស្សក្នុងការដឹកនាំជីវិតរស់នៅរបស់ខ្លួន តម្រង់សកម្មភាពរបស់ខ្លួនឆ្ពោះទៅរកគុណធម៌ ហើយត្រូវដើរតាមផ្លូវដែលខ្លួនឯងបានជ្រើសរើស។ ទ្រឹស្ដីរបស់លោកគឺ «គ្មាននរណាម្នាក់កាចសាហាវឃោរឃៅដោយចេតនាឡើយ»។ អ្នកដែលប្រព្រឹត្តអំពើឃោរឃៅ គឺបណ្ដាលមកពីភាពល្ងង់ខ្លៅ (Ignorance) ខ្វះការចេះដឹង។ ប្រការនេះធ្វើឱ្យមនុស្សលង់លក់ក្នុងតណ្ហា ហើយប្រព្រឹត្តអំពើបាបកម្មដោយមិនដឹងខ្លួន។*

**សូក្រាត** *គឺជាទស្សនវិទូម្នាក់ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លា ទៅលើគរុកោសល្យ។ លោកបានបង្កើតវិធីសាស្ត្របង្កើតពុទ្ធិ ដើម្បីបង្ហាញពីអពុទ្ធិ ដើម្បីឱ្យសិស្សគណទាមទារនូវការពិត។ គាត់មិនបានបង្រៀនទេ តែគាត់បានធ្វើឱ្យសិស្សគណស្វែងរកន័យនៃសច្ចធម៌ដោយខ្លួនឯង។ វិធីសាស្ត្រនេះផ្ដោតលើការទុកចិត្តលើមនុស្ស។ មនុស្សតែងតែមានញាណនៃ* **សច្ចធម៌** *ដែលយើងត្រូវតែជួយបង្កើត* **សច្ចធម៌** *នេះ។ វិធីសាស្ត្របង្រៀនរបស់* **សូក្រាត** *នៅតែពេញនិយមរហូតដល់សព្វថ្ងៃ ហើយដែលគេអាចចែកចេញជាពីរផ្នែកគឺ៖ (១) ការចោទសួរសំណួរ ឬ* **ការចំអកបែបសូក្រាត** *(l'Ironie socratique) និង* **ការបង្កើតគំនិត ឬសិល្បៈនៃការបង្កើតក្មួន** *(la maïeutique)។ ម្ដាយរបស់* **សូក្រាត** *គឺជាឆ្មប ហើយ* **សូក្រាត** *អះអាងថា ខ្លួនគាត់ក៏ប្រកបរបរនេះដែរគឺ៖* **សិល្បៈនៃការបង្កើតក្មួន** *(la maïeutique)។ តែ* **សូក្រាត** *បង្កើតគំនិត។*

**ការចំអកបែបសូក្រាត ៖ សូក្រាត** *ប្រើសិល្បៈចោទសួរ ដោយប្រើសំនួនវោហាស័ព្ទទៅកាន់គូសន្ទនា ដើម្បីធ្វើឱ្យគេធាប់យល់ និងមានលក្ខណៈអរូបី។ ការរិះគន់ ឬការទិតៀនចំពោះគូសន្ទនាមានចរិតគុណធម៌។* **សូក្រាត** *ប្រើវិធីសាស្ត្រលើកទឹកចិត្តដល់គូសន្ទនា តាមរយៈការបញ្ចើចបញ្ចើ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយមិនឱ្យគូសន្ទនាមានឱកាសប្រើអស្មិមានះក្នុងពេលចោទឆ្លើយ ហើយបើកច្រកឱ្យគូសន្ទនានិយាយកាន់តែបានទូលំទូលាយ ដោយមិនដណ្ដើមឥស្សរភាពផ្ដាច់មុខឡើយ។ សិល្បៈចោទសួររបស់ **សូក្រាត** តែងតែមានប្រៀបលើគូសន្ទនា។ លោកប្រើប្រាស់នូវទេពកោសល្យ និងវិចារវិទ្យាតាមរយៈវគ្គសន្ទនាខ្លីៗ ប្រើពាក្យសាមញ្ញងាយយល់ តែលោកសួររហូតដល់គូសន្ទនារកអ្វីឆ្លើយលែងរួច ហើយទទួលសារភាពថាមិនចេះតែម្ដង។ សិល្បៈក្នុងការចោទសួរនេះ ត្រូវបានគេហៅថា **ការចំអកបែបសូក្រាត** (l'Ironie socratique)។ ដើម្បីអប់រំមនុស្ស **សូក្រាត** ត្រូវជម្រះ និងជម្រុះឱ្យអស់នូវការចេះដឹងមិនត្រឹមត្រូវ(un faux-savoir) ប្រៀបដូចជាគេលាងពាងដើម្បីត្រងទឹកថ្មី ដែលស្អាតដូច្នេះដែរ។

**ការបង្កើតគំនិត ឬ សិល្បៈនៃការបង្កើតកូន** ៖ ការបង្កើតគំនិតគឺជាដំណាក់កាលទីពីរនៃគរុកោសល្យរបស់ **សូក្រាត** ដែលត្រូវបន្តបន្ទាប់ពីចោទសួរសំណួរ។ ការបង្កើតគំនិត គឺជាវិធីទាញយកគំនិតពីគូសន្ទនា ពោលគឺជាសិល្បៈក្នុងការបង្កើតគោលគំនិត (C'est un art d'accoucher les idées)។ **សូក្រាត** ត្រូវប្រើទ្រឹស្ដី និងចំណេះដឹងវិជ្ជមាន ដល់គូសន្ទនាដែលទើបតែទទួលការអប់រំដោយសំណួរ។ បន្ទាប់ពីគូសន្ទនាជម្រុះឱ្យអស់នូវការចេះដឹងមិនត្រឹមត្រូវ(un faux-savoir) ទើប **សូក្រាត** ធ្វើការបញ្ចូលចំណេះដឹងពិតប្រាកដ(un vrai savoir) ដល់គូសន្ទនាតាមរយៈការពន្យល់ឱ្យគូសន្ទនាយល់ច្បាស់ពីទស្សនាទានផ្សេងៗ។

**ច្បាប់** ៖ ច្បាប់សម្រាប់សង្គមបែងចែកជាពីរយ៉ាងគឺ ច្បាប់សរសេរ និងច្បាប់ឥតសរសេរ។ ច្បាប់សរសេរគឺជាច្បាប់សម្រាប់នគរដែលត្រូវបានចងក្រងសម្រាប់ឱ្យប្រជាពលរដ្ឋគោរព។ បើជនណាមិនគោរពច្បាប់ តុលាការត្រូវកាត់ទោសចោទប្រកាន់។ ច្បាប់ឥតសរសេរគឺជាទំនៀមទម្លាប់ ប្រពៃណីដែលឥតមានចងក្រងទុកទេ ហើយក៏គ្មានតុលាការកាត់សេចក្ដីដែរ។ ច្បាប់នេះត្រូវបានគេបង្រៀនតគ្នា ពីមាត់មួយទៅមាត់មួយទៀត។ មនុស្សកើត

មកភ្ជាមត្រូវទទួលឥទ្ធិពលពីច្បាប់ឥតសរសេរភ្លាម។

**សូក្រាត** បានរៀបចំយុវជនដែលចូលចិត្តរៀនសូត្រជាក្រុម ក្នុងគោលដៅរៀបចំជាមុននូវអ្នកដឹកនាំនយោបាយក្នុងពេលអនាគត។ លោកចូលចិត្តជជែកសន្ទនានៅតាមដងផ្លូវ និងទីសាធារណៈហើយលោកបានទាក់ទាញទឹកចិត្តយុវជន ប្រកបដោយភាពប៉ិនប្រសប់តាមរយៈការប្រៀនប្រដៅ និងការពន្យល់បង្ហាត់បង្ហាញយុវជនកុំឱ្យចេះតែជឿ និងអនុវត្តតាមទំនៀមទម្លាប់ដែលគេធ្លាប់បានទទួលការអប់រំនៅក្នុងគ្រួសារ។ **សូក្រាត** មិនយល់ស្របតាមទស្សនវិជ្ជារូបធាតុនិយម។ **សូក្រាត** បានប្រឆាំងជំទាស់នឹងទ្រឹស្តីដែលមានពីមុនមក ៖ សារធាតុ និងសិទ្ធិនៃអំណាច អ្នកដឹកនាំ សាសនា គំនិតពីព្រះអាទិទេព គុណធម៌ អំពើល្អ អំពើយុត្តិធម៌ អំពើអាក្រក់ និងអំពើអយុត្តិធម៌។ លោកមិនយល់ស្របជាមួយនយោបាយប្រជាភិថុតនៃលទ្ធិប្រជាធិបតេយ្យនៅក្នុងបុរីអាតែន។

**សូក្រាត** ត្រូវបានតុលាការនៃក្រុងអាតែនកាត់ទោសប្រហារជីវិតពីបទថា បានក្បត់សាសនា ផ្សព្វផ្សាយសាសនាបរទេស និងជាអ្នកបំពុលយុវជនឱ្យពុករលួយ។ **សូក្រាត** ជំទាស់អ្វីៗទាំងអស់ដែលអាចបង្កើតឱ្យមានបញ្ហានយោបាយនៅក្នុងបុរីអាតែន។ ប្រការនេះជាមូលហេតុដែលចៅក្រមចាត់ទុកគាត់ជាមនុស្សប្រកបដោយគ្រោះថ្នាក់។

នៅពេលដែល **សូក្រាត** ស្ថិតនៅក្នុងពន្ធនាគារ សាវករបស់លោកបានរៀបចំឱ្យលោកលួចរត់ចេញពីគុក តែ **សូក្រាត** បានបដិសេធ។ ថ្វីត្បិតតែ **សូក្រាត** យល់ឃើញថាការកាត់ទោសនេះគ្មានយុត្តិធម៌ តែលោកត្រូវបានចៅក្រមកាត់ទោសតាមច្បាប់។ ដោយសារតែមានច្បាប់នេះហើយ ទើបទីក្រុង(polis)អាចដំណើរការបាន។ ដោយសារតែច្បាប់នេះហើយ ទើប **សូក្រាត** បានក្លាយទៅជា **សូក្រាត** ពិតប្រាកដ។ ដោយសារតែរដ្ឋ និងច្បាប់នេះហើយ ទើប **សូក្រាត** បានមានអ្វីៗ។ ប្រសិនបើគាត់លួចរត់មានន័យថា គាត់បដិសេធនូវអ្វីៗទាំងអស់ដែលគាត់បានបង្រៀន។ ដូច្នេះ

**សូក្រាត** *ត្រូវផ្តល់គំរូនៃការគោរពរដ្ឋ និងការគោរពច្បាប់។ លោកបាននិយាយថា៖* **ច្បាប់គឺជាមាតាបិតារបស់ខ្ញុំ។**

# ប្លាតុង
## (៤២៧-៣៤៧ឆ្នាំមុនគ្រិស្តសករាជ)

**ប្លាតុង** *(Platon)* គឺជាសាវករបស់ **សូក្រាត**។ **ប្លាតុង**កើតក្នុងត្រកូលអភិជនដែលគួរតែធ្វើការជាមន្ត្រីជាន់ខ្ពស់ដឹកនាំប្រទេស។ មុន**ប្លាតុង** ទស្សនវិទូមុន **សូក្រាត** យកធម្មជាតិជាកម្មវត្ថុនៃការសិក្សា។ ក្នុងក្របខណ្ឌនៃទស្សនវិជ្ជាធម្មជាតិ ពិភពលោកកកើតឡើងដោយសារធាតុចំនួនបួនគឺ ៖ ទឹក ដី ភ្លើង និងខ្យល់។ គេខិតខំពន្យល់ពីប្រភពនៃចក្រវាល។

ក៏ប៉ុន្តែ **ប្លាតុង**បានដាក់ចេញនូវភារកិច្ច ស្វែងរកអំពើល្អពិតប្រាកដ។ ក្នុងន័យនេះ ចំពោះ **ប្លាតុង** ការហាត់គិតបែបទស្សនវិជ្ជា គឺជាលំហាត់បែបប្រាជ្ញាដើម្បីបណ្តុះបណ្តាលខ្លួនឯង។ ក្នុងន័យនេះ **ប្លាតុង**បានធ្វើការជាច្រើនជាមួយទស្សនវិទូពីតាហ្គ័រនិយម ដោយប្រើប្រាស់លំហាត់គណិតវិទ្យា ដើម្បីធ្វើ **វិសុទ្ធកម្មអាត្មន** *(purification de l'âme)*។ ដើម្បីគិតឱ្យបានត្រឹមត្រូវ គេត្រូវត្រៀមខ្លួនបោះបង់ចោលនូវមតិមុន ដោយសារមតិនេះខុស ឬមិនពេញលេញ ឬពិតតែផ្នែកខ្លះ។ លំហាត់នេះជួយឱ្យព្រលឹងសុទ្ធល្អ ដោយចាប់យកអ្វីដែលពិត ជាជាងអ្វីដែលមិនច្បាស់លាស់ ហើយត្រៀមលក្ខណៈចាប់យកមតិយោបល់ថ្មី។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់ **ប្លាតុង** គឺ៖ *La République*។

វិធីគិតរបស់**ប្លាតុង** គឺគេត្រូវឆ្លងកាត់ និងទៅឱ្យហួសពីពុទ្ធិដែលគេមាន ឆ្ពោះទៅរកការពិត និងអំពើល្អ។ វិធីនេះមានឈ្មោះថា ៖ ទ្រឹស្តីនៃគំនិត *(la théorie des idées)*។ **ប្លាតុង**ចោទសួរដូចសាលាមីឡេដែរ ៖ តើសារធាតុអ្វីដែលនៅសេសសល់ តាមរយៈ**ការផ្លាស់ប្តូរ** *(le devenir)* និង **ភាពមិនទៀងទាត់** *(l'éphémère)* នេះ? តើអ្វីទៅនៅជាអចិន្ត្រៃយ៍? **ប្លាតុង**ឆ្លើយថា ៖ **កំណិត**។ ដូច្នេះ ទស្សនវិជ្ជារបស់**ប្លាតុង**ផ្តោតលើ **គំនិត** *(les Idées)*។

**កំណិត ៖ គំនិត** គឺជា ភាវៈ *(être)* និង តម្លៃ *(valeur)* បូកបញ្ចូលគ្នា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គំនិតគឺជាប្រភពនៃភាវៈទាំងអស់ ហើយនៅក្នុងពេលតែមួយ ក៏ជាប្រភពនៃអំពើល្អ។ ភាវៈគឺជាតម្លៃ។ គំនិតមានភាពដាច់ខាត (Les Idées sont absolu)។ ដូច្នេះហើយទើប**ប្លាតុង**បានសរសេរពីគំនិតស្តីពីសមភាព គំនិតស្តីពីយុត្តិធម៌ គំនិតស្តីពីសោភ័ណ គំនិតស្តីពីភាពធំធេង គំនិតស្តីពីការគួរសម។ល។ តើពុទ្ធិស្តីពីគំនិតចេញមកពីណា? **សូក្រាត** និយាយពីគំនិតពីខាងក្នុង(Idées innées)។ ឯ**ប្លាតុង**និយាយពីអនុស្សារណៈឬការចងចាំ(réminiscence)។ ចំពោះ**ប្លាតុង** និយាយថា គំនិតពីខាងក្នុងមិនគ្រប់គ្រាន់ទេ ព្រោះគំនិតមានមុនពេលចាប់កំណើត(la naissance) ទៅទៀត។ នៅពេលដែលយើងកើត អាត្ម័នបាត់បង់នូវការចងចាំច្បាស់លាស់។

**អនុស្សារណៈ ឬ ការចង់ចាំ** (réminiscence)៖ **ប្លាតុង** ប្រើប្រាស់វិធីសាស្ត្របង្កើតកូនរបស់ **សូក្រាត** ដើម្បីរំឭកឡើងវិញ ដោយហៅថា **អនុស្សារណៈ** (réminiscence)។ អាត្ម័នដែលបានស្គាល់នូវភាពប្រាកដនិយមក្នុងពិភពអាទិទេព លើភពផែនដី និងនៅក្នុងស្ថាននរក មិនអាចបំភ្លេចនូវការចងចាំរបស់ខ្លួនបានឡើយ។ អាត្មន័ដែលធ្លាប់ចងចាំរួច អាចនឹងនឹកឃើញវិញនូវអនុស្សាវរីយ៍ចាស់ៗដែលធ្លាប់បានឆ្លងកាត់។ ដូច្នេះ ទស្សនវិទូមានមុខងារធ្វើឱ្យអាត្មន័មានការចងចាំដែលធ្វើឱ្យអាត្មន័អាចធ្វើដំណើរឆ្ពោះទៅរកព្រះអាទិទេព។ គោលដៅនៃការអប់រំ គឺដើម្បីរំឭកឡើងវិញ និងធ្វើឱ្យភ្លឺច្បាស់នូវអនុស្សាវរីយ៍នៃគំនិតដែលបានគិតគូរពីពេលមុនការចាប់កំណើត។ ការចាប់កំណើតនេះ (naissance) មានន័យថា ៖ មុនពេលវេលា។ **ប្លាតុង**និយាយថា ៖ អាត្មន័មើលឃើញគំនិតមុនពេលចាប់កំណើត (L'âme a contemplé les Idées avant sa naissance)។ ប្រការនេះមានន័យថា ៖ យើង ខិតចំប្រឹងប្រែងប្រមើលមើល ឬធ្វើការព្យាករណ៍អ្វីមួយនៅថ្ងៃខាងមុខ ដែលហួសពីសមត្ថភាពស្រមើស្រមៃរបស់យើងទៅទៀត។ ដូច្នេះ គំនិតនេះមានរួចមកហើយ តែកប់ត្រង់ណាមួយ។ យើងត្រូវខិតខំរំឭកវា។

**សេរីភាព ៖ ប្លាតុង**បានអំពាវនាវឱ្យមានសេរីភាពដែលអនុញ្ញាត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យមនុស្សអាចសម្រេចហួសសមត្ថភាពរបស់ខ្លួនទៅទៀត។ **សូក្រាត** និយាយថា ៖ ខ្ញុំដឹងថា ខ្ញុំអត់ចេះអ្វីទាំងអស់។ តែ**ប្លាតុង**និយាយថា ៖ ដឹងថាខ្ញុំភ្លេចបាត់អស់។ ដូច្នេះ ខ្ញុំត្រូវខិតខំប្រឹងប្រែងរំឭកឡើងវិញនូវអនុស្សាវរីយ៍ ដើម្បីរំឭកគំនិត។ ប្រសិនបើគ្មានគំនិតទេ នោះក៏គ្មានពុទ្ធិដែរ។ ដូច្នេះ ពុទ្ធិពិតប្រាកដមាននៅត្រឹមកម្រិតនៃគំនិតប៉ុណ្ណោះ។

**ទស្សនវិជ្ជាទ្វិភាគនិយម** *(le dualisme)*៖ **ប្លាតុង**បានបង្កើតទ្រឹស្តី**ឥន្ទ្រិយភព** *(le monde sensible)* និងទ្រឹស្តី**មនោភព** *(le monde intelligible)*។ ឥន្ទ្រិយភពជាភពនៃពុទ្ធិដែលបុគ្គលបានត្រឹមតែ**ការទទួលអារម្មណ៍** *(la perception)* តាម **ឥន្ទ្រិយារម្មណ៍** *(la sensation)* តាមរយៈភ្នែក ច្រមុះ ត្រចៀក អណ្តាត និងកាយ។ ពុទ្ធិកម្រិតឥន្ទ្រិយភពជាពុទ្ធិក្លែងក្លាយដែលប្រែប្រួលតាមកាលៈទេសៈ និងតាមអារម្មណ៍។ ចំណែកមនោភព គឺជាភពនៃពុទ្ធិដែលបានមកដោយសារមនោ( គំនិត បញ្ញា និងវិចារណៈ) តែ **ប្លាតុង** នៅតែភ្ជាប់មនោភពទៅនឹងឥន្ទ្រិយភព។ ពោលគឺ ដើម្បីទទួលបានពុទ្ធិពិតប្រាកដ ពុទ្ធិដែលទទួលបានពីឥន្ទ្រិយភព ត្រូវយកវិនិច្ឆ័យ ដោយប្រើប្រាស់មនោទៀត គឺ៖ គំនិត បញ្ញា និងវិចារណៈ។ ឧទាហរណ៍ តាមរយៈការគិតប្រកបដោយវិចារណញ្ញាណ យើងអាចយល់ពីឥន្ទ្រិយភព ពោលគឺវិទ្យាសាស្ត្រធម្មជាតិ។ តែយើងត្រូវសិក្សាឱ្យជ្រៅថែមទៀត ដើម្បីយល់ពីច្បាប់ធម្មជាតិ និងបាតុភូតផ្សេងៗ។ ពោលគឺយើងត្រូវមើលទៅក្រៅតាមរយៈវិនិច្ឆ័យ ដោយប្រើប្រាស់មនោទៀត ( គំនិត បញ្ញា និងវិចារណៈ) ដើម្បីយល់ពីភពគំនិត *(le monde des Idées)*។ ការសិក្សាស្រាវជ្រាវទស្សនវិជ្ជា គឺជាការបណ្តុះសមត្ថភាពស្វែងយល់ពីអ្វីដែលឥន្ទ្រិយភព ឬភពខាងក្នុងមិនអាចយល់បាន។ មនុស្សម្នាក់ៗត្រូវប្រើប្រាស់គំនិតរបស់ខ្លួន ធ្វើវិសុទ្ធកម្ម រហូតដល់អាចមើលឃើញគំនិត។ គំនិតប្រមូលផ្តុំភាវៈ និងតម្លៃ។ ប្រភពនៃតម្លៃទាំងអស់ គឺអំពើល្អ។ ប្រសិនបើគ្មានអំពើល្អទេ សមភាព និងយុត្តិធម៌ក៏គ្មានតម្លៃអ្វីដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**អាត្ម័ន** ៖ ចំពោះ **ប្លាតុង** ព្រលឹង ឬ **អាត្ម័ន** *(l'âme)* ស្ថិតនៅជាអមតៈ។ អាត្ម័នមិនមែនជាគំនិតទេ តែអាត្ម័នស្រដៀងនឹងគំនិតដែរ ដោយសារអាត្ម័នមានលក្ខណៈសាមញ្ញ និងអមតៈ។ គំនិតក៏មានលក្ខណៈអមតៈ សាមញ្ញ និងមិនប្រែប្រួល។ **ប្លាតុង** បែងចែកអាត្ម័នជាបីផ្នែក៖ (១) ការស្រេកឃ្លាន និងកាមតណ្ហា ដែលជាអាត្ម័នដែលស្ថិតនៅក្នុងពោះផ្នែកខាងក្រោម។ គោលការណ៍របស់វា គឺការខ្វះវិចារណញ្ញាណ ហើយមានតែតណ្ហា តែគុណធម៌របស់វា គឺការអត់ធ្មត់។ លក្ខណៈនេះត្រូវនឹងវណ្ណៈប្រជាកសិករ និងអ្នកជំនួញ (២) បេះដូង គឺជាអាត្ម័នទីពីររបស់មនុស្សដែលជាកន្លែងបង្កើតតណ្ហា ហើយស្ថិតនៅក្នុងពោះផ្នែកខាងលើ។ គោលការណ៍របស់វា គឺកំហឹង រីឯគុណធម៌ គឺសេចក្ដីក្លាហាន។ លក្ខណៈនេះត្រូវនឹងវណ្ណៈទាហាន និង (៣) គំនិត *(l'esprit)* គឺជាផ្នែកទីបីនៃអាត្ម័នដែលស្ថិតនៅក្នុងក្បាល។ គោលការណ៍របស់វា គឺវិចារណញ្ញាណ ចំណែកឯគុណធម៌ គឺការប្រុងប្រយ័ត្ន *(la prudence)*។ អាត្ម័នដែលលក្ខណៈនេះត្រូវនឹងវណ្ណៈទស្សនវិទូដែលជាអ្នកគ្រប់គ្រង និងដឹកនាំប្រទេសជាតិឆ្ពោះទៅរកវឌ្ឍនភាព និងភាពចម្រើនរុងរឿង។

**បញ្ហានយោបាយ** ៖ ទស្សនវិជ្ជារបស់ **ប្លាតុង** ផ្ដោតផងដែរលើបញ្ហានយោបាយ។ **ប្លាតុង** បានសរសេរសៀវភៅចំនួនពីរស្ដីពីបញ្ហានយោបាយ ៖ សាធារណរដ្ឋ និងច្បាប់។ **ប្លាតុង** ធ្វើអត្ថាធិប្បាយពីម៉ូដែលរដ្ឋគំរូ។ នៅពេលដែលអាត្ម័នទាំងបីមានសុខដុមនឹងគ្នា រដ្ឋក៏មានសុខដុមផងដែរ។ រដ្ឋមានសុខដុម មានយុត្តិធម៌ ដោយសារតែពលរដ្ឋដើរតួនាទីទៅតាមកម្រិតនៃអាត្ម័ន។ នយោបាយត្រូវចំណុះឱ្យសីលធម៌ *(la politique doit se soumettre à la morale)*។ ដូច្នេះ **ប្លាតុង** បានបង្កើតឡើងនូវមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ដោយផ្ដល់តួនាទីសំខាន់ដល់ការអប់រំ តាមរយៈការបង្រៀនប្រជាជនឱ្យចេះ ច្បាប់ និងមានសមត្ថភាពធ្វើអំពើល្អពិតប្រាកដ និងដើម្បីឆ្លើយតបទៅនឹងការទាមទារនៃគំនិត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## សៀវភៅស្ដីពីការគ្រប់គ្រងរដ្ឋ ឬ សាធារណរដ្ឋរបស់ប្លាតុង

**ប្លាតុង**សរសេរសៀវភៅស្ដីពី «**ការគ្រប់គ្រងរដ្ឋ**» ដែលមានទាំងអស់ ១០កណ្ឌ ជាការសន្ទនានៅផ្ទះរបស់ Polémarque រវាង Socrate, Polémarque, Thrasymaque, Glaucon Adimante និងភ្ញៀវពីរនាក់ទៀត។ សិល្បៈនៃការសន្ទនា ឬវិចារវិទ្យាអនុញ្ញាតឱ្យគេវិភាគពីបញ្ហាផ្សេងៗ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ពីសម្មតិកម្មមួយទៅសម្មតិកម្មមួយទៀត និងដោយប្រើឧទាហរណ៍ពិសេស និងជាក់ស្ដែងដើម្បីរកនិយមន័យអរូបី។ ទស្សនវិជ្ជារបស់**ប្លាតុង** គឺជាទស្សនវិជ្ជាសព្វឯកវិធី (Déduction) ដោយវិភាគពីច្បាប់ ឬបញ្ហារួមទៅរកព្រឹត្តិការណ៍ជាក់ស្ដែង។ **ប្លាតុង**ប្រើវិធីសាស្ត្របង្កើតកូនរបស់**សូក្រាត** ដើម្បីបង្កើតគំនិត។ **សូក្រាត**ក៏ប្រើប្រាស់នៅក្នុងការសន្ទនានូវវិធីសាស្ត្រតក្កវិទ្យាផងដែរ។

**យុត្តិធម៌** ៖ តាមរយៈការសន្ទនាស្ដីពីយុត្តិធម៌ **ប្លាតុង**ចង់ឱ្យនិយមន័យវិធាន ដែលត្រូវយកមកគ្រប់គ្រងសាធារណរដ្ឋ ដែលជារដ្ឋមានឧត្តមគតិខ្ពស់ និងក្នុងក្ដីស្រមើស្រមៃដែល**សូក្រាត**ចង់បង្កើតឡើង។ លោកចង់កំណត់សិទ្ធិ និងភារកិច្ចនៅក្នុងសង្គម និងកំណត់ផលប្រយោជន៍ និងការចូលរួមរបស់សមាជិកក្នុងសង្គម។ **សូក្រាត**ចាប់ផ្ដើមពិភាក្សាជាមួយCéphale ពីយុត្តិធម៌ក្នុងការបែងចែកមត៌ក។ **សូក្រាត**និយាយថា៖ «យុត្តិធម៌មិនមែនជាការនិយាយពីសច្ចធម៌ឡើយ ហើយក៏មិនមែនប្រគល់ឱ្យបុគ្គលណាម្នាក់នូវអ្វីដែលគាត់ត្រូវបានដែរ»។ យុត្តិធម៌មានន័យទូលំទូលាយ។ យុត្តិធម៌គឺត្រូវធ្វើល្អចំពោះមិត្ត និងធ្វើអាក្រក់ចំពោះសត្រូវ។ មិត្តពិតប្រាកដ គឺមិត្តល្អ ហើយមិត្តអាក្រក់ គឺជាសត្រូវ។ ដូច្នេះ យុត្តិធម៌គឺត្រូវមានការដាក់ទោសទណ្ឌចំពោះការរំលោភ។ យុត្តិធម៌ចំពោះពលរដ្ឋ គឺការគោរពច្បាប់។ យុត្តិធម៌គឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យនៃក្រុងអាតែន។ ការគ្រប់គ្រងរដ្ឋរបស់**សូក្រាត**ឈរលើមូលដ្ឋាននៃយុត្តិធម៌ក្នុងន័យទូលាយ។ ចំពោះ**សូក្រាត** យុត្តិធម៌មិនមែនតែជួយអ្នកទទួលផលប្រយោជន៍ទេ តែគឺត្រូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជួយដល់ជនរងគ្រោះ។ **ប្លាតុង**យល់ឃើញថា យុត្តិធម៌គឺត្រូវបែងចែកឡើងវិញនូវទ្រព្យសម្បត្តិ ដើម្បីរកចំណុចកណ្តាលមួយ។

**ស្តីពីការអប់រំ ៖ សូក្រាត**យល់ថាតន្ត្រី និងការហាត់ប្រាណត្រូវដើរតួនាទីសំខាន់ក្នុងការអប់រំយុវជន។ **ប្លាតុង**បានលើកឡើងពីទំនាក់ទំនងរវាងរាងកាយ និងអាត្មន។ **សូក្រាត**និយាយថា ក្មេងដែលមានការអប់រំល្អនឹងក្លាយជាមនុស្សពេញលក្ខណៈ ពួកគេនឹងមើលឃើញគ្រប់រឿងទាំងអស់ ហើយច្រើនជាងអ្វីដែលយើងឃើញ។ ដូច្នេះ **ប្លាតុង**បានសរសេរយ៉ាងច្រើនពាក់ព័ន្ធនឹងការអប់រំកុមារដែលលោកចាត់ទុកថា គឺជាការអប់រំមនុស្សថ្មីសម្រាប់សាធារណរដ្ឋដ៏ឧត្តុង្គឧត្តម។ គេត្រូវបង្ហាញក្មេងនូវអ្វីដែលស្រស់ស្អាត និងល្អ។ ដូច្នេះ គេត្រូវត្រួតពិនិត្យឱ្យបានដិតដល់នូវកវីនិពន្ធ។

**រដ្ឋយុត្តិធម៌ ៖** ជីវភាពរបស់កងទ័ពមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការរីកចម្រើនរបស់រដ្ឋ។ ក៏ប៉ុន្តែ យុត្តិធម៌សង្គម គឺជាគោលដៅចម្បងនៃការគ្រប់គ្រងរដ្ឋ។ **សូក្រាត**និយាយថា ៖ «ដំបូងគេត្រូវធ្វើយ៉ាងដូចម្តេចឱ្យជីវភាពរបស់កងទ័ពបានល្អប្រសើរ។ ក៏ប៉ុន្តែ គេបង្កើតរដ្ឋមិនមែនដើម្បីបម្រើវណ្ណៈណាមួយឡើយ។ គេត្រូវធ្វើយ៉ាងណាឱ្យពលរដ្ឋទាំងអស់បានសប្បាយទាំងអស់គ្នា»។ នៅក្នុងទីក្រុងក្នុងឧត្តមគតិរបស់**ប្លាតុង** គេហាមឃាត់នូវការសម្បូណ៌ខ្ជះខ្ជាយ និងភាពក្រីក្រតោកយ៉ាក។ សម្រាប់**ប្លាតុង** សាធារណរដ្ឋគឺជាទីក្រុងដែលមានសមភាពដែលគ្មានអ្នកមាន និងគ្មានអ្នកក្រ។ **ប្លាតុង**ចង់បង្កើតច្បាប់គ្រប់គ្រងកិច្ចសន្យាលក់ដូរ ច្បាប់សម្រាប់ពលករ អំពើហិង្សា ចៅក្រម ពន្ធ ការនាំចេញ និងនាំចូលទំនិញជាដើម។ **ប្លាតុង**លើកឡើងពីប្រភពច្បាប់ដែលបង្កើតឡើងដោយព្រះអាទិទេព។ «គឺជាអាប៉ូឡុងដែលជាអាទិទេពនៃ Delphes ដែលតាក់តែងច្បាប់ ដែលធំ ដែលល្អ និងដំបូងបំផុត»។

រដ្ឋត្រូវតែមានគតិបណ្ឌិត មានភាពក្លាហាន មានអំណត់ និងមានយុត្តិធម៌។ គតិបណ្ឌិតគឺស្ថិតនៅក្នុងការប្រយ័ត្នប្រយែង និងនៅក្នុងវិទ្យា-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាស្ត្រ។ ការគ្រប់គ្រងរដ្ឋត្រូវប្រគល់ឱ្យមនុស្សមួយក្រុមតូច ដែលជាអ្នកការពារផលប្រយោជន៍ពិតប្រាកដរបស់រដ្ឋ។ នៅក្នុងរដ្ឋ ត្រូវមានវិទ្យាសាស្ត្រ។ រដ្ឋដែលមានយុត្តិធម៌ គឺ៖«នៅពេលដែលសណ្ដាប់ធ្នាប់នៅក្នុងរដ្ឋ ទាំងអ្នកពាណិជ្ជករ អ្នកកងទ័ព និងអ្នកតុលាការត្រូវស្ថិតនៅក្នុងព្រំដែនពិសេសមួយ ដែលផ្ទុយពីអំពើអយុត្តិធម៌។ អ្វីដែលរដ្ឋធ្វើ គឺជាអំពើយុត្តិធម៌»។ យុត្តិធម៌មានតែនៅក្នុងរដ្ឋដែលគ្រប់គ្រងបានល្អ។ យុត្តិធម៌មានគោលដៅជានាំឱ្យមានសណ្ដាប់ធ្នាប់សង្គម។ **ប្លាតុង** ឱ្យនិយមន័យអំពើអយុត្តិធម៌ថាជាការគ្មានសណ្ដាប់ធ្នាប់ វិបត្តិ ការកំសាក និងអំពើអសកម្មដទៃទៀត។

**មហាក្សត្រ-ទស្សនវិទូ** ៖ ដើម្បីអនុវត្តគំនិតរបស់ខ្លួន **ប្លាតុង**បានចាកចេញពីក្រុងអាតែន ដើម្បីធ្វើដំណើរដល់ស៊ីស៊ីល(Sicile)។ នៅទីនោះ **ប្លាតុង**បានចងមេត្រីភាពជាមួយ**ឌីយ៉ុង**(Dion) ដែលជាគ្រូសារគ្រប់គ្រងនៅសាយរ៉ាយូស (Syracuse) ដោយសង្ឃឹមថានឹងបណ្ដុះបណ្ដាល**ឌីយ៉ុង**ឱ្យក្លាយទៅជា **មហាក្សត្រ-ទស្សនវិទូ** (le philosophe-roi) ទៅតាមសុបិន្តរបស់ខ្លួន។ **ប្លាតុង**មិនចង់ឡើងកាន់អំណាចខ្លួនឯងឡើយ តែចង់មានឥទ្ធិពលលើអ្នកនយោបាយ និងផ្សាភ្ជាប់នយោបាយទៅនឹងបញ្ញា។ ក៏ប៉ុន្តែ គម្រោងរបស់**ប្លាតុង**ត្រូវបរាជ័យ ហើយគាត់ក៏បានចាកចេញពីទីនោះ។ ពេលធ្វើដំណើរតាមផ្លូវ សំពៅក៏លិចទឹក ហើយ**ប្លាតុង**ត្រូវបានចោរសមុទ្រចាប់។ បន្ទាប់ពីរួចខ្លួនពីចោរសមុទ្រ **ប្លាតុង**បង្កើតសាលាដ៏ល្បីមួយឈ្មោះ **បណ្ឌិត្យសភា**។

ដើម្បីគ្រប់គ្រងរដ្ឋឱ្យបានល្អ **ប្លាតុង**បានស្នើសុំឱ្យទស្សនវិទូក្លាយជាស្ដេចគ្រប់គ្រងប្រទេស ហើយស្ដេចត្រូវតែក្លាយខ្លួនជាទស្សនវិទូ។ លោកយល់ថាគេត្រូវរកទស្សនវិទូពិតប្រាកដដែលចូលចិត្តស្វែងរកសច្ចធម៌ ហើយមានតែទស្សនវិទូពិតប្រាកដទេដែលអាចដឹកនាំមនុស្សបាន តាមរយៈការគោរពច្បាប់ និងស្ថាប័ន។ មានតែទស្សនវិទូប៉ុណ្ណោះដែលចូលចិត្តវិទ្យាសាស្ត្រដែលធ្វើការដើម្បីលើកកម្ពស់យុត្តិធម៌ សោភ័ណភាព និងគុណធម៌ដទៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទៀត។ ដើម្បីបណ្ដុះបណ្ដាលទស្សនវិទូ គេត្រូវរៀនរេខាគណិត ឬវិទ្យាសាស្ត្រខាងគណនាលេខ ធរណីមាត្រ តារាសាស្ត្រ វិចារវិទ្យា រូបវិទ្យា និងវិទ្យា-សាស្ត្រមនុស្សសាស្ត្រដទៃទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# **អារីស្តូត**

## **(៣៨៤-៣២២ឆ្នាំ មុនគ្រិស្តសករាជ)**

**អារីស្តូត** *(Aristote)* ជាសាវករបស់**ប្លាតុង**ក្នុងរយៈពេលជិត២០ឆ្នាំ និងធ្លាប់បង្រៀននៅបណ្ឌិត្យសភាផងដែរ។ **អារីស្តូត**បង្កើតនូវប្រព័ន្ធទស្សនវិជ្ជាដែលក្លាយទៅជាប្រព័ន្ធគំនិតមួយដ៏សំខាន់នៃបស្ចិមប្រទេស។ ស្នាដៃរបស់**អារីស្តូត**ផ្តោតលើវិស័យជាច្រើន ៖ តក្កវិទ្យា រូបវិទ្យា តារាវិទ្យា ជីវវិទ្យា ចិត្តវិទ្យា **បរមត្ថវិជ្ជា** *(métaphysique)* សីលធម៌*(éthique)* នយោបាយ វោហាសាស្ត្រ*(rhétorique)* និងកំណាព្យ។ ម្យ៉ាងវិញទៀត **អារីស្តូត**គឺជាអ្នកបង្កើតគំនិតវិចារណញ្ញាណ ៖ តក្កវិទ្យា ប្រភេទ គំនិតទូទៅ និង **ត្រៃយ-វាទនិយម** *(Syllogisme)*។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់ **អារីស្តូត** គឺ៖ La Métaphisique ឬបរមត្ថវិទ្យា។

**ទស្សនវិជ្ជាទ្វិកនិយម** *(le dualisme)* ៖ **ប្លាតុង**បានបង្កើតទ្រឹស្តីទ្វេ **ឥន្ទ្រិយភព** *(le monde sensible)* និង **មនោភព** *(le monde intelligible)*។ ពុទ្ធិដែលទទួលបានតាមឥន្ទ្រីយារម្មណ៍ត្រូវវិនិច្ឆ័យដោយប្រើប្រាស់មនោ (គំនិត បញ្ញា និងវិចារណៈ) ដើម្បីយល់ពីភពគំនិត *(le monde des Idées)*។ ប្រការនេះ គឺជាលក្ខខណ្ឌទ្វេរបស់**ប្លាតុង**រវាង **ឥន្ទ្រិយភព** និងគំនិត។ ក៏ប៉ុន្តែ **អារីស្តូត**បានបង្កើតលក្ខខណ្ឌទ្វេរវាង **ឯក** *(singulier)* និង **សាកល** *(universel)* រវាង **ភាពជាក់ស្តែង** *(concret)* និង **ទូទៅ** *(général)* ពោលគឺ **អរូបី** *(abstrait)*។

**និយមន័យទស្សនវិជ្ជា** ៖ **អារីស្តូត**បានសិក្សាពីបរិមាណ និងគុណភាព និងបានបង្កើតឱ្យមាន**ទស្សនាទាន** *(concept)* ឬ**យថាប្រភេទ** *(catégories)*។ វិទ្យាសាស្ត្រសិក្សាពីបរិមាណ និងគុណភាពវត្ថុដោយប្រើ-ប្រាស់យថាប្រភេទ។ **អារីស្តូត**ឱ្យនិយមន័យទស្សនវិជ្ជាថា ជាវិទ្យាសាស្ត្រនៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មូលហេតុបឋម** *(causes premières)* ឬ **ភាវៈជាភាវៈ** *(être en tant qu'être)*។ ឧទាហរណ៍ វិទ្យាសាស្ត្រសិក្សាពីមូលហេតុដែលធ្វើឱ្យលោហៈរីកមាឌ។ លោហៈរីកមាឌបណ្ដាលមកពីកម្ដៅ។ មូលហេតុដែលធ្វើឱ្យមានកម្ដៅ គឺភ្លើង។ល។ ទាំងអស់នេះមិនមែនជាមូលហេតុបឋមទេ។ **ប៉ារមេនីដ** ធ្លាប់បានបង្កើតទ្រឹស្ដីនៃ**ភាវៈ ឬជីវន្តវិជ្ជា** *(ontologie)*។ សាលាមីឡេរបស់ **តាលែស** ចាត់ទុកសារធាតុជាមូលដ្ឋាននៃអ្វីៗទាំងអស់ដែល **តាលែស** ខ្លួនឯងចាត់ទុកថាជា **ទឹក**។ ក៏ប៉ុន្តែ ទស្សនវិទូផ្សេងទៀតនៃសាលាមីឡេ ចាត់ទុកថា ជាភ្លើង ឬអនន្ត។ **អារីស្តូត**ហៅ **សារធាតុ** *(substance)* ថាជា **ភាវៈនៅក្នុងខ្លួនឯង** *(être en soi)* **ភាវៈជាភាវៈ** *(être en tant qu'être)* ដែលមិនចេះប្រែប្រួល។ យើងមិនដែលឃើញ **ភាវៈជាភាវៈ**ទេ។ យើងបានឃើញត្រឹមមនុស្ស សត្វ បក្សី វត្ថុ គំនិត ។ល។

**បរមត្ថវិជ្ជា ៖ អារីស្តូត**កំណត់ប្រធានបទនៃការសិក្សារបស់វិទ្យាសាស្ត្រ និងទស្សនវិជ្ជា។ វិទ្យាសាស្ត្រសិក្សាពីអ្វីដែលប្រែប្រួល និងដែលទទួលអារម្មណ៍បានតាមឥន្ទ្រីយារម្មណ៍( ភ្នែក ច្រមុះ ត្រចៀក អណ្ដាត និងកាយ)។ ចំណែកឯទស្សនវិជ្ជាសិក្សាពីភាវៈ*(être)* ដែលមិនប្រែប្រួល *(immuable)* ដែលជា **ជីវន្តវិទ្យា** *(ontologie)* ឬជា **បរមត្ថវិទ្យា** *(métaphysique)*។ មិនប្រែប្រួលមានន័យថា ទោះជាមានការផ្លាស់ប្ដូរយ៉ាងណា វានៅតែជាភាវៈដដែល។ នេះហើយគឺជាមូលហេតុបឋម តាមការយល់របស់**អារីស្តូត** គឺភាវៈ។

**រូបធាតុ និង ទម្រង់ ៖** ទស្សនាទានដ៏សំខាន់មួយទៀតរបស់**អារីស្តូត** គឺ **រូបធាតុ** *(la matière)* និង **ទម្រង់** *(la forme)*។ រូបធាតុ គឺជា**ភាវៈមានឋាមពល** *(l'être en puissance)* ឬដែលមិនទាន់ច្នៃ ពោលគឺមិនទាន់មានសភាពពិតប្រាកដ ដូចជាវត្ថុធាតុដើម។ ផ្ទុយទៅវិញ ទម្រង់ គឺជារូបធាតុដែលបានច្នៃ ដែលបានប្រែរូប ពីភាវៈមានឋាមពល ឬដែលមិនទាន់ច្នៃទៅជា**ភាវៈសកម្ម** *(l'être en acte)*។ ការប្រែរូបពី ភាវៈមានឋាមពលទៅ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាភាវៈសកម្ម កាត់បន្ថយសក្តានុពល(ឋាមពល)របស់សារធាតុ ដោយសារការមានទម្រង់ តែទន្ទឹមនឹងនេះក៏ជាភាវៈបច្ចុប្បន្ន (actualité) ផងដែរ។ ចំពោះ **អារីស្តូត** រូបធាតុ និងទម្រង់មិនមែនជាសភាពផ្ទុយគ្នាទេ តែអ្វីក៏ដោយមានរូបធាតុ និងទម្រង់ក្នុងពេលតែមួយ ពោលគឺផ្នែកខ្លះមិនទាន់កំណត់ តែផ្នែកខ្លះទៀតមានទម្រង់បច្ចុប្បន្ន។ **អារីស្តូត** មានសហជ-**ញ្ញាណ** (intuition) ថា៖ អ្វីៗដែលជាភាវៈមានឋាមពលតែងតែប្រែប្រួលទៅជាភាវៈសកម្ម។

**ហេតុផល ៖** ទស្សនាទានមួយទៀតរបស់ **អារីស្តូត** គឺ **ហេតុផល** (la cause)។ ចំពោះ **អារីស្តូត** ហេតុផលនៃអ្វីមួយគឺជាលក្ខខណ្ឌនៃតថភាព (conditions de réalité)។ **អារីស្តូត**បង្ហាញនូវភាពខុសគ្នារវាងមូលហេតុ៤យ៉ាង ៖

- **ហេតុផលសម្ភារៈនិយម** (la cause matérielle)៖ គឺជារូបធាតុដែលកំណត់តថាភាព (réalité) ដូចជាវត្ថុធាតុដើម។ ប្រសិនបើគ្មានវត្ថុធាតុដើមទេ គេក៏មិនអាចមានភាវៈបច្ចុប្បន្នដែរ។

- **ហេតុផលទម្រង់** (la cause formelle)៖ គឺជាការកំណត់រូបរាងនៃវត្ថុធាតុដើមឱ្យទៅជាភាវៈបច្ចុប្បន្ន។ រូបរាងកាត់បន្ថយសក្តានុពលនៃសារ-ធាតុ ឬវត្ថុធាតុដើម។

- **ហេតុផលប្រសិទ្ធភាព** (la cause efficiente)៖ គឺជាអ្នកដែលធ្វើឱ្យរូបធាតុមានទម្រង់ពិតប្រាកដ។

- **ហេតុផលបញ្ចប់** (la cause finale)៖ គឺជាគោលដៅ (le but) ពោលគឺហេតុផលនៃដំណើរការទាំងអស់នេះ។ តាមរយៈគោលដៅនេះ គេបានប្រែក្លាយរូបធាតុឱ្យមានទម្រង់ពិតប្រាកដ។

ទស្សនាទានរបស់ **ប្លាតុង** ផ្តោតលើគំនិត (Idées) ជាសំខាន់។ គំនិតរបស់**ប្លាតុង**មានលក្ខណៈ អមតៈ មិនប្រែប្រួល និងអស្តិរូប (transcendante - ពីឥន្ទ្រីយកពផ្លោះទៅរកមនោភពដែលស្ថិតនៅទីខ្ពស់)។ ទស្សនាទានរបស់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**អារីស្តូត** ផ្តោតទៅលើរាង (la forme) ដែល **អារីស្តូត** ហៅថា eidos។ ក៏ប៉ុន្តែរាងរបស់ **អារីស្តូត** គឺជាដំណើរការធ្វើបច្ចុប្បន្នកម្ម (le processus d'actualisation) និងមានជវភាព (dynamique)។

**អាត្មន័** ៖ **ប្លាតុង**បែកពិភពជាពីរ៖ **ឥន្ទ្រិយភព** (le monde sensible) និង **គំនិត** (Idées)។ ចំណែក **អារីស្តូត**វិញបែកពិភពតាមលំដាប់ ៖ រូបធាតុនៅស្ងៀម(la matière inerte) រូបធាតុសរីរាង្គ(la matière vivante) សរីរាង្គរស់(l'organisme vivante) ហើយនៅក្នុងសរីរាង្គមាន សរីរៈ(les organes)។ ដោយសាររាងសរីរៈបានក្លាយទៅជាអង្គភាពនៃភាវៈរស់(l'unité d'un être vivant) ហើយ **អារីស្តូត** ហៅរាង នេះថាជា ព្រលឹង ឬអាត្មន័។ នៅពេលដែលអាត្មន័កាន់តែដកចេញពីរូបធាតុ អាត្មន័ឡើងកាន់តែខ្ពស់ ឆ្ពោះទៅរកបច្ចុប្បន្នកម្មនៃអាត្មន័(l'actualisation de l'âme) រហូតដល់កំពូល។ នៅកំពូលមានបញ្ញា(l'intellect) ៖ បញ្ញាអកម្ម(l'intellect passif)ដែលនៅពឹងអាស្រ័យលើរូបធាតុ និងបញ្ញាសកម្ម(l'intellect actif) ដែលរំដោះខ្លួនផុតពីរូបធាតុ ហើយក្លាយជាអមតៈ។

**ត្រៃយវាទនិយម** ៖ **អារីស្តូត** បានបង្កើតទ្រឹស្តីត្រៃយវាទនិយម(Syllogisme) ដែលមានប្រយោគចំនួនបីគឺ ៖

( ទី១ )-មនុស្សទាំងអស់ត្រូវតែស្លាប់

( ទីពីរ )-**សូក្រាត**ក៏ជាមនុស្ស និង

( ទី៣ )-ដូច្នេះ **សូក្រាត**ត្រូវតែស្លាប់។

**សុភមង្គល** ៖ ចំពោះ **អារីស្តូត** សុភមង្គលគឺជាអំពើល្អដ៏កំពូល។ ចំពោះមនុស្ស សុភមង្គលគឺការធ្វើអ្វីទៅតាមគុណធម៌របស់មនុស្ស។ សុភមង្គលរបស់មនុស្សគឺសភាពដែលមានសម្ភារៈគ្រប់គ្រាន់។

**នយោបាយ** ៖ **ប្លាតុង** ផ្តល់សារៈសំខាន់ដល់នយោបាយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំរដ្ឋ។ **អារីស្តូត** បកស្រាយទ្រឹស្តី **ប្លាតុង** បន្ថែមទៀតដោយចាត់ទុកថា ៖ មនុស្សគឺជាសត្វនយោបាយ(zoon politicon,



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*un animal politique)*។ *មនុស្សគឺជាសមាជិកនៃសង្គមដែលបង្កើតឡើងជាបុរីរដ្ឋ(ville-État) និងជាពលរដ្ឋ*។

**អាទិទេព ៖ អារីស្តូត** *ហៅ* **អាទិទេព** *(Dieu) ថាជា* **អំពើបរិសុទ្ធ** *(l'acte pur)*។ *ធម្មជាតិទាំងអស់សុទ្ធតែជំរុញដោយ* **តណ្ហាចង់បាន អាទិទេព** *(le désir de Dieu)*។ *គឺការៈនេះឯង ដែលទោរទៅរកអំពើបរិសុទ្ធដោយសារតណ្ហា*។ *អំពើបរិសុទ្ធ គឺជាអំពើល្អបំផុត អំពើល្អប្រកបដោយបញ្ញាញាណ(le pur intelligible) ដែលជា* **អាទិទេព**។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សាលាអេពីគួរ
## (សតវត្សរ៍ទី៤ និងទី៣មុនគ្រិស្តសករាជ) និង

# សាលាខន្តីនិយម
## (សតវត្សរ៍ទី៣មុនគ្រិស្តសករាជ)

*សាលាទស្សនវិជ្ជាពីរដែលមានឥទ្ធិពលជាច្រើនសតវត្សរ៍លើទស្សនវិជ្ជាបស្ចិមប្រទេស គឺ សាលា***អេពីគួរ** *(l'École épicurienne) និងសាលា* **ខន្តីនិយម** *(l'École stoïcienne)។ សាលាទាំងពីរបានបង្កើតទ្រឹស្តីសីលធម៌ជាច្រើន ដើម្បីជួយឱ្យមនុស្សទាំងពួងអាចរស់នៅបានល្អប្រសើរ។*

**អេពីគួរ** *(Épicure) រស់នៅចន្លោះចុងសតវត្សរ៍ទី៤ និងទី៣ មុនគ្រិស្តសករាជ។ ទ្រឹស្តីអេពីគួរចែកចេញជាបីផ្នែក ៖ (ទី១)-***តក្កវិជ្ជា** *ដែលជានិយាម និងវិធានដើម្បីស្វែងរកការពិត។ (ទីពីរ)-***រូបវិជ្ជា** *ដែលជាទ្រឹស្តីស្តីពីធម្មជាតិ ដើម្បីអនុវត្តនិយាម និងវិធាននៃផ្នែកទីមួយ។ និង (ទី៣)-* **សីលធម៌** *ដែលជាគោលដៅជីវិត និងជាមធ្យោបាយសម្រេចបាននូវគោលដៅនេះ។ គោលដៅនៃទស្សនវិជ្ជា គឺជួយមនុស្សឱ្យមានសុភមង្គលជាពិសេសភាពស្ងប់ស្ងាត់នៃអាត្ម័ន។ ពោលគឺការសម្រេចបានសន្តិភាពក្នុងចិត្ត (un état intérieur de paix)។ សន្តិភាពក្នុងចិត្តមិនមែនការមិនអើពើ ឬព្រងើយកន្តើយ (une indifference) ឡើយ តែវាជាឯករាជ្យផ្ទៃក្នុង (une indépendance intérieure) ឬភាពស្ងប់ស្ងាត់ផ្ទៃក្នុង ដោយមិនរវីរវល់នឹងការគម្រាមកំហែង ឬតណ្ហាផ្សេងៗ។*

**សុភមង្គល** *៖ ដើម្បីទទួលបានសន្តិភាពផ្លូវចិត្ត ឬសុភមង្គលនេះ យើងត្រូវមានគំនិតត្រឹមត្រូវពីធម្មជាតិ និងត្រូវគោរពតាមច្បាប់ធម្មជាតិ ក្នុងបរិស្ថានដែលយើងរស់នៅ។ ឧបសគ្គដែលរារាំងមិនឱ្យមនុស្សទទួលបាន*

នូវសុភមង្គល គឺការភ័យខ្លាចអាទិទេព និងការភ័យខ្លាចសេចក្ដីស្លាប់។ ដើម្បីជម្នះការភ័យខ្លាចនេះ ពួកអេពីគួរនិយមបានបង្កើតទ្រឹស្ដីចក្រវាលដែលជាលោកជាតុអនន្ត និងអមតៈ ដែលមិនចេះស្លាប់។ ពួកគេបានប្រើប្រាស់ទ្រឹស្ដីអាតូមនិយម ដើម្បីពន្យល់ពីចក្រវាល។ នៅពេលដែលមានខ្លួន តែងតែមានចលនា។ ខ្លួនកើតឡើងពីអាតូមជាច្រើន ហើយអាតូមនីមួយៗមិនអាចបំបែកបាន និងមិនផ្លាស់ប្ដូរដោយសារអាតូមទាំងនោះជាធាតុតែមួយ។

**អាតូម** ៖ ទ្រឹស្ដីស្ដីពីធម្មជាតិផ្ដោតលើការធ្លាក់ចុះក្រោមនៃអាតូមដែលប៉ះទង្គិចគ្នាហើយបង្កើតបានជាចលនា។ ដូច្នេះ ចក្រវាល និងធម្មជាតិគឺជាចលនាមេកានិច។ អ្វីៗដែលកើតឡើងក្នុងលោកគ្រប់គ្រងដោយច្បាប់មេកានិចដែលមិនចេះការពារ ឬដាក់ទណ្ឌកម្មមនុស្សលោកឡើយ។ ក្នុងន័យនេះ គ្មានមូលហេតុអ្វីដែលមនុស្សត្រូវខ្លាចអាទិទេពទេ។ ទស្សនវិទូអេពីគួរនិយមយល់ឃើញថា អាទិទេពរស់នៅលើមេឃជាមួយនឹងផ្កាយ។ ចំណែកសេចក្ដីស្លាប់វិញ គឺជាការបែកខ្ញែកនៃអាតូម។ មានតែព្រលឹង ឬអាត្ម័នទេដែលស្ថិតនៅជាអមតៈ តែអាតូមនៃអាត្ម័ននឹងបែកខ្ញែកដែរ។ ដូច្នេះ គ្មានហេតុផលអ្វីដែលត្រូវខ្លាចសេចក្ដីស្លាប់ ដ៏ដូចជាគ្មានហេតុផលដែលត្រូវខ្លាចពេលមុនចាប់កំណើតដែរ។ នៅពេលដែលយើងកំពុងរស់នៅ គ្មានទេសេចក្ដីស្លាប់ ហើយនៅពេលដែលសេចក្ដីស្លាប់មកដល់ យើងលែងមានជីវិតរស់នៅទៀតហើយ។ ដូច្នេះ សេចក្ដីស្លាប់តាមយើងមិនទាន់ទេ។

**ខន្ដីនិយម** ៖ ទ្រឹស្ដី **ខន្ដីនិយម** *(la doctrine stoïcienne)* បែកចេញជាបីផ្នែក ហើយមានគោលដៅបង្រៀនមនុស្សឱ្យចេះរស់នៅ។ ពាក្យ *Les stoïciens* មកពីពាក្យក្រិកថា stoa ដែលមានន័យថា៖ កន្លែងដែលគេជួបជុំគ្នា។ ទស្សនជនក្រិកល្បីៗជាច្រើន គឺជាពួកខន្ដីនិយម ដូចជា *Cicéron, Sénèque, Épictète, Marc Aurèle* ជាដើម។ ទ្រឹស្ដីខន្ដីនិយមបែកចេញជាបីផ្នែកដែរ ៖ (ទី១)-**តក្កវិជ្ជា** ឬទ្រឹស្ដីនៃពុទ្ធិ។ (ទីពីរ)-**រូបវិជ្ជា** ឬទ្រឹស្ដីនៃធម្មជាតិ។ និង (ទី៣)-**សីលធម៌**។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**តក្កវិជ្ជា** ៖ តក្កវិទ្យាខន្តីនិយមផ្តោតលើការត្រិះរិះពិចារណា យ៉ាងទូលំទូលាយ (l'aperception compréhensive) ដែលមានន័យថា៖ វត្ថុផ្សេងៗបានធ្វើឱ្យអាត្ម័នមានការចាប់អារម្មណ៍យ៉ាងច្បាស់ និងយ៉ាងប្រត្យក្ស។ ដោយសារមានការចាប់អារម្មណ៍យ៉ាងប្រត្យក្សនេះហើយ ទើបអាត្ម័នទទួលយក និងបង្កើតបានជាពុទ្ធិ និងវិទ្យាសាស្ត្រ។ ពោល គឺជាបទពិសោធន៍នៃសក្ដិកម្ម។

**ប្រភពនៃពុទ្ធិ** ៖ ទស្សនវិជ្ជាខន្តីនិយមមិនផ្តោតលើគំនិតដូច**ឡាតុខ** ឬទ្រឹស្តីពាង និងដំណើរការធ្វើបច្ចុប្បន្នកម្មឡើយ។ ផ្ទុយទៅវិញ ពួកគេយល់ថា **ការទទួលអារម្មណ៍** (la perception) តាម**ឥន្ទ្រិយារម្មណ៍** (la sensation) គឺជាប្រភពនៃពុទ្ធិ។ ពួកគេយល់ថា គំនិតទូទៅ គឺជាសញ្ញាណអរូបី ជាឈ្មោះ ជាពាក្យ តែមិនមែនជាតថភាពឡើយ។ មានតែវត្ថុជាក់លាក់ គឺជាតថភាព។ អ្វីដែលភ្នែកមើលឃើញ មិនមែនសត្វគោជាទូទៅទេ តែជាគោជាក់ស្តែងមួយ។

**អាទិទេព** ៖ គេយល់ថាពិភពលោក និងធម្មជាតិទាំងមូលគ្រប់គ្រងដោយអាទិទេពដែលជាអាត្ម័ននៃលោកដែលមានតុល្យភាព។ «**អាទិទេព គឺជាអ្វីៗទាំងអស់។ ហើយអ្វីៗទាំងអស់ គឺជាអាទិទេព**»។ អាទិទេពមិនមែនស្ថិតនៅក្រៅតថភាពទេ។ អាទិទេព និងពិភពលោកគឺតែមួយ។ ដូច្នេះ អ្វីៗដែលកើតឡើង គឺដោយសារអាទិទេព។ ដូច្នេះ ទស្សនវិជ្ជាមជ្ឈ-ជាតុនិយម ជាទស្សនវិជ្ជាដែលឈរលើមូលដ្ឋាននៃសណ្តាប់ធ្នាប់ធម្មជាតិ និងព្រហ្មលិខិតដែលព្រះបានចារមករួចស្រេចហើយ។

**សេរីភាព** ៖ ប្រសិនបើអ្វីៗសម្រេចដោយអាទិទេព និងព្រហ្មលិខិត នោះសេរីភាពមនុស្សត្រូវតែមាន តែមនុស្សត្រូវតែអាចទាក់ទងជាមួយភ្លើងខាងក្នុងរបស់ខ្លួន និងភ្លើងដែលទ្រទ្រង់ចក្រវាល ហើយត្រូវដាក់ខ្លួននៅក្រោមច្បាប់ចក្រវាល។ សេរីភាព និងការដាក់ខ្លួន(soumission) ត្រូវកើតឡើងព្រមៗគ្នា ក្នុងគោលដៅទទួលបាននូវអ្វីដែលល្អប្រសើរ។ ដូច្នេះ សេរីភាព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មិនមែនជាការជ្រើសរើសស្រេចចិត្តទេ គឺការទទួលស្គាល់ការចាំបាច់ដ៏សុក្រឹត ហើយដាក់ខ្លួនទទួលយកតែម្តង។

**វិចារណញ្ញាណសាកល** ៖ ទ្រឹស្តីមជ្ឈជាតុនិយមក៏បែងផងដែរពី **វិចារណញ្ញាណសាកល** (une Raison universelle) ដែលស្រពិចស្រពិល (immanent) និង **អស្តិរូប** (transcendant) ស្ថិតនៅខ្ពស់។ ដូច្នេះគេចោទសួរថាតើមានអំពើអាក្រក់ឬទេ? អំពើអាក្រក់ និងអំពើល្អ គឺជាកញ្ចក់ឆ្លុះឱ្យគ្នាទៅវិញទៅមក។ ប្រសិនបើគ្មានអំពើអាក្រក់ទេនោះក៏គ្មានអំពើល្អដែរ។ ដូច្នេះ ចាំបាច់ត្រូវមានអំពើអាក្រក់។ ប្រសិនបើគ្មានអំពើអាក្រក់ទេ នោះក៏គ្មានតម្លៃ និងគ្មានគុណភាពដែរ។ ដូច្នេះ អំពើអាក្រក់ជាការចាំបាច់មួយ ដើម្បីមានអំពើល្អ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៣
# ទស្សនវិជ្ជាមជ្ឈិមសម័យ

*ចាប់ពីដើមសតវត្សរ៍ទី១នៃគ្រិស្តសករាជ គ្រិស្តសាសនាចាប់ផ្តើមមានឥទ្ធិពលទៅលើចក្រភពរ៉ូម៉ាំង។ ទីក្រុងអាតែនលែងមានតួនាទីជាមជ្ឈមណ្ឌលនៃការអភិវឌ្ឍទស្សនវិជ្ជា ដូចពេលមុនទៀតហើយ។ សាសនាចាប់ផ្តើមដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គម។*

*នៅក្នុងមជ្ឈិមសម័យដែលមានរយៈពេលចាប់ពី៤០០ឆ្នាំនៃគ.ស.ដល់១៤០០ឆ្នាំនៃគ.ស. ព្រះវិហារកាតូលិកបានបង្ខិតជំនឿទស្សនវិជ្ជាឱ្យខិតចូលជិតសង្គម និងនយោបាយ។ ព្រះវិហារគឺជាស្ថាប័នសង្គមដែលបង្កើតឡើងដោយឈរលើមូលដ្ឋានជំនឿទស្សនវិជ្ជា និងទទួលបានអំណាច និងទ្រព្យសម្បត្តិតាមរយៈជំនឿនេះ។*

*ទស្សនវិជ្ជាកាតូលិកនៅក្នុងមជ្ឈិមសម័យអាចចែកចេញជាពីរដំណាក់កាល ៖ (១) ដំណាក់កាលទីមួយ គឺជាដំណាក់កាលដែលគេជឿលើទស្សនវិជ្ជារបស់* **អូហ្គូស្តាំង** *(Augustin) និង* **ប្លាតុង** *និង (២) ដំណាក់កាលទីពីរ គឺជាដំណាក់កាលដែលគេជឿលើស្នាដៃរបស់* **តូម៉ាស ដាក់កាំង** *(Thomas D'Aquin) និង***អារីស្តូត** *ដែលជាសាវករបស់* **ប្លាតុង**។ *នៅក្នុងដំណាក់កាលទីពីរនេះ ទស្សនវិទូមានគោលដៅចម្បង គឺការពារផលប្រយោជន៍របស់សាសនា។*

# សាំង អូហ្គូស្តាំង
## (៣៥៤-៤៣០ គ.ស.)

**អូហ្គូស្តាំង** *(Augustin) កើតនៅឆ្នាំ ៣៥៤នៃគ្រិស្តសករាជ នៅពេលដែលគ្រិស្តសាសនាបានក្លាយទៅជាសាសនាតែមួយគត់នៃចក្រភពរ៉ូម៉ាំង។* **អូហ្គូស្តាំង** *សិក្សាទស្សនវិជ្ជាតាំងពីតូច ដោយអានស្នាដៃរបស់* **ស៊ីសេរ៉ុង** *(Cicéron) ដែលជាទស្សនវិទូ*មជ្ឈជាតុនិយម *(Stoïcien)*។ នៅពេលអាយុ *៣៣ឆ្នាំ* **អូហ្គូស្តាំង** *បានចាប់ផ្តើមជឿសាសនាគ្រិស្ត ដោយអានស្នាដៃរបស់* **ប្លាតុង**។

**ស្នាដៃសំខាន់** ៖ *ស្នាដៃសំខាន់របស់***អូហ្គូស្តាំង** *គឺ* **បុរីអាទិទេព** *(Cité de Dieu) ដែលមានគោលដៅពន្យល់ពីសាសនាគ្រិស្តតាមរយៈប្រវត្តិ-សាស្ត្រ និង* **ការសារភាព** *(Confessions) ដែលជាស្នាដៃទស្សនវិជ្ជា។*

**ជំនឿនិងវិចារណញ្ញាណ** ៖ *ទស្សនវិជ្ជារបស់***អូហ្គូស្តាំង***ស្ថិតនៅចន្លោះទស្សនវិជ្ជាក្រិកបុរាណ និងសាសនាគ្រិស្ត រវាងទ្រឹស្តី និងជំនឿសាសនា ដោយមិនសូវទាមទារនូវសង្គតិភាពនៃ***វិចារណញ្ញាណ** *(la raison) ដោយសារទស្សនវិជ្ជានេះចាក់ឫសគល់ចូលក្នុងបទពិសោធជំនឿសាសនារបស់គាត់។ ទស្សនវិជ្ជានេះឈរលើមូលដ្ឋាននៃទំនាក់ទំនងរវាងជំនឿ និង* **វិចារណញ្ញាណ**។ **វិចារណញ្ញាណ** មិនមានព្រំដែនឡើយ *ហើយក៏មិនទទួលស្គាល់នូវអានុភាពខាងក្រៅដែរ។ ចំណែកឯជំនឿត្រូវឈរលើមូលដ្ឋាននៃ* **វិវរណៈ** *(Révélation) ពោលគឺដីការបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក។ ដូច្នេះ គឺព្រះជាម្ចាស់ជាអ្នកផ្តល់***វិចារណញ្ញាណ**។

**ខ្ញុំជឿដើម្បីឱ្យខ្ញុំយល់** ៖ *ទស្សនវិជ្ជារបស់***អូហ្គូស្តាំង***គឺ ៖ ជំនឿជាលក្ខខណ្ឌទីមួយ ហើយ***វិចារណញ្ញាណ** *ជាលក្ខខណ្ឌទីពីរ។ ជំនឿគឺជាដីការបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក ដូចពាក្យស្លោកពោលថា ៖* **ខ្ញុំ**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជឿដើម្បីឱ្យខ្ញុំយល់** *(je crois pour comprendre)។ គំនិតសំខាន់របស់គាត់គឺជំនឿនាំមុខការយល់ ហើយជំនឿ គឺជាលក្ខខណ្ឌចាំបាច់នៃការយល់នេះ។ ប្រការនេះមានន័យថា គេមិនអាចទៅដល់ចំណុចសំខាន់តាមរយៈតែហេតុផលត្រឹមត្រូវប៉ុណ្ណោះទេ។*

**ភាពឥតន័យ** ៖ *ភាពឥតន័យ(absurde) ឬ បដិកម្ម(le contradictoire) ដើរតួនាទីសំខាន់។ ខ្ញុំជឿដោយសារតែភាពឥតន័យ (je crois parce que c'est abosurde)។ អ្វីដែលចំណុះឱ្យវិធាននៃតក្កវិទ្យា គឺជាមនុស្សលោក។ តែអ្វីដែលជាព្រះជាម្ចាស់ គឺស្ថិតនៅហួសពីមនុស្សលោក ពោលគឺហួសពីតក្កវិទ្យា។ ដូច្នេះ ដើម្បីយល់ពីព្រះជាម្ចាស់ គេត្រូវរកភាពផ្ទុយគ្នាក្នុងទម្រង់ជាភាពឥតន័យ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# តូម៉ាស ដាក់កាំង
## (១២២៥-១២៧៤)

នៅក្នុងយុគសម័យមជ្ឈិម គឺប្រមាណជា៦០០ឆ្នាំក្រោយ **អូហ្គូស្តាំង** *(Augustin)* សាលាទស្សនវិជ្ជាថ្មីមួយបានលេចចេញជារូបរាងឡើងនៅក្នុងព្រះវិហារគ្រិស្តសាសនា ដែលគេហៅថា *École scolastique*។ ទស្សនវិជ្ជានេះឈរលើមូលដ្ឋានជំនឿដើម្បីស្វែងរកការយល់ដឹង។ **អានសែល** នៃខែនធ័របឺរី *(Anselme de Canterbury)* បានបង្កើននូវទឡ្ហីករណ៍នៃភាវៈ *(argument ontologique)*ក្នុងគោលដៅផ្តល់ភស្តុតាងនៃវត្តមានរបស់អាទិទេព *(l'existence de Dieu)*។ អំណះអំណាងនេះ គឺសាមញ្ញ ៖ អាទិទេពល្អឥតខ្ចោះ។ ភាពល្អឥតខ្ចោះនាំមកនូវអត្ថិភាព។ មូលហេតុសំខាន់ គឺថា ៖ ប្រសិនបើអាទិទេពល្អឥតខ្ចោះ តែបែរជាគ្មានអត្ថិភាពទៅវិញ នោះគេមិនអាចរកភាវៈណាដែលល្អឥតខ្ចោះដូចអាទិទេព ដែលមានអត្ថិភាពបានឡើយ។ ដូច្នេះ ខ្លឹមសារសំខាន់នៃទស្សនាទាន «**អាទិទេព**» គឺប្រមូលផ្តុំនូវអ្វីដែលល្អឥតខ្ចោះទាំងអស់ រួមទាំងអត្ថិភាពផងដែរ។

ទស្សនវិទូម្នាក់ដ៏សំខាន់នៅមជ្ឈិមសម័យ គឺ **តូម៉ាស ដាក់កាំង** *(Thomas D'Aquin)* ដែលកើតនៅប្រទេសអ៊ីតាលី និងធ្លាប់ជាសាស្ត្រាចារ្យនៅប្រទេសបារាំង និងរ៉ូមជាដើម។ លោកជាទស្សនវិទូ និងជាគ្រូធំនៃសាសនាកាតូលិកនៅក្នុងសតវត្សរ៍ទី១៣។ យើងអាចនិយាយបានថា **តូម៉ាស ដាក់កាំង** គឺជាមនុស្សជំនាន់ព្រះបាទ **ជ័យវរ្ម័នទី៧**។

**តូម៉ាស ដាក់កាំង** *(Thomas D'Aquin)* គឺជាទស្សនវិទូដ៏ល្បីម្នាក់ដែលធ្វើសំយោគស្នាដៃរបស់**អារីស្តូត** និងទស្សនវិជ្ជាគ្រិស្តសាសនា។ នៅក្នុងប្រវត្តិទស្សនវិជ្ជា មានទស្សនវិទូចំណានៗបីរូបដែលបានបង្កើតនូវប្រព័ន្ធទស្សនវិជ្ជាដ៏មានឥទ្ធិពលគឺ ៖ **អារីស្តូត** នៅក្នុងយុគសម័យបុរាណ **តូម៉ាស**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ដាក់កាំង** ទៅនៅក្នុងមជ្ឈិមសម័យ និង **ហេហ្គែល** (Hegel) នៅក្នុងសតវត្សរ៍ទី១៩។ នៅទ្វីបអឺរ៉ុប ស្នាដៃរបស់**អារីស្តូត**ត្រូវបាត់ពីមជ្ឈដ្ឋានអ្នកសិក្សាទៅហើយ។ តែនៅមជ្ឈិមសម័យ បណ្ឌិតជាតិជ្វីហ្វ និងអារ៉ាប់បាននាំយកស្នាដៃរបស់**អារីស្តូត**មកកាន់ទ្វីបអឺរ៉ុប អាហ្វ្រិកខាងជើង និងអេស្ប៉ាញ។ ដោយយកទ្រឹស្តីរបស់**អារីស្តូត**ជាមូលដ្ឋាន **តូម៉ាស ដាក់កាំង** បានបកស្រាយបង្ហាញពីអត្ថិភាពរបស់ព្រះអាទិទេព។

ដើម្បីធ្វើសំយោគរវាងទស្សនវិជ្ជា និងសាសនា **តូម៉ាស ដាក់កាំង** បានយកទ្រឹស្តីពុទ្ធិរបស់**អារីស្តូត**មកប្រើ ពោលគឺគេអាចទទួលពុទ្ធិបានតាមរយៈវេទនារម្មណ៍ (choses sensibles) តាមរយៈការធ្វើអរូបីនៃរចនាសម្ព័ន្ធវិចារណញ្ញាណ។ **តូម៉ាស ដាក់កាំង** បានយកទ្រឹស្តីនេះទៅប្រើក្នុងសាសនា ៖ គេអាចស្គាល់ព្រះអាទិទេពបានដោយប្រយោលតែប៉ុណ្ណោះតាមរយៈបច្ច័យរបស់លោក គឺវេទនារម្មណ៍(ការបង្កើតលោក)។ ចំពោះទស្សនវិជ្ជាគឺជាខ្ញុំបម្រើរបស់សាសនា។ គោលដៅសំខាន់នៃទស្សនវិជ្ជា និងសាសនា គឺដើម្បីស្វែងរកពុទ្ធិ និងសច្ចធម៌។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**តូម៉ាស ដាក់កាំង** គឺ «Exposition de la somme théologique»។

**ចំណាត់ថ្នាក់នៃភាវៈ** ៖ **តូម៉ាស ដាក់កាំង** បានខ្ចីពី**អារីស្តូត**នូវទស្សនាទាន «ចំណាត់ថ្នាក់នៃភាវៈ (la conception hiérarchisée des êtres)» (**អារីស្តូត**វិញចែកពិភពតាមលំដាប់ ដើមឈើ សត្វ មនុស្ស ចែកលំដាប់ថ្នាក់មនុស្ស និងលំដាប់ថ្នាក់អាត្ម័នផងដែរ)។ តែនៅជំនាន់**អារីស្តូត** គេមិនចាត់ទុកថាអាទិទេពជាអ្នកបង្កើតលោកឡើយ។ ដូច្នេះហើយ ទើប **តូម៉ាស** រៀបចំចំណាត់ថ្នាក់ (hiérarchie) ដូចតទៅ ៖ (១) នៅខាងក្រោមគេបំផុត គឺជា **ទម្រង់** (formes) ដែលលាយឡំជាមួយនឹងសារធាតុ(matière) (២) នៅពីលើគេបំផុត គឺស្រទាប់នៃទម្រង់បរិសុទ្ធ (formes pures) អរូបី (immatérielles) ដែលរំដោះផុតពីសារធាតុទាំងពួង (៣) ហើយនៅចន្លោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កណ្តាល គឺជា **ទម្រង់រូបី** (formes matérielles) ខ្ពស់បំផុត និងទម្រង់បរិសុទ្ធទាបបំផុត ពោលគឺអាត្ម័នដែលរស់នៅក្នុងខ្លួនមនុស្ស។

**អាត្ម័ន** ៖ អាត្ម័ន ឬព្រលឹងមនុស្ស គឺជាទម្រង់ដែលលាយឡំខ្លាំងជាងគេជាមួយនឹងសារធាតុ ហើយដែលភ្ជាប់ទៅនឹងរាងកាយមនុស្ស( តែចំពោះ**អារីស្តូត**វិញយល់ថា អាត្ម័នគឺជាទម្រង់មួយនៃរាងកាយមនុស្ស)។ ទន្ទឹមនឹងនេះ អាត្ម័នគឺជាទម្រង់បរិសុទ្ធដែលមានកម្រិតទាបបំផុត។ ហើយនៅពីលើព្រលឹងនេះ គឺជាស្រទាប់នៃទម្រង់បរិសុទ្ធ គឺជាពពួកទេវតា(les anges)។ សរុបមក ព្រលឹងមនុស្សដែលមានលក្ខណៈរូបី និងអរូបី ស្ថិតនៅចន្លោះពពួកទេវតាដែលនៅពីលើ និងទម្រង់សារធាតុ ដែលស្ថិតនៅខាងក្រោម។

**អត្ថិភាពនៃអាទិទេព** ៖ ដើម្បីបង្ហាញពីអត្ថិភាពនៃអាទិទេព **តូម៉ាស** យល់ឃើញថា ចលនាទាំងអស់បង្កើតឡើងដោយការៈដែលមានចលនា ដែលជាម៉ូទ័របង្កើតឱ្យមានចលនា។ ហើយម៉ូទ័រនេះបង្កើតឡើងដោយច្រវាក់នៃម៉ូទ័រផ្សេងៗទៀត រហូតដល់ចុងក្រោយបំផុត គឺជាម៉ូទ័រទីមួយដែលនៅដើមគេ។ ហើយ **ម៉ូទ័រទីមួយ ដែលគ្មានចលនានេះ គឺជាអាទិទេព**។

**ហេតុផលដើម** ៖ ទស្សនាទាន **ម៉ូទ័រទីមួយ** (premier moteur) ស្រដៀងគ្នានឹងទស្សនាទាន **ហេតុផលដើមទីមួយ** (la cause première) ដែរ។ ហេតុផលមួយវាបណ្តាលមកពីហេតុផលមួយទៀត។ ដូច្នេះ នៅពេលដែលគេស្វែងរកហេតុផល ដែលស្ថិតនៅច្រវាក់ដើមខ្សែ គឺជាហេតុផលដើម ដែលមិនអាស្រ័យលើហេតុផលណាផ្សេងទៀត ដែលភាសាទស្សនវិជ្ជាហៅថា «**ហេតុផលដើម**» ឬ «**ហេតុផលខ្លួនឯង** (cause en soi)» ដែលភាសាឡាតាំងហៅថា causa sui ពោលគឺជា **អាទិទេព**។

**ទំនាក់ទំនងរវាងអាត្ម័ននិងរាងកាយ** ៖ **តូម៉ាស ដាក់កាំង** បានបង្កើតទស្សនាទានមួយទៀត គឺទំនាក់ទំនងរវាងអាត្ម័ន និងរាងកាយមនុស្ស។ **ប្លាតុង**យល់ឃើញថា រាងកាយមនុស្ស គឺជាគុកសម្រាប់ដាក់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*អាត្ម័ន។* **អារីស្តូត***យល់ថា អាត្ម័ន គឺជាទម្រង់មួយនៃរាងកាយមនុស្ស។ ចំណែកឯ* **តូម៉ាស***វិញយល់ថារាងកាយមនុស្ស និងអាត្ម័នបង្កើតបានជាវត្ថុតែមួយ ដោយសារតែទំនាក់ទំនងរវាងទម្រង់ និងសារធាតុ។*

**ទំនាក់ទំនងរវាងទស្សនវិជ្ជា និងសាសនា ៖** *ទ្រឹស្តីរបស់* **តូម៉ាស ដាក់កាំង** *គឺជាលទ្ធផលនៃការធ្វើសំយោគរវាងទស្សនវិជ្ជារបស់***អារីស្តូត** *និងជំនឿគ្រិស្តសាសនា។ ដោយសារតែពិភពលោកយើងត្រូវបានបង្កើតឡើងដោយអាទិទេព យើងមានកាតព្វកិច្ចគោរព និងសិក្សាពិភពលោកនេះឱ្យបានច្បាស់។ ទ្រឹស្តីនេះធ្វើឱ្យទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋកាន់តែខិតចូលជិតគ្នាថែមទៀត។*

*ក្នុងន័យនេះ ទស្សនវិជ្ជា(philosophie) និងសាសនាវិទ្យា(théologie) ប្រុបាច់ចូលគ្នាជាធ្លុងមួយ។ ក៏ប៉ុន្តែ គេឃើញផងដែរថា ទស្សនវិជ្ជា និងសាសនាវិទ្យា មានចំណុចរួមផង និងមានចំណុចខុសគ្នាផង។ ទស្សនាទានសាសនាវិទ្យាឈរលើមូលដ្ឋានដើមពីពុទ្ធិដែលមានពីដើមមក ក្នុងរូបភាពជាគម្ពីរធម៌ សៀវភៅធម៌ វិវរណៈ (Révélation) ស្ថាប័ន និងព្រះវិហារជាដើម។ ដូច្នេះ សាសនាត្រូវផ្អែកលើពុទ្ធិដើមដំបូង។ ផ្ទុយទៅវិញ ទស្សនវិជ្ជាត្រូវឈរលើមូលដ្ឋាននៃការចោទជាសំណួរមិនចេះចប់មិនចេះហើយ។ ដូច្នេះ មាគ៌ានៃទស្សនវិជ្ជាគឺរកទីបញ្ចប់គ្មានឡើយ។*

*យុគមជ្ឈិមសម័យដែលគ្របដណ្តប់ដោយវិហារកាតូលិកបានចាប់ផ្តើមធ្លាក់ចុះបន្តិចម្តង ចាប់ពីសតវត្សរ៍ទី១៣។ ការធ្លាក់ចុះនេះបណ្តាលមកពីមូលហេតុសំខាន់ៗមួយចំនួនៈ*

*ទីមួយ-ការកកើតឡើងនៃវណ្ណៈពាណិជ្ជករ ជាដើមដំបូងនៅអ៊ីតាលី ហើយបន្ទាប់មកនៅក្នុងប្រទេសឯទៀត។ នៅពេលមុន ពួកអភិជនសក្តិភូមិច្រើនមិនមែនជាអ្នកចេះដឹង ល្ងង់ខ្លៅ និងសាហាវឃោរឃៅ។ ដូច្នេះ ប្រជារាស្រ្តសាមញ្ញគោរពព្រះវិហារកាតូលិកដែលមានប្រាជ្ញា និងសីលធម៌ខ្ពស់ជាងពួកអភិជន។ វណ្ណៈពាណិជ្ជករថ្មីមានប្រាជ្ញាខ្ពស់ដូចលោកសង្ឃកាតូ-*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លិកដែរ។ មិនតែប៉ុណ្ណោះពួកគេមានការយល់ដឹងខ្ពស់ពីការងារប្រទេសជាតិ ហើយប្រជាជនចាត់ទុកពួកនេះថា ជាអ្នកទាមទារនូវសេរីភាពជូនដល់ប្រជាជន។ ម្យ៉ាងវិញទៀត និន្នាការប្រជាធិបតេយ្យកាន់តែរីកដុះដាលឡើងៗ ដើម្បីទាមទាររំដោះសេដ្ឋកិច្ចឱ្យចេញផុតពីពួកសក្តិភូមិ។

ទីពីរ-ការរីកធំធាត់នៃអំណាចរបស់រាជានិយមនៅប្រទេសបារាំង អង់គ្លេស និងអេស្ប៉ាញ។ បន្ទាប់ពីបានប្រយុទ្ធប្រឆាំងនឹងភាពអាណាធិបតេយ្យផ្ទៃក្នុង និងបានចងសម្ព័ន្ធមិត្រជាមួយពួកឈ្មួញអ្នកមាន ចាប់ពីពាក់កណ្តាលនៃសតវត្សរ៍ទី១៥មក ស្តេចមានអានុភាពយ៉ាងខ្លាំងក្លាក្នុងការប្រយុទ្ធជាមួយសម្តេចប៉ាប ដើម្បីរក្សាផលប្រយោជន៍ប្រទេសជាតិ។

ទីបី-សម្តេចប៉ាបបានបាត់បង់នូវកិត្យានុភាពខាងផ្នែកសីលធម៌ដែលគេធ្លាប់មានក្នុងអំឡុងសតវត្សរ៍ទី១១ដល់ទី១៣។ ក្នុងសតវត្សរ៍ទី១៥ តួនាទីរបស់សម្តេចប៉ាបជាមេព្រះវិហារកាតូលិកស្ថិតនៅចំណុះឱ្យស្តេចអ៊ីតាលី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជាបុនវុឌ្ឍិសម័យ

យុគសម័យ «**បុនវុឌ្ឍិសម័យ**» គឺជាសម័យកាលដែលអំណាចនៃព្រះវិហារកាតូលិកធ្លាក់ចុះ និងអំណាចនៃវិទ្យាសាស្ត្រកើនឡើងៗ ពួកអភិជនសក្តិភូមិចាប់ផ្តើមបាត់បង់នូវអំណាចនយោបាយ និងអំណាចសេដ្ឋកិច្ច នៅក្នុងខណៈដែលវណ្ណៈឈ្មួញអ្នកមានបានក្លាយខ្លួនបន្តិចម្តងៗទៅជាវណ្ណៈអភិជនបែបថ្មី។ រដ្ឋបានដើរតួនាទីជំនួសឱ្យព្រះវិហារ ហើយស្តេចបានប្រមូលអំណាចរដ្ឋជាប់នៅក្នុងដៃ។ តួនាទីរបស់ស្ថាប័នរដ្ឋត្រូវបានពង្រីក និងពង្រឹងជាលំដាប់។

យុគសម័យ «**បុនវុឌ្ឍិសម័យ**» ដែលជាសម័យដែលវប្បធម៌ និងអារ្យធម៌ក្រិក **រស់ឡើងវិញ** (Renaissance)» គឺជាយុគសម័យចន្លោះសតវត្សរ៍ទី១៥ និង១៦ ដែលបង្កើតនូវមូលដ្ឋានគ្រឹះនៃយុគសម័យទំនើប។ យុគសម័យនេះពោរពេញដោយគំនិតថ្មីៗ ពាក្យថា «**រស់ឡើងវិញ**» មានន័យថា ត្រឡប់ទៅរកប្រភពដើមវិញ ការត្រឡប់ទៅរកការសិក្សាស្នាដៃក្រិកបុរាណ ឬការរស់ឡើងវិញនៃស្នាដៃពីបុរាណ។ យុគសម័យ «**បុនវុឌ្ឍិសម័យ**» គឺជាយុគសម័យស្មុគ្រស្មាញ ពោរពេញដោយនិន្នាការផ្ទុយគ្នាសម្បូណ៌ដោយអ្នកប្រាជ្ញដែលស្រេកឃ្លានចំណេះដឹង អ្នកវិទ្យាសាស្ត្រដែលងប់ងល់នឹងការស្រាវជ្រាវ អ្នកស្វែងរកទឹកដីថ្មីនៅទ្វីបអាមេរិក អ្នកប្រាជ្ញដែលរកឃើញនូវវិទ្យាសាស្ត្រទំនើបៗ សិល្បករ ជាងគំនូរ ជាងឆ្លាក់រូប និងតន្ត្រីករដ៏មានទេពកោសល្យ ។ល។

ខាងផ្នែកទស្សនវិជ្ជា គេចាប់ផ្តើមសិក្សាស្នាដៃរបស់**ប្លាតុង**ឡើងវិញ។ ទស្សនវិទូសម័យ មានដូចជា **ម៉ាគីយ៉ាវែល** (Machiavelli) (១៤៦៩-១៥២៧) **អេរ៉ាសមុស** (Erasmus) (១៤៦៦-១៥៣៦) **ថូម៉ាស ម័រ** (Thomas More) (១៤៧៨-១៥៣៥) ជាដើម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យុគសម័យ «**បុនវុឌ្ឍិសម័យ**» ដែលជាសម័យនៃវិទ្យាសាស្ត្រ។ នៅយុគសម័យនោះមានអ្នកប្រាជ្ញធំៗចំនួនបួននាក់គឺ ៖

**កូប៉េនិក** (Nicolas Copernic) (១៤៧៣-១៥៤៣)៖ យុគសម័យ «**បុនវុឌ្ឍិសម័យ**» គឺជាយុគសម័យរកឃើញថ្មីក្នុងវិស័យតារាសាស្ត្រ។ មុននេះ គេតែងនិយាយពីប្រព័ន្ធផែនដី ពោលគឺភពទាំងអស់វិលជុំវិញផែនដី។ ក៏ប៉ុន្តែ **កូប៉េនិក** (Nicolas Copernic) បានបង្ហាញឱ្យឃើញថា ពិភពលោកយើង ជាពិភពលោកដែលផែនដី និងភពផ្សេងទៀតវិលជុំវិញព្រះអាទិត្យ។ ប្រការនេះមានន័យថា មនុស្សមិនមែនស្ថិតនៅចំកណ្ដាលនៃប្រព័ន្ធចក្រវាលទេ ហើយក៏មិនមែនអាទិទេពបានបង្កើតលោកនេះមក ដើម្បីសម្រាប់តែមនុស្សលោកផងទាំងពួងដែរ។ ម្យ៉ាងវិញទៀតយុគសម័យនេះ គឺជាយុគសម័យដែលទស្សនវិជ្ជាបរមត្ថវិជ្ជា និងសាសនារីកចម្រើនយ៉ាងលឿនគ្មានអ្វីផ្ទឹម។

**កេប្លែរ** (Kepler) (១៥៧១-១៦៣០) ៖ **កេប្លែរ** គឺជាគណិតវិទូ និងតារាវិទូជនជាតិអាឡឺម៉ង់ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងបដិវត្តន៍វិទ្យាសាស្ត្រក្នុងសតវត្សរ៍ទី១៧។ លោកបានបង្កើតច្បាប់ស្ដីពីចលនាផែនដី។ ស្នាដៃនិពន្ធរបស់លោកបានក្លាយទៅជាមូលដ្ឋានសម្រាប់ការបង្កើតទ្រឹស្ដីរបស់ញូតុន ស្ដីពីទំនាញផែនដី។ លោកក៏ធ្វើការក្នុងផ្នែកអុបទិច ដោយបានបង្កើតតេឡេស្កុបបែបថ្មីម្យ៉ាង សម្រាប់ការស្រាវជ្រាវខាងផ្នែកតារាសាស្ត្រ។

**ហ្គាលីឡេ** (Galilée) (១៥៦៤-១៦៤២)៖ **ហ្គាលីឡេ** គឺជាអ្នកប្រាជ្ញជនជាតិអ៊ីតាលី ដែលដើរតួនាទីក្នុងការកែប្រែទស្សនវិជ្ជាធម្មជាតិឱ្យក្លាយទៅជាវិទ្យាសាស្ត្រទំនើប និងប្រែក្លាយបុនវុឌ្ឍិវិទ្យាសាស្ត្រ ឱ្យទៅជាបដិវត្តន៍វិទ្យាសាស្ត្រ។ លោកគឺជាអ្នកមានទស្សនៈប្រកាន់យកប្រព័ន្ធព្រះអាទិត្យ ដែលមានព្រះអាទិត្យនៅចំកណ្ដាល ក្នុងខណៈដែលពិភពលោកទាំងមូលជឿថា ផែនដីគឺស្ថិតនៅចំកណ្ដាល។ ដោយមានការជំទាស់ពីសំណាក់តារាវិទូឯទៀត គេបានធ្វើការសើបអង្កេតនៅក្នុងឆ្នាំ ១៦១៥ ដែលចាត់ទុកថាម-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តិប្រព័ន្ធព្រះអាទិត្យ គឺជាទស្សនៈធ្លុតនិងឥតន័យ។ **ហ្គាលីឡេ** សិក្សាពីល្បឿន ទំនាញផែនដី ទម្ងាក់សេរី គោលការណ៍ប្រៀបធៀប (principle of relativity) ការនៅនឹងមួយកន្លែងជាដើម។

**ញ៉ូតុន** (Newton) (១៦៤២-១៧២៧)៖ **ញ៉ូតុន** គឺជាគណិតវិទូ តារាវិទូ សាសនាវិទូ និងរូបវិទូជនជាតិអង់គ្លេស ហើយដែលគេចាត់ទុកថាជាអ្នកវិទ្យាសាស្ត្រដ៏មានឥទ្ធិពលម្នាក់ នៅគ្រប់ពេលនិងគ្រប់វេលា និងដែលជាមនុស្សកំពូលខាងផ្នែកបដិវត្តន៍វិទ្យាសាស្ត្រ។ សៀវភៅរបស់លោកដែលមានចំណងជើងថា «**គោលការណ៍គណិតវិទ្យានៃទស្សនវិទូធម្មជាតិ**» ត្រូវបានបោះពុម្ពផ្សាយលើកទី១ នៅក្នុងឆ្នាំ១៦៨៧។ ទ្រឹស្តីរបស់**ញូតុន** ត្រូវបានប្រើប្រាស់ ដើម្បីរៀបចំច្បាប់ស្តីពីចលនា និងទំនាញផែនដីសកល។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី៤
# ទស្សនវិជ្ជាសម័យថ្មី

*សម័យថ្មី គឺជាសម័យដែលរំដោះខ្លួនឱ្យចាកផុតពីយុគមជ្ឈិមសម័យ និងជាសម័យមួយដែលទស្សនវិជ្ជាមានឯករាជ្យក្នុងការគិត។ លក្ខខណ្ឌចាំបាច់នៃការទទួលបាននូវសេរីភាពថ្មីនេះ គឺការធ្លាក់ចុះនៃសាសនាកាតូលិកនៅទ្វីបអឺរ៉ុបនៅក្នុងសតវត្សរ៍ទី១៦ ដែលបង្កើតឱ្យមានទីកន្លែងអព្យាក្រឹតសម្រាប់ទស្សនវិទូធំៗស្វែងរកវិចារណញ្ញាណ។ នៅក្នុងយុគសម័យ* «**បុនរុត្ថិសម័យ**» *ក៏មានចលនាស្វែងរកវិចារណញ្ញាណនេះដែរ តែនៅក្នុងសម័យនោះ ទស្សនវិទូគិតតែសិក្សាពីគំនិតនៃក្រិកបុរាណ។ ទស្សនវិជ្ជាក្នុងយុគសម័យថ្មីផ្ដោតលើការសិក្សាស្ដីពីវិធីសាស្រ្តក្នុងការស្វែងរកការពិត។ នៅពេលនោះមានសាលាទស្សនវិជ្ជាចំនួនពីរបានកើតឡើង ៖*

*(១) សាលាទស្សនវិជ្ជាទីមួយយល់ឃើញថា ការគិតអាចរកឃើញគំនិតថ្មី ដោយមិនចាំបាច់មានការចូលរួមពីបទពិសោធឡើយ។ ទស្សនៈនេះបង្កើតបានជាចរន្តទស្សនវិជ្ជាវិចារណញ្ញាណនិយម ដែលមាន* **ដេកាត** *ជាមេដឹកនាំ។*

*(២) សាលាទស្សនវិជ្ជាទីពីរយល់ឃើញថា ប្រសិនបើមានតែការគិតហើយគ្មានការចូលរួមពីឥន្ទ្រីយារម្មណ៍ គេមិនអាចរកឃើញការពិតឡើយ។ ទស្សនៈនេះបង្កើតបានជាចរន្តទស្សនវិជ្ជាពិសោធនិយម។*

*ចំណុចរួមនៃសាលាទស្សនវិជ្ជាទាំងពីរនេះ គឺធ្វើយ៉ាងណាឱ្យមនុស្ស*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ថិតនៅជាស្នូល និងជាគោលដៅចុងក្រោយនៃការសិក្សាស្រាវជ្រាវ។ ដូច្នេះ ទស្សនវិជ្ជានៅអឺរ៉ុបនាយុគសម័យថ្មី គឺជាទស្សនវិជ្ជាផ្ដោតលើប្រធានបទ។ ការគោរពមនុស្សបានក្លាយទៅជាសមិទ្ធផលរួមនៃទស្សនវិជ្ជាសម័យថ្មី។ ប្រព័ន្ធទស្សនវិជ្ជារបស់**កង់ត៍** បានរុញទស្សនវិជ្ជាសម័យថ្មីឱ្យឈានដល់ចំណុចកំពូល ហើយប្រព័ន្ធទស្សនវិជ្ជានេះប្រកាសថា មនុស្សមាន «តម្លៃយ៉ាងដាច់ខាត»។ ទស្សនវិទូក្រោយ**កង់ត៍** គឺ **ហ្វិកត៍** និង **សែ្សលលីង** បានចាត់ទុកឫសគល់នៃសម្បជញ្ញៈរបស់មនុស្សថាមានតម្លៃដាច់ខាត។ **ហេហ្គែល** បានរុញនិន្នាការនេះឱ្យទៅមុខយ៉ាងលឿន តែលោកបានភ្ជាប់ទស្សនវិជ្ជាទៅនឹងសាសនា។ សាវករបស់ **ហេហ្គែល** ក៏ចាប់ផ្ដើមងាកទៅរកទស្សនវិជ្ជាសាសនា និងចាប់អារម្មណ៍ទៅលើទស្សនវិជ្ជាបុរាណ និងទស្សនវិជ្ជាសម័យមជ្ឈិម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្វ្រង់ស៊ីស បេកិន
## (១៥៦១-១៦២៦)

**ហ្វ្រង់ស៊ីស បេកិន** (Francis Bacon) កើតនៅក្នុងឆ្នាំ ១៥៦១ នៅទីក្រុងឡុងដ៍ ក្នុងគ្រួសារសមាជិកសភាជាន់ខ្ពស់ (Lord) ដែលឪពុកលោកជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ លោករៀននៅសាកលវិទ្យាល័យខេមប្រ៊ីជចំនួនបីឆ្នាំ ប៉ុន្តែបន្ទាប់មកសុខចិត្តចាកចោលសាកលវិទ្យាល័យដោយឥតមានសញ្ញាបត្រ ដើម្បីចូលធ្វើការក្នុងបេសកកម្មការទូតដែលផ្តល់ឱកាសឱ្យគាត់អាចធ្វើដំណើរពាសពេញអឺរ៉ុបបាន។ ក៏ប៉ុន្តែ បន្ទាប់ពីឪពុករបស់លោកលាចាកលោកនេះទៅ **ហ្វ្រង់ស៊ីស បេកិន** ត្រូវត្រឡប់មកអង់គ្លេសវិញ ហើយធ្វើការក្នុងវិស័យយុត្តិធម៌។ ទន្ទឹមនឹងនេះ លោកក៏ចាប់អារម្មណ៍លើការពិសោធ ការតែងនិពន្ធអក្សរសិល្ប៍ និងវិទ្យាសាស្ត្រ។ នៅពេលស្តេចថ្មី James I ឡើងសោយរាជ្យនៅក្នុងឆ្នាំ ១៦០៣ លោកត្រូវបានតែងតាំងជាសមាជិកសភាជាន់ខ្ពស់(Lord) និងជាអគ្គព្រះរាជអាជ្ញាដូចឪពុកលោកដែរ ហើយបន្ទាប់មកជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ស្នាដៃសំខាន់៖** ស្នាដៃសំខាន់របស់**បេកិន** គឺ **ការស្តារវិទ្យាសាស្ត្រឡើងវិញ** (Instauratio Magna-The Great Instauration)។ នៅក្នុងស្នាដៃនេះ **បេកិន** បានស្នើសុំធ្វើកំណែទម្រង់ដំណើរការបង្កើតពុទ្ធិ ក្នុងគោលដៅលើកកម្ពស់ការសិក្សាស្រាវជ្រាវ ដោយបង្កើតឱ្យមានវិធីសាស្ត្រថ្មីក្នុងការសិក្សាវិទ្យាសាស្ត្រ។ នៅក្នុងស្នាដៃ Novum Organum លោកបានបង្កើតអភិក្រមថ្មីក្នុងការរិះរកពុទ្ធិវិទ្យាសាស្ត្រ ដោយបង្កើតវិធីសាស្ត្រសិក្សាវិទ្យាសាស្ត្រតាមរយៈការសង្កេត និងការប្រើ**ឯកាសព្ទវិធី** (induction)។

**វិធីសាស្ត្រពិសោធនិយម** (Empiricism)៖ **ហ្វ្រង់ស៊ីស បេកិន** គឺជាបិតានៃពិសោធនិយម ដោយលោកបានកំណត់នូវភារកិច្ចថា នឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រែក្លាយដំណើរការស្រាវជ្រាវវិទ្យាសាស្ត្រ(ការទទួលពុទ្ធិ)ឱ្យទៅជាការងារជាក់ស្ដែង ដោយប្រើសមត្ថភាពរបស់មនុស្ស ៖ តាមរយៈ ការគិត ការស្រមើស្រមៃ និងអារម្មណ៍។ ដើម្បីសម្រេចបានគោលដៅនេះ លោកត្រូវបង្កើតទំនាក់ទំនងឱ្យបានត្រឹមត្រូវ រវាងសមត្ថភាពរបស់មនុស្ស និងផ្ដល់ឱ្យមនុស្សនូវវិធីសាស្ត្រអនុវត្ត។ មានតែមនុស្សទេដែលអាចប្រែក្លាយគំនិត និងសមត្ថភាពក្នុងការទទួលពុទ្ធិរបស់ខ្លួន ឱ្យក្លាយជាអាវុធជាក់ស្ដែង សម្រាប់គោលដៅដ៏ពិសិដ្ឋគឺការស្គាល់ពីធម្មជាតិ។ ទស្សនវិទូបុរាណក្រិកបានប្រើវិធីសាស្ត្រ វិចារណញ្ញាណ និងឯកសព្វវិធី ដើម្បីស្វែងយល់ពីពិភពលោក។ ដើម្បីសិក្សាពីធម្មជាតិ **ហ្វ្រង់ស៊ីស បេកិន** ប្រើវិធីសាស្ត្រធ្វើពិសោធន៍ (expérimentation) និងឯកសព្វវិធី (induction)។ ដូច្នេះ ការពិសោធគឺជាមូលដ្ឋាននៃវិទ្យាសាស្ត្រ។ បន្ទាប់ពីបានរកឃើញអ្វីថ្មី គេបង្កើតឡើងនូវវិធានច្បាប់ថ្មីដែលគ្របគ្រងទំនាក់ទំនងដែលមានស្រាប់។ ការពិសោធមានគោលដៅកែកំហុសរបស់ឥន្ទ្រីយារម្មណ៍ តែគេត្រូវធ្វើវិសុទ្ធកម្មជាមុនសិន។ ការធ្វើវិសុទ្ធកម្មនេះអនុញ្ញាតឱ្យគេបង្កើតពុទ្ធិថ្មី។

**ចំណាត់ថ្នាក់វិទ្យាសាស្ត្រ** ៖ នៅក្នុងស្នាដៃរបស់លោក The Great Instauration **បេកិន** បង្កើតប្រព័ន្ធចំណាត់ថ្នាក់វិទ្យាសាស្ត្រដោយឈរលើមូលដ្ឋាននៃសមត្ថភាពក្នុងការរៀន ៖ (១) ប្រវត្តិសាស្ត្រ(ធម្មជាតិ និងប្រទេស) សម្រាប់ការទន្ទេញចងចាំ (២) កំណាព្យ សម្រាប់ការស្រមើស្រមៃ និង(៣) ទស្សនវិជ្ជា(សាសនា ធម្មជាតិ និងមនុស្សជាតិ) សម្រាប់វិចារណញ្ញាណ។

**បេកិន** ចង់បង្កើតវិទ្យាសាស្ត្រឡើងវិញដោយចាប់ផ្ដើមពីការប្រមូលទិន្នន័យ និងសមាសធាតុ បន្ទាប់មកធ្វើការសង្កេត ដោយប្រើប្រាស់នូវវិធីសាស្ត្រធ្វើពិសោធពីគ្រប់ទិដ្ឋភាពទាំងអស់ និងដោយប្រើគ្រប់អញ្ញត្តិទាំងអស់។ បន្ទាប់មក ត្រូវស្រង់យកលទ្ធផលទៅធ្វើចំណាត់ថ្នាក់ក្នុងតារាង (តារាងវត្តមាន តារាងអវត្តមាន និងតារាងដឺក្រេ)។ នៅក្នុងដំណាក់កាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចុងក្រោយនៃការធ្វើពិសោធនេះ គេត្រូវធ្វើសេចក្តីសន្និដ្ឋានដែលអាចឱ្យគេបង្កើតជាទ្រឹស្តីទូទៅ។

**ការធ្វើអង្កេត** ៖ ដើម្បីបំបាត់ចោលនូវគំនិតខុស **បេកិន** ផ្តល់អនុសាសន៍ឱ្យធ្វើអង្កេតស្តីពី វិធីសាស្ត្រក្នុងការផ្ទេរពុទ្ធិ។ ក៏ប៉ុន្តែ របកគំហើញនូវពុទ្ធិថ្មីៗទាមទារឱ្យមានការស្រាវជ្រាវ ការពិនិត្យ បញ្ជាក់ឡើងវិញ ការវាស់នូវពុទ្ធិថ្មីដែលទទួលបានពីការពិសោធ។ បន្ទាប់ពីប្រមូលទិន្នន័យដែលបានមកពីការសង្កេត ត្រូវរៀបចំទិន្នន័យតាមលំដាប់លំដោយ និងសម្របសម្រួលទិន្នន័យទាំងនេះ។ **បេកិន** ប្រឹងប្រែងឈ្វេងយល់ពីទិន្នន័យពិសោធន៍ដែលមិនស្ថិតនៅក្នុងការត្រិះរិះពិចារណាតាមបែបបរមត្ថវិទ្យា។ វិធីសាស្ត្រនេះមានឥទ្ធិពលទៅលើទស្សនវិទូពិសោធនិយម ដូចជា **ដេវីដ ហ្យូម** (David Hume) ជាដើម។

**បរមត្ថវិជ្ជាជាការសិក្សាស្តីពីធម្មជាតិ** ៖ **បេកិន** យល់ថា ចាំបាច់ត្រូវបញ្ជាក់ពីទំនាក់ទំនងរវាងបរមត្ថវិទ្យា និងទស្សនវិជ្ជាទីមួយ។ ទស្សនវិជ្ជាទីមួយសិក្សាពីភាវៈ លក្ខណៈវិនិច្ឆ័យសំខាន់ៗ គោលការណ៍តក្កវិទ្យា និងគណិតវិទ្យា ដោយធ្វើការទិតៀនការឱ្យនិយមន័យមិនច្បាស់លាស់ស្តីពី ភាវៈ សារធាតុ បរិមាណ សកម្មភាព តែរក្សាឱ្យបាននូវមូលដ្ឋានពុទ្ធិវិទ្យាសាស្ត្ររួមគ្នា។ បរមត្ថវិទ្យាខុសពីទស្សនវិជ្ជាដែលជា «មាតានៃវិទ្យាសាស្ត្រទាំងអស់»។ បរមត្ថវិទ្យា គឺជាការសិក្សាស្តីពីប្រភេទនៃធម្មជាតិ។ ដូច្នេះ បរមត្ថវិទ្យាមិនមែនស្ថិតនៅក្រៅធម្មជាតិឡើយ។ ផ្ទុយទៅវិញ បរមត្ថវិទ្យាគឺជាផ្នែកមួយយ៉ាងសំខាន់នៃធម្មជាតិតែម្តង។

**តក្កវិជ្ជា និងឯកសព្វវិធីបែបថ្មី** ៖ វិធីក្នុងការត្រិះរិះពិចារណាត្រូវចាប់ផ្តើមពីទិន្នន័យ និងហេតុការណ៍ធម្មជាតិដែលច្បាស់លាស់។ ដូច្នេះ ពុទ្ធិត្រូវចាប់ផ្តើមពីប្រវត្តិសាស្ត្រវិទ្យាសាស្ត្រ និងពិសោធន៍ ការប្រមូលបទពិសោធ និងការសង្កេត ដោយរៀបជាលំដាប់ក្នុងតារាងពិសេស បន្ទាប់មកទើបប្រើ **ឯកសព្វវិធី** (induction) ពិតប្រាកដ។ **បេកិន** បដិសេធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សព្វឯកាវិធី** (deduction) ដែលជាវិធីសាស្ត្រនៃតក្កវិទ្យារបស់ **អារីស្តូត** ហើយប្រើ**ឯកាសព្វវិធី**តាមបែបវិទ្យាសាស្ត្រវិញ។ ចលនាពីហេតុការណ៍មួយៗ ទៅរកការសន្និដ្ឋានរួមត្រូវធ្វើឡើងជាដំណាក់កាល តាមរយៈការតម្លើងពីពិសោធន៍ ទៅបង្កើតជាទ្រឹស្តីទូទៅ និងត្រឡប់មកវិញ ពីទ្រឹស្តីទូទៅ ដើម្បីរកហេតុការណ៍មួយៗ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជាវិចារណញ្ញាណនិយម

**វិចារណញ្ញាណនិយម** (Rationalisme) គឺចរន្តនៃទស្សនវិជ្ជានៅក្នុងសតវត្សរ៍ទី ១៧ និង១៨ ជាពិសេស គឺ **ដេកាត** (Descartes) **ឡៃបនិត** (Leibniz) និង **ស្ពីណូហ្សា** (Spinoza)។ ទស្សនវិជ្ជាសិក្សាពីទំនាក់ទំនងរវាងពុទ្ធិ និងជំនឿ។ ពុទ្ធិគឺជាជំនឿពិសេសមួយ ពោលគឺជាជំនឿដែលមានភាពជាក់លាក់។ ទ្រឹស្តីនៃពុទ្ធិ (Épistémologie, theory of knowledge) គឺជាប្រធានបទដ៏សំខាន់នៃទស្សនវិជ្ជា។ **កង់ត៍**បានចោទសួរថា តើយើងអាចសិក្សាពីវិទ្យាសាស្ត្របានឬទេ? របៀបណា? **ដេកាត** និង**ឡុក្ក** យល់ឃើញថា មនុស្សខុសពីសត្វនៅត្រង់ថា មនុស្សគឺជាសត្វលោកដែលចេះគិត។

តើពុទ្ធិកើតឡើងរបៀបណា? ចរន្តវិចារណញ្ញាណនិយមយល់ថា ដើម្បីឈានទៅដល់ពុទ្ធិ គេត្រូវពឹងផ្អែកលើតក្កវិជ្ជា និងប្រាជ្ញា(intellect)។ ការត្រិះរិះពិចារណានេះចាប់ផ្តើមពីតថភាពជាមូលដ្ឋានដែលមិនពឹងផ្អែកលើពិសោធន៍។ តថភាពនេះមានមុនពិសោធន៍ទៅទៀត(a priori)។

ដូច្នេះ បន្ទាប់ទៅនេះយើងនឹងពិភាក្សាពីទស្សនវិទូនៃសតវត្សរ៍ទី១៧ និង១៨ គឺ ៖ **ដេកាត**, **ឡៃបនិត** និង **ស្ពីណូហ្សា** ដែលតំណាងឱ្យចរន្តវិចារណញ្ញាណនិយម(Rationalistes)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# រ៉ឺណេ ដេកាត
## (១៥៩៦-១៦៥០)

**ដេកាត** *(Descartes) សិក្សានៅសាលាយេស៊ូនៅ La Flèche ដែលជាកន្លែងមួយដែលបង្រៀនឱ្យសិស្សចេះត្រិះរិះពិចារណា និងមានសមត្ថភាពវិភាគដោយឯករាជ្យ។*

**ស្នាដៃសំខាន់** ៖ *ស្នាដៃសំខាន់របស់* **ដេកាត** *គឺ* **អភិប្រាយស្តីពីវិធីសាស្ត្រ** *(Discours de la méthode), Traité des passions*។

*នៅក្នុងឆ្នាំ១៦៣៧* **ដេកាត** *បានបោះផ្សាយស្នាដៃទស្សនវិជ្ជាដ៏ល្បីល្បាញបំផុតក្នុងប្រវត្តិទស្សនវិជ្ជាពិភពលោក គឺ «***អភិប្រាយស្តីពីវិធីសាស្ត្រ** *(Discours de la méthode)»។* **ដេកាត** *ប្រើប្រាស់វិធីសាស្ត្រគណិតវិទ្យា ដើម្បីជាមូលដ្ឋាននៃគំនិត ដូចទស្សនវិទូផ្សេងទៀតតាំងពីជំនាន់* **ពីតាហ្គ័រ** *មកម្ល៉េះ។*

**ខ្ញុំគិត ដូច្នេះខ្ញុំមានអត្ថិភាព** ៖ *ទស្សនវិជ្ជារបស់***ដេកាត***ផ្តោតលើការស្វែងរកភាពច្បាស់លាស់(la certitude)។ លោកបានយកគំនិតរបស់* **ប្លាតុង** *មកប្រើ ពោលគឺ ៖* **មតិ** *គឺជាការប្រហាក់ប្រហែល ចំណែកឯ* **ពុទ្ធិ** *វិញ គឺជាការច្បាស់លាស់ពេញលេញ គ្មានការស្រពេចស្រពិល។ ដូច្នេះហើយទើប***ដេកាត***បានចាប់ស្វែងរកភាពច្បាស់លាស់ ៖ តើធ្វើយ៉ាងណាទើបយើងអាចដឹងច្បាស់ថា វត្ថុអ្វីមួយពិត? តើយើងធ្វើដូចម្តេច ដើម្បីរកភាពច្បាស់លាស់ ដូចគណិតវិទ្យា? ក្នុងន័យនេះ* **ដេកាត***ចាប់ផ្តើមសួរខ្លួនឯង និងចោទសួរពីពុទ្ធិទាំងអស់ ដែលជា* **វិធីសាស្ត្រតាមបែបសង្ស័យ** *(le doute méthodique)។ តាមរយៈការសង្ស័យ និងការចោទសួរនេះ គេអាចរកឃើញលទ្ធផល និងទទួលបាននូវភាពច្បាស់លាស់។ ដើម្បីចេះដឹងអ្វីច្បាស់ គេត្រូវប្រើប្រាស់វិធីសាស្ត្រតាមបែបសង្ស័យ។ ជាបឋម* **ដេកាត**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សង្ស័យពីអ្វីដែលគាត់រៀនពីសៀវភៅ និងសង្ស័យពីបទពិសោធតាមឥន្ទ្រិយារម្មណ៍ (expérience sensible)។ **ដេកាត** សង្ស័យអ្វីៗទាំងអស់ ហើយគ្មានអ្វីដែលច្បាស់លាស់ទេ។ ដូច្នេះហើយទើប **ដេកាត** បានបង្កើតទ្រឹស្ដីមួយដ៏ល្បី គឺ ៖ «ខ្ញុំសង្ស័យ ខ្ញុំគិត ខ្ញុំមានអត្ថិភាព»។ មានតែអ្នកដែលសង្ស័យទេដែលគិត។ **ដេកាត** ប្រើឃ្លាដ៏ល្បីល្បាញមួយគឺ ៖ «**ខ្ញុំគិត ដូច្នេះខ្ញុំមានអត្ថិភាព** (je pense, donc je suis) ជាភាសាឡាតាំង Cogito ergo sum»។ ទស្សនវិជ្ជានេះកើតឡើងពីការចោទសួរពីភាវៈ និងពីអ្វីដែលនៅសល់បន្ត នៅក្នុងពិភពលោកមួយដែលផ្លាស់ប្ដូរមិនចេះចប់។

**វិធីសាស្ត្រតាមបែបសង្ស័យ** ៖ វិធីសាស្ត្ររបស់ **ដេកាត** មានដូចតទៅ៖ «មិនត្រូវចាប់ផ្ដើមពីសក្ខីកម្មច្បាស់លាស់ឡើយ។ ត្រូវវិភាគពីគំនិតពីធាតុសាមញ្ញបំផុត។ រៀបចំធ្វើចំណាត់ថ្នាក់ធាតុទាំងនោះ ពីលំដាប់សាមញ្ញទៅស្មុគ្រស្មាញ ដើម្បីអាចយល់ដឹងពីបញ្ហាស្មុគ្រស្មាញ។ ចុងបញ្ចប់ត្រូវផ្ទៀងផ្ទាត់ធាតុទាំងអស់ ដោយមិនត្រូវឱ្យមានចន្លោះ ទៅតាមលំដាប់ច្បាស់លាស់ និងពេញលេញ។ ទាល់តែធ្វើដូច្នេះ ទើបគេអាចហៅបានថាជាពុទ្ធិ»។ **ដេកាត**បានជ្រើសរើសយកវិធីសាស្ត្រ «ផ្លូវកណ្ដាល (la voie du juste milieu)» ពោល គឺត្រូវធ្វើតាមសង្គមត្រូវការ ហើយមានសកម្មភាពយ៉ាងណាកុំឱ្យបង្កើតបញ្ហា។

**ទស្សនាទានច្បាស់** ៖ តើត្រូវធ្វើដូចម្ដេចទើបមានភាពច្បាស់លាស់? គេត្រូវទាមទារនូវទស្សនាទានច្បាស់ ហើយផ្សេងពីគេ (des concepts clairs et distints)។ ទស្សនាទានច្បាស់(des concepts clairs) នៅពេលដែលគេអាចកំណត់វាបានដោយឥតខ្ចោះ ពោលគឺគេអាចកំណត់ព្រំដែនរបស់វា បើធៀបនឹងទស្សនាទានផ្សេងទៀត។ ទស្សនាទានផ្សេងពីគេ (des concepts distints) នៅពេលដែលគេអាចយល់ពីវាបានដោយមានតម្លាភាពឥតខ្ចោះ។ ដើម្បីគិតដោយឈរលើមូលដ្ឋានតថភាព គេត្រូវមានទស្សនាទានច្បាស់ ហើយផ្សេងពីគេ។ សមាសធាតុសំខាន់ៗនៃទស្សនវិជ្ជារបស់**ដេកាត**មាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចតទៅ ៖

**ទីមួយបង្ហាញពីអត្ថិភាពរបស់អាទិទេព** (*l'existence de Dieu*)។ ដោយត្រិះរិះតាមទស្សនាទានច្បាស់ ហើយផ្សេងពីគេ (*des concepts clairs et distints*)នេះ **ដេការត** បានឈានដល់អត្ថិភាពនៃប្រធានបទនៃការគិត និងបានបង្ហាញពីអត្ថិភាពរបស់អាទិទេព។ **ដេការត**បានកត់សម្គាល់ថា គាត់មានគំនិតពីអាទិទេព ពោលគឺគំនិតពីភាវៈល្អឥតខ្ចោះ។ ក៏ប៉ុន្តែ អាទិទេពគឺជាប្រធានបទដែលត្រូវមានការសង្ស័យ ដោយសារសារជាតុនៃការសង្ស័យដែលមិនល្អឥតខ្ចោះ។ ដោយសារតែ អាទិទេពខ្លួនឯងមិនមែនល្អឥតខ្ចោះ អាទិទេពមិនអាចជាប្រភពនៃគំនិតដែលជាភាវៈដែលល្អឥតខ្ចោះដាច់ខាត។ ដូច្នេះ ជាភាវៈដែលល្អឥតខ្ចោះត្រូវតែមានតំណាងជាភាវៈដែលយ៉ាងហោចណាស់ក៏ល្អឥតខ្ចោះស្មើនឹងអ្វីដែលខ្លួនធ្វើជាតំណាង ពោលគឺអាទិទេពនេះឯង។ ដូច្នេះ **ដេការត**ចេញពី៖ (១)គំនិតនៃតំណាងរបស់ពុទ្ធិប្រធាន (*sujet pensant*) ដែលអាចជាភាវៈល្អឥតខ្ចោះ (២) តំណាងរបស់វាមិនអាចជាពុទ្ធិប្រធាន ដែលមិនល្អឥតខ្ចោះ និង (៣) តំណាងនេះមានមានប្រភពមកពីភាវៈល្អឥតខ្ចោះខ្លួនឯង ពោលគឺអាទិទេព។ ចំពោះ**ដេការត** គំនិតនៃភាពល្អឥតខ្ចោះត្រូវតែចេញមកពីប្រភពដែលល្អឥតខ្ចោះដូចប្រធានបទដែរ ហើយក៏ត្រូវតែល្អឥតខ្ចោះជាងគំនិតទៅទៀត។ ដូច្នេះ ការបង្ហាញពីអត្ថិភាពរបស់អាទិទេព គឺចេញមកពីគំនិតច្បាស់លាស់ និងផ្សេងពីគេ។ សេរីភាពរបស់អាទិទេព គឺជា **សេរីភាពមិនអើពើ** (*la liberté de Dieu est une liberté d'indifférence*)ពោលគឺ អាទិទេពគ្មានអ្វីដែលត្រូវសង្ស័យឡើយ។ ភាវៈដែលល្អឥតខ្ចោះ និងអមតៈមិនមានទីបញ្ចប់ឡើយ។ ដូច្នេះ សេរីភាពមិនអើពើ គឺជាសេរីភាពរបស់អាទិទេព។ ចំពោះមនុស្សលោកវិញ សេរីភាពនេះស្ថិតនៅក្នុងកម្រិតមួយយ៉ាងទាបបំផុត។ មនុស្សលោកតែងតែមានការខ្វះខាត និងមានទីបញ្ចប់ដែលបង្ហាញពីភាពខុសគ្នាខ្លាំងរវាងសេរីភាពមនុស្សជាមួយនឹងសេរីភាពរបស់អាទិទេព។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ឌ.ពីវិចារណញ្ញាណរបស់ដេកាត** *(le rationalism de Descartes)*។ **ដេកាត**បានសួរថា តើមានអ្វីដែលនៅសេសសល់ពីដំណើរការនៃការផ្លាស់ប្តូរនេះ? **ដេកាត**បានយកក្រណាត់ជ្រលក់ប្រេងមួយផ្ទាំងដែលរឹង គ្មានក្លិន និងមានរាងត្រីកោណកែងទៅដុត។ ពេលដុតអស់នៅសល់តែកម្ទេចផេះ ជុំក្លិនឈ្ងៀម។ ដូច្នេះ បន្ទាប់ពីមានការផ្លាស់ប្តូរគុណភាពនៃក្រណាត់ជ្រលក់ប្រេងនេះ ដូចជារាង ពណ៌ ក្លិនជាដើមដូរទាំងអស់ លើកលែងតែទស្សនាទានទេដែលនៅសល់ គឺជាក្រណាត់ជ្រលក់ប្រេងដដែល។ ជារួមពិភពលោកខាងក្រៅមានរាងជាធរណីមាត្រ។ គុណភាពតាមឥន្ទ្រីយារម្មណ៍មិនមែនជាខ្លឹមសារ*(essence)*នៃវត្ថុទេ។ ខ្លឹមសាររបស់វា គឺជាទំហំ *(l'étendue)*។ ទំហំមិនមែនជារបស់ទទេទេ។ ទំហំត្រូវមានរូបរាង។ ដូច្នេះ វត្ថុត្រូវមានតថភាពរូបរាងនៃទំហំ *(une réalité physique de l'étendue)* និងធរណីមាត្រនៃតថភាពរូបសាស្ត្រ *(géométrisation de la réalité physique)*។ ដូច្នេះ សារធាតុមិនមែនទទេ ឬអាតូមទេ តែគឺជាទំហំពិតប្រាកដនៃរាងកាយ ហើយរូបរាងរបស់វា គឺគណិតវិទ្យា។ ដូច្នេះហើយ ទើបគេហៅ**ដេកាត**ថា ជាអ្នកវិចារណញ្ញាណនិយម។

**ឌ.បីឧស្សរវិជ្ជាទ្វិភាគនិយមរបស់ដេកាត** *(la philosophie dualiste)* ពោលគឺ អ្វីៗទាំងអស់លើលោកមានតថភាពជាមូលដ្ឋានពីរដែលមិនអាចកាត់បន្ថយទៅវិញទៅមកបាន ៖ **ជំហំ** *(l' étendue ឬ res extensa)* និង **គំនិត** *(la pensée ឬ res cogitans)*។ គំនិតមានភាពសកម្ម និងមានចលនាដោយខ្លួនឯង។ ទំហំមានភាពអកម្ម ហើយចលនារបស់វាបណ្តាលមកពីក្រៅ។ **ដេកាត**បានធ្វើសេចក្តីសន្និដ្ឋានពីរ ៖

១- អ្វីដែលជាទំហំ *(l'étendue)* ដូចជាធម្មជាតិ ត្រូវតែពន្យល់ដោយទំនាក់ទំនងខាងក្រៅរបស់វា ដោយទ្រឹស្តីមេកានិច ពោលគឺមិនមែនដោយចលនា ឬការផ្លាស់ប្តូរដោយឯកឯង ឬដោយកម្លាំងពីក្នុងឡើយ។ ទ្រឹស្តីនេះក៏អាចយកទៅពន្យល់ពីរាងកាយដែលមានជីវិតផងដែរ។ រាងកាយរបស់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សត្វ គឺជាទំហំដែលមានភាពអសកម្ម ហើយចំណុះឱ្យច្បាប់នៃចលនាមេកានិច។

២- អ្វីដែលជាគំនិត និងស្មារតី បណ្ដាលមកពីផ្នែកខាងក្នុង និងសកម្មភាពយ៉ាងដាច់ណាត់។ ឆន្ទៈ(la volonté) វិមំសា ឬការវិនិច្ឆ័យ (l'entendement) វាចេញពីខាងក្នុង មិនមែនបណ្ដាលមកពីខាងក្រៅឡើយ។ ចំពោះ **ដេកាត** គំនិត និងឆន្ទៈទាមទារឱ្យមានសកម្មភាពពីខាងក្នុងយ៉ាងខ្លាំង និងត្រូវកើតឡើងដោយឯកឯងទាំងស្រុង។

ប្រការខាងលើនេះមានន័យថារាងកាយ និងព្រលឹង( ឬអារម្មណ៍) នៅដាច់ពីគ្នា។ ប្រការនេះ ធ្វើឱ្យគេជឿលើអាត្ម័នអមតៈ (l'âme immortelle)។ ចំណែកឯរាងកាយត្រូវស្ថិតនៅក្នុងលំហ និងត្រូវរលាយរូបរាងបាត់។ ចំណែកឯអាត្ម័នដែលស្ថិតនៅផ្នែកខាងក្នុងនៃគំនិតមិនរលាយតាមរាងកាយឡើយ។

ក្នុងន័យនេះ **ដេកាត**មិនបានដោះស្រាយបញ្ហាទំនាក់ទំនងរវាងរាងកាយ និងអាត្ម័ន ឬអារម្មណ៍ឡើយ។ ឧទាហរណ៍ ឆន្ទៈបញ្ជាឱ្យលើកដៃ ដៃលើកទៅចូលក្នុងលំហ(l'étendue)។ ហើយនៅពេលដែលកន្លែងណាមួយក្នុងរាងកាយឈឺចាប់ នោះគេឈឺក្នុងអារម្មណ៍ផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្ពីណូហ្សា
## (១៦៣២-១៦៧៧)

**ស្ពីណូហ្សា** *(Spinoza) កើតនៅអាំស្ទែរដាំ ក្នុងគ្រួសារជ្វីហ្វព័រទុយហ្គេ ហើយរស់នៅហូឡង់ពេញមួយជីវិត។ ទស្សនវិជ្ជារបស់***ស្ពីណូហ្សា***ផ្ដោតលើ ឯករាជ្យ(l'indépendance) ហើយសម្រាប់គាត់ នៅក្នុងលោកនេះ គ្មានអ្វីសំខាន់ជាងគំនិតឯករាជ្យ(l'indépendance de la pensée) និងមនុស្សជាតិឯករាជ្យ (l'indépendance d'être humain) ឡើយ។* **ស្ពីណូហ្សា** *រករបរទទួលទានជាអ្នកសម្អាតកញ្ចក់វ៉ែនតា និងរស់ពេញមួយជីវិតក្នុងភាពក្រីក្រតោកយ៉ាក។ នៅពេលមានជីវិត លោកបានបោះពុម្ពស្នាដៃសំខាន់ៗចំនួនពីរ ៖* **គោលការណ៍នៃទស្សនវិជ្ជាដេកាត** *និង***បទអត្ថាធិប្បាយស្ដីពីសាសនានិងនយោបាយ**។ *ក្រោយមរណភាពរបស់គាត់ ស្នាដៃសំខាន់ៗរបស់***ស្ពីណូហ្សា***ត្រូវបានបោះពុម្ព ដូចជា* **សីលធម៌** *(l'Éthique)ជាដើម។ សាកលវិទ្យាល័យ Heidelberg ធ្លាប់បានស្នើសុំឱ្យ***ស្ពីណូហ្សា***ដឹកនាំដេប៉ាតឺម៉ង់ទស្សនវិជ្ជា តែលោកបដិសេធ ដោយសារលោកខ្លាចបាត់បង់នូវភាពឯករាជ្យរបស់ខ្លួន និងខ្លាចគេមិនឱ្យគិត និងបង្រៀននូវអ្វីដែលលោកគិតថាជារឿងពិត។*

**ស្នាដៃសំខាន់** *៖ ស្នាដៃសំខាន់របស់* **ស្ពីណូហ្សា** *គឺ* **«គោលការណ៍នៃទស្សនវិជ្ជារបស់ដេកាត»** *(Principes de la philosophie de Descartes) (L'Éthique)* **«អត្ថាធិប្បាយស្ដីពីនយោបាយ»** *(Traité politique)* **«កំណែទម្រង់នៃវិមំសា»** *(La réforme de l'entendement)*។

*ទស្សនវិជ្ជារបស់* **ស្ពីណូហ្សា** *ផ្ដោតជាសំខាន់លើឯករាជ្យដោយឥតលក្ខខណ្ឌដែលផ្សារភ្ជាប់នឹងភាពចាំបាច់(l'indépendance-nécessité)។ គំនិតសំខាន់ៗនៃទស្សនវិជ្ជានេះមានដូចតទៅ ៖*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សីលធម៌** *(l'éthique)* ៖ គេមិនអាចនិយាយពីសីលធម៌ ដោយមិនគិតពីសេរីភាពទេ។ ចំពោះអ្វីដែលគ្មានសេរីភាព គេមិនអាចនិយាយថា វាមានបញ្ហាសីលធម៌នោះទេ។ ឧទាហរណ៍ ប្រសិនបើក្បឿងមួយសន្លឹកធ្លាក់ពីលើដំបូលផ្ទះលើក្បាលមនុស្ស ហើយធ្វើឱ្យមនុស្សនោះស្លាប់ អំពើនេះមិនមែនផ្ទុយនឹងសីលធម៌ឡើយ ដោយសារតែក្បឿងនេះគ្មានសេរីភាពឡើយ។ ដូច្នេះ គេអាចបង្ហាញពី សីលធម៌ ដោយឈរលើមូលដ្ឋានសេរីភាពតាមរយៈវិធីសាស្ត្រធរណីមាត្រ*(la méthode géométrique)*។ ដូច្នេះ ចំពោះ **ស្ពីណូហ្សា** សេរីភាព និងភាពចាំបាច់*(la nécessité)* គឺតែមួយ។

**សារជាតុ** *(la substance)* ៖ អាទិទេព គឺជាសារជាតុ។ ចំពោះ **ស្ពីណូហ្សា** សារជាតុមិនមែនជាទឹកដូច**តាឡេស**ទេ តែសារជាតុ គឺជាភាវៈដែលមិនពឹងផ្អែកលើអ្វីទៀតក្រៅពីខ្លួនវាឡើយ។ ដោយសារជាតុ គឺជាអាទិទេព សារជាតុនៅជាអមតៈ និងស្ថិតស្ថេរគ្រប់ពេលវេលា។ អាទិទេពស្ថិតនៅក្នុងខ្លួនឯង ដោយខ្លួនឯង និងជាមូលហេតុនៃខ្លួនឯង*(Dieu est en soi, par soi, cause de soi)*។ **ដេការត**យល់ថា អ្វីៗទាំងអស់លើលោកត្រូវបែកជាពីរ គឺ **ទំហំ** *(l'étendue)* និង **គំនិត** *(la pensée)* ដែលដាច់ដោយឡែកពីគ្នា។ ក៏ប៉ុន្តែ ចំពោះ**ស្ពីណូហ្សា**វិញ សារជាតុត្រូវមានលក្ខណៈទាំងពីរនេះរួមគ្នា **ទំហំ** និង **គំនិត** បូកបញ្ចូលគ្នា។ ចំពោះ**ដេការត** ព្រះអាទិទេពមានសេរីភាពមិនអើពើ*(la liberté d'indifférence)*។ តែចំពោះ **ស្ពីណូហ្សា**វិញ ព្រះអាទិទេព សេរីភាព និងភាពចាំបាច់ គឺតែមួយ។ សារជាតុមានលក្ខណៈតែមួយ សាមញ្ញ មិនអាចបំបែកបាន និងអមតៈ។ សារជាតុមានជីវិតអមតៈ ដោយសារវា គឺជា**ភាវៈនៅក្នុងខ្លួនឯង** *(l'être en soi)*។ នៅក្នុងទស្សនវិជ្ជាស្ពីណូហ្សា អាទិទេព និងសារជាតុគឺតែមួយ។ **អាទិទេព-សារជាតុ** មានអត្ថិភាពពិតៗ។ **ស្ពីណូហ្សា**យល់ឃើញថា ភាវៈត្រូវមានភាពពេញលេញ*(la plénitude de l'être)* ក្នុងភាពតែមួយ*(le monisme)*។

**សេរីភាពពិតប្រាកដ** *(la liberté véritable)* ៖ នៅពេលដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យើងឈានទៅដល់គោលដៅកំណត់ ដោយយើងមានការខ្វះខាត យើងគ្មានសេរីភាពឡើយ។ កង្វះខាតធ្វើឱ្យយើងបាត់បង់នូវសេរីភាព។ សេរីភាពពិតប្រាកដមានពេលដែលយើងទទួលស្គាល់ការចាំបាច់ត្រូវមានសារជាតុទោលដែលមានលក្ខណៈសព្វគ្រប់ ដោយមិនត្រឹមតែទទួលស្គាល់ តែត្រូវទទួលយកមតិរបស់វាផងដែរ។ ឧទាហរណ៍ នៅក្នុងធរណីមាត្រយើងមានសម្មតិកម្មថា ៖ ផលបូកនៃមុំបីក្នុងត្រីកោណ ត្រូវស្មើនឹងផលបូកនៃមុំកែងពីរ។ ពេលដែលយើងយល់ពីការចាំបាច់នៃរូបមន្តនេះ យើងមានអារម្មណ៍សប្បាយចិត្តពិតប្រាកដ ដោយដឹងភាពត្រឹមត្រូវ និងភាពចាំបាច់។ មនុស្សមានភារៈកិច្ចធ្វើឱ្យមានភាពចាំបាច់ដូចអាទិទេព(la nécessité divine) ដើម្បីរំដោះខ្លួនចេញពីតណ្ហារបស់មនុស្ស (le désir humain) ដើម្បីកុំឱ្យនៅសល់តណ្ហាអ្វីផ្សេងទៀត។

**ពុទ្ធិ** (la connaissance) ៖ ចំពោះ**ស្ពីណូហ្សា** ពុទ្ធិមានបីប្រភេទ ៖ (១) ពុទ្ធិតាមឥន្ទ្រីយារម្មណ៍(connaissance sensibles) ដែលជាពុទ្ធិទូទៅ មិនសូវច្បាស់ និងងាយស្រួលនឹងខុស ដោយសារតែនៅត្រឹមកម្រិតឥន្ទ្រីយ៍ យើងធាប់យល់ឃើញអ្វីៗចប់ត្រឹមហ្នឹង (២) គំនិតប្រកបដោយវិចារណញ្ញាណ (la pensée rationnelle) ដែលនឹងវិវត្តទៅជាចំណេះដឹងផ្នែកវិទ្យាសាស្ត្រដោយប្រើប្រាស់វិធីសាស្ត្រវិភាគស៊ីជម្រៅ។ វិទ្យាសាស្ត្រភ្ជាប់ ពុទ្ធិតាមឥន្ទ្រីយារម្មណ៍ទៅនឹងពុទ្ធិសហជញ្ញាណ តាមរយៈច្រវាក់នៃហេតុផល (៣) ពុទ្ធិសហជញ្ញាណ(la connaissance intuitive) គឺជាពុទ្ធិដែលទទួលបានដោយប្រើប្រាស់វិធីសាស្ត្រវិភាគច្បោលៗទៅក្នុងសារជាតុ ដើម្បីបញ្ជាក់ពីភាពចាំបាច់នៃអាទិទេព។ ដូច្នេះ ពុទ្ធិសហជញ្ញាណ គឺជាពុទ្ធិពិតប្រាកដ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឡៃបនិត
## (១៦៤៦-១៧១៦)

**ឡៃបនិត** (Leibniz) កើតនៅទីក្រុង Leipzig នាពាក់កណ្ដាលសតវត្សរ៍ទី១៧។ យុគសម័យនេះ គឺជាការចាប់ផ្ដើមនៃបដិវត្តន៍ឧស្សាហកម្ម ជាចុងយុគសម័យបុរាណ និងដើមយុគសម័យទំនើបដែលពោរពេញដោយគំនិតថ្មីៗ។ **ឡៃបនិត** ធ្លាប់បានទៅសិក្សានៅប្រទេសបារាំង អង់គ្លេស និងហូឡង់ ហើយបានក្លាយជាមិត្តរបស់**ស្ពីណូហ្សា**។ **ឡៃបនិត** គឺជាគណិតវិទូដែលបានរកឃើញវិធីគណនាឌីផេរង់ស្យែល(le calcul différentiel)។ ម្យ៉ាងវិញទៀត **ឡៃបនិត** សិក្សាពីបញ្ហាជាច្រើន ដូចជានយោបាយ ច្បាប់ សេដ្ឋកិច្ច សាសនា ស្ថាបត្យកម្ម និងបច្ចេកវិទ្យាជាដើម។ លោកបានបោះពុម្ពសៀវភៅសង្ខេបស្ដីពីទស្សនវិជ្ជា ដែលមានចំណងជើងថា Monadologie។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់ **ឡៃបនិត** គឺ «**ម៉ូណាដវិជ្ជា**» (Monadologie) «**សុន្ទរកថាស្ដីពីបរមត្ថវិជ្ជា និងម៉ូណាដូវិជ្ជា**» (Discours de métaphysique et Monadologie)។

ទស្សនវិជ្ជារបស់ **ឡៃបនិត** ផ្ដោតលើបញ្ហាដូចតទៅ ៖

**សារធាតុ** (la substance) ៖ **ឡៃបនិត**បានចោទសួរពីសារធាតុ។ ចំពោះ**ឡៃបនិត** សារធាតុនៃវត្ថុ គឺ **ថាមពល** (l'énergie)។ ថាមពល គឺជាគោលការណ៍នៃសកម្មភាព។ គាត់ចាប់ផ្ដើមសិក្សាពីគោលការណ៍នៃសកម្មភាព ជាពិសេសឧបសគ្គដែលរារាំងសកម្មភាព។ ដូច្នេះ គាត់សិក្សាពីថាមពលដំបូងដែលមានអតីតកាលផង និងអនាគតកាលផង ហើយដែលគាត់ហៅថា **កម្លាំង** (puissance)។ ដើម្បីជានានូវសង្គតិភាព **ឡៃបនិត**យល់ថា ទស្សនាទានសារធាតុនេះត្រូវមានតែមួយឯកតាប៉ុណ្ណោះ។ ប្រសិនបើសារធាតុអាចបំបែកបាន នោះវាលែងជាសារធាតុទៀតហើយ។ តាមការពិត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សារធាតុគឺជាធាតុផ្ទុយនឹង **អភាវៈ** (le non-être)។

**ថាមពល** (l'énergie)៖ **ឡៃបនិត**មានមតិផ្ទុយពី**ដេកាត**ចំពោះ **ទំហំ** (l' étendue ឬ res extensa) និង **គំនិត** (la pensée ឬ res cogitans)។ **ឡៃបនិត**យល់ថា **ទំហំ** (l'étendue) អាចត្រូវបំបែកបានរហូតដល់អនន្ត (ដូចការគណនាឌីផេរង់ស្យែល)។ ដូច្នេះ ទំហំ គឺជាទីលានសម្រាប់បន្ត សកម្មភាព ហើយការស្រាវជ្រាវតែងតែដំណើរការគ្មានទីបញ្ចប់ ដូចជា ការស្រាវជ្រាវវិទ្យាសាស្ត្រដូច្នេះឯង។ ហើយនៅក្នុងទំហំនេះ ក៏គ្មានឯកតា (l'unité)តូចៗដែរ ដោយសារតែទំហំនេះមិនមែនជាសារធាតុទេ។ ក៏ប៉ុន្តែ ស្នូលដែលមិនអាចបំបែកបាននោះ គឺជា **ថាមពល** (l'énergie) ដែលទស្សន វិទូផ្សេងទៀតហៅថាអាតូម មិនអាចបំបែកបាន។ **ឡៃបនិត**ឱ្យឈ្មោះអាតូម ថាមពល (l'atome d'énergie) នេះថា monade ដែលមកពីពាក្យក្រិកថា monos មានន័យថាមួយ។ Monade គឺជាឯកតាថាមពល ស្ថិតនៅក្នុងលំហ គ្មានទំហំ គ្មានបង្អួច និងមិនអាចបំបែកបាន។ វាជាចំណុចមួយ សាមញ្ញ រូបី។ គ្មានអ្វីដែលអាចមានឥទ្ធិពលលើវាពីក្រៅបានឡើយ។ វាពឹងផ្អែកលើ ខ្លួនឯងទាំងស្រុង ហើយថាមពលនេះចេញពីក្នុងខ្លួនវាតែម្តង។

**ទំនួលអារម្មណ៍** (la perception) ៖ ទំនួលអារម្មណ៍ គឺជាលទ្ធផល នៃឥន្ទ្រីយារម្មណ៍(sensation) និងការវិនិច្ឆ័យ(jugement) ហើយបង្កើតបានជា សម្បជញ្ញៈ (la conscience) ឬញាណពិចារណា។ មនុស្សដឹងពីហេតុការណ៍ ផ្សេងៗតាមរយៈឥន្ទ្រីយារម្មណ៍ (la sensation) ដូចជា ភ្នែក ច្រមុះ ត្រចៀក អណ្តាត។ល។ តាមរយៈទំនួលអារម្មណ៍(la perception)នេះ ធ្វើឱ្យយើង ត្រិះរិះពិចារណា(intériorisé) តាមរយៈសម្បជញ្ញៈ(la conscience)។ ក្នុងន័យ នេះ monade ក៏មានលក្ខណៈដូចសម្បជញ្ញៈដែរ គឺជាកញ្ចក់រស់ និងអមតៈ នៃចក្រវាល។ ក៏ប៉ុន្តែ ថ្វីត្បិតតែ monade នេះជាទំនួលអារម្មណ៍នៃចក្រវាល វាមិនអាចផ្តិតយកចក្រវាលឱ្យបានគ្រប់ផ្នែកស្មើៗគ្នាឡើយ។ **ឡៃបនិត**បែក ទំនួលអារម្មណ៍ជាពីរផ្នែក ៖ ទំនួលអារម្មណ៍ធំ(grandes perceptions) និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទំនួលអារម្មណ៍តូច(petites perceptions)។ ទំនួលអារម្មណ៍ធំកើតឡើង ដោយប្រើប្រាស់នូវឥន្ទ្រីយទាំងអស់ ដូចជា ភ្នែក ច្រមុះ ត្រចៀក អណ្តាត។ នៅពេលដែលមនុស្សគេងលក់ គេលែងដឹងអ្វីទាំងអស់ក៏ពិតមែន តែសរីរាង្គ នៅតែបន្តជានិច្ច ហើយបង្កើតបានជាទំនួលអារម្មណ៍តូច ដែលចិត្តវិទូហៅ ថា អញ្ញាណ (inconscience)។ ដូច្នេះ ទំនួលអារម្មណ៍ធានាបាននូវនិរន្តរភាព ក្នុងគ្រប់វិស័យទាំងអស់។

**ឯកតា** monade ៖ ចក្រវាលទាំងមូលកើតឡើងដោយ monade ដែល ត្រូវមានចំណាត់ថ្នាក់ តាមលំដាប់ (hiérarchie) ៖ (ទី១) នៅផ្នែកខាងក្រោម ជាងគេ គឺជា monade សាមញ្ញដែលនាំឱ្យមានទំនួលអារម្មណ៍តូច នៅកម្រិត រុក្ខជាតិ (ទី២) នៅផ្នែកកណ្តាល កម្រិតសត្វមាន monade ដែលអាចមាន ទំនួលអារម្មណ៍ច្បាស់ជាង និងជាកន្លែងសម្រាប់ការចងចាំ(mémoire) ពោល គឺជាព្រលឹង ឬអាត្មន (ទី៣) កម្រិតទីបី គឺជាស្មារតី (l'esprit) វិចារណ-ញ្ញាណ(la raison) ហើយបានឈានដល់កម្រិតកំពូល គឺការពិតអមតៈ(les vérités éternelles)។ ដូច្នេះ monade ដែលស្ថិតនៅក្នុងលំហ ឆ្លុះបញ្ចាំង ចក្រវាលទាំងមូល តែ monade នីមួយៗមានទស្សនៈរៀងៗខ្លួនពីចក្រវាលនេះ ផ្នែកខ្លះឆ្លុះបញ្ចាំងយ៉ាងច្បាស់ តែផ្នែកខ្លះទៀតបានយ៉ាងស្រពិចស្រពិល ប៉ុណ្ណោះ អាស្រ័យលើទីតាំងរបស់ខ្លួនក្នុងលំហអាកាស។

**ទំនាក់ទំនងរវាងរាងកាយ និងអាត្មន ៖ ឡៃបនិត**យល់ឃើញ ថា រាងកាយ និងអាត្មនប្រៀបបីដូចជានាឡិកាពីរដែលចង្អុលម៉ោងដូចគ្នា។ ចាប់ពីពេលដំបូង អាទិទេពបានបង្កើតរាងកាយ និងអាត្មនដើម្បីឱ្យពួកគេ ស្ថិតនៅក្នុងសភាពសុខដុមរមនីយនឹងគ្នា និងមានភាពល្អឥតខ្ចោះតាំងពី ពេលដំបូង។

**គោលការណ៍វិចារណញ្ញាណគ្រប់គ្រាន់** (le principe de raison suffisante) ៖ ដោយមានការជំរុញពីខាងក្នុង monade នីមួយៗខិតខំ ប្រឹងប្រែងទទួលអារម្មណ៍យ៉ាងច្បាស់ពីចក្រវាល។ ដូច្នេះ នៅក្នុងចក្រវាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះ គ្មានអ្វីមួយដែលមានអត្ថិភាពដោយគ្មានវិចារណញ្ញាណគ្រប់គ្រាន់នោះទេ។ ពោលគឺវត្ថុមួយត្រូវតែអាចពន្យល់បានដោយវត្ថុមួយទៀត។ ដូច្នេះ វត្ថុមួយមិនអាចផ្ទុយនឹងវត្ថុមួយទៀតទេ ពោលគឺវត្ថុពីរអាចមានអត្ថិភាពជាមួយគ្នាបាន។ នេះគឺជាគោលការមិនផ្ទុយគ្នា(le principe de non-contradiction)។

**អាទិទេព** (Dieu) ៖ Monade នីមួយៗឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវចក្រវាលមួយភាគធំ។ ដោយ monade គឺជាឯកតានៃថាមពល វាខិតខំបំភ្លឺលោកឱ្យបានខ្លាំងក្លាបំផុត។ ក៏ប៉ុន្តែ ដើម្បីឱ្យ monade អាចបំភ្លឺលោកឱ្យបានច្បាស់ជាសកល (la claret universelle) វាមិនមែនត្រូវមានទស្សនៈរៀងៗខ្លួនពីចក្រវាលនេះ តែត្រូវគ្របដណ្តប់លើចក្រវាលទាំងមូលតែម្តង ដែល **ឡៃបនិត** ហៅថា monade នៃ monades ពោលគឺជា **អាទិទេព**តែម្តង។ ប្រការនេះមានន័យថា អាទិទេពមានវត្តមាននៅគ្រប់ទីកន្លែង។ ដូច្នេះ ដោយឈរលើ **គោលការណ៍ហេតុផលគ្រប់គ្រាន់** (le principe de raison suffisante) នៅពេលដែលយើងគិតថាអាចមានអាទិទេព គឺអាទិទេពត្រូវតែមានជាការចាំបាច់ (du moment que Dieu est possible, il existe nécessairement)។ អាទិទេពចាំបាច់សម្រាប់អ្វីៗទាំងអស់ក្នុងលោកនេះ ជាសកម្មភាព និងជាអ្នកបង្កើតលោក។ អំពើល្អ គឺមកពីអាទិទេព ចំណែកអំពើអាក្រក់ គឺមកពីលក្ខខណ្ឌនៃការបង្កើតលោក (le bien vient de Dieu; le mal, de la condition de la créature) ហើយបើគ្មានអំពើអាក្រក់ ក៏គ្មានអំពើល្អដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជាពិសោធនិយម

តើពុទ្ធិកើតឡើងរបៀបណា? ចរន្តវិចារណញ្ញាណនិយមយល់ថា ដើម្បីឈានទៅដល់ពុទ្ធិ គេត្រូវពឹងផ្អែកលើតក្កវិជ្ជា និងប្រាជ្ញា(intellect) ក្នុងការត្រិះរិះពិចារណា ដោយមិនពឹងផ្អែកលើពិសោធន៍ឡើយ ដោយសារតែពុទ្ធិមានមុនពិសោធន៍ទៅទៀត(a priori)។ ទស្សនវិទូដែលយល់ថាពុទ្ធិមិនមែនចេញពីការគិតទេ តែចេញមកពីពិសោធន៍ត្រូវបានគេហៅថាចរន្តពិសោធនិយម។

ចលនាទស្សនវិជ្ជាពិសោធនិយម(empirisme)បានកើតឡើងនៅអង់-គ្លេស ក្នុងសតវត្សរ៍ទី១៧។ ទស្សនវិជ្ជានេះផ្តោតលើចំណុចសំខាន់ពីរ ៖ (១) ពុទ្ធិកើតមកពីបទពិសោធតាមឥន្ទ្រីយារម្មណ៍ និង (២) មូលដ្ឋានគ្រឹះនៃសីលធម៌ចេញមកពីរបៀបរបបរស់នៅរបស់មនុស្ស នៅក្នុងសង្គម និងនៅក្នុងរដ្ឋ។ ពួកពិសោធនិយមទាត់ចោលអំណះអំណាងថា គំនិតដែលតាមរយៈតែការត្រិះរិះពិចារណា តែប៉ុណ្ណោះអាចឱ្យគេយល់បានពីតថភាព។ ផ្ទុយទៅវិញ ទស្សនវិទូអង់គ្លេស **ចន ឡុក** (Locke) ទស្សនវិទូអៀកឡង់ **ប៊ែកឃ្លី** (Berkeley) និងទស្សនវិទូស្កត់ឡែន **ដេវីដ ហ្យូម** (Hume) យល់ឃើញថា បទពិសោធដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតពុទ្ធិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ចន ឡុក្ក
## (១៦៣២-១៧០៤)

**ចន ឡុក្ក** *(John Locke)* កើត និងរស់នៅក្នុងប្រទេសអង់គ្លេសក្នុងពាក់កណ្ដាលសតវត្សរ៍ទី១៧។ លោកមិនជឿលើទ្រឹស្ដីរបស់**ប្លាតុង**ដែលថា គំនិតកើតពីក្នុង*(les idées innées)* មកទេ ដោយមានទទ្បីករណ៍ថាៈ «គេគ្មានអ្វីអាចមាននៅក្នុងស្មារតីបានឡើយ ប្រសិនបើស្មារតីនេះមិនមានសតិសម្បជញ្ញៈ *(il ne peut rien y avoir dans l'esprit sans que l'esprit en ait conscience)*»។ លោកមិនទទួលយកទ្រឹស្ដីដែលថា មានគំនិតដើមយ៉ាងដាច់ខាត។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ចន ឡុក្ក** គឺ «**លិខិតស្ដីពីខន្ដី**» *(Lettres sur la tolerance)* «**អភិប្រាយស្ដីពីរដ្ឋាភិបាលស៊ីវិល**» *(Traité du gouvernement civil)* «**សិក្ខាកថាស្ដីពីវិមំសាមនុស្ស**» *(Essai sur l'entendement humain)*។

ទស្សនវិជ្ជារបស់ **ចន ឡុក្ក** ផ្ដោតលើចំណុចដូចតទៅ ៖

**បទពិសោធ** ៖ **ឡុក្ក**ទាត់ចោលទ្រឹស្ដីដែលថា មនោ*(mind)* មានគំនិតនិងទស្សនាទានពីកំណើតមកម្ល៉េះ។ អាត្ម័នចាប់ផ្ដើមពីវត្ថុទទេ*(une tabula rasa)*។ ដូច្នេះ មនុស្សកើតមកប្រៀបបីដូចជាក្រដាសសអិចឹង*(clean slate)*។ គំនិតទាំងអស់សុទ្ធតែជាគំនិតដែលទទួលបាន*(des idées acquises)* មិនមែនកើតពីខាងក្នុងនោះទេ ពោលគឺទទួលបានតាមរយៈឥន្ទ្រីយារម្មណ៍។ ដូច្នេះ គំនិតចេញពីប្រភពតែមួយគត់ គឺបទពិសោធ។ បទពិសោធន៍មានពីរប្រភេទ ៖ (១) បទពិសោធខាងក្រៅ*(l'expérience extérieure)*ដែលទទួលបានពីឥន្ទ្រីយារម្មណ៍ និង(២) បទពិសោធខាងក្នុង *(l'expérience intérieure)*។ ប្រសិនបើគ្មានឥន្ទ្រីយារម្មណ៍ទេ នោះស្មារតីមិនអាចធ្វើអ្វីបានឡើយ។ យើង

*មិនអាចគិត ដោយគ្មានឥន្ទ្រីយារម្មណ៍បានឡើយ។ ទទួលអារម្មណ៍ហើយ ទើបយើងអាចគិតបាន។* **ឡុក្ក** *ចែកគំនិតជាពីរ ៖ គំនិតសាមញ្ញ(idées simples) ដែលជាឥន្ទ្រីយ៍របស់យើងដែលជាវត្ថុធាតុដើមនៃពុទ្ធិ និងគំនិតផ្គុំ(idées composées) ដែលជាស្មារតី ដែលកើតមកពីការប្រៀបធៀបគំនិត និងធ្វើឱ្យជាអរូបី។*

**រាងកាយ** *៖ រាងកាយមានគុណភាពពីរ ៖ (១) ភាពរឹងមាំ ទំហំ ចលនាដែលជាគុណភាពពិតៗដែលស្ថិតនៅក្នុងរាងកាយ តែជាគុណភាពលំដាប់ទីពីរ និង (២) ពណ៌សម្បុរ ក្លិន និងសំឡេងដែលដឹងតាមឥន្ទ្រីយារម្មណ៍ ស្ថិតក្រៅរាងកាយ ក៏ប៉ុន្តែចំណុះឱ្យទំទួលអារម្មណ៍នៃបុគ្គលម្នាក់ៗ។*

**សារជាតុ** *៖ គ្មាននរណាម្នាក់ធ្លាប់បានជួបសារជាតុ ក្នុងបទពិសោធន៍របស់ខ្លួនឡើយ។ ដោយទាល់តែមានបទពិសោធទើបយើងអាចគិតបាន ដូច្នេះ សារជាតុនេះគ្មានទេនៅលើលោក។*

**គុណភាព និងគំនិត** *៖ គំនិតស្ថិតនៅក្នុងស្មារតី ចំណែកឯគុណភាពស្ថិតនៅក្នុងវត្ថុ។ ដូច្នេះ មានតែគុណភាពទេដែលពិត ចំណែកឯគំនិតវិញមិនមែនជាគុណភាពពិតនោះទេ។ គំនិតអាស្រ័យទៅលើញាណរបស់យើង។*

**ការផ្លាស់ប្តូរ** *៖ ក្រៅពីអាទិទេព អ្វីៗទាំងអស់សុទ្ធតែផ្លាស់ប្តូរ។ នៅពេលដែលយើងមានគំនិតដែលមិនផ្លាស់ប្តូរ នេះមិនមែនជាវត្ថុពិតទេ គឺជាផលសិប្បនិម្មិតនៃការត្រិះរិះពិចារណា។ ពុទ្ធិរបស់យើងមិនអាចទៅហួសពីគំនិតរបស់យើងឡើយ។ តាមបទពិសោធ យើងមិនអាចឈានទៅដល់អ្វីដែលពិតៗឡើយ បានត្រឹមតែឃើញពីខាងក្រៅ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ដេវីត ហ្យូម
## (១៧១១-១៧៧៦)

**ដាវីត ហ្យូម** *(David Hume)* គឺជាទស្សនវិទូស្កុតឡែន(អង់គ្លេស) នៅក្នុងសតវត្សរ៍ទី១៨ ដែលមាននិន្នាការបទពិសោធនិយម។ ទស្សនវិជ្ជារបស់ **ដាវីត ហ្យូម** បានក្លាយជាមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជារបស់ទស្សនវិទូអាឡឺម៉ង់ **អេម៉ានុយអែល កង់ត៍** *(Emmanuel Kant)*។ លោកយល់ឃើញថា ប្រភពនៃពុទ្ធិ គឺទំនួលអារម្មណ៍តាមឥន្ទ្រីយារម្មណ៍ ពោលគឺតាមរយៈបទពិសោធ និងការជួបផ្ទាល់។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ដាវីត ហ្យូម** គឺ «**សិក្សាកថាទស្សនវិជ្ជាស្ដីពីវិមំសា**» *(Essai philosophiques sur l'entendement)* «**ការសិក្សាស្រាវជ្រាវស្ដីពីគោលការណ៍សីលធម៌**» *(Enquête sur les principes de la morale)* «**អភិប្រាយស្ដីពីសារជាតុមនុស្ស**» *(Traité de la nature humaine)*។

ទស្សនវិជ្ជារបស់ **ហ្យូម** មានចំណុចសំខាន់ៗដូចតទៅ ៖

**អាកប្បកិរិយារិះគន់** *(une attitude critique)* ៖ **ដាវីត ហ្យូម** យល់ថាដើម្បីឱ្យមនុស្សដោះស្រាយបញ្ហាការៈបាន ទាល់តែពួកគេប្រកាន់នូវ**អាកប្បកិរិយារិះគន់**។ នៅសម័យនោះ ពាក្យរិះគន់មានន័យថា ៖ «ស្មារតីត្រូវពិនិត្យមើលខ្លួន ដោយខ្លួនឯង ដោយសង្កេតមើលប្រតិបត្តិការ និងវិធីសាស្ត្ររបស់ខ្លួន ដើម្បីឱ្យសរីរាង្គអាចស្គាល់បាន ចាប់បាននូវសារ-ជាតុ និងផ្ដល់តម្លៃ»។ ដូច្នេះ គេត្រូវស្គាល់ខ្លួនឯង ដើម្បីយល់ពុទ្ធិវត្ថុដែលគេចង់ដឹង៖ តើមនោដែលចង់ដឹងត្រូវធ្វើអ្វី? តើពាក្យថាយល់មានន័យដូចម្ដេច? ដើម្បីទទួលបាននូវពុទ្ធិ តើត្រូវមានប្រតិបត្តិការជាមូលដ្ឋានអ្វីខ្លះ? ដូច្នេះ នៅពេលដែលមនុស្សទទួលបាននូវពុទ្ធិ តើមានតម្លៃអ្វីខ្លះ មានព្រំដែន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*អ្វីខ្លះ? មានសារៈសំខាន់អ្វីខ្លះ?* **ហ្យូម** *យល់ថាមនុស្សកើតមកមិនមែនយកគំនិតមកជាមួយទេ តែគឺសភាវៈ(instincts) ដែលបង្កើតពុទ្ធិរបស់យើង។ សម្រាប់* **ហ្យូម** *មនោ(mind) មិនមែនជាក្រដាសស(tabula rasa)ឡើយ តែវាមានលក្ខណៈមួយដែលជួយឱ្យយើងអាចយល់ដឹងពីពិភពលោកបាន។*

**គំនិត***(l'idée) ៖ គំនិតបានមកពីបទពិសោធតាមឥន្ទ្រីយារម្មណ៍ (l'expérience sensible)។ នៅពេលដែលយើងគិត គំនិតជំពាក់ត្របាញ់ជាមួយគ្នា ដោយអនុលោមតាមលំដាប់ ដូចជា ៖ គំនិតដូចគ្នា ជិតគ្នាក្នុងលំហ ឬក្នុងពេលវេលា តាមហេតុផល។ យើងភ្ជាប់គំនិតមួយចំនួនជាមួយគ្នា ដោយគំនិតទាំងនោះស្រដៀងគ្នា។*

**ហេតុ-ផល** *(la causalité) ៖ ប្រសិនបើទំនួលអារម្មណ៍* **B** *ដើរតាមក្រោយទំនួលអារម្មណ៍* **A** *ជានិច្ច រវាង* **A** *និង* **B** *មានទំនាក់ទំនងជិតគ្នា ឬប្តូរគ្នា។ ក៏ប៉ុន្តែ បើយើងថា* **A** *ជាហេតុនាំឱ្យមាន* **B** *ហើយ* **B** *គឺជាផលវិបាកនៃ* **A** *នេះគឺជាទំនាក់ទំនង* **ហេតុ-ផល**។ *ប្រការនេះមានន័យថា* **B** *ចាំបាច់ត្រូវតែកើតក្រោយ* **A** *ហើយ* **A** *ចាំបាច់ត្រូវតែនាំឱ្យមាន* **B**។ *ក្នុងន័យនេះ* **ដេវីដ ហ្យូម** *បានប្រកាសពីទ្រឹស្តី***បច្ច័យនិយមដាច់ខាត** *(déterminisme absolu) ពោលគឺអ្វីៗត្រូវបានសម្រេចទុកជាមុន។ ច្បាប់នេះមិនមែនកើតឡើងតែក្នុងធម្មជាតិទេ តែវាកើតឡើងក្នុងសីលធម៌ និងក្នុងប្រវត្តិសាស្ត្រផងដែរ។ លោក***ហ្យូម***បានសរសេរថា ៖ «អ្វីៗទាំងអស់តែងតែមានមូលហេតុ ហើយនៅក្នុងលក្ខខណ្ឌដូចគ្នា មូលហេតុដូចគ្នានេះនឹងនាំមកនូវបច្ច័យដូចគ្នាដែរ»។*

**ដេវីដ ហ្យូម** *បានការពារទ្រឹស្តី***បច្ច័យនិយម***នៃប្រវត្តិសាស្ត្រ ដោយបង្ហាញឱ្យឃើញនូវភាពចាំបាច់ និងសន្តតិភាពនៃសកម្មភាពរបស់មនុស្ស ដោយសារមនុស្សមានភាពចាំបាច់ដូចគ្នា និងមានមូលហេតុដែលកើតឡើងជាបន្តបន្ទាប់ដូចគ្នាដែលនឹងធ្វើឱ្យព្រឹត្តិការណ៍កើតឡើង តាមលំដាប់-លំដោយដូចគ្នា ពោលទ្រឹស្តី***ហេតុផល** *(la causalité) របស់* **ហ្យូម** *ឈរលើ*

មូលដ្ឋាននៃទម្លាប់ (l'habitude) របស់មនុស្ស។

មានមតិបានលើកឡើងថា ប្រសិនបើ **ដេវីដ ហ្យូម** មិនបានទិតៀនពិនិត្យទ្រឹស្តីហេតុផលទេ នោះប្រហែលជា **អេម៉ានុយអែល កង់ត៍** មិនអាចបង្កើតទស្សនវិជ្ជារបស់គាត់បានឡើយ។

# ទស្សនវិជ្ជាមនោនិយម

## អេម៉ានុយអែល កង់ត៍

**(១៧២៤-១៨០៤)**

**អេម៉ានុយអែល កង់ត៍** *កើត និងរស់នៅទីកន្លែងតែមួយគឺ Königsberg ប្រទេសអាឡឺម៉ង់ នៅក្នុងសតវត្សទី១៨។ លោកបានកែប្រែយ៉ាងខ្លាំងក្លានូវគំនិតទស្សនវិជ្ជា ហើយជាអ្នករស់គឺដើម្បីសរសេរស្នាដៃរបស់គាត់។ គាត់ទទួលឥទ្ធិពលពីម្ដាយរបស់គាត់ និងពី*ញូតុន *និងវិទ្យាសាស្ត្រសម័យនោះ និងបានសិក្សាពីទស្សនវិជ្ជារបស់*ឡៃបនិត*។*

**ស្នាដៃសំខាន់ ៖ អេម៉ានុយអែល កង់ត៍** *បានសរសេរស្នាដៃសំខាន់ៗចំនួនបីគឺ ៖ (១)* **ការរិះគន់វិចារណញ្ញាណសុទ្ធ***(Critique de la raison pure)* (២) **ការរិះគន់វិចារណញ្ញាណអនុវត្ត***(Critique de la raison pratique)* និង (៣) **ការរិះគន់ការវិនិច្ឆ័យ***(Critique du jugement)*។ *ទស្សនវិជ្ជារបស់* **កង់ត៍** *ផ្ដោតលើសំណួរចំនួនបីគឺ ៖ (១) «តើជាទូទៅអ្វីទៅវិទ្យាសាស្ត្រជាអ្វី? (Comment la science est-elle en general possible?)» (២) «តើខ្ញុំត្រូវធ្វើដូចម្ដេច? (Que dois-je faire?)»* និង (3) *«តើខ្ញុំអាចសង្ឃឹមលើអ្វីបាន? (Que m'est-il permis d'espérer?)»*។

**ក- ការរិះគន់វិចារណញ្ញាណសុទ្ធ** *(Critique de la raison pure)*

*ពាក្យថា* **រិះគន់** *(Critique)* មានន័យថា ៖ *គំនិតចោទជាសំណួរដោយខ្លួនឯង ដើម្បីឱ្យដឹង និងវាយតម្លៃសារៈសំខាន់របស់ខ្លួនឯង។ ពាក្យថា* **វិចារណញ្ញាណ** *(raison) គឺជាគំនិតទ្រឹស្ដីដែលបង្កើតឡើងដោយពុទ្ធិប្រធាន ពោលគឺជាវិចារណញ្ញាណដែលបង្កើតនូវទ្រឹស្ដី។ ហើយពាក្យ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថា **សុទ្ធ** (pure) មានន័យថា ការទិតៀនដែលពិនិត្យមើលវិចារណញ្ញាណ ដែលមិនធ្វងកាត់បទពិសោធដែលពិនិត្យខ្លួនឯងតែម្ដង ហើយមិនលាយ-ឡំនឹងលទ្ធផលពិសោធជាក់ស្ដែង។ ដូច្នេះ កម្មវត្ថុនៃការទិតៀន គឺជាគំនិតដែលមានទម្រង់សុទ្ធ មុននឹងមានបទពិសោធ។ ពាក្យថា **សុទ្ធ** (pure) នេះមានន័យថាមុន (a priori) ដែលផ្ទុយនឹងក្រោយ (a posteriori)។ មុន (a priori) មានន័យថាស្ថិតនៅក្នុងចិត្តមុនបទពិសោធទៅទៀត។ ដូច្នេះ **ការរិះគន់វិចារណញ្ញាណសុទ្ធ** មានគោលដៅពិនិត្យមើលទ្រឹស្ដីដោយខ្លួនឯងមុនបទពិសោធ។

**គោលបំណង ៖** សៀវភៅ **ការរិះគន់វិចារណញ្ញាណសុទ្ធ** មានគោលដៅឆ្លើយនឹងសំណួរថា៖ «តើជាទូទៅអ្វីទៅវិទ្យាសាស្ត្រជាអ្វី? (Comment la science est-elle en general possible?)»។ នៅជំនាន់នោះវិទ្យាសាស្ត្រមានត្រឹមគណិតវិទ្យា និងរូបវិទ្យាប៉ុណ្ណោះ ហើយ**កង់ត៍**មានបំណងស្រាវជ្រាវរកមូលដ្ឋានគ្រឹះ ដើម្បីឱ្យការវិនិច្ឆ័យគំនិត(jugement de la pensée) រូបវិទ្យាមានការទទួលស្គាល់ជាទូទៅ និងមានភាពជឿជាក់ដូចគណិតវិទ្យាដែរ។ នេះគឺជាចំណុចចាប់ផ្ដើមនៃទស្សនវិជ្ជារបស់**កង់ត៍**។ នៅសម័យនោះ គណិតវិទ្យាត្រូវបានគេទទួលស្គាល់ថា ជាវិទ្យាសាស្ត្រសុទ្ធ(une science pure) មុនបទពិសោធ(a priori)។ **កង់ត៍** បានច្រានចោលទ្រឹស្ដី**ហេតុផល** (la causalité) របស់ **ហ្វូម** ដែលឈរលើមូលដ្ឋាននៃទម្លាប់(l'habitude)របស់មនុស្សដោយពោលថា **ហ្វូម**បានដាស់គាត់ឱ្យភ្ញាក់ឡើងពីសុបិន្តផ្នែកទ្រឹស្ដី(le sommeil dogmatique)។ គាត់បានអះអាងថា គណិត-វិទ្យាមានភាពជាក់លាក់(certitidue) និងឈរលើសក្ខីកម្ម (l'évidence)ដែលមិនធ្វើឱ្យមានការសង្ស័យអ្វីទាំងអស់។ ដូច្នេះ ដើម្បីចាត់ទុករបកគំហើយណាមួយ ជាតថភាពវិទ្យាសាស្ត្រ របកគំហើយនេះត្រូវមានមូលដ្ឋានចាំបាច់(nécessaire) និងសាកល(universel)។

**ការវិនិច្ឆ័យ ៖** (jugement) ការវិនិច្ឆ័យចែកចេញជាពីរក្រុមគឺ( ការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិនិច្ឆ័យ គឺជាប្រយោគដែលមានពុទ្ធិប្រធាន កិរិយាស័ព្ទ និងគុណនាម) ៖

ក្រុមទីមួយ (១) **ការវិនិច្ឆ័យមុនបទពិសោធ** *(jugement a priori)* ដែលឈរលើមូលដ្ឋាននៃគំនិតខ្លួនឯងដែលជាការវិនិច្ឆ័យចាំបាច់ និងសាកល ដូចជាគណិតវិទ្យាដែរ( គេអាចបង្ហាញថា ផលបូកនៃមុំទាំងបីនៃត្រីកោណ ស្មើនឹងផលបូកនៃមុំកែងពីរ) និង(២) **ការវិនិច្ឆ័យក្រោយបទពិសោធ** *(jugement a posteriori)* ដែលកើតឡើងតាមរយៈបទពិសោធដែលគ្មានលក្ខណៈចាំបាច់ និងសាកល។

ក្រុមទីពីរ (១) **ការវិនិច្ឆ័យបែបវិភាគ** *(jugement analytique)* នៅពេលដែលគុណនាមបង្ហាញពីលក្ខណៈនៃពុទ្ធិប្រធានដែលគេដឹងរួចហើយ( ដូចជា រាងកាយមនុស្សមានទំហំ) និង (២) **ការវិនិច្ឆ័យបែបសំយោគ** *(jugement synthétique)* នៅពេលដែលគុណនាមផ្តល់ព័ត៌មានបន្ថែមទៀតទៅនឹងទស្សនាទានដែលពាក់ព័ន្ធនឹងប្រធាន។ ម្យ៉ាងវិញទៀត ទាំងការវិនិច្ឆ័យមុនបទពិសោធ ទាំងការវិនិច្ឆ័យក្រោយបទពិសោធ អាចជាការវិនិច្ឆ័យបែបវិភាគ ឬបែបសំយោគ។ ដូច្នេះ **ការវិនិច្ឆ័យបែបវិភាគ** មិនផ្តល់ព័ត៌មានថ្មីឡើយ ហើយចំណែកឯការវិនិច្ឆ័យបែបសំយោគក្រោយបទពិសោធ *(jugement synthétique a posteriori)* មិនអាចជាការវិនិច្ឆ័យមួយដែលចាំបាច់ និងដែលសាកលបានឡើយ។ **កង់ត៍**បានធ្វើសេចក្តីសន្និដ្ឋានថា មានតែ **ការវិនិច្ឆ័យបែបសំយោគមុនបទពិសោធ** *(jugement synthétique a priori)* (ដែលបង្រៀនអ្វីថ្មីដល់យើង ហើយដែលចាំបាច់ និងសាកល) ទើបអាចចាត់ទុកថាមានលក្ខណៈវិទ្យាសាស្ត្រ។

**ប្រភពពុទ្ធិ** ៖ **កង់ត៍**យល់ឃើញថា ពុទ្ធិមានប្រភពចំនួនពីរ ៖ ឥន្ទ្រិយារម្មណ៍ *(la sensibilité)* ដែលមនុស្សទទួលបាននូវការចាប់អារម្មណ៍ និងវិមំសា ឬការវិនិច្ឆ័យ*(l'entendement)* ពោលគឺការគិតលើពុទ្ធិវត្ថុ។ តាមរយៈនេះ **កង់ត៍**ចង់រកឱ្យឃើញថា នៅក្នុងឥន្ទ្រិយារម្មណ៍ និងការយល់ក៏មានពុទ្ធិមុនបទពិសោធដែរ ដើម្បីឱ្យគេអាចពន្យល់ពីអ្វីទៅជា **ការវិនិច្ឆ័យ**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**បែបសំយោគ** *(jugement synthétique)* **មុនបទពិសោធ** *(a priori)* *ពោល គឺវិទ្យាសាស្ត្រ។ ក្នុងន័យនេះ ដើម្បីទទួលបាននូវពុទ្ធិ គេត្រូវស្រាវជ្រាវរក ប្រធានបទណាដែលមុនបទពិសោធ ក្នុងគោលដៅវិភាគរក* **ការវិនិច្ឆ័យ បែបសំយោគមុនបទពិសោធ។**

*សៀវភៅ* **ការរិះគន់វិចារណញ្ញាណសុទ្ធ** មានបីផ្នែក ៖ (១) **សោភ័ណភាពមុនបទពិសោធ** (២) **តក្កវិទ្យាមុនបទពិសោធ** និង (៣) **វិចារវិទ្យាមុនបទពិសោធ។**

១- **សោភ័ណភាពមុនបទពិសោធ** *(Esthétique transcendantale)* ៖ *ដើម្បីឱ្យឥន្ទ្រិយ៍(appareil perceptif) ទទួលអារម្មណ៍បាន ត្រូវតែ មានបាតុភូតកើតឡើង។ ដូច្នេះ ទំនួលអារម្មណ៍ដែលយើងទទួលបាន តាមរយៈឥន្ទ្រិយ៍ ដូចជាពណ៌ ក្លិន សំឡេង គឺជាបាតុភូតក្រោយបទពិសោធ តែស្ថិតនៅក្នុងលំដាប់កំណត់មួយដែលឥន្ទ្រិយ៍របស់យើងចាប់បាន។ យើង ចាត់ថ្នាក់ទំនួលអារម្មណ៍នេះនៅក្នុងលំហ និងនៅក្នុងពេលវេលា។ ដូច្នេះ លំហ និងពេលវេលា គឺជាលក្ខខណ្ឌចាំបាច់ និងសាកល សម្រាប់បទពិសោធ តាមឥន្ទ្រិយារម្មណ៍។ ដូច្នេះ លំហ និងពេលវេលា គឺជាទម្រង់មុនបទពិសោធ នៃទំនួលអារម្មណ៍។* **កង់ត៍***ចាត់ទុកពេលវេលាជាទម្រង់សុទ្ធនៃឥន្ទ្រិយ៍ខាង ក្នុង ហើយលំហ គឺជាទម្រង់សុទ្ធនៃឥន្ទ្រិយ៍ខាងក្រៅមុនបទពិសោធ។*

**កង់ត៍** *យល់ឃើញថា ការទទួលពុទ្ធិពីវត្ថុផ្សេងៗជាបាតុភូត ពោល គឺទៅតាមអ្វីដែលយើងមើលឃើញនិងជួបប្រទះក្នុងបទពិសោធ តាមអាការៈ ខាងក្រៅ(apparence) មិនមែនស្គាល់វត្ថុខ្លួនវានោះឡើយ។ ចំពោះ***កង់ត៍** *អាការៈខាងក្រៅ(apparence) ពោលគឺបាតុភូត គឺជាតថភាពពិត តែមិនមែន ជាវត្ថុខ្លួនវានោះឡើយ វាជាវត្ថុដែលឥន្ទ្រិយ៍យើងទទួលបាន។ ពិភពលោក ដែលយើងទទួលអារម្មណ៍ គឺជាពិភពលោកនៃបាតុភូត មិនមែនជាពិភពលោកនៃវត្ថុក្នុងខ្លួនឯងនោះទេ (le monde, tel qu'elle s'offre à nous, est un monde de phénomènes, non un monde de choses en soi)*។ ចំពោះ**កង់ត៍**

ភាវៈមានឯកពជ្យពីវិចារណញ្ញាណរបស់យើង តែយើងមិនអាចស្គាល់ភាវៈនេះបានទេ។ ដូច្នេះ **កង់ត៍**បានសិក្សាពីវេទយិតភាព(sensibilité) ឬឥន្ទ្រីយារម្មណ៍ ពោលគឺសមត្ថភាពរបស់យើងក្នុងការទទួលពុទ្ធិដែលទាមទារនូវទម្រង់មុនបទពិសោធ។

២- **តក្កវិជ្ជាមុនបទពិសោធ** (Logique transcendantale) ៖ ក្នុងដំណាក់កាលបន្ទាប់ **កង់ត៍**ស្រាវជ្រាវរកថា តើសមត្ថភាពរបស់យើងក្នុងការស្គាល់ត្រូវមានទម្រង់មុនបទពិសោធឬទេ? ប្រការនេះនឹងដើរតួនាទី នៅពេលដែលយើងគិតពីកម្មវត្ថុ។

**ការវិនិច្ឆ័យចាំចាច់ និងសាកល** (les jugements nécessaires et universels) ៖ វេទយិតភាពមានលក្ខណៈអកម្ម ចំណែកឯវិមំសា ការវិនិច្ឆ័យដើម្បីបង្កើតទស្សនាទាន (entendement) គឺជាអនុគមន៍សកម្មនៃស្មារតី។ វិមំសា ឬការវិនិច្ឆ័យ គឺជាដំណើរការសំយោគនៃការចាប់អារម្មណ៍ប្រកបដោយវេទយិតភាព (impression sensible)។ ដូច្នេះ នៅពេលដែលការយល់ធ្វើសំយោគនៃសហជញ្ញាណប្រកបដោយវេទយិតភាព តើវាត្រូវប្រើប្រាស់នូវទម្រង់មុនបទពិសោធអ្វី? **កង់ត៍**យល់ថាការវិនិច្ឆ័យ មួយបែបៗត្រូវឆ្លើយទៅនឹងទម្រង់នៃការគិតផ្សេងៗគ្នា ដោយសារតែទម្រង់សុទ្ធនៃវេទយិតភាពដូចជាលំហ និងពេលវេលាមិនមែនមកពីបទពិសោធទេ តែវាមានមុនបទពិសោធទៅទៀត ដែលជាពុទ្ធិសុទ្ធ។ **កង់ត៍**ហៅទម្រង់មុនបទពិសោធនៃគំនិត (les formes a priori de la pensée) ថាជាលក្ខណៈវិនិច្ឆ័យនៃការយល់ (les categories de l'entendement)។ គេមានលក្ខណៈវិនិច្ឆ័យច្រើន តែលក្ខណៈវិនិច្ឆ័យដែលសំខាន់ជាងគេ គឺហេតុផល (la causalité)។ ដូច្នេះ ទំនាក់ទំនងហេតុផល ដែលបង្កើតដោយទម្លាប់មិនគ្រប់គ្រាន់ទេ ដើម្បីឱ្យគេអាចចាត់ទុកពុទ្ធិនេះ ថាជាវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្រទាមទារ **ការវិនិច្ឆ័យនេះត្រូវតែចាំចាច់ និងសាកល**។ វិទ្យាសាស្ត្រត្រូវតែជាពុទ្ធិថ្មី ពោលគឺត្រូវតែជាសំយោគចាំបាច់ និងសាកល។ ដូច្នេះ វាត្រូវតែនៅមុន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បទពិសោធ(a priori)។

**ការបង្កើតពុទ្ធិ ៖** ដើម្បីឱ្យមានពុទ្ធិ ត្រូវមានឥន្ទ្រីយ៍ដែលតាមរយៈនោះ ទំនួលអារម្មណ៍(sensations)ត្រូវបានទទួលក្នុងលំហ និងនៅក្នុងពេលវេលា ដោយបង្កើតបានជាវេទយិតភាព(la sensibilité)មុនបទពិសោធ។ បន្ទាប់មកត្រូវមានការវិនិច្ឆ័យ(entendement)ដែលត្រូវសម្របសម្រួលទំនួលអារម្មណ៍នេះ ទៅតាមលក្ខណៈវិនិច្ឆ័យមុនបទពិសោធ។ ពោលគឺដើម្បីឱ្យមានពុទ្ធិទាមទារនូវ ទំនួលអារម្មណ៍ និងការវិនិច្ឆ័យព្រមៗគ្នា។ វិទ្យាសាស្ត្រមានប្រភពពីរខុសគ្នា ៖ (១) មកពីបទពិសោធ ដែលយើងទទួលបាន និង (២) មកពីទម្រង់មុនបទពិសោធនៃសមត្ថភាពក្នុងការទទួលពុទ្ធិ(la faculté de connaître) របស់យើង។ ដូច្នេះ ការគិតគឺជាការប្រមូលផ្តុំសមាសភាគទាំងពីរ ឱ្យទៅជាឯកតាតែមួយ។ កម្មវត្ថុនៃពុទ្ធិ គឺជាឯកតារួមនៃគំនិតដែលត្រូវឆ្លងកាត់វិចារណញ្ញាណ។ សរុបមក សមត្ថភាពក្នុងការទទួលពុទ្ធិមិនមែនជាបទពិសោធ ដូចពួកពិសោធនិយមបានអះអាង ហើយក៏មិនមែនជាភាពសុខដុមរវាងសមត្ថភាពទទួលពុទ្ធិ និងបទពិសោធ ដូច**ឡៃបនិត**បានអះអាងឡើយ។ ផ្ទុយទៅវិញ គឺសមត្ថភាពក្នុងការទទួលពុទ្ធិ និងទម្រង់មុនបទ-ពិសោធ ដែលរៀបចំ និងបង្កើតបទពិសោធដែលជារបកគំហើយបែបបដិវត្តន៍របស់**កង់ត៍**។ ក្នុងន័យនេះ រូបវិទ្យាមានលក្ខណៈដូចគណិតវិទ្យា ដោយសារមូលដ្ឋានចាំបាច់ និងសាកល នៅក្នុងគំនិតនៃអ្នកប្រាជ្ញ។

**វិទ្យាសាស្ត្រ ៖** វិទ្យាសាស្ត្រមានពិតមែន។ វិទ្យាសាស្ត្រ គឺជាការវិនិច្ឆ័យដែលត្រូវតែជាការចាំបាច់ និងសាកល មុនបទពិសោធ។ នៅក្នុងពុទ្ធិ គេត្រូវបែកឱ្យច្បាស់នូវពុទ្ធិប្រធាន(sujet) និងពុទ្ធិ វត្ថុ(objet)។ ទម្រង់ និងលក្ខណៈវិនិច្ឆ័យមុនបទពិសោធន៍ដែលនាំទៅរកពុទ្ធិ ធ្វើឱ្យយើងបានស្គាល់ត្រឹមតែបាតុភូតតែប៉ុណ្ណោះ តែមិនអាចឱ្យយើងរកឃើញវត្ថុក្នុងខ្លួន (la chose en soi)បានឡើយ។ វត្ថុក្នុងខ្លួន(la chose en soi) ឬles noumères នេះមិនអាចស្គាល់បានឡើយ។ ក្នុងន័យនេះ គេមិនអាចបញ្ឈប់ការស្រាវ-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជ្រាវវិទ្យាសាស្ត្របានឡើយ។ ការស្រាវជ្រាវវិទ្យាសាស្ត្រមិនមានទីបញ្ចប់ឡើយ ហើយត្រូវតែធ្វើឥតឈប់ឈរ។ យើងអាចស្គាល់ពីតថភាពត្រឹមតែអ្វីដែលយើងមើលឃើញ តាមរយៈលំហរ ពេលវេលា និងហេតុផល។

**៣- វិចារវិជ្ជាមុនបទពិសោធ** *(Dialectique transcendantale)* ៖ សមត្ថភាពទទួលពុទ្ធិកម្រិតទីបី គឺនៅពេលដែលគំនិតមុនបទពិសោធមានលក្ខណៈយ៉ាងពេញលេញ*(les Idées a priori maintiennent la visée de la totalité)*។ បន្ទាប់ពីបានពន្យល់ពីវេទយិតភាពដែលមានទម្រង់មុនបទពិសោធ និងការយល់ **កង់ត៍**ចាប់ផ្តើមពន្យល់ពីគំនិតទាំងបីនៃវិចារណញ្ញាណ ៖ គំនិតនៃអាត្ម័ន( បាតុភូតខាងក្នុងរួម) គំនិតនៃពិភពលោក( បាតុភូតខាងក្រៅរួម) និងគំនិតនៃអាទិទេព( បាតុភូតរួមនៃតថភាព និងអ្វីដែលអាចមាន )។

**គំនិតនៃអាត្ម័ន** *(l'Idée de l'âme)* ៖ អាត្ម័ន គឺជាគំនិត ហើយក៏មិនមែនជាវត្ថុដែរ ថ្វីត្បិតតែមានទស្សនវិទូខ្លះ ដូចជា**ឡាត់ុខ**បានអះអាងថាបានបង្ហាញថា អាត្ម័ននេះមានភាពអមតៈ។ នេះគឺគ្រាន់តែជាការស្រមើ-ស្រមៃប៉ុណ្ណោះ។ អាត្ម័ន គឺជាបាតុភូតខាងក្នុងរួម។

**គំនិតនៃពិភពលោក** *(l'Idée du monde)* ៖ ពិភពលោក គឺជាបាតុភូតខាងក្រៅរួមដែលយើងមិនដែលជួបក្នុងបទពិសោធរួម។ អ្វីដែលយើងជួប គឺជាផ្នែកខ្លះប៉ុណ្ណោះនៃពិភពលោក។ ជាការពិត យើងអាចទទួលបាននូវពុទ្ធិវិទ្យាសាស្ត្រចាំបាច់ និងសាកល ក្នុងពិភពលោក និងក្នុងចក្រ-វាល តែមិនមែនក្នុងចក្រវាលទាំងអស់ទេ ពីព្រោះវាហួសពីសមត្ថភាពរបស់យើងក្នុងការទទួលពុទ្ធិ។

**គំនិតនៃអាទិទេព** *(l'Idée de Dieu)* ៖ ចំពោះ**កង់ត៍** អាទិទេព គឺជាគំនិត។ យើងមិនអាចបង្ហាញពីអត្ថិភាពនៃអាទិទេព ហើយក៏មិនអាចបដិសេធថាគ្មានអាទិទេពបានដែរ។ នៅពេលដែល**កង់ត៍**និយាយថា គាត់មិនអាចស្គាល់ ឬបង្ហាញនូវអត្ថិភាពនៃអាទិទេពបាន គាត់ក៏មិនបានបដិសេធថាគ្មានអាទិទេពដែរ។ ត្រង់កន្លែងនេះ **កង់ត៍**បាននិយាយថា ដោយសារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែពុទ្ធិមានកម្រិត យើងត្រូវតែជឿថាមានអាទិទេពពិតមែន (Il me fallait limier le savoir pour faire place à la croyance)។

សរុបមក ស្នាដៃទីមួយរបស់**កង់ត៍** គឺឆ្លើយទៅនឹងសំណួរ «តើខ្ញុំអាចទទួលពុទ្ធិបានយ៉ាងដូចម្ដេច?»។ ការរៀនសូត្រពីបាតុភូត ឬការទទួលពុទ្ធិ គឺជាដំណើរការគ្មានទីបញ្ចប់។ ខ្ញុំអាចដឹងថា ខ្ញុំអាចដឹងបានត្រឹមតែបាតុភូតប៉ុណ្ណោះ ដូច្នេះ វិទ្យាសាស្ត្រមានព្រំដែនកំណត់។

**ខ- ការរិះគន់វិចារណញ្ញាណអនុវត្ត** (Critique de la raison pratique)

វិចារណញ្ញាណអនុវត្ត គឺវិចារណញ្ញាណដែលមានសកម្មភាព (l'action) ៖ ការសម្រេចចិត្ត ជម្រើស អាកប្បកិរិយា។ វិចារណញ្ញាណអនុវត្ត គឺវិចារណញ្ញាណដែលបានសម្រេច ដើម្បីមានសកម្មភាព ដូចជាអាកប្បកិរិយាសីលធម៌ ពោលគឺវិចារណញ្ញាណត្រូវចោទសួរថា តើខ្ញុំមានការកិច្ចអ្វីខ្លះ? តើខ្ញុំមានកាតព្វកិច្ចសីលធម៌អ្វីខ្លះត្រូវធ្វើ? វិចារណញ្ញាណនេះពិនិត្យទិតៀនខ្លួនឯង ដើម្បីរកន័យ សារៈសំខាន់ លទ្ធភាព និងព្រំដែនរបស់វា។ **ការរិះគន់វិចារណញ្ញាណអនុវត្ត** មានន័យថា ការពិនិត្យមើលនូវវិចារណញ្ញាណដែលជាប្រទីបបំភ្លឺសីលធម៌នៃជីវិតជាក់ស្ដែង នៅពេលមុនបទពិសោធ។ គោលដៅនៃសៀវភៅនេះ គឺដើម្បីស្វែងយល់ពីលក្ខខណ្ឌនៃការសម្រេចចិត្តប្រកបដោយ សីលធម៌។

**តម្លៃសីលធម៌** (La valeur morale) ៖ តម្លៃសីលធម៌ គឺជាតម្លៃមុនបទពិសោធ និងមិនចំណុះឱ្យលទ្ធផលនៃសកម្មភាពពីខាងក្រៅ ឬបរិការណ៍កំណត់ណាមួយឡើយ ពោលគឺជាតម្លៃក្នុងខ្លួនឯង (la valeur en soi)។ មានមនុស្សខ្លះខិតខំបំពេញតាមសកម្មភាពខាងក្រៅមួយចំនួន ដើម្បីបង្ហាញពីសកម្មភាពសីលធម៌។ នៅក្នុងសង្គមមនុស្ស គេតែងតែយល់ឃើញថា សកម្មភាពមួយចំនួនក្នុងសង្គម គឺជាតម្លៃសីលធម៌ ដោយមិនគិតថាសកម្ម-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពទាំងនោះផ្ទុយពីចំណង់ចំណូលចិត្តរបស់មនុស្ស ហើយធ្វើឱ្យប៉ះពាល់ដល់សេរីភាពរបស់មនុស្សក៏ដោយ។ **កង់ត៍** យល់ឃើញថា សកម្មភាពមួយមានតម្លៃសីលធម៌ ដោយសារតែការសម្រេចចិត្តគោរពតាមច្បាប់សីលធម៌ ដោយមិនគិតពីគោលដៅ ឬបច្ច័យខាងក្រៅ ដូចជាបំណងក្នុងការទទួលបាននូវការគោរពពីប្រជាពលរដ្ឋឡើយ។ ដូច្នេះ សកម្មភាពដែលជាកាតព្វកិច្ចដែលត្រូវធ្វើ(je dois) គឺជាមូលហេតុតែមួយគត់នៃតម្លៃសីលធម៌ ពោលគឺការទាមទារដោយគ្មានសំណង(une exigence nue)។

**សុឆន្ទៈ** (La bonne volonté) ៖ សុឆន្ទៈ គឺជាទឹកចិត្តរបស់មនុស្សពីខាងក្នុង ដើម្បីមានសង្គតិភាពជាមួយតម្លៃសីលធម៌។ ផ្ទុយទៅវិញ ចំណង់-ចំណូលចិត្តរបស់យើងទាញយើងឱ្យទៅធ្វើអ្វីផ្សេង ដោយសារចំណង់ចំណូលចិត្តនេះវាចំណុះឱ្យតថភាពខាងក្រៅ។ ដូច្នេះ **សុឆន្ទៈ**ស្ថិតនៅចន្លោះតម្លៃសីលធម៌ និងចំណង់ចំណូលចិត្តរបស់មនុស្ស ដោយសារតែមានឆន្ទៈចង់ធ្វើតាមតម្លៃសីលធម៌ ដែល**កង់ត៍**ហៅថា ស្វ័យភាពនៃឆន្ទៈ(autonomie de la volonté) - ឆន្ទៈដែលគោរពច្បាប់ដោយខ្លួនឯង ពោលគឺការគោរពតាមកាតព្វកិច្ច (l'obéissance au devoir-je dois)។

**សេរីភាព** (La liberté) ៖ ចំពោះ**កង់ត៍** ការគោរពកាតព្វកិច្ចមិនមែនជាកំហិតទៅលើសេរីភាពទេ តែគឺជាសេរីភាពខ្លួនឯងតែម្តង។ សេរីភាពគឺជាស្វ័យភាពនៃឆន្ទៈរបស់យើង ដែលមិនធ្វើឱ្យមនុស្សក្លាយទៅជាសម្ភារៈ ឬខ្ញុំបម្រើនៃមនោសញ្ចេតនា និងចំណង់ចំណូលចិត្តរបស់យើង ហើយតាមរយៈសុឆន្ទៈអនុញ្ញាតឱ្យមនុស្សគោរពកាតព្វកិច្ចរបស់ខ្លួន។ អ្នកខ្លះយល់ថា សេរីភាពគឺការធ្វើតាមអារម្មណ៍ (humeurs) មនោសញ្ចេតនាពិតៗ (les sentiments spontanés) របស់មនុស្ស។ ក៏ប៉ុន្តែ **កង់ត៍**យល់ឃើញថា អារម្មណ៍ និងមនោសញ្ចេតនាគ្រាន់តែជាបាតុភូត ដែលចំណុះឱ្យពិភពខាងក្រៅ និងច្បាប់ហេតុផល(la loi de causalité)ប៉ុណ្ណោះ។ បើធ្វើតាមអារម្មណ៍ និងមនោសញ្ចេតនាទាំងនេះមានន័យថាគោរពតាមច្បាប់លោកិយដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្ទុយនឹងសេរីភាព ដែលចេញពីឆន្ទៈពីខាងក្នុងខ្លួនរបស់មនុស្ស។ នេះគឺជាស្វ័យភាពនៃឆន្ទៈ។ ឧទាហរណ៍ **សូក្រាត**មិនព្រមរត់ហើយសុខចិត្តស្លាប់ ដោយសារតែលោកចង់ឱ្យការស្លាប់នេះមានតម្លៃសីលធម៌។ **សូក្រាត**សុខចិត្តគោរពតាមច្បាប់ ពោលគឺគោរពតាមច្បាប់ស្វ័យភាពនៃកាតព្វកិច្ច។ ដូច្នេះ ស្វ័យភាពនៃឆន្ទៈនេះមានតម្លៃដាច់ខាត។

**បទបញ្ជានៃវិចារណញ្ញាណអនុវត្ត** *(l'impératif de la raison pratique)* ៖ **កង់**ចែកបទបញ្ជានេះជាពីរប្រភេទ ៖ (១) **បទបញ្ជាដាច់ខាត** *(l'impératif catégorique)* ៖ គឺជាបទបញ្ជាសុទ្ធ(មុនបទពិសោធ) នៃច្បាប់សីលធម៌ ពោលគឺខ្ញុំមានកាតព្វកិច្ចធ្វើ ដោយសារតែនេះជាកាតព្វកិច្ចរបស់ខ្ញុំ*(Je dois, car je dois)*។ សកម្មភាពសីលធម៌មិនគិតពីបច្ច័យនៃសកម្មភាពរបស់ខ្លួនឡើយ ហើយការសម្រេចចិត្តនេះគិតត្រឹមតែបច្ច័យដែលមានលក្ខណៈសីលធម៌ប៉ុណ្ណោះ ហើយសកម្មភាពនេះមិនចំណុះឱ្យលក្ខខណ្ឌអ្វីទាំងអស់*(pur, a priori ou inconditionnel)*។ (២) **បទបញ្ជាសម្មតិកម្ម** *(l'impératif hypothétique)* ៖ គឺជាបទបញ្ជាដែលការសម្រេចចិត្តត្រូវធ្វើដោយគិតពីបទពិសោធ ហើយជាបទបញ្ជាដែលគ្មានស្វ័យភាពដោយឈរលើមូលដ្ឋាននៃបទពិសោធ ក្នុងពេលវេលា និងក្នុងលំហ។ ការសម្រេចចិត្តនេះធ្វើឡើងដោយមានលក្ខខណ្ឌ*(conditionnel)* ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងណាមួយ។

**សីលធម៌** *(La moralité)* ៖ ចែកចេញជា៖ (១) ទម្រង់ *(la forme)* គឺជាច្បាប់ ដែលជាកាតព្វកិច្ចដាច់ខាត *(l'absolue nécessité du "je dois")* ពោលគឺមានភាពចាំបាច់ និងសាកល និង (២) សារធាតុ *(la substance)* គឺជាលទ្ធផល ឬជាបច្ច័យជាក់ស្តែងនៃសកម្មភាព ដូចជាខ្លឹមសារនៃគោលការណ៍សីលធម៌ដែលប្រែប្រួលទៅតាមប្រទេស និងទៅតាមពេលវេលា។

សរុបមក ស្នាដៃទីពីររបស់**កង់** គឺឆ្លើយទៅនឹងសំណួរ «តើខ្ញុំត្រូវធ្វើអ្វី?»។ ក្នុងស្ថានភាពជាក់ស្តែង ខ្ញុំត្រូវពិចារណាពីបទបញ្ជាដាច់ខាត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលមិនប្រាសចាកពីសេរីភាពរបស់ខ្ញុំឡើយ ដែលជាកាតព្វកិច្ចរបស់ខ្ញុំ ដែលជាអំពើប្រកបដោយសីលធម៌នៃសកម្មភាពរបស់ខ្ញុំ។ ការសម្រេចចិត្តរបស់ខ្ញុំធ្វើឡើងដោយមិនគិតពីបច្ច័យនៃសកម្មភាពរបស់ខ្ញុំឡើយ។

**គ- ការរិះគន់ការវិនិច្ឆ័យ** *(Critique du jugement)*

ការវិនិច្ឆ័យ(jugement)នៅក្នុងតក្កវិទ្យាគឺជាទស្សនាទានដែលត្រឹមត្រូវ។ **ការរិះគន់ការវិនិច្ឆ័យ** ពិនិត្យមើលវិចារណញ្ញាណដែលអាចផ្ដល់ការវិនិច្ឆ័យ ៖ តើមូលហេតុអ្វីបានជាយើងមានសមត្ថភាពធ្វើការវិនិច្ឆ័យ? *(la capacité d'énoncer des jugements)* ដែលជា **គោលដៅចុងក្រោយ** *(la finalité)*។ ចំពោះ **ឡៃបនិត** គំនិតទាំងអស់របស់លោកមានគោលដៅចុងក្រោយ និងត្រូវចំណុះឱ្យភាពសុខដុមពីដើមទី។ **កង់ត៍**ក៏ទទួលរងឥទ្ធិពលពីគំនិតនេះដែរ។ សៀវភៅចុងក្រោយ **ការរិះគន់ការវិនិច្ឆ័យ** របស់**កង់ត៍** ពិភាក្សាទម្រង់ផ្សេងៗនៃគោលដៅចុងក្រោយនេះ។ រាល់ការវិនិច្ឆ័យត្រូវមានគោលដៅ ពោលគឺចង់ឱ្យគោលដៅនេះជាការពិត។ នៅពេលដែលយើងបង្កើតគោលការណ៍សីលធម៌ ឬច្បាប់វិទ្យាសាស្ត្រណាមួយ យើងចង់ឱ្យការវិនិច្ឆ័យនេះមានន័យច្បាស់លាស់ ពោលគឺជាសមត្ថភាពរបស់យើងក្នុងការធ្វើការវិនិច្ឆ័យ ដែលជាគោលដៅចុងក្រោយ។

បន្ទាប់ពីត្រិះរិះពិចារណាពីការៈមានជីវិតដែលជាសាក្សីនៃជីវិត **កង់ត៍** បានសិក្សាពីសាក្សីនៃសោភ័ណភាព។ សោភ័ណភាពមានទម្រង់ពីរបែប ៖ (១) មានសោភ័ណភាពដែលយើងជួបនៅក្នុងធម្មជាតិ និង (២) សោភ័ណ-ភាពដែលយើងជួបនៅក្នុងស្នាដៃមនុស្ស ក្នុងសិល្បៈជាដើម។ ក្នុងករណីទាំងពីរនេះ យើងឃើញក្នុងសោភ័ណភាពនេះនូវគោលដៅចុងក្រោយដែលមិនបានកំណត់ជាមុន មិនចំណុះឱ្យអ្វីទាំងអស់ តែមានគោលដៅចុងក្រោយដោយសេរី *(une finalité libre)* ដែលធ្វើឱ្យយើងទទួលអារម្មណ៍គ្មានទីបញ្ចប់ និងជាអនន្ត។ នេះហើយ គឺជាគោលដៅចម្បងនៃស្នាដៃចុង



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*ក្រោយរបស់* **កង់ត៍** *គឺដើម្បីឆ្លើយទៅនឹងសំណួរថា៖«តើមានអ្វីដែលឱ្យយើងអាចសង្ឃឹមបាន?»*

*សរុបមក ស្ពានដែទីបីរបស់* **កង់ត៍** *គឺឆ្លើយទៅនឹងសំណួរ «តើខ្ញុំអាចសង្ឃឹមលើអ្វីបាន?»។ ខ្ញុំអាចសង្ឃឹមបានថា ពុទ្ធិរបស់ខ្ញុំពីបាតុភូតនានាមិនអាចហាមឃាត់ខ្ញុំមិនឱ្យសង្ឃឹមបានឡើយ។ ជាចុងក្រោយ ខ្ញុំសង្ឃឹមលើន័យ។ ការសង្ឃឹមដែលមិនមែនឈរលើមូលដ្ឋាននៃពុទ្ធិដែលយើងមិនអាចបង្ហាញ ហើយទន្ទឹមនឹងនេះមិនអាចបដិសេធបាន។ នេះគឺជាជំនឿ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្គូតលៀប ហ្វិកត៍
## (១៧៦២-១៨១៤)

**ហ្គូតលៀប ហ្វិកត៍** *(Johann Gottlieb Fichte) កើតនៅ Rammenau សាក់សូនី អាឡឺម៉ង់ ក្នុងឆ្នាំ១៧៦២។ លោករៀននៅក្នុងសាកលវិទ្យាល័យ Jena និង Leipzig។ ដោយខ្វះខាតថវិកា លោកត្រូវបង្ខំចិត្តឈប់រៀននៅឆ្នាំ ១៧៨៤ ដោយមិនបានទទួលសញ្ញាបត្រអ្វីទាំងអស់។ លោកធ្វើការជាគ្រូបង្រៀនតាមផ្ទះនៅទីក្រុង Zurich។ វាសនារបស់លោកបានត្រូវកែប្រែ បន្ទាប់ពីបានអានស្នាដៃរបស់* **កង់ត៍** *ក្នុងឆ្នាំ១៧៩០ ហើយ ក៏ចាប់ផ្ដើម ស្វែងរកជួបជាមួយទស្សនវិទូ***កង់ត៍**។ **ហ្វិកត៍** *បានធ្វើដំណើរទៅជួប* **កង់ត៍** *នៅ Königsberg នៅក្នុងឆ្នាំ១៧៩១ តែ* **កង់ត៍** *ហាក់បីដូចជាមិនសម្ដែងការសាទរអ្វីសោះដែលជាហេតុធ្វើឱ្យ* **ហ្វិកត៍** *ខកចិត្តយ៉ាងខ្លាំង។*

**ស្នាដៃសំខាន់** *៖ ដើម្បីបង្ហាញថាលោកមានចំណេះដឹងខាងផ្នែកទស្សនវិជ្ជានៃការទិតៀនរបស់***កង់ត៍ ហ្វិកត៍***បានសរសេរ និងបោះពុម្ពយ៉ាងប្រញាប់ប្រញាល់ក្នុងឆ្នាំ១៧៩២ សៀវភៅស្ដីពីទំនាក់ទំនងរវាងទស្សនវិជ្ជានៃការទិតៀន ជាមួយនឹងបញ្ហា វិវរណៈ ដោយអាទិទេព (revelation) ដែល* **កង់ត៍** *មិនទាន់ទាំងបានសរសេរផង។ ស្នាដៃនេះមានចំណងជើងថា «***ការសាកល្បងិតៀន វិវរណៈ***» ដែលអ្នកខ្លះច្រឡំស្មានថាជាស្នាដៃរបស់ផ្ទាល់របស់* **កង់ត៍**។ *បន្ទាប់ពី***កង់ត៍** *គាំទ្រជាសាធារណៈស្នាដៃនេះ កេរ្តិ៍ឈ្មោះរបស់***ហ្វិកត៍** *ចាប់ផ្ដើមរីកសុះសាយក្នុងមជ្ឈដ្ឋានទស្សនវិជ្ជា។* **ហ្វិកត៍** *ត្រូវបានតែងតាំងជាប្រធានដេប៉ាតឺម៉ង់ទស្សនវិជ្ជា នៅសាកលវិទ្យាល័យ Iena ពីឆ្នាំ១៧៩៤ដល់ឆ្នាំ១៧៩៩។ នៅក្នុងឆ្នាំ ១៧៩៤ លោកបានបោះពុម្ពការសិក្សាកថាមួយក្រោមចំណងជើងថា «***មូលដ្ឋាននៃវិទ្យាសាស្ត្រស្ដីពីពុទ្ធិ** *(Foundations of the Science of Knowledge)» ដើម្បីទុក*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាសៀវភៅឱ្យនិស្សិតរៀន។ ទស្សនវិជ្ជារបស់**ហ៊្វិកត៍** បានក្លាយជាទស្សនវិជ្ជាមនោនិយមអាឡឺម៉ង់ នៅក្នុងដំណាក់កាលចន្លោះ**កង់ត៍** និង **ហេហ្គែល**។

**វិជ្ជាសាស្ត្រស្តីពីពុទ្ធិ** ៖ «វិទ្យាសាស្ត្រស្ដីពីពុទ្ធិ» ឬជាវិទ្យាសាស្ត្រនៃវិទ្យាសាស្ត្រ គឺជាប្រព័ន្ធទស្សនវិជ្ជារបស់ **ហ៊្វិកត៍** ដែលជាអភិប្រាយរបស់គាត់ស្ដីពីវិធីសាស្ត្រ។ ថ្វីត្បិតតែទស្សនវិជ្ជាគឺជាវិទ្យាសាស្ត្រ តែខ្លឹមសាររបស់វាខុសគ្នា ពីប្រព័ន្ធទស្សនវិជ្ជាមួយ ទៅទស្សនវិជ្ជាមួយទៀត។ ក្នុងន័យនេះ **ហ៊្វិកត៍** មានបំណងបង្កើត «វិទ្យាសាស្ត្រស្ដីពីពុទ្ធិ(transcendental philosophy)» ឬវិទ្យាសាស្ត្រនៃវិទ្យាសាស្ត្រ ដើម្បីកំណត់ឱ្យច្បាស់ពីលក្ខណសម្បត្តិនៃទស្សនវិជ្ជាជាវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្រត្រូវមានមូលដ្ឋានរឹងមាំ និងត្រូវរៀបចំជាប្រព័ន្ធ។ សំខាន់បំផុតវិទ្យាសាស្ត្រត្រូវមានមូលដ្ឋានដាច់ខាត ដែលឈរលើខ្លួនឯង។ វិទ្យាសាស្ត្រត្រូវមានទាំងខ្លឹមសារ និងទម្រង់ ពោលគឺកម្មវត្ថុនៃពុទ្ធិ និងពុទ្ធិស្ដីពីកម្មវត្ថុ។ ពុទ្ធិដាច់ខាត គឺជាពុទ្ធិនៃពុទ្ធិ។ ក្នុងន័យនេះ ចំពោះ**ហ៊្វិកត៍** ពុទ្ធិពីខ្លួនឯង(la connaissance du soi) ស្ថិតនៅចំកំពូលនៃវិទ្យាសាស្ត្រ។ **ហ៊្វិកត៍** ស្វែងរកប្រភពនៃភាវៈដែលជាមិនមែនខ្ញុំ (non-moi) ដើម្បីបង្ហាញពីពុទ្ធិអំពីសមត្ថភាពក្នុងស្គាល់ពីកម្មវត្ថុដែលអាចមានពីមុនមក និងលក្ខខណ្ឌដែលអាចឱ្យមានពុទ្ធិ(transcendental self)។ ប្រការនេះបង្ហាញ ពីគុណភាពនៃវិទ្យាសាស្ត្រនៃពិសោធន៍ និងនៃពិសោធន៍ខ្លួនឯង។ ពោលគឺជាសំណួរដែល**កង់ត៍**បានសួរថា «តើមានលក្ខខណ្ឌអ្វីខ្លះសម្រាប់វិទ្យាសាស្ត្រ? តើមានលក្ខខណ្ឌអ្វីខ្លះសម្រាប់ពិសោធន៍?»។ ត្រង់នេះ **ហ៊្វិកត៍** ចង់ឱ្យគេឯងបានឃើញពីពុទ្ធិនៃការពិត និងប្រភពរបស់វា។ ដើម្បីបង្កើតមូលដ្ឋានដ៏រឹងមាំសម្រាប់ពុទ្ធិ **ហ៊្វិកត៍**កំណត់គោលការណ៍បួន ៖

ទីមួយ- តើធ្វើដូចម្ដេចបានដឹងថា វិទ្យាសាស្ត្រស្ដីពីពុទ្ធិគ្របដណ្ដប់ពុទ្ធិរបស់មនុស្សទាំងអស់ រួមទាំងពុទ្ធិដែលនឹងរកឃើញនៅពេលខាងមុខ?

ទីពីរ- មូលដ្ឋានទីមួយៗនៃវិទ្យាសាស្ត្រស្ដីពីពុទ្ធិគឺជាផ្នែកមួយនៃវិទ្យាសាស្ត្រនៃពុទ្ធិ។ តើធ្វើដូចម្ដេចទើបអាចកំណត់បានថា វិទ្យាសាស្ត្រស្ដី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីពុទ្ធិខុសពីវិទ្យាសាស្ត្រដូចម្ដេច?

ទីបី- វិទ្យាសាស្ត្រស្ដីពីពុទ្ធិអះអាងពីការរៀបចំទម្រង់ សម្រាប់វិទ្យា-សាស្ត្រទាំងអស់។ ដូច្នេះ តើវិទ្យាសាស្ត្រស្ដីពីពុទ្ធិខុសពីតក្កវិទ្យាយ៉ាងដូចម្ដេច ដោយសារតែតក្កវិទ្យាក៏អះអាងដូចគ្នា?

ទីបួន- វិទ្យាសាស្ត្រស្ដីពីពុទ្ធិគឺជាវិទ្យាសាស្ត្រ។ ដូច្នេះ វាមានកម្មវត្ថុ ហើយកម្មវត្ថុនេះគឺជាប្រព័ន្ធពុទ្ធិកម្រិតខ្ពស់។ តើប្រព័ន្ធនេះវាដំណើរការដូចម្ដេចចំពោះកម្មវត្ថុ?

**មូលដ្ឋាននៃទស្សនវិជ្ជា** ៖ ទស្សនវិជ្ជាដែលជាវិទ្យាសាស្ត្រនៃវិទ្យា-សាស្ត្រត្រូវតែជាពុទ្ធិដាច់ខាត និងមានមូលដ្ឋានសម្រាប់វិទ្យាសាស្ត្រទាំងអស់។ ក៏ប៉ុន្តែ អំណះអំណាងនេះវាខុសពីពិសោធន៍ថា ពុទ្ធិមិនអាចដាច់ខាតបាន ដោយសារតែងតែមានពុទ្ធិថ្មីជានិច្ច របកគំហើញថ្មី។ ពុទ្ធិដាច់ខាតនេះមិនមែនមានន័យថាចុងបញ្ចប់នៃពុទ្ធិ(the end of knowledge)ឡើយ។ វាមានន័យថា ពុទ្ធិនេះបើកទូលាយ បង្កើតឱ្យមានពុទ្ធិថ្មីមិនចេះចប់។ ពុទ្ធិដាច់ខាត គឺពុទ្ធិដែលយល់ពីខ្លួនឯង យល់ពីភាវៈ មនុស្ស ពិភពលោក និងសម្បជញ្ញៈ(immanence)។ **ហ្វិកត៍** លើកឡើងពីវិទ្យាសាស្ត្រកំពូលដែលត្រូវក្ដោបក្ដាប់កម្មវត្ថុជាច្រើន លើសពីតក្កវិទ្យា និងចិត្តវិទ្យាទៅទៀត។ ក្នុងន័យនេះ វិទ្យាសាស្ត្រស្ដីពីពុទ្ធិ គឺជាវិទ្យាសាស្ត្រនៃវិទ្យាសាស្ត្រដែលសាកលជាប្រព័ន្ធ និងដែលមានលក្ខណៈសព្វឯកវិធី (deduction)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្វ្រីឌ្រីច ស្ហេលលីង
## (១៧៧៥-១៨៥៤)

**ហ្វ្រីឌ្រីច ស្ហេលលីង** *(Friedrich Schelling)* គឺជាទស្សនវិទូមួយក្នុងចំណោមទស្សនវិទូមនោនិយមអាឡឺម៉ង់ ដូច **ហ្វិកតេ** និង **ហេហ្គែល** ដែរ។ កើតនៅ Leonberg រដ្ឋ Baden-Würtenberg អាឡឺម៉ង់ ក្នុងឆ្នាំ១៧៧៥។ បន្ទាប់ពីចប់សាលាលោកចូលរៀននៅក្នុងមហាវិទ្យាល័យសាសនាក្នុងសាកលវិទ្យាល័យ Tübingen ក្នុងឆ្នាំ១៧៩០ នៅពេលដែលលោកមានអាយុ ១៥ឆ្នាំនៅឡើយ។ នៅទីនោះលោកបានជួបជាមួយ**ហេហ្គែល** ហើយក្លាយជាមិត្តភក្តិ។ **ស្ហេលលីង** សិក្សាទស្សនវិជ្ជា សាសនាវិទ្យា និងអក្សរសាស្ត្របុរាណ ហើយទទួលសញ្ញាបត្រថ្នាក់បណ្ឌិតនៅឆ្នាំ១៧៩២។

នៅឆ្នាំ១៧៩៥-១៧៩៨ លោកបានរៀនបន្តខាងផ្នែកគណិតវិជ្ជា និងវិទ្យាសាស្ត្រធម្មជាតិនៅសាកលវិទ្យាល័យ Leipzig ហើយលោកធ្លៀតធ្វើការជាគ្រូបង្រៀនតាមផ្ទះគ្រួសារអ្នកមាន។ លោកបានទៅស្តាប់ **ហ្វិកតេ** បង្រៀននៅសាកលវិទ្យាល័យអីយ៉េណាដែរ តែមិនសូវពេញចិត្តជាមួយនឹងទស្សនវិជ្ជារបស់**ហ្វិកតេ** ប៉ុន្មានទេ។ ដោយមានការគាំទ្រយ៉ាងខ្លាំងពីកវីដ៏ល្បី Goethe លោកត្រូវបានតែងតាំងក្នុងអាយុ២៣ឆ្នាំជាសាស្ត្រាចារ្យរងនៅសាកលវិទ្យាល័យអីយ៉េណា។ នៅឆ្នាំ១៨០៨ លោកត្រូវបានតែងតាំងជាអគ្គលេខាធិការនៃបណ្ឌិត្យសភាវិចិត្រសិល្បៈ ហើយនៅឆ្នាំ១៨៤១ លោកត្រូវបានតែងតាំងជាបណ្ឌិតសភាចារ្យនៃបណ្ឌិត្យសភាវិទ្យាសាស្ត្រ Prussia។

**ស្នាដៃសំខាន់ ៖ ស្ហេលលីង**បានខិតខំផ្សាភ្ជាប់ទស្សនវិជ្ជារបស់**ស្ពីណូហ្សា** ស្តីពីធម្មជាតិ ទៅនឹងមនោវិជ្ជាជវភាពរបស់ **ហ្វិកតេ**។ លោកសរសេរ និងបោះពុម្ពស្នាដៃលើកទីមួយរបស់លោកក្នុងឆ្នាំ១៧៩៧ សៀវភៅស្តីពីទស្សនវិជ្ជាធម្មជាតិ(Des idées pour une philosophie de la nature)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ហើយនៅឆ្នាំ១៨០០ បានបោះពុម្ពផ្សាយស្នាដៃដ៏ល្បីល្បាញដែលមានចំណងជើងថា «***ប្រព័ន្ធមនោនិយមនៃទស្សនវិជ្ជាពុទ្ធិ*** (System des transzendentalen Idealismus)»។ លោកបានបង្កើតជាមួយ**ហេហ្គែល** នូវទស្សនាវដ្តីទិតៀនទស្សនវិជ្ជា។ នៅឆ្នាំ១៨០១ លោកបានបោះពុម្ពផ្សាយ «**អភិប្រាយប្រព័ន្ធទស្សនវិជ្ជារបស់ខ្ញុំ**»។ នៅក្នុងស្នាដៃនេះ លោកបានប្តូរទស្សនៈរបស់លោកយ៉ាងខ្លាំង។ លោកបានលើកឡើងពីគំនិតស្តីពីសមមូលដាច់ខាតរវាងមនោនិយម និងប្រាកដនិយមដោយបង្ហាញថាភាពខុសគ្នារវាងមនោនិយម និងប្រាកដនិយម រវាងពុទ្ធិប្រធាននិងពុទ្ធិវត្ថុ មានតែនៅក្នុងបាតុភូត និងករណីទោលទេ។ «នៅក្នុងខ្លួន» បញ្ញត្តិទាំងនេះមានសមមូលនឹងគ្នា។ លោកបានបោះពុម្ពផ្សាយនៅឆ្នាំ១៨០២ «**អភិប្រាយបន្តស្តីពីប្រព័ន្ធទស្សនវិជ្ជារបស់ខ្ញុំ**» នៅឆ្នាំ១៨០៤ «**ទស្សនវិជ្ជានិងសាសនា**» និង«**ការស្រាវជ្រាវទស្សនវិជ្ជាស្តីពីសារជាតិនៃសេរីភាពរបស់មនុស្ស**»។*

*ទស្សនវិជ្ជារបស់ **ស្សេលលីង** គឺជាទស្សនវិជ្ជាវើរវាយនិយម សោភ័ណនិយម ស្រមើស្រមៃ មិនវិចារណញ្ញាណនិយម និងអព្ភន្តរញ្ញាណ(intuitive)។ ទស្សនវិជ្ជារបស់ **ស្សេលលីង** មិនមែនឈរលើមូលដ្ឋាននៃវិចារណញ្ញាណជាមូលដ្ឋាននៃតថភាព ឬការយល់ដឹង( ដូច**កង់ត៍**) តែមានមូលដ្ឋានមកពីការស្រមើស្រមៃប្រកបដោយនវកម្ម (creative)។*

***ទស្សនវិជ្ជាធម្មជាតិ ៖ ស្សេលលីង** គូសបញ្ជាក់ថា ធម្មជាតិមិនមែនគ្រាន់តែជាកម្មវត្ថុ ឬបណ្តុំនៃកម្មវត្ថុប៉ុណ្ណោះទេ តែវាមានព្រលឹង។ ធម្មជាតិមិនមែនត្រឹមតែជា«ផលិតផល»ឡើយ តែវាជា«ផលិតភាព»។ ធម្មជាតិ គឺជាការឯកភាពជាដំបូងនៃខណៈផ្ទុយទាំងពីរ។ គេឃើញមានវត្តមាន«ផលិត-ភាព» ក្នុងផលិតផល តែវាមិនបាត់ក្នុងផលិតផលនេះទេ វាប្រេបាច់ចូលគ្នានិងបង្កើតផលិតផលឡើងវិញ។ សមមូល និងការប្រឆាំងគ្នារវាង«ផលិតផល» និង«ផលិតភាព» នាំឱ្យមានចលនាប្រឆាំងគ្នាផ្ទៃក្នុងនៃសកម្មភាព*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផលិត ហើយបង្កើតឱ្យដំណើរការធម្មជាតិមានជវភាពដែលបង្កើតឱ្យមានការសំយោគ ដែលជានាឱ្យមានប៉ូលទាំងពីរ និងបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់ការបំប្លែង(transformation)បន្តទៅទៀត។ នៅចុងបំផុតនៃដំណើរការនេះ នៅក្នុងធម្មជាតិ គេឃើញមានការប្រឆាំងគ្នារវាងពន្លឺ និងរូបធាតុ។ ពន្លឺ គឺជាគោលការណ៍មនោវិជ្ជា(Idéaliste) ទីមួយ ពោលគឺជា «អាត្ម័ន» ចំណែកឯរូបធាតុ គឺជា «ភាពប្រាកដនិយម(Réel)»។ ការភ្ជាប់គ្នារវាងពន្លឺ និងរូបធាតុ បង្កើតឱ្យមានដំណើរការប្រកបដោយជវភាពតាមរយៈកម្លាំងនៃទំនាញផែនដី។

**ទស្សនវិជ្ជាពុទ្ធិ** ៖ ទស្សនវិជ្ជាធម្មជាតិ គឺជាទស្សនវិជ្ជាមួយ ក្នុងចំណោមទស្សនវិជ្ជាសំខាន់ៗចំនួនពីរ។ ទស្សនវិជ្ជាធម្មជាតិចាប់ផ្ដើមពីពុទ្ធិវត្ថុ គឺធម្មជាតិ ដែលគេជួបប្រទះនៅក្នុងនោះនូវឧត្តមគតិ ឬមនោ ហើយរំកិលដល់ព្រំដែននៃអាត្ម័ន ហើយអាចឈានទៅហួសពីព្រំដែននេះថែមទៀត។ ដូច្នេះ ប្រសិនបើទស្សនវិជ្ជាធម្មជាតិឆ្លងពីធម្មជាតិ ទៅអាត្ម័ន ដូច្នេះវាត្រូវផ្លាស់ឈ្មោះពីទស្សនវិជ្ជាធម្មជាតិ ទៅទស្សនវិជ្ជាអាត្ម័ន ឬទស្សនវិជ្ជាមនោនិយម។ តែប្រព័ន្ធទស្សនវិជ្ជានេះ នៅតែជាទស្សនវិជ្ជាធម្មជាតិ។ ក៏ប៉ុន្តែ ចលនាទស្សនវិជ្ជាអាចចាប់ផ្ដើមមិនមែនតែពីពុទ្ធិវត្ថុ(objet)ប៉ុណ្ណោះទេ តែក៏អាចចាប់ផ្ដើមពីពុទ្ធិប្រធាន (sujet) ផងដែរ ក្នុងគោលដៅដកចេញពីចលនាទស្សនវិជ្ជានេះនូវកម្មវត្ថុ។មាគ៌ានេះគឺជាមាគ៌ានៃទស្សនវិជ្ជាពុទ្ធិ។ សច្ចធម៌ទីមួយនៃទស្សនវិជ្ជាពុទ្ធិ គឺសមីការ «ខ្ញុំ គឺជា ខ្ញុំ» ឬ «ខ្ញុំ មានអត្ថិភាព»។ និក្ខេបបទនេះសំដែងនូវអំពើស្គាល់ខ្លួនឯង ដែលក្នុងនោះ «ខ្ញុំ» ត្រូវបានធ្វើជាកម្មវត្ថុនៃការស្គាល់ និងមានសមមូលជាមួយនឹង«ខ្ញុំដែលមើលមកខ្លួនឯង ជាមួយនឹង ខ្ញុំដែលគេមើលមក»។ «ខ្ញុំដែលគេមើលមក» គឺជា «ខ្ញុំ» ដែលជាកម្មវត្ថុ ដោយមានកំហិតជាសត្យានុម័ត។ ដើម្បីដាក់កំហិតលើខ្លួនឯង ខ្ញុំត្រូវមានសកម្មភាពដែលមានកំហិត ហើយសកម្មភាពនេះត្រូវដាក់កំហិតលើសកម្មភាពផ្សេងទៀត «ជាសត្យានុម័ត» ឬ «ពិតប្រាកដ»



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃ«ខ្ញុំ»ខ្លួនឯង។

ប្រការនេះមានន័យថា «ខ្ញុំ»មាននៅក្នុងខ្លួនឯងនូវសកម្មភាពដែលមានទិសដៅផ្ទុយគ្នា ទាំងមនោគតិនិយមផង ទាំងប្រាកដនិយមផង។ ការស្គាល់ខ្លួនឯង(conscience du soi) អាចទៅរួចទាល់តែទាំងពីរនេះនៅជាមួយគ្នា។ តែទាំងពីរនេះមិនអាចមានអត្ថិភាពដោយគ្មានសកម្មភាពទីបី ដែលចងភ្ជាប់ទាំងពីរនេះ ហើយក៏មិនបង្កលទ្ធភាពឱ្យទាំងពីរនេះកម្ទេចគ្នាទៅវិញទៅមកដែរ។ ហើយសកម្មភាពទីបីនេះ គឺជាអំពើនៃការស្គាល់ខ្លួនឯង។ តុល្យភាពមានចលនានៃសកម្មភាពផ្ទុយគ្នានេះអាចទៅរួចទាល់តែក្នុងរូបភាពជាវឌ្ឍនភាពមិនចេះចប់មិនចេះហើយ។ **ស្ស៊ែលលីង** លើកឡើងថា ទស្សនវិជ្ជាពុទ្ធិមានទិសដៅស្ដាបនាឡើងវិញនូវវឌ្ឍនភាពនេះ ដែលជា «ប្រវត្តិសាស្ត្រនៃការស្គាល់ខ្លួនឯង»។ យើងឃើញថា «ខ្ញុំដែលមើលមកខ្លួនឯង» សមមូលយ៉ាងពេញលេញជាមួយនឹង «ខ្ញុំដែលគេមើលមក»។ តែពីពេលដំបូង គ្មានសមីការនេះទេ។ «ខ្ញុំដាច់ខាតដែលគ្មានទីបញ្ចប់» (Moi-absolu) បានរកឃើញថា «ខ្ញុំមានទីបញ្ចប់ (Moi fini)» និងមានកំហិតដូចនេះមានលក្ខណៈអ្វីមួយ ដែលជា «មិនមែនខ្ញុំ» (non-Moi)។ នេះគឺជាសម័យកាលទីមួយនៃការស្គាល់ខ្លួនឯងដែលបញ្ចប់ដោយការពិនិត្យមើលខ្លួនឯងប្រកបដោយផលិតភាព ពោលគឺការយល់ដឹងពីសកម្មភាពនៃខ្ញុំដោយអសកម្ម ដោយឥន្ទ្រីយារម្មណ៍។ ដំណាក់កាលបន្ទាប់ គឺការបង្ហាញ «ខ្ញុំ» ដោយខ្លួនឯង ជាការពិចារណា ពោលគឺការគិតជាឯកជន។ ដំណាក់កាលទីបី ធ្វើឱ្យ«ខ្ញុំ»ធ្វើអំពើតាមឆន្ទៈដោយសេរី។ ពោលគឺការឈានពីទស្សនវិជ្ជាទ្រឹស្តី ទៅទស្សនវិជ្ជាអនុវត្ត។ សេរីភាពអាចមានទាល់តែមានវត្តមាននៃប្រធានផ្សេងទៀត ហើយចលនារបស់វាទៅរកគោលដៅឧត្តមគតិនឹងបន្តប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ តែដំណើរការប្រវត្តិសាស្ត្រគឺជាការចាំបាច់ដែលប្រឆាំងនឹងការសម្រេចចិត្តដោយសេរីនៃ«ខ្ញុំ»។ ដើម្បីឱ្យស្គាល់ខ្លួនឯងថា ជា«ខ្ញុំ»ដែលគ្មានទីបញ្ចប់ «ខ្ញុំ»ត្រូវតែគិតពីសមមូលនៃសេរីភាព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងភាពចាំបាច់ និងវិចារណញ្ញាណនិងអញ្ញាណសតិ។

**ការសិក្សាស្តីពីសិល្បៈ ៖ ស៊្សេលលីខ** ប្រើប្រាស់សិល្បៈដើម្បីបង្កើតទ្រឹស្តីទស្សនវិជ្ជារបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃអព្ភន្តរញ្ញាណនៃ **ការនិតៀនការវិនិច្ឆ័យ** របស់ **កង់ត៍**។ ស្នាដៃសិល្បៈគឺជាផលិតផលរបស់មនុស្សមានទេពកោសល្យ(génie)។ ម្យ៉ាង មនុស្សមានទេពកោសល្យធ្វើដោយវិចារណញ្ញាណ ដោយកំណត់គោលដៅ និងប្រើប្រាស់បច្ចេក-ទេស។ ក៏ប៉ុន្តែ ស្នាដៃនេះបានរីកធំធាត់ហួសពីការគិតគូប្រកបដោយវិចា-រណញ្ញាណដែលក្នុងនោះមានអ្វីដែលធំសម្បើម។ សមាសធាតុបន្ថែមនេះបណ្តាលមកពីសកម្មភាពអញ្ញាណសតិ(inconscient)របស់មនុស្សមានទេពកោសល្យ។ គាត់ធ្វើវត្ថុមានទីបញ្ចប់ឱ្យក្លាយទៅជាវត្ថុដែលគ្មានទីបញ្ចប់ ហើយចុងក្រោយឱ្យទៅជាអ្វីដែលល្អប្រណីត។

ដោយផ្សាភ្ជាប់វត្ថុមានទីបញ្ចប់ និងគ្មានទីបញ្ចប់ វិចារណញ្ញាណនិងអញ្ញាសតិ ស្នាដៃសិល្បៈល្អប្រណីត គឺជាការសំដែងដោយសត្យានុម័តនៃសមីការដែលជាគោលដៅចុងក្រោយនៃការខិតខំបង្ហាញរបស់ **ស៊្សេលលីខ**។

**ទ្រឹស្តីដាច់ខាត ៖ ស៊្សេលលីខ** អាចបង្ហាញសមីការដាច់ខាតរវាងវិចារណញ្ញាណ និងអញ្ញាណសតិ សេរីភាពនិងភាពចាំបាច់ តាមរយៈទស្សនាទានស្តីពីវិវរណៈនៃព្រះអាទិទេព(revelation divine) និងទាល់តែនៅក្នុងភាពដាច់ខាត(absolu) នៅក្នុង«ខ្ញុំគ្មានទីបញ្ចប់ (Moi absolu)» ដែលមិនត្រូវច្រឡំជាមួយនឹង«ខ្ញុំមនុស្ស»ឡើយ។ **ស៊្សេលលីខ** ក៏ចាប់ផ្តើមបង្កើតទ្រឹស្តីស្តីពីភាពដាច់ខាត ឬអាទិទេព ដោយគ្មានទិដ្ឋភាពចិត្តវិទ្យា ឬទស្សនវិជ្ជាធម្មជាតិឡើយ។ អាទិទេព គឺជាសកម្មភាពដែលគ្មានទីបញ្ចប់ ដែលខិតខំប្រឹងប្រែងទៅរកការកម្ទេចចោលទាំងស្រុង។ តាមរយៈការខិតខំប្រឹង-ប្រែងនេះបានធ្វើឱ្យអាទិទេពក្លាយទៅជាកម្មវត្ថុសម្រាប់ខ្លួនឯង។ ការខិតខំប្រឹងប្រែងនេះមានតាំងពីពេលមុនអាទិទេពស្គាល់ខ្លួនឯងទៅទៀត។ គេហៅវាថា ជាមូលដ្ឋានងងឹតនៃព្រះអាទិទេពនៅក្នុងអាទិទេពខ្លួនឯង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ស្សៀលលីង** ហៅការធ្វើឱ្យអាទិទេព ទៅជាអាទិទេព ប្រៀបបីដូចជាការនាំចេញពីកន្ទែងផងនឹតមកកន្ទែងភ្លឺ។ ការធ្វើឱ្យអាទិទេពស្គាល់ដោយខ្លួនឯង គឺជា **អាទិទេពដូចសតិបញ្ញា**។ អាទិទេពដែលមានលក្ខណៈពីរដូច្នេះ ទាមទារឱ្យមានគោលការណ៍បង្រួបបង្រួម ដែលនៅពេលដំបូង ភពងងឹត និងភពពន្លឺនៅជាមួយគ្នាដោយមិនលាយឡំគ្នា និងមិនផ្ទុយគ្នា ហើយនៅខាងលើបំផុតលេចចេញជា «អាត្ម័ន»។ ដូច្នេះ នៅក្នុងអាទិទេព សតិបញ្ញាមានពន្លឺតែងតែឈ្នះភពងងឹតជានិច្ច។

**ទស្សនវិជ្ជាវិជ្ជមាននិយម** ៖ បន្ទាប់ពីការបោះពុម្ពផ្សាយស្នាដៃ «**ការស្រាវជ្រាវទស្សនវិជ្ជាស្ដីពីខ្លឹមសារនៃសេរីភាពរបស់មនុស្ស**» ដែលមានគំនិតពីវិចារវិទ្យានៃអាទិទេព **ស្សៀលលីង** បានធ្វើការសន្និដ្ឋានពីការចាំបាច់ក្នុងការពិនិត្យឡើងវិញ លើការប្រើប្រាស់ពាក្យនៅក្នុងទស្សនវិជ្ជារបស់ខ្លួន។ នៅក្នុងស្នាដៃមុនៗ លោកចាប់ផ្ដើមពីគំនិតនៃសមីការដាច់ខាតរវាងមនោនិយម និងប្រាកដនិយម។ **ស្សៀលលីង** យល់ឃើញថា សមីការនេះមិនអាចសម្រេចបានភ្លាមៗឡើយ ហើយត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួនទៅតាមកម្រិតផ្សេងៗនៃការរៀបចំភពរូបធាតុ និងភពអាត្ម័ន។ គាត់បានគិតដោយប្រើសព្វឯកវិធី(déduction)នូវកម្រិតទាំងនេះ។ ចំណុចចុងក្រោយនៃសព្វឯកវិធីនេះ គឺបញ្ញត្តិស្ដីពីអាទិទេព។ នៅក្នុងដំណាក់កាលនេះ **ស្សៀលលីង** ជួបនឹងបញ្ហាមួយ ៖ តើវាសមស្របនឹងភាពជាក់ស្ដែងឬទេ? បើដូច្នេះមែន នៅក្នុងដំណាក់កាលដំបូង គេមានតែអាទិទេពកំពុងលូតលាស់ដែលនឹងក្លាយជាអាទិទេពពិតប្រាកដ នៅក្នុងដំណាក់កាលចុងក្រោយតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ទស្សនាទាននេះវាផ្ទុយនឹងទ្រឹស្ដីអាទិទេពនៅក្នុងសាសនាគ្រិស្ត។ ដូច្នេះ **ស្សៀលលីង** ត្រូវតែរកច្រកចេញឱ្យបាន។ លោកហៅទស្សនវិជ្ជាដែលកំពុងសាងសង់ខ្លឹមសារនៃវត្ថុថាជា «**ទស្សនវិជ្ជាអវិជ្ជមាន**» ហើយទស្សនវិជ្ជានៃអត្ថិភាព ថាជា «**ទស្សនវិជ្ជាវិជ្ជមាន**»។ នៅក្នុងទស្សនវិជ្ជាវិជ្ជមានត្រូវមានសមាសធាតុពិសោធន៍។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្វ្រីឌ្រីច ហេហ្គែល
## (១៧៧០-១៨៣១)

**ហ្វ្រីឌ្រីច ហេហ្គែល** *(Friedrich Hegel)* គឺជាទស្សនវិទូដែលបានកសាងប្រព័ន្ធទស្សនវិជ្ជាទីបី បន្ទាប់ពីលោក **អារីស្តូត** នៅជំនាន់ក្រិកបុរាណ និង **តូម៉ាស ដាក់កាំង** នាយុគសម័យមជ្ឈិម។ លោកកើតនៅ Stuttgart បានសិក្សា ហើយក្លាយជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Iéna។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ហ្វ្រីឌ្រីច ហេហ្គែល** គឺ «**ភាពខុសគ្នារវាងទស្សនវិជ្ជារបស់** Fichte **និង** Schelling» *(Différence entre les systems de Fichte et de Schelling)* «**បាតុភូតវិទ្យានៃគំនិត**» *(La Phénoménologie de l'esprit)* «**ទស្សនវិជ្ជានៃប្រវត្តិវិទ្យា**» *(La philosophie de l'histoire)*។

**ហេហ្គែល** មានមហិច្ឆតាបង្កើតនូវប្រព័ន្ធទស្សនវិជ្ជាមួយដែលពេញលេញ ដោយមានគ្រប់សមាសភាគតែម្តង។ **ហេហ្គែល**យល់ឃើញថា ប្រព័ន្ធទស្សនវិជ្ជាដែលពិត គឺជាប្រព័ន្ធគំនិតដែលមានរឿងគ្រប់យ៉ាង។ ក៏ប៉ុន្តែ តើត្រូវធ្វើដូចម្តេច ដើម្បីប្រមូលផ្តុំឱ្យបានគ្រប់រឿងបាន? **ហេហ្គែល** បានលើកឡើងថា ៖ «អ្វីដែលពិត គឺអ្វីដែលមានវិចារណញ្ញាណ ហើយអ្វីដែលមានវិចារណញ្ញាណ គឺជាអ្វីដែលពិត*(tout ce qui est réel est rationnel et tout ce qui est rationnel est réel)*»។ ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃប្រព័ន្ធនេះ **ហេហ្គែល**បានលើកយកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាច្រើនមកបញ្ជាក់។ ប្រព័ន្ធទស្សនវិជ្ជារបស់**ហេហ្គែល** គឺជាប្រព័ន្ធគំនិតដែលយកប្រវត្តិសាស្ត្រធ្វើជាត្រីវិស័យ។ ប្រព័ន្ធនេះត្រូវបានគេដាក់ឈ្មោះឱ្យថា ជាប្រព័ន្ធ «តក្កវិទ្យាទាំងអស់*(un système panlogique – tout est logique)*» ដោយមិនបានចែកជាពីរផ្នែក ៖ តថភាព *(réalité)* និងវិចារណញ្ញាណ*(raison)*។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**តក្កវិជ្ជាវិចារវិជ្ជា** *(la logique dialectique)* ៖ **ហេហ្គែល** បានបង្កើតប្រព័ន្ធទស្សនវិជ្ជាមួយដែលមានបីផ្នែក ៖ មតិស្រប *(thèse)* មតិផ្ទុយ *(antithèse)* និងសំយោគមតិ*(synthèse)*។ **ហេហ្គែល** បានបង្កើតប្រព័ន្ធតក្កវិទ្យាវិចារវិទ្យា*(la logique dialectique)* ដែលឈរលើមូលដ្ឋាននៃភាវៈ*(l'être)*។ ទស្សនាទាននេះគ្របដណ្ដប់លើភាវៈទាំងអស់ ហើយត្រូវអនុវត្តចំពោះអ្វីៗទាំងអស់។ ដូច្នេះ ដើម្បីឱ្យមានលក្ខណៈសាកល ទស្សនាទាននៃ «ភាវៈ» នេះមិនត្រូវមានគុណភាពអ្វីទាំងអស់។ ក្នុងន័យនេះ **ហេហ្គែល** បាននិយាយថា ភាវៈសុទ្ធដាច់ខាត*(l'être pur absolu)* គ្មានគុណភាព មិនខុសពីអភាវៈ*(non-être)*ឡើយ។ ដូច្នេះ ភាវៈ និងអភាវៈដូចតែគ្នា ដោយសារទាំងភាវៈ ទាំងអភាវៈសុទ្ធតែគ្មានគុណភាព។ ក៏ប៉ុន្តែ តាមតក្កវិទ្យា ភាវៈសុទ្ធត្រូវតែផ្ទុយពីអភាវៈ។ ក៏ប៉ុន្តែ ទន្ទឹមនឹងនេះទាំងពីរនេះក៏មានលក្ខណៈដូចគ្នាដែរ។ ប្រការនេះនាំឱ្យយើងមាន ភាវៈជាមតិស្រប និងអភាវៈជាមតិផ្ទុយ។ សំយោគមតិ គឺការបូកបញ្ចូលគ្នានូវភាវៈ និងអភាវៈតែម្ដង។ ពោលគឺការផ្លាស់ប្ដូរពីសភាពមួយទៅសភាពមួយទៀត*(le devenir)*។ ចំណុចនេះគឺជាមូលដ្ឋានគ្រឹះនៃវិចារវិទ្យារបស់ **ហេហ្គែល**។

**វិចារវិជ្ជា** *(dialectique)* ៖ យើងមានសមីការដែលមានអញ្ញត្តិបី ៖ ភាវៈ អភាវៈ និងការផ្លាស់ប្ដូរ។ ដូច្នេះ ការផ្លាស់ប្ដូរ គឺជាការប្រែប្រួលពីភាវៈទៅអភាវៈ និងពីអភាវៈ ទៅភាវៈដែលជាព្រឹត្តិការណ៍ ឬជាដំណើរការដែល **ហេហ្គែល**ឱ្យឈ្មោះថា ជាសភាពផ្ទុយ*(négation)*។ ចំពោះ **ហេហ្គែល** ភាវៈគឺជាអរូបី ហើយអភាវៈក៏ជាអរូបីដែរ។ ក៏ប៉ុន្តែ តាមរយៈដំណើរការផ្ទុយពីរដង គេទទួលបានការផ្លាស់ប្ដូរដែលមានលក្ខណៈរូបី។ វិចារវិទ្យា គឺជាដំណើរការផ្លាស់ប្ដូរនៅក្នុងប្រព័ន្ធសមីការ ៖ (១) ពីភាវៈទៅអភាវៈ និង (២) ពីអភាវៈទៅភាវៈ ដែលបង្កើតសភាពផ្ទុយពីរដង*(la double négation)*។ ដំណើរការផ្ទុយពីរដងនេះបានបំបាត់នូវទំនាស់ផ្ទៃក្នុង*(contradiction)* ហើយប្រែក្លាយទំនាស់នេះទៅជាដំណើរការបង្កើតថ្មីដែលជាសារជាតុនៃភាវៈ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(la substance de l'être)។

**ប្រព័ន្ធទស្សនវិជ្ជា** ៖ ប្រព័ន្ធទស្សនវិជ្ជារបស់ **ហេហ្គែល** មានសមាសភាពបីធំៗ គឺ៖ (១) តក្កវិទ្យា ជាមតិស្រប (la thèse) (២) ទស្សនវិជ្ជានៃធម្មជាតិ (l'entithèse) និង (៣) ទស្សនវិជ្ជានៃស្មារតី (la synthèse) ។ នៅក្នុងសមាសភាពនីមួយៗមានស្នាដៃបី។ នៅក្នុងស្នាដៃនីមួយៗមានសៀវភៅបី។ សៀវភៅនីមួយៗចែកចេញជាបីផ្នែក។ ផ្នែកនីមួយៗចែកជាបីជំពូក។ល។ ទម្រង់បីផ្នែកនេះ គឺជាលក្ខណៈចម្បងនៃប្រព័ន្ធទស្សនវិជ្ជារបស់ **ហេហ្គែល**។

**១- តក្កវិទ្យា** ៖ តក្កវិទ្យានិយាយអំពីគំនិតសុទ្ធ ពោលគឺគំនិតពីភាវៈ គំនិតពីអភាវៈ និងគំនិតពីការផ្លាស់ប្តូរពីសភាពមួយទៅសភាពមួយទៀត (le devenir)។ តក្កវិទ្យានិយាយពីការយកគំនិតទៅគិត ហើយតាមរយៈវិចារវិទ្យា គំនិតបង្កើតសកម្មភាពផ្ទុយពីខាងក្នុង(la négation de son intériorité) ហើយឈានទៅរកសភាពខាងក្រៅ(le déploiement vers l'extérieur)។

**២- ទស្សនវិជ្ជានៃធម្មជាតិ** ៖ បំពោះ **ហេហ្គែល** ធម្មជាតិគឺជាគំនិតដែលបានឆ្លងកាត់វគ្គ សកម្មភាពផ្ទុយ(la pensée qui est passé par la négation) ដែលជាប្រធានបទចម្បងនៃទស្សនវិជ្ជានៃធម្មជាតិ។ គំនិតបំបាត់ផ្នែកខាងក្នុងដោយខ្លួនឯង សិក្សាខ្លួនឯងដោយខ្លួនឯង ដោយមើលមកខាងក្រៅ ហើយស្ថិតនៅក្នុងលំហ និងក្នុងពេលវេលា។

**៣- ទស្សនវិជ្ជានៃស្មារតី** ៖ បន្ទាប់ពីឆ្លងកាត់សកម្មភាពផ្ទុយពីខាងក្នុងលើកទីមួយ(la première négation) ហើយគំនិតត្រូវឆ្លងកាត់សកម្មភាពផ្ទុយលើកទីពីរ ហើយទើបមកដល់ខាងក្នុង។ ត្រង់កន្លែងនេះ គំនិតគិតពីខាងក្រៅ ហើយបំបាត់នូវភាពខាងក្រៅរបស់ខ្លួន។ ដំណាក់កាលនេះ គេហៅថា ឆ្លងកាត់សកម្មភាពផ្ទុយនៃសកម្មភាពផ្ទុយ(la négation de la négation)។ នៅត្រង់នេះ ស្មារតីទទួលនូវការពិនិត្យឡើងវិញពីរដង និងការឆ្លងកាត់សកម្មភាពផ្ទុយពីរដង។ ដូច្នេះ ទស្សនវិជ្ជានៃស្មារតី គឺជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សំយោគនៃប្រព័ន្ធទស្សនវិជ្ជារបស់**ហេហ្គែល**។

**ធម្មជាតិ និងស្មារតី** ៖ ធម្មជាតិដែលគំនិតសុទ្ធបំបាត់នូវផ្ទៃក្នុងរបស់វា បានមកដល់ផ្នែកខាងក្នុងនៃគំនិតដែលគិត។ ស្ថិតនៅក្នុងដំណាក់កាលនេះ គំនិតបានក្លាយជាតថភាពទៅជា«ភាវៈ» តាមរយៈការឆ្លងកាត់សកម្មភាពផ្ទុយពីរដងនេះ*(la double négation)*។ ធម្មជាតិ គឺជារជ្ជកាលនៃផ្នែកខាងក្រៅ*(le règne de l’extériorité)* និងភាពចាំបាច់ ហើយក៏ជាគំនិតដែលបានឆ្លងកាត់នូវសកម្មភាពផ្ទុយដោយខ្លួនឯង។ ផ្ទុយទៅវិញ ស្មារតី គឺជារជ្ជកាលនៃផ្នែកខាងក្នុង*(le règne de l’intériorité)* ហើយស្មារតីមិនទទួលឥទ្ធិពលអ្វីពីខាងក្រៅឡើយ។ ដូច្នេះ ស្មារតី គឺជាសេរីភាពដាច់ខាត។ ដូច្នេះ ស្មារតីដែលស្ថិតនៅក្នុងធម្មជាតិ គឺជាសេរីភាពក្នុងឋាមភាព តែបន្ទាប់ពីឆ្លងកាត់ដំណើរការផ្ទុយមក វាក្លាយទៅជាសេរីភាពដាច់ខាតជាក់ស្ដែង។ ពោលគឺស្មារតីស្ថិតនៅក្នុងធម្មជាតិ គិតពីធម្មជាតិ បំបាត់ចោលនូវផ្នែកខាងក្រៅនៃវត្ថុធម្មជាតិ ហើយក្លាយទៅជាសេរីភាពអនន្ត។ តាមរយៈដំណើរការផ្ទុយនេះ ធម្មជាតិត្រូវបានបំបាត់ពីខាងក្រៅ ក៏ប៉ុន្តែមាននៅសល់អ្វីមួយដែលត្រូវបានប្រែក្លាយទៅជាតថភាពខ្ពស់ជាងមុន*(une réalité supérieure)* នៅក្នុងផ្នែកខាងក្នុងនៃស្មារតី។ ដូច្នេះ ស្មារតីមិនបានកម្ទេចធម្មជាតិទាំងស្រុងឡើយ ពោលគឺកម្ទេចត្រឹមតែផ្នែកខាងក្រៅ ដើម្បីធ្វើឱ្យវាក្លាយទៅជាវត្ថុផ្សេងទៀតដែលអមតៈ។ តាមរយៈដំណើរការនេះ អាទិទេពសម្រេចនូវតថភាពជាអមតៈ។

ស្មារតីឆ្លងកាត់នូវដំណាក់កាលចំនួនបី គឺ ស្មារតីអត្តនោម័ត*(l’esprit subjectif)* ស្មារតីសត្យានុម័ត*(l’esprit objectif)* និង ស្មារតីដាច់ខាត*(l’esprit absolu)*។

**ស្មារតីអត្តនោម័ត** ៖ ស្មារតីអត្តនោម័ត គឺជាស្មារតីនៅដំណាក់កាលទីមួយ ដែលជាស្មារតី ដែលងើបចេញពីធម្មជាតិ ដើម្បីត្រឡប់មកខ្លួនឯងវិញ។ ការងើបចេញពីធម្មជាតិនេះ មានបីកម្រិត ៖ (១) **អាត្មន** *(l’âme)*-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្មារតីនៅជាប់ជាមួយរាងកាយនៅឡើយ ដោយរាងកាយ គឺជាគំនិតដែលបញ្ចេញខាងក្រៅ*(le corps est de la pensée extériorisée)* ហើយដែលបាត់នូវភាពខាងក្នុង (២) **សម្បជញ្ញៈ** *(la conscience)*-អាត្ម័នបំបាត់ឯកភាពជាមួយនឹងរាងកាយ ចេញពីកាយដើម្បីអាចគិតដោយខ្លួនឯង។ ដូច្នេះ សម្បជញ្ញៈ គឺនៅពេលដែលអាត្ម័នសម្រេចបាននូវភាពច្បាស់លាស់ដោយខ្លួនឯង និង (៣) **វិចារណញ្ញាណ** *(la raison)*-គឺជាការសំយោគរវាងអាត្ម័ន និងសម្បជញ្ញៈ។ បន្ទាប់ពីដោះស្រាយនូវភាពផ្ទុយគ្នារវាងស្មារតី និងធម្មជាតិ គេទៅដល់វិចារណញ្ញាណដែលជាដំណាក់កាលដែលគេច្បាស់ថា ស្មារតី និងធម្មជាតិបានក្លាយទៅជាតែមួយ។

**ស្មារតីសត្យានុម័ត** ៖ គឺជាការឆ្លងកាត់សកម្មភាពផ្ទុយនៃស្មារតីអត្តនោម័ត ទៅដល់ពិភពពិតមួយដែលហៅថាច្បាប់។ **ហេហ្គែល**បានចែកច្បាប់ជាបីដំណាក់កាល ៖ (១) **ច្បាប់អរូបី** *(le droit abstrait)* ដែលធានាឱ្យមនុស្សទាំងអស់មានឱកាសប្រើប្រាស់នូវអ្វីដែលគេមានតាមរយៈកិច្ចសន្យាដែលជាការបញ្ចេញនូវឆន្ទៈទូទៅ ក្នុងគោលដៅធានាដល់ពលរដ្ឋគ្រប់រូបអាចប្រើប្រាស់ច្បាប់នេះបាន។ ច្បាប់មានលក្ខណៈអរូបី ដោយសារវាមិនទាន់ក្លាយទៅជាសីលធម៌ (២) **សីលធម៌** *(la moralité)* កើតមកពីច្បាប់អរូបីដែលបានឆ្លងកាត់សកម្មភាពផ្ទុយគ្នា។ សីលធម៌ គឺជាស្មារតីដែលគិតពីខ្លួនឯងដែលចេញផុតពីច្បាប់អត្តនោម័ត ដើម្បីក្លាយទៅជាមូលដ្ឋានគ្រឹះនៃច្បាប់សាកល (៣) **តថភាពសីលធម៌ និងសង្គម** *(la réalité morale et sociale)* គឺជាសំណុំនៃច្បាប់ ស្ថាប័ននយោបាយ ទំនៀមទម្លាប់ វិធានទម្រង់ និងម៉ូដែល នៅក្នុងសង្គមមួយ។ វាគឺជាសំយោគរវាងច្បាប់អរូបី និងសីលធម៌។ តថភាពសីលធម៌ និងសង្គមចែកចេញជាបីដំណាក់កាល ៖ គ្រួសារ សង្គមពលរដ្ឋ និងរដ្ឋ។ ដូច្នេះ ចំពោះ**ហេហ្គែល** រដ្ឋគឺជាការឈានដល់កម្រិតប្រវត្តិសាស្ត្រនៃដំណើរការទាំងអស់។ រដ្ឋ គឺជាតថភាពជាក់ស្តែងនៃវិចារណញ្ញាណនៅក្នុងសហគមន៍មនុស្ស។ ទស្សនវិជ្ជានៃប្រវត្តិសាស្ត្រ

របស់**ហេហ្គែល** គឺជាន័យរបស់ប្រវត្តិសាស្ត្រ ឬអាចនិយាយម្យ៉ាងទៀតថា សារៈសំខាន់ និងទិសដៅរបស់ប្រវត្តិសាស្ត្រស្ថិតនៅត្រង់វឌ្ឍនភាពនៃស្មារតី ដែលគិតគូពីសេរីភាពនៃស្មារតីនេះ តាមរយៈការរៀបចំរដ្ឋ ដែលមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ។

**ស្មារតីដាច់ខាត** ៖ ស្មារតីដាច់ខាត គឺជាស្មារតីមនុស្សធម៌ដែលត្រឡប់មកដល់ផ្នែកខាងក្នុងរបស់ខ្លួនដែលមានលក្ខណៈទូលំទូលាយនិងស៊ីជម្រៅ ហើយដែលរក្សាបាននូវធម្មជាតិយ៉ាងច្រើនបំផុត។ ស្មារតីដាច់ខាតចែកចេញជាបីដំណាក់កាល គឺ៖ (១) **សិល្បៈ** គឺជាតំណាងផ្នែកខាងក្រៅនៃភាពដាច់ខាត ហើយសិល្បៈចែកជាបីទៀតគឺ (ក) សិល្បៈនិមិត្តរូបដែលជាសិល្បៈអាស៊ី និងអេហ្ស៊ីប (ខ) សិល្បៈបុរាណ ដែលជាសិល្បៈក្រិក និង (គ) សិល្បៈសាសនាគ្រិស្ត (២) **សាសនា** ដែលបំបាត់នូវភាពខាងក្រៅចេញ ហើយនៅសល់តែផ្នែកខាងក្នុងដែលចលនានៃអាត្ម័នបានឡើងទៅដល់អាទិទេព ហើយគ្របដណ្តប់នូវទម្រង់ដែលមានវេទយិតភាពទាំងអស់ និង (៣) **ទស្សនវិជ្ជា** គឺជាស្មារតីដាច់ខាតដែលត្រឡប់មករកខ្លួនឯងវិញ តាមរយៈគំនិតសុទ្ធ ដែលធ្វើឱ្យគេអាចយល់បាន។ ទស្សនវិជ្ជា គឺជាសំយោគរវាងសិល្បៈ និងសាសនា ហើយដែលមានលក្ខណៈទូលំទូលាយ និងជឿនលឿនជាងសិល្បៈ និងសាសនាទៅទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៥
# ទស្សនវិជ្ជាសម័យទំនើប

*ទស្សនវិជ្ជាវិវត្តមិនមែនតាមខ្សែបន្ទាត់ត្រង់ឡើយ។ ចរន្តទស្សនវិជ្ជាវិវត្តទៅតាមវដ្តរបស់វា។ នៅពេលដែលទស្សនៈចាស់ឈានទៅដល់ភាពទាល់ច្រក ទស្សនវិទូថ្មីទទួលភារកិច្ចក្នុងការស្វែងរកទស្សនៈថ្មីសម្រាប់ទស្សនវិជ្ជា។ ដូច្នេះ ទស្សនវិជ្ជាសម័យទំនើបបានចាប់បដិសន្ធិនៅដើមសតវត្សរ៍ទី១៩ តាមរយៈការទិតៀនទស្សនវិជ្ជារបស់* **ហេហ្គែល**។ *ទស្សនវិទូទាំងនោះគឺ* **អាតួ ស្សូប៉េនអាវ** *(Arthur Schopenhaur) និង* **លូដវីគ ហ្វយ័របាក់** *(Ludwig Feuerbachs) ជាដើម។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អាតួ ស្សូប៉េនអាវ
## (១៧៨៨-១៨៦០)

**អាតួ ស្សូប៉េនអាវ** *(Arthur Schopenhauer)* កើតនៅDantzig អាឡឺម៉ង់ ក្នុងត្រកូលធនាគារិក និងពាណិជ្ជករដែលមានទ្រព្យសម្បត្តិហូរហៀរ។ ទោះបីជាខិតខំប្រឹងប្រែងយកចិត្តទុកដាក់លើមុខរបររបស់គ្រួសារ **ស្សូប៉េនអាវ**មានអារម្មណ៍រវើរវាយ ហើយផ្តោតអារម្មណ៍លោកលើការអានសៀវភៅទស្សនវិជ្ជាតែម្តង។ បន្ទាប់ពីឪពុករបស់លោកធ្វើអត្តឃាដមក **ស្សូប៉េនអាវ** កាន់តែក្រៀមក្រំឡើង១ ហើយគាត់បានប្តេជ្ញាចិត្តសិក្សាទស្សនវិជ្ជានៅសាកលវិទ្យាល័យ Göttingen និង Berlin។ ក្នុងឆ្នាំ១៨១៣ លោកបានការពារនិក្ខេបបទទស្សនវិជ្ជាក្រោមចំណងជើងថា ៖ «**ឫសគល់ទាំងបួននៃគោលការណ៍វិចារណញ្ញាណគ្រប់គ្រាន់**» *(De la Quadruple Racine du principe de raison suffisante)* នៅសាកលវិទ្យាល័យ Iéna។ តែលោករស់នៅក្នុងស្ថានភាពឯកោ។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ស្សូប៉េនអាវ** គឺ «**ពិភពលោកជាឆន្ទៈ និងជាតំណាង**» *(Le Monde comme Volonté et comme Représentation)* ដែលត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៨១៩។ ក្នុងឆ្នាំ១៨៥១ លោកបោះពុម្ពផ្សាយ *Parerga et Paralipomena*។

**ស្សូប៉េនអាវ** មានមហិច្ឆតាបង្កើតនូវប្រព័ន្ធទស្សនវិជ្ជាមួយដែលពេញលេញ ដោយមានគ្រប់សមាសភាគតែម្តង។ លោកធ្លាប់បង្រៀនទស្សនវិជ្ជានៅសាកលវិទ្យាល័យប៊ែរឡាំងជាមួយ **ហេហ្គែល** ដែលលោកទិតៀនយ៉ាងខ្លាំង។ លោកចាត់ទុក **ហេហ្គែល** និង **ហ្វិកត៍** ជាពួកសូហ្វីសដែលគ្រាន់តែកែប្រែគំនិតធំៗរបស់ **កង់ត៍** តែប៉ុណ្ណោះ។ តែប្រណាំងប្រជែងជាមួយ **ហេហ្គែល** ពិតជាពិបាកណាស់។ លោកត្រូវចេញពីសាកល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិទ្យាល័យ ដោយសារគ្មានសិស្សរៀនជាមួយ។ លោកសង្ឃឹមថា ថ្ងៃណាមួយគេច្បាស់ជាយល់ពីទស្សនវិជ្ជារបស់លោក។ ទីបំផុតនៅចុងបំផុតនៃជីវិតរបស់លោក ទើបទស្សនវិជ្ជារបស់លោកត្រូវបានគេទទួលស្គាល់ថាមានសារៈសំខាន់ ហើយមជ្ឈដ្ឋានទស្សនវិជ្ជាបានងាកចេញពីទស្សនវិជ្ជារបស់ **ហេហ្គែល**។ **ស្សូប៉េនអាច** យល់ថាពិភពលោកមានទិដ្ឋភាពពីរ ៖ ជាតំណាងផង និងជាវត្ថុក្នុងខ្លួន(la chose en soi)ផង។ ប្រការនេះមានន័យថាពិភពលោកគឺជាពុទ្ធិវត្ថុផង និងជាពុទ្ធិប្រធានផង។

**ពិភពលោកជាតំណាង** (Le Monde comme Représentation) ៖ យើងចាត់ទុកពិភពលោកជាតំណាង ពេលដែលយើងចាត់ទុកពិភពលោកជាពុទ្ធិវត្ថុ។ ដើម្បីទទួលបានពុទ្ធិ **ស្សូប៉េនអាច** ប្រើវិធីសាស្ត្ររបស់ **កង់ត៍** ដែលចែកជាពុទ្ធិប្រធាន-ពុទ្ធិវត្ថុ ដែលជាលក្ខខណ្ឌទូទៅ ក្នុងការសិក្សាពិភពលោក(Critique of Pure Reason)។ ការវិភាគរបស់**កង់ត៍**ផ្ដោតលើបញ្ញត្តិពីរផ្ទុយគ្នា ៖ វត្ថុក្នុងខ្លួន (la chose en soi) ដែលជាវត្ថុក្នុងភាពដាច់ខាត និងការទទួលអារម្មណ៍របស់យើងដែលហៅថា «បាតុភូត»។ មានតែតាមរយៈការបង្ហាញបាតុភូតទេដែលយើងអាចទទួលបាននូវពុទ្ធិប្រៀបធៀបនៃវត្ថុ (une connaissance relative des choses)។ **ស្សូប៉េនអាច** យល់ថាបាតុភូតដែលយើងទទួលអារម្មណ៍បាន គ្មានអ្វីក្រៅពីឥន្ទ្រីយារម្មណ៍របស់យើងនោះឡើយ។

**ស្សូប៉េនអាច** យល់ថាពិភពលោក គឺជាតំណាង (représentation) ដោយអត្តនោម័តនៃប្រាជ្ញា(Intellect)របស់យើង ៖ យើងទទួលអារម្មណ៍បានតាមតែរយៈរបាំងបំភ័ន្តដែលធ្វើឱ្យយើងឃើញយ៉ាងស្រពិចស្រពិលប៉ុណ្ណោះ។ ផ្ទុយពី**កង់ត៍**ដែលយល់ថា**វត្ថុក្នុងខ្លួន**មិនអាចដឹងបាន លោកយល់ថាគេអាចឈានដល់តថភាពបរមត្ថវិទ្យាជាមូលដ្ឋាននៃវត្ថុក្នុងខ្លួន។ ពុទ្ធិប្រធានអាចស្គាល់ភ្លាមពីភាវៈខាងក្នុងរបស់ខ្លួន ពីចំណង់របស់ខ្លួនដែលអនុញ្ញាតឱ្យចាប់យកនូវខ្លឹមសារនៃពិភពលោកដែលយើងចូលទៅក្នុងនោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយខ្លួនឯង។ ដូច្នេះ មិនមែនវត្ថុក្នុងខ្លួននាំឱ្យមានឥន្ទ្រីយារម្មណ៍ទេ។ ទំនាក់ទំនងរវាងវត្ថុក្នុងខ្លួន និងឥន្ទ្រីយារម្មណ៍របស់យើង ប្រៀបបីដូចជាផ្នែកទាំងពីរនៃកាក់តែមួយដូច្នេះឯង។ មិនមែនផ្នែកមួយជាមូលហេតុនៃផ្នែកមួយទៀតទេ។ ផ្នែកទាំងពីរនៅលើកាក់តែមួយ។

**ពិភពលោកជាឆន្ទៈ** *(Le Monde comme Volonté)* ៖ ក៏ប៉ុន្តែ ពិភពលោកមិនមែនគ្រាន់ជាតំណាង(*représentation*)ប៉ុណ្ណោះទេ។ ពិភពលោកក៏ជា**វត្ថុក្នុងខ្លួន**ផងដែរ នៅពេលដែលយើងចាត់ទុកពិភពលោកជាប្រធានបទនៃពុទ្ធិ។ គឺមនុស្សខ្លួនឯងដែលអាចទៅដល់**វត្ថុក្នុងខ្លួន**។ មនុស្សអាចស្គាល់ខ្លួនឯងមិនមែនត្រឹមតែពីខាងក្រៅទេ តែក៏អាចស្គាល់ខ្លួនឯងពីខាងក្នុងផងដែរ។ ពីខាងក្រៅ មនុស្សគឺជារាងកាយមានយន្តការជីវវិទ្យា និងសរីរាង្គនិងតួនាទីជាច្រើន។ បើយើងមើលទៅមនុស្សផ្សេង យើងឃើញតែសំបកខាងក្រៅប៉ុណ្ណោះ។ ក៏ប៉ុន្តែ ប្រសិនបើយើងមើលមកខ្លួនយើង យើងដឹងថាក្នុងខ្លួនយើងមានអ្វីដែលច្រើនជាងនេះ។ យើងម្នាក់ៗដឹងថា ពេលដែលយើងលើកដៃ ឬលើកអវៈយវៈផ្សេងទៀត យើងក៏ត្រូវខំប្រឹងពីខាងក្នុងផងដែរ។ ស្ថានភាពនេះហៅថា **អំពើនៃឆន្ទៈ**។ ការខំប្រឹងនេះមិនមែនបណ្តាលមកពីឥន្ទ្រីយារម្មណ៍ពីខាងក្រៅទេ ហើយក៏មិនស្ថិតនៅក្នុងលំហដែរ។

**ស្ប៉ូប៉េនអាវ** យល់ថាចលនារាងកាយនេះចេញមកពីក្នុង ដោយខ្លួនឯង ហើយមិនមែនជាអំពើនៃឆន្ទៈមកពីខាងក្រៅឡើយ។ តែលោកក៏មិនបានបញ្ជាក់ឱ្យបានច្បាស់ថា អំពើនៃឆន្ទៈវាគឺជាវត្ថុនៅក្នុងខ្លួនរបស់មនុស្សដែរ។ អំពើទាំងនេះកើតឡើងនៅក្នុងពេលវេលាណាមួយ ហើយពេលវេលា គឺជាទម្រង់នៃឥន្ទ្រីយារម្មណ៍ពីខាងក្នុង ដែលបើកឱ្យយើងស្គាល់បាតុភូត មិនមែនឱ្យស្គាល់វត្ថុក្នុងខ្លួនឡើយ។ ឥន្ទ្រីយារម្មណ៍ក្នុងខ្លួនអាចឱ្យយើងដឹងពីវត្ថុក្នុងខ្លួន ដែលនៅជិតយើងជាងវត្ថុរូបធាតុឯទៀត ដែលនៅឆ្ងាយពីវត្ថុនៅក្នុងខ្លួន ដោយសារតែពេលវេលា និងលំហ។ ក្នុងន័យនេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វត្ថុនៅក្នុងខ្លួនអាចពិពណ៌នាបានតាមរយៈឆន្ទៈ។ មានតែនៅក្នុងខ្លួនយើងពាល់គ្នាទេ ដែលគេអាចទៅកាន់វត្ថុនៅក្នុងខ្លួនបាន។ មិនចាំបាច់តែរាងកាយយើងទេ វត្ថុផ្សេងទៀតក៏មានខ្លឹមសារភាវៈ និងឆន្ទៈដែរ ហើយដោយសារនិម្មាបនកម្មនៃពិភពលោកយ៉ាងសុខដុម អាចឱ្យយើងនិយាយពីខ្លឹមសារតែមួយ។

**ស្សូប៉ែនអាវ** បន្ទោស **កង់ត៍** ថា មិនបានចាប់អារម្មណ៍លើបទ-ពិសោធខាងក្នុងដែលបង្ហាញឱ្យឃើញតាមរយៈឆន្ទៈ (Volonté) ដែលជាទម្រង់មួយសំខាន់បំផុតនៃបទពិសោធ។ លោកយល់ឃើញថា ឆន្ទៈគឺជាបង្អួចតែមួយគត់របស់មនុស្សទៅកាន់ពិភពលោក នៅក្រោយតំណាង ពោលគឺវត្ថុក្នុងខ្លួនឯងរបស់ **កង់ត៍**។ ដូច្នេះ លោកជឿជាក់ថាគេអាចដឹងបានពីវត្ថុក្នុងខ្លួនឯង(**កង់ត៍** យល់ថាមិនអាច) ដោយសារគេអាចយល់ពីទំនាក់ទំនងរវាងតំណាងនិងវត្ថុក្នុងខ្លួនឯង ប្រៀបបីដូចជាទំនាក់ទំនងរវាងឆន្ទៈនិងរាងកាយរបស់យើង។ **ស្សូប៉ែនអាវ** យល់ថា ពិភពលោកទាំងមូលគឺជាតំណាងនៃឆន្ទៈដែលឆន្ទៈបុគ្គលរបស់យើងគឺជាបាតុភូត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# លូដវីគ ហ្វយ័របាក់
## (១៨០៤-១៨៧២)

**លូដវីគ ហ្វយ័របាក់** *(Ludwig Feuerbach) កើតនៅក្នុងឆ្នាំ១៨០៤ នៅក្នុងទីក្រុងLandshut បាវ៉ារី។ លោកបានសិក្សាសាសនាវិទ្យា នៅសាកលវិទ្យាល័យ Heidelberg បន្ទាប់មកសិក្សាទស្សនវិជ្ជានៅសាកលវិទ្យាល័យប៊ែរឡាំងដែលនៅទីនោះលោកបានរៀនជាមួយ* **ហេហ្គែល** *ចំនួនពីរឆ្នាំ។ បន្ទាប់ពីការធ្លាក់ចុះនៃឥទ្ធិពលរបស់* **ហេហ្គែល** *លោកស្ថិតនៅក្នុងមជ្ឈដ្ឋាន* **ហេហ្គែល***និយមឆ្វេងនិយម ដោយប្រកាន់យកជំហរសេរីនិយម មិនជឿលើអាទិទេព និងសម្ភារនិយម។ លោកសរសេរទិតៀនសាសនា ហើយទស្សនវិជ្ជារបស់លោកមានឥទ្ធិពលយ៉ាងខ្លាំងលើចលនាសម្ភារនិយមប្រវត្តិសាស្ត្រ និងទៅលើ* **កាល ម៉ាក្ស** *(Karl Marx)* **ហ្វ្រីដ្រីច អង់ហ្គែល** *(Friedrich Engels)* **រីឆាដ វ៉ាគន័រ** *(Richard Wagner) និង* **ហ្វ្រីដ្រីច នីតស៍** *(Friedrich Nietzsche)។*

**ស្នាដៃសំខាន់** *៖ បន្ទាប់ពីបានបោះពុម្ពសៀវភៅលើកទី១របស់លោក «Thoughts on Death and Immortality» ក្នុងឆ្នាំ១៨៣០ លោកត្រូវគេបណ្តេញចេញពីសាកលវិទ្យាល័យ។ ស្នាដៃសំខាន់របស់***ហ្វយ័របាក់** *គឺ «***ខ្លឹមសារនៃសាសនាគ្រិស្ត***» ដែលត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៨៤១ ដែលធ្វើឱ្យលោកចាប់ផ្តើមល្បីល្បាញ។*

*ទស្សនវិជ្ជារបស់* **ហ្វយ័របាក់** *ផ្តោតទៅលើសារជាតុអត្តនោម័តនិយមរបស់មនុស្ស និងមតិស្តីពីភាពអមតៈនៃមត៌កវប្បធម៌របស់មនុស្ស។ ទស្សនៈទាំងនេះកើតឡើងបន្តិចម្តងៗ ដោយចាប់ផ្តើមពីការទិតៀនទស្សនវិជ្ជាហេហ្គែល ហើយស្ថិតនៅក្រោមឥទ្ធិពលរបស់* **ហេហ្គែល** *លោកបានសរសេរពីភាពអមតៈនៃអាទិទេពដែលជា«ការចាប់ផ្តើមជីវិតដំបូងរបស់*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មនុស្ស»។ **ហ្វយ័រទាក់** សរសេរពីការវិវត្តិនៃទស្សនវិជ្ជារបស់គាត់ថា «គំនិតដំបូងរបស់ខ្ញុំ គឺព្រះអាទិទេព គំនិតទីពីរ គឺ វិចារណញ្ញាណ ហើយគំនិតចុងក្រោយ គឺមនុស្ស ៖ ប្រធានបទនៃអាទិទេព គឺវិចារណញ្ញាណ ហើយប្រធានបទនៃវិចារណញ្ញាណ គឺមនុស្ស»។ **ហ្វយ័រទាក់** បានក្លាយជាទស្សនវិទូអាឡឺម៉ង់ទីមួយនៅក្នុងសតវត្សរ៍ទី១៩ ដែលបានស្នើនូវវិធីសាស្ត្រទស្សនវិជ្ជាថ្មី ៖ «ទស្សនវិជ្ជាថ្មីដែលប្រែក្លាយមនុស្ស រួមទាំងធម្មជាតិ ជាមូលដ្ឋាននៃមនុស្ស ឱ្យទៅជាមុខវិជ្ជាតែមួយគត់ ជាសាកល និងខ្ពស់បំផុតនៃទស្សនវិជ្ជា ដោយបំប្លែងបុរាណវិជ្ជា រួមទាំងសរីរវិទ្យាឱ្យក្លាយទៅជាវិទ្យាសាស្ត្រសាកល»។

**ទស្សនវិជ្ជាប្រវត្តិសាស្ត្រ** (*la philosophie historique*) ៖ **ហ្វយ័រទាក់** គូសបញ្ជាក់ថា មនុស្សតែងតែធ្វើការត្រិះរិះពិចារណាពីទស្សនវិជ្ជា។ ប្រវត្តិសាស្ត្រនៃប្រព័ន្ធទស្សនវិជ្ជាត្រូវបានគេយល់ថា គឺជាប្រវត្តិសាស្ត្រនៃគំនិតរបស់ទស្សនវិទូមួយៗ។ តាមពិត ប្រព័ន្ធទស្សនវិជ្ជាដែលកើតឡើងនៅក្នុងចរន្តនៃប្រវត្តិសាស្ត្រទស្សនវិជ្ជាត្រូវតែចាត់ទុកថាជាទស្សនៈចាំបាច់នៃវិចារណញ្ញាណ។ គំនិតទាំងនេះមិនមែនបង្កើតឡើងដោយការត្រិះរិះពិចារណាទស្សនវិជ្ជាទេ។ នៅពេលដែលគិត ទស្សនវិទូនីមួយៗបានឡើងផុតពីលក្ខណៈបុគ្គលរបស់ខ្លួន ហើយដើរតួនាទីជាឧបករណ៍ដែលក្នុងនោះគំនិតបានក្លាយទៅជាទស្សនៈរួមនៃសម័យកាលនោះ ដែលបន្ទាប់មកត្រូវបានបញ្ចូលទៅក្នុងវិចារណញ្ញាណនៃប្រវត្តិទស្សនវិជ្ជា។ សកម្មភាពនៃគំនិតទាំងនេះប្រៀបបីដូចជាការទទួលយកគំនិតដោយបុគ្គលម្នាក់ៗ។ គំនិតទាំងនេះបានឆ្លងពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀត ហើយគំនិតទាំងនេះបង្កើតខ្លួនឯងដោយកំណត់ខ្លួនឯង និងវិចារណញ្ញាណរបស់មនុស្សជាមធ្យោបាយនៃការសម្រេចបាននូវបំណងប្រាថ្នារបស់ខ្លួន។

**ការជិតៀនគ្រិស្តសាសនា** ៖ នៅក្នុងស្នាដៃរបស់លោក *The Essence of Christianity* (១៨៤៣) **ហ្វយ័រទាក់** សរសេរថាលោកមានគោលដៅ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីរយ៉ាង ៖

ទីមួយ-វាយប្រហារលើទស្សនៈរបស់**ហេហ្គែល**ថា តថភាពសាសនា និងទស្សនវិជ្ជាគឺដូចគ្នា ដោយបង្ហាញថា**ហេហ្គែល**មានជោគជ័យក្នុងការបង្ហាញថាសាសនាដូចទស្សនវិជ្ជា ដោយគ្រាន់តែលុបចេញពីសាសនានូវខ្លឹមសារមួយចំនួនដែលខុសពីទស្សនវិជ្ជា។

ទីពីរ-លើកកម្ពស់អ្វីដែលហៅថាទស្សនវិជ្ជាវិជ្ជមាន ដោយបង្ហាញឱ្យឃើញថារូបភាពដំបូងរបស់ព្រះអាទិទេព គឺជាមនុស្សប្រុស ហើយសាច់ និងឈាមរបស់គេ គឺជាសាច់ឈាមនៃអ្នកត្រកូលខ្ពស់។

គំនិតសំខាន់របស់ **ហ្វយ័របាក់** គឺដោយសារមនុស្សមានសាសនា ហើយសត្វគ្មានសាសនា ដូច្នេះ គន្លឹះឱ្យយល់ពីសាសនាគឺត្រូវយល់ថា តើមនុស្សខុសពីសត្វយ៉ាងដូចម្ដេច។ ពោលគឺមនុស្សខុសពីសត្វត្រង់ថានៅពេលមនុស្សសិក្សាយល់ដឹងពីពិភពលោក មនុស្សប្រើវិចារណញ្ញាណ។

**ហ្វយ័របាក់** យល់ថាព្រះអាទិទេពគឺជាកម្មវត្ថុទ្រឹស្ដីនៃការត្រិះរិះពិចារណាប្រកបដោយវិចារណញ្ញាណ ឬ«**អាទិទេព ជា អាទិទេព**» ដែលជាអង្គមួយដែលគ្មានកាល និងមិនអាចទៅដល់ និងមិនមានពាក់ព័ន្ធជាមួយនឹងការវេទនារបស់មនុស្ស ហើយចុងបំផុតគ្មានអ្វីប្លែកពីវិចារណ-ញ្ញាណឡើយ។

**ហ្វយ័របាក់** សន្និដ្ឋានថា សាសនាគឺជាទម្រង់ផ្សេងមួយនៃការស្គាល់ខ្លួនឯងរបស់មនុស្ស(human self-consciousness) ដោយសារមានទំនាក់ទំនងរវាងមនុស្សទៅនឹងខ្លឹមសាររបស់ខ្លួន។ ដូច្នេះ អាទិទេព គឺជាខ្លឹមសារដាច់ដោយឡែករបស់មនុស្ស ដែលរាប់បញ្ចូលទាំងអារម្មណ៍ វិចារណញ្ញាណ និងឆន្ទៈផងដែរ។

**ទស្សនវិជ្ជាថ្មី ៖ ហ្វយ័របាក់** បានបោះពុម្ពសៀវភៅពីរក្នុងឆ្នាំ ១៨៤០ និង១៨៤៣ ក្នុងគោលដៅទាញចេញពីការទិតៀនផ្ទៃក្នុងនៃទស្សនវិជ្ជាចាស់( ដែលឈានដល់ចំណុចខ្ពស់បំផុត គឺប្រព័ន្ធរបស់ **ហេហ្គែល**)នូវ

គោលការណ៍មួយចំនួនដែលជាមូលដ្ឋាននៃទស្សនវិជ្ជាថ្មីដែលជាទស្សនវិជ្ជានៃអនាគត។ ក៏ប៉ុន្តែ នៅក្នុងស្នាដៃទាំងនោះលោកសរសេរតែពីសាសនាប៉ុណ្ណោះ។ លោកបានសរសេរនូវទស្សនាទានមួយចំនួនពាក់ព័ន្ធនឹងបុរាណវិទ្យាទស្សនវិជ្ជាដែលលោកចង់យកមកជំនួសទស្សនវិជ្ជាចាស់។ តែនៅក្នុងស្នាដៃដែលបោះពុម្ពផ្សាយក្នុងអំឡុងឆ្នាំ ១៨៤០ និង ១៨៥០ **ហ្វយ័របាក់** សរសេរពិសាសនា។ ដូច្នេះ ទស្សនវិជ្ជាថ្មីរបស់លោកហាក់បីដូចជាគ្មានអ្វីប្លែកពីសំណេរចាស់ៗរបស់លោកស្តីពីសាសនាឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អូហ្គុស កុងត៍
## (១៧៩៨-១៨៥៧)

**អូហ្គុស កុងត៍** *(Auguste Comte)» គឺជាទស្សនវិទូបារាំងដែលកើតនៅក្នុងអំឡុងពេលនៃការផ្លាស់ប្តូរខាងផ្នែកសង្គមដែលបង្កើតឡើងដោយបដិវត្តន៍បារាំង។ លោកបានបង្កើត «***សាលាទស្សនវិជ្ជាវិជ្ជមាននិយម***»។ ទ្រឹស្តីរបស់លោក* **កុងត៍** *ផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍវិទ្យាសាស្ត្រ និងអនាគតនៃវិទ្យាសាស្ត្រ។ លោកយល់ឃើញថា ការពន្យល់តាមបែបវិទ្យា-សាស្ត្រនឹងគ្របដណ្តប់គ្រប់វិស័យទាំងអស់នៃបទពិសោធ។ ចំពោះ* **អូហ្គុស កុងត៍** *វិទ្យាសាស្ត្រមិនមែនត្រឹមតែជាពុទ្ធិឡើយ តែជាការយល់ដឹងពីពិភពលោកទាំងមូល។*

**ស្នាដៃសំខាន់** *៖ ស្នាដៃដ៏ល្បីល្បាញរបស់លោកគឺ «***មេរៀនស្តីពីទស្សនវិជ្ជាវិជ្ជមាន** *(Cours de la philosophie positive)» ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៨៤២។*

**ទស្សនវិជ្ជាវិជ្ជមាន** *៖ ទស្សនវិជ្ជារបស់* **អូហ្គុស កុងត៍** *គឺជា «***ទស្សនវិជ្ជាវិជ្ជមាន***» ពោលគឺទស្សនវិជ្ជារដែលឈរលើមូលដ្ឋាននៃច្បាប់ និងព្រឹត្តិ-ការណ៍ជាក់ស្តែង ហើយមិនត្រូវមានការពន្យល់តាមបែបបរមត្ថវិទ្យា (méta-physique) ឡើយ។ ទ្រឹស្តី «***វិជ្ជមាន***» មានន័យថា ទ្រឹស្តីនេះគឺជាទ្រឹស្តីវិទ្យាសាស្ត្រដែលឈរលើមូលដ្ឋាននៃព្រឹត្តិការណ៍ជាក់ស្តែង។ បន្ទាប់ពីបានសិក្សាពីវឌ្ឍនភាពនៃវិទ្យាសាស្ត្រ* **អូហ្គុស កុងត៍** *បានបង្កើតទ្រឹស្តីមួយថា វិទ្យាសាស្ត្រណាក៏ដោយត្រូវឆ្លងកាត់បីដំណាក់កា លៈ (១)* **សាសនា** *(état théologique) គឺជាការពន្យល់ព្រឹត្តិការណ៍ដោយឈរលើហេតុផលសាសនា អបិយជំនឿ និងអាទិទេព ហើយដំណាក់កាលនេះត្រូវចែកចេញជាបីទៀត គឺ (ក) ជំនឿលើវត្ថុ (ខ) ជំនឿលើព្រះជាច្រើន និង (គ) ជំនឿលើព្រះ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែមួយ (២) **បរមត្ថវិជ្ជា** *(état métaphysique)* គឺជាដំណាក់កាលមួយដែលវិទ្យាសាស្ត្របានវិវត្តដល់ដំណាក់កាលមួយដែលគេមានទ្រឹស្តីរូបវិទ្យាខ្លះជាទ្រឹស្តីអរូបី ដែលគេមិនទាន់អាចពន្យល់បានច្បាស់នៅឡើយ ហើយដំណាក់កាលនេះបន្តរហូតដល់ចុងយុគសម័យមជ្ឈិម (៣) **វិជ្ជមាននិយម** *(état positif)* គឺជាដំណាក់កាលដែលវិទ្យាសាស្ត្រចាប់ផ្តើមចាក់ឫសចាប់ពីចុងយុគសម័យមជ្ឈិមមកម្ល៉េះ។ ការពន្យល់តាមបែបវិជ្ជមាន គឺជាការពន្យល់ដែលឈរលើមូលដ្ឋាននៃច្បាប់ដែលផ្សារភ្ជាប់បាតុភូតដែលកើតឡើងជាបន្តបន្ទាប់។

**ចំណាត់ថ្នាក់នៃវិជ្ជាសាស្ត្រ** ៖ វិទ្យាសាស្ត្រនីមួយៗត្រូវឆ្លងកាត់ដំណាក់កាលទាំងបីខាងលើនេះ។ នៅដំណាក់កាលទីមួយ គឺមានលេខនព្វន្ត បន្ទាប់មកគឺ មេកានិច តារាសាស្ត្រ រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា។ នៅដំណាក់កាលទីពីរ ការសិក្សាវិទ្យាសាស្ត្រកាន់តែមានភាពស្មុគ្រស្មាញដោយសារតែការករកើតឡើងនៃសង្គម ហើយវិទ្យាសាស្ត្រថ្មីបានកើតឡើងគឺរូបវិទ្យាសង្គម ឬសង្គមវិទ្យា។ នៅពេលដែលវិទ្យាសាស្ត្របានវិវត្តទៅមុខយ៉ាងលឿន គេឈានដល់ដំណាក់កាលទីបីដែលជាដំណាក់កាលវិជ្ជមាននិយម។ នៅក្នុងដំណាក់កាលនេះ **អូហ្គុស កុងត៍** បានបង្កើតសីលធម៌សង្គមឈរលើមូលដ្ឋានវិទ្យាសាស្ត្រ និងពុទ្ធិសង្គមដែលជាវិទ្យាសាស្ត្រវិជ្ជ-មាន។ ប្រព័ន្ធគំនិតរបស់ **អូហ្គុស កុងត៍** គឺដំបូងគេមានបទពិសោធបន្ទាប់មក ដោយឈរលើមូលដ្ឋាននៃព្រឹត្តិការណ៍ដែលគេអាចសង្កេតឃើញគេបង្កើតបានជាច្បាប់ ហើយច្បាប់នេះអាចឱ្យគេយល់បានពីទិដ្ឋភាពជាក់ស្តែងនៃមនុស្ស និងសង្គម។ ក្នុងន័យនេះ **អូហ្គុស កុងត៍** យល់ឃើញថាការវិវត្តនៃវិទ្យាសាស្ត្រអាចឱ្យគេលែងត្រូវការការពន្យល់តាមបែបបរមត្ថវិទ្យាទៀតហើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អង់រី ប៊ែកសុន
## (១៨៥៩-១៩៤១)

*ទស្សនវិជ្ជារបស់* **អូហ្គុស កុងត៍** *គឺជាទស្សនវិជ្ជាដែលឈរលើមូលដ្ឋាននៃវិទ្យាសាស្ត្រ ដើម្បីពន្យល់សារៈសំខាន់របស់មនុស្ស និងសង្គម។ ផ្ទុយទៅវិញទស្សនវិជ្ជារបស់* **អង់រី ប៊ែកសុន** *(Henri Bergson)» គឺជាប្រតិកម្មទៅនឹងចរន្តនៃ«***ទស្សនវិជ្ជាវិជ្ជមាននិយម***»។ លោកកើតនៅទីក្រុងប៉ារីសក្នុងគ្រួសារជ្វីហ្វ ហើយស្លាប់នៅក្នុងឆ្នាំ១៩៤១ នៅពេលដែលទ័ពអឺត្លែរកំពុងកាន់កាប់ទីក្រុងប៉ារីស។ ដូច***សូក្រាត***ដែលមិនសុខចិត្តលួចរត់ចេញពីគុក* **អង់រី ប៊ែកសុន** *សុខចិត្តឈរតម្រង់ជួរដូចគេឯងយ៉ាងយូរ ក្នុងសីតុណ្ហភាពដ៏ត្រជាក់ រួចមកក៏ធ្លាក់ខ្លួនឈឺ រហូតដល់ស្លាប់។*

**ស្នាដៃសំខាន់** ៖ *ស្នាដៃទីមួយរបស់លោក គឺជានិក្ខេបបទថ្នាក់បណ្ឌិតដែលមានចំណងជើងថា ៖ «***សិក្សាកថាស្តីពីទិន្នន័យភ្លាមៗនៃសម្បជញ្ញៈ*** (Essai sur les données immédiates de la conscience)» 1889 គឺជាការសិក្សាលើសម្បជញ្ញៈរបស់មនុស្ស។*

**សម្បជញ្ញៈរបស់ខ្លួន** *(la conscience de soi)* ៖ *បែកចេញជាពីរ (១) ការផ្លាស់ប្តូរស៊ីជម្រៅនៃខ្ញុំ(le devenir profound du moi) គឺជាគុណភាព (la qualité) និងភាពខាងក្នុង(l'intériorité) ដែលនៅក្នុងនោះសារជាតុទាំងអស់ច្របាច់បញ្ចូលគ្នា និងបង្កើតថ្មីក្នុងរយៈពេលកំណត់មួយ និង (២) លំហ និងពេលវេលា(espace-temps) នៃការផ្លាស់ប្តូរនេះ ដែលជាផ្នែកខាងក្រៅ(l'extériorité) និងជាបរិមាណ(la quantité) ។ ឧទាហរណ៍ នាម៉ោង៦ នាឡិកាប៉ោលគោះជួង៦ដងផ្ទួនៗគ្នា ស្នូរជួងទាំង៦លើកនេះលាន់ជាប់ៗគ្នាក្នុងរយៈពេលណាមួយ។ ក៏ប៉ុន្តែ សម្រាប់ខ្ញុំខាងក្នុង(le moi intérieur) ស្នូរជួងទាំង៦នេះប្រៀបបីដូចជាបទភ្លេងដែលធ្វើឱ្យសម្បជញ្ញៈធ្វងកាត់*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នូវដំណាក់កាលគុណភាព។ ស្ទួរជួងទី២ខុសពីស្ទួរជួងទី១។

សរុបមក នៅពេលដែលគេវាយជួង គេឃើញមានទិដ្ឋភាពពីរយ៉ាង ៖ (១) **ពិជ្ជភាពបរិមាណ** (multiplicité quantitative) ដែលយើងអាចរាប់បាន និងអាចវាយតម្លៃបានដោយប្រើប្រាស់ចំនួន។ ទិដ្ឋភាពបរិមាណនេះពាក់ព័ន្ធទៅនឹង **ខ្ញុំសំបកក្រៅ** (le moi superficiel) ដែលជាជាតុផ្សេងមួយ ហើយដែលគេប្រើចំពោះវត្ថុ និង (២) **ពិជ្ជភាពគុណភាព** (multiplicité qualitative) ដែលពាក់ព័ន្ធទៅនឹង **ជីជម្រៅនៃខ្ញុំ** (le moi profond) ដែលជា **ខ្ញុំពិតប្រាកដ** (le moi véritable) ។ គឺនៅក្នុងខ្ញុំនេះហើយដែល លោក **ប៊ែកសុន** ហៅថា **សេរីភាព** (la liberté)។

**សេរីភាព** (la liberté) និង **បច្ចយនិយម** (déterminisme) ៖ គោលការណ៍បច្ចយនិយម គឺ អ្វីៗទាំងអស់មានហេតុផល(tout a une cause)។ នៅក្នុងលក្ខខណ្ឌដូចគ្នា គេមានហេតុផលដូចគ្នា ដែលបណ្តាលឱ្យមានបច្ចយដូចគ្នា។ **ប៊ែកសុន**យល់ថា បញ្ចយនិយមអាចអនុវត្តបានចំពោះពេលវេលាដែលដូចៗគ្នា គឺជា «លំហ-ពេលវេលា» ដែលជាផ្នែកខាងក្រៅ។ ក៏ប៉ុន្តែ គោលការណ៍បច្ចយនិយមនេះមិនអាចអនុវត្តបានចំពោះ **ជីជម្រៅនៃខ្ញុំ** (le moi profond) បានឡើយ ដោយសារពីពេលមួយ ទៅពេលមួយទៀត គឺសុទ្ធតែខុសគ្នាទាំងអស់។ ក្នុងន័យនេះ **ជីជម្រៅនៃខ្ញុំ** មិនចំណុះឱ្យគោលការណ៍ **បច្ចយនិយម** ឡើយ។

**សកម្មភាពសេរី** (un acte libre) ៖ សកម្មភាពសេរី គឺជាសកម្មភាពដែលធ្វើដោយ **ជីជម្រៅនៃខ្ញុំ** (le moi profond) ទាំងស្រុងដែលបង្កើតឡើងដោយគុណភាពនៃរយៈពេលសុទ្ធ(la multiplicité qualitative de la durée pure) ពោល គឺគេអាចធ្វើសេចក្តីសម្រេចចិត្តពីជម្រៅនៃភាវៈទាំងស្រុងតែម្តង។ ដូច្នេះ សេរីភាព គឺជាសកម្មភាពសេរីនៃ **ជីជម្រៅនៃខ្ញុំ** នៅក្នុងរយៈពេលសុទ្ធ (la liberté est un acte libre du moi profound dans la durée pure)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សារធាតុ** *(la matière)* និង **អាត្ម័ន** *(l'âme)* ៖ ទ្វិកនិយម *(le dualisme)* របស់ **ប៊ែកសុន** ផ្ដោតលើទំនាក់ទំនងរវាងសារធាតុ និងអាត្ម័ន។ នៅក្នុងស្នាដៃ *Matière et Mémoire* **ប៊ែកសុន** បានកត់សម្គាល់ថា សារធាតុស្ថិតនៅក្នុងពិភពនៃលំហនៃរាងកាយ។ ការចងចាំ*(mémoire)* ស្ថិតនៅក្នុងពិភពនៃរយៈពេលសុទ្ធ ទីជម្រៅនៃខ្ញុំ ពោលគឺជាអាត្ម័នដែលនៅក្នុងនោះ គឺជាសេរីភាព។ រាងកាយ គឺជាឧបករណ៍នៃកម្មភាពដែលអាចឱ្យគេឃើញវត្ថុ ហើយអាចធ្វើសកម្មភាព ដោយប្រើប្រាស់ឧបករណ៍នេះ។

ទំនាក់ទំនងរវាងអាត្ម័ន និងរាងកាយប្រៀបបីដូចជាសាជីដែលមានកំពូលប៉ះទៅនឹងផ្ទៃនៃលំហ។ ចុងសាជីប្រៀបបីដូចជា **ទីជម្រៅនៃខ្ញុំ** សរុបដែលរស់នៅក្នុងរយៈពេលសុទ្ធ ហើយដែលប៉ះជាមួយលំហខាងក្រៅ ប្រៀបបីដូចជាសកម្មភាពខាងក្រៅ។ នៅពេលដែលរាងកាយយើងកម្រើក ចលនានៃរាងកាយនេះប៉ះទៅនឹងលំហខាងក្រៅ។ ខួរក្បាលដែលនៅលើដងខ្លួន គឺជាសរីរាង្គដែលមានតួនាទីគិត និងចងចាំ ដែលស្ថិតនៅខាងក្នុងទីជម្រៅនៃខ្ញុំ ដែលផ្ទុកទៅដោយអនុស្សាវរីយ៍សុទ្ធ។ ដូច្នេះ ខួរក្បាលស្ថិតនៅចុងសាជី ដែលជាកន្លែងជួបប្រសព្វជាមួយមជ្ឈដ្ឋានខាងក្រៅ។

**ប៊ែកសុន** យល់ថា អាត្ម័នមិនចំណុះឱ្យខួរក្បាលទេ តែវាឯករាជ្យពីខួរក្បាល និងពីរាងកាយរបស់មនុស្ស។ ដូច្នេះ គេអាចសន្និដ្ឋានថា អាត្ម័នអាចរស់នៅជាអមតៈ។

**បញ្ហាជីវិត** *(le problème de la vie)* ៖ នៅក្នុងស្នាដៃ *L'Évolution créatrice* ដែលបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩០៧ **ប៊ែកសុន** ធ្វើការវិភាគពីបញ្ហាជីវិត។ សត្វមានជីវិតមានសមត្ថភាពបង្កើត ដោយគ្មានព្រំដែន ដើម្បីបន្សាំទៅនឹងតម្រូវការចាំបាច់របស់ពួកគេ។ **ប៊ែកសុន** បានទាត់ចោលអំណះអំណាងរបស់ទស្សនវិជ្ជាវិជ្ជមាននិយមដែលយល់ថាគេអាចចាត់ទុកថាជាវិទ្យាសាស្ត្រ រាល់បាតុភូតទាំងឡាយណាដែលអាចពន្យល់បានដោយប្រើវិធីសាស្ត្រមេកានិច ហើយនៅគ្រប់កម្រិតទាំងអស់នៃវិទ្យាសាស្ត្រ គឺជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទំនាក់ទំនងរវាងហេតុ និងបច្ច័យ។ តាមទ្រឹស្តីនៃទស្សនវិជ្ជាវិជ្ជមាននិយម អ្វីដែលកើតឡើងមុន កំណត់បច្ច័យនៃអ្វីដែលនឹងកើតមានខាងក្រោយ ហើយអ្វីៗទាំងអស់កើតមានឡើងទៅតាមផែនការដែលគ្រោងទុកជាមុន។ **ប៊ែកសុន** បានទាត់ចោលការពន្យល់បែប បច្ច័យនិយម ក៏ដូចជាការពន្យល់ថា ភាវៈដ៏មានមហិទ្ធិឫទ្ធិដ៏អស្ចារ្យ ឬអាទិទេពគឺជាអ្នកកំណត់អនាគត និងអ្វីៗដែលនឹងកើតមានឡើង។ លោកយល់ឃើញថា ជីវិតគឺជាការបង្កើតជាបន្តបន្ទាប់ដោយគ្មានទីបញ្ចប់ដែលលោកឱ្យឈ្មោះថា **ជំហរជីវិត** (élan vital)។ អំណះអំណាងនេះ គឺជាមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវនៃជីវវិទ្យាម៉ូលេគុល។

**សភាវគតិ** (l'instinct) និង **បញ្ញា** (l'intelligence) ៖ សភាវគតិប្រើចំពោះសត្វ ចំណែកបញ្ញា ប្រើចំពោះមនុស្ស។ **សភាវគតិ** គឺជាសភាពនៃជំហរជីវិតដែលសត្វប្រើប្រាស់ដើម្បីសម្របសម្រួល និងបន្សាំទៅនឹងបរិស្ថានជុំវិញខ្លួន។ នៅពេលសត្វត្រូវឆ្លើយតបទៅនឹងមជ្ឈដ្ឋានជុំវិញ សត្វត្រូវប្រើ-ប្រាស់សភាវគតិរបស់ខ្លួន ដោយមិនចាំបាច់គិត ឬមិនចាំបាច់មើល ដើម្បីបំពេញតាមតម្រូវការចាំបាច់របស់ខ្លួន។ សភាវគតិ គឺជាចំណេះដឹង និងដំណើរការដែលកើតឡើងដោយឯកឯង ដោយមិនដឹងខ្លួន(inconscient)។ **បញ្ញា** គឺជាឧបករណ៍ដែលមនុស្សប្រើប្រាស់ ដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន តាមរយៈការយល់ ការប្រមើលមើល ត្រិះរិះពិចារណា រៀបចំផែនការ។ បញ្ញាពុះចិញ្ច្រាំទិន្នន័យនៃតថភាពជាក់ស្តែងជាកំណាត់ៗ ដើម្បីងាយស្រួលក្នុងការត្រិះរិះពិចារណា និងវិភាគ។ សភាវគតិ និងបញ្ញាមិនមែនផ្ទុយគ្នាទេ តែគឺនៅជាមួយគ្នា។

**សហជញ្ញាណ** (l'intuition) ៖ **សហជញ្ញាណ** គឺជាសភាវគតិដែលឈានដល់កម្រិតមួយដែលអាចផ្តាច់ចេញពីសកម្មភាពផ្ទាល់របស់វាដែលអាចគិត និងត្រិះរិះពីកម្មវត្ថុ។ ទស្សនវិជ្ជារបស់**ប៊ែកសុន** ត្រូវបានគេចាត់ទុកថា ជាទស្សនវិជ្ជាសហជញ្ញាណ។ ពុទ្ធិសហជញ្ញាណ គឺជាពុទ្ធិ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលត្រឹមត្រូវ តែដែលគេមិនទាន់អាចបង្ហាញបានថាត្រឹមត្រូវ។ អ្នកប្រាជ្ញខ្លះបានធ្វើការសន្និដ្ឋានលើទិន្នន័យវិទ្យាសាស្ត្រដោយត្រឹមត្រូវ ប៉ុន្តែគេនៅមិនទាន់អាចរកអំណះអំណាងតាមផ្លូវវិទ្យាសាស្ត្របានក៏ដោយ។ យើងអាចនិយាយម្យ៉ាងបានទៀតថា សហជញ្ញាណ គឺជាសំយោគរវាងសភាវគតិ និងបញ្ញារបស់មនុស្ស។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សូរ៉េន គៀរគីហ្គាដ
## (១៨១៣-១៨៥៥)

**សូរ៉េន គៀរគីហ្គាដ** *(Sören Kierkegaard)* និង **ហ្វ្រីដ្រីច នីតស៍** *(Friedrich Nietzsche)* គឺជាទស្សនវិទូនៃសតវត្សរ៍ទី១៩ដែលគេចាត់ទុកថាជាអ្នកនៅក្រោចរន្តគំនិត។ ទស្សនវិទូទាំងពីរបានខិតខំធ្វើយតបទៅនឹងការប្រឈមធំៗជាច្រើន។ ចំពោះពួកគេ ការត្រិះរិះពិចារណាតាមបែបទស្សនវិជ្ជា មិនអាចកាត់ផ្តាច់បានពីប្រវត្តិរូបរបស់គាត់។ ហើយ **គៀរគីហ្គាដ** និង **ហ្វ្រីដ្រីច នីតស៍** បានឆ្លងកាត់នូវកម្រងទស្សនវិជ្ជា ហើយទស្សនវិជ្ជារបស់ពួកគេកើតចេញពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ ដូច្នេះ ដើម្បីយល់ពីទស្សនវិជ្ជារបស់ពួកគេ ត្រូវដឹងពីប្រវត្តិរបស់ពួកគេជាមុនសិន។

**សូរ៉េន គៀរគីហ្គាដ** *(Sören Kierkegaard)* កើតនៅក្នុងឆ្នាំ១៨១៣ ហើយស្លាប់នៅក្នុងឆ្នាំ១៨៥៥ នៅកូប៉េអាក។ ឪពុករបស់**គៀរគីហ្គាដ**បានរៀបការជាលើកទីពីរជាមួយស្រីបម្រើរបស់ខ្លួន ហើយពេលដែល**គៀរគីហ្គាដ**ចាប់កំណើត ឪពុកលោកមានអាយុ៥៦ឆ្នាំទៅហើយ។ បន្ទាប់ពីធ្វើជំនួញក្លាយទៅជាអ្នកមាន គាត់បានដកខ្លួនថយ ដើម្បីរស់នៅដោយស្ងប់ស្ងាត់ ធ្វើការសិក្សា និងគោរពបូជាគ្រិស្តសាសនាយ៉ាងខ្ជាប់ខ្ជួន។ **គៀរគីហ្គាដ** ទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីឪពុករបស់លោក។ តាំងពីនៅកុមារវ័យ គាត់ចូលចិត្តបិទមុខ ពួន និងស្លៀកពាក់ក្លែងបន្លំ។ នៅពេលធំពេញវ័យ លោកសរសេរដោយប្រើពាក្យពេចន៍មិនចំពោះ ហើយមិនពិភាក្សាលើប្រធានបទដោយត្រង់ៗ ដោយសរសេរវាលវង់សិន មុននឹងចូលដល់ប្រធានបទ តាមរយៈការប្រើតួអង្គដែលគាត់ប្រឌិតឡើង ដើម្បីពិភាក្សា។ គាត់បានចូលរៀនសាសនាវិទ្យា នៅសាកលវិទ្យាល័យកូប៉េនអាក។ នៅក្នុងឆ្នាំ១៨៤១ **គៀរ-គីហ្គាដ** បានប្រឡងជាប់សញ្ញាបត្រខាងផ្នែកសាសនាវិទ្យា ដោយការពារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និក្ខេបបទដែលមានចំណងជើងថា «ទស្សនាទាននៃការចំអក ដោយលើកយក**សូក្រាត**ជាឧទាហរណ៍»។ ជីវិតរបស់ **គៀរគឺហ្គាដ** ជួបប្រទះនឹងបញ្ហាបីយ៉ាងគឺ ចំណង់ឥតស្រាកស្រាន្ត ការមន្ទិលសង្ស័យ និងក្ដីអស់សង្ឃឹម។ នៅពេលមានអាយុ២៨ឆ្នាំ លោកបានភ្ជាប់ពាក្យជាគូដណ្ដឹងជាមួយក្មេងស្រីម្នាក់អាយុ១៨ឆ្នាំ។ បន្ទាប់មកលោកយល់ថា គឺជាការយល់ច្រឡំទៅវិញ ដោយលោកមានតណ្ហាចង់នៃបនិតជាមួយនារីនោះ តែមិនចង់បានធ្វើជាគូស្រករទេ។ បន្ទាប់ពីឆ្លងកាត់ការឈឺចាប់អស់រយៈពេលមួយឆ្នាំមក **គៀរ-គឺហ្គាដ** បានប្រគល់ចិញ្ចៀនបញ្ជាំចិត្តទៅឱ្យនារីជាគូដណ្ដឹង ដើម្បីផ្ដាច់ពាក្យជាមួយនាងវិញ។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់ **គៀរគឺហ្គាដ** គឺ **«ទស្សនាទាននៃការចំអក ដោយលើកយកសូក្រាតជាឧទាហរណ៍»***(Le Concept d'ironie constamment rapport à Socrate)* **«អភិប្រាយនៃក្ដីអស់សង្ឃឹម»** *(Traité du désespoir)* **«ការភ័យខ្លាច និងការញាប់ញ័រ»** *(Crainte et tremblement)* **«កម្ទេចទស្សនវិជ្ជា»** *(Miettes philosophiques)*។

**គៀរគឺហ្គាដ** គឺជាទស្សនវិទូដែលចូលចិត្តធ្វើសង្គ្រាមប៉ាកកា។ នៅក្នុងពេលជាមួយ លោកសរសេរទិតៀនសាសនាគ្រិស្ត និងវិហារកាតូលិកផង និងសរសេរអត្ថបទដើម្បីកសាងគ្រិស្តសាសនាផង។ ពេលខ្លះគ្រឹះស្ថានបោះពុម្ពផ្សាយស្នាដៃរបស់លោកត្រូវរត់ចោលស្រុកទៀតផង។ លោកយល់ថា លោកមានបេសកកម្មពិសេសដែលត្រូវបំពេញ តាមរយៈពាក្យសម្ដីសំណេរ និងសកម្មភាពជាក់ស្ដែង ក្នុងការតស៊ូប្រឆាំងនឹងវិហារកាតូលិកដាណឺម៉ាក។

**គៀរគឺហ្គាដ** ចាត់ទុកខ្លួនឯងថាជាទស្សនវិទូឯកជន ដោយសំណេររបស់លោក គឺជាសំណេរដែលមានលក្ខណៈបុគ្គល។ ក៏ប៉ុន្តែ អ្វីដែលលោកសរសេរមានគោលដៅដាស់សាធារណជនឱ្យយល់ពីសាសនាកាតូលិក។ ក្នុងវិស័យទស្សនវិជ្ជា លោកខ្ចីពី**ហេហ្គែល** នូវ **វិចារវិជ្ជា**។ ក៏ប៉ុន្តែ វិចារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិទ្យារបស់ **គៀរគឺហ្គាដ** ខុសពីវិចារវិទ្យារបស់ **ហេហ្គែល** ដែលមានគោលដៅឈ្វេងយល់និងដោះស្រាយមតិផ្ទុយទំនាស់និងវិវាទនៃប្រវត្តិសាស្ត្រសាកលលោក។ **ហេហ្គែល** យល់ថា «អ្វីដែលពិត គឺមានវិចារណញ្ញាណ ហើយអ្វីដែលមានវិចារណញ្ញាណត្រូវតែពិត»។ ចំណែក **គៀរគឺហ្គាដ** យល់ថាគេមិនអាចស្មោះត្រង់ដាច់ខាតទៅនឹងគ្រិស្តសាសនាបានឡើយ។ បើចង់ស្មោះ ត្រូវតែពាក់របាំងមុខ ឬក៏ត្រូវប្រើពាក្យពេចន៍មិនចំពោះ។ ទន្ទឹមនឹងនេះ លោកក៏មានមតិផ្ទុយដែរ(paradoxe) ដោយសារតែលោកច្រើនលើកយកដីការរបស់ព្រះជាម្ចាស់មកនិយាយ។

ទស្សនវិជ្ជារបស់ **គៀរគឺហ្គាដ** ផ្តោតលើន័យនៃជីវិត ឬអត្ថិភាពរបស់មនុស្សដែលបង្កើតឱ្យមានចរន្តទស្សនវិជ្ជាមួយដែលមានឈ្មោះថា «**អត្ថិភាពនិយម**» (existentialisme)។ នៅក្នុងស្នាដៃរបស់លោកដែលមានចំណងជើងថា L'Instant **គៀរគឺហ្គាដ** បញ្ជាក់ពីតម្លៃដាច់ខាតរបស់បុគ្គលម្នាក់ៗ នៃភាពអត្តនោម័តនៃបុគ្គលម្នាក់ៗ និងនៃ **ពេលព្រមៗគ្នា** (l'instant) ដែលបានកន្លងផុតទៅ។

**អត្ថិភាព** (l'existence) ៖ គឺជាការកើតឡើងនៃសេរីភាពទទួលខុសត្រូវរបស់ប្រធាន។ ប្រសិនបើយើងមើលអ្វីៗដែលកើតឡើងពីខាងក្រៅ យើងឃើញទឹកហូរ មែកឈើធ្លាក់ មនុស្សកំពុងធ្វើអ្វីមួយដែលកើតឡើងព្រមៗគ្នា។ ក៏ប៉ុន្តែ សកម្មភាពសេរីរបស់មនុស្សវាខុសពីធម្មជាតិ។ សកម្មភាពរបស់មនុស្សចេញមកពីបេះដូងរបស់មនុស្សដែលមានការទទួលខុសត្រូវ។ មនុស្សដែលមានសកម្មភាព មិនមែនបណ្តាលមកពីទំនាក់ទំនងរវាងហេតុនិងបច្ច័យឡើយ។ សកម្មភាពសេរីរបស់មនុស្សមានប្រភពផ្សេង សកម្មភាពនេះបង្កើតឱ្យមាន **ការកាត់ផ្តាច់អត្ថិភាព** (une rupture existentielle)។ ហើយ **គៀរគឺហ្គាដ** ជាអ្នកបង្កើតពាក្យ **អត្ថិភាព** (l'existence) នេះឡើង។ ពាក្យអត្ថិភាពនេះមិនមែនមានន័យថាជាវត្តមាននៃវត្ថុអ្វីមួយនៅក្នុងតថភាពឡើយ តែមានន័យថា ការចេញពីកំអែនៃវត្ថុ ការបង្កើតឱ្យមានការកាត់ផ្តាច់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលមិនមែនជាលទ្ធផលនៃការបន្តដូចៗគ្នាឡើយ។ នៅពេលដែលមនុស្សធ្វើសេចក្តីសម្រេចចិត្តដោយសេរី គេបង្កើតឱ្យមានការកាត់ផ្តាច់អត្ថិភាព។ គឺជាសកម្មភាពដែលប្រធានបទមានវត្តមាន ដោយឆ្លងកាត់ពេលវេលាដែលចេះតែបន្ត និងបុកទម្លាយពេលវេលានេះ ដែល **គៀរគឺហ្គាដ** ហៅថា **ពេលព្រមៗគ្នា** (l'instant)។ ទស្សនាទាននៃពេលវេលាត្រូវផ្សាភ្ជាប់ជាមួយនឹងប្រធានបទដែលធ្វើសេចក្តីសម្រេចចិត្តនៅក្នុងពេលនោះ និងមានសកម្មភាពនៅក្នុងពេលនោះ ហើយតាមរយៈការកាត់ផ្តាច់អត្ថិភាពនេះប្រធានបទឆ្លងកាត់ពេលនេះ។ គេមិនមែនឆ្លងកាត់ពេលវេលាទេ តែនេះគឺជា**ពេលព្រមៗគ្នា** (l'instant)។ ដូច្នេះ ទស្សនាទាន អត្ថិភាព និងពេលវេលា មិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ ដើម្បីគូសបញ្ជាក់ពីតថភាពដាច់ខាតតែមានតែមួយ។

**យេស៊ូគ្រិស្ត** (le Christ) ៖ ព្រះ**យេស៊ូគ្រិស្ត** គឺជាមតិផ្ទុយគ្នាដាច់ខាត (le paradoxe absolu) ពោលគឺព្រះយេស៊ូមិនអាចបង្ហាញពីកស្តុតាងនៃធម្មជាតិផ្ទុយគ្នារបស់ខ្លួន ហើយក៏មិនបានបដិសេធផងដែរ។ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា Post-scriptum **គៀរគឺហ្គាដ** ប្រៀបធៀប**សូក្រាត**ទៅនឹង**យេស៊ូគ្រិស្ត**។ លោកថា **សូក្រាត**ដែលជាគ្រូបានជួយឱ្យសាវករបស់លោករកឃើញនូវការពិត ដោយបង្រៀនពួកគេពីវិធីសាស្ត្ររកការពិតដោយខ្លួនឯង ចំណែកឯ**យេស៊ូគ្រិស្ត**ដែលជាព្រះ គឺជាសារជាតុនៃការរកឃើញនេះតែម្តង។ ចំណែកឯភាពខុសគ្នារវាង**សូក្រាត** និង**យេស៊ូគ្រិស្ត** គឺ**យេស៊ូគ្រិស្ត**បានត្រឹមតែបង្រៀនការពិត ហើយខ្លួនឯងនេះជាការពិតតែម្តង តាមរយៈជំនឿ។ ចំពោះ **គៀរគឺហ្គាដ** អ្នកជឿសាសនាគ្រិស្តវាជាការចាំបាច់ផង និងមិនអាចទៅរួចផង ហើយគ្មាននរណាម្នាក់អាចជាអ្នកជឿសាសនាគ្រិស្តពិតប្រាកដឡើយ ដោយពួកគេបានត្រឹមតែជាតំណាងផ្លូវការនៃព្រះវិហារកាតូលិកប៉ុណ្ណោះ។

**ជំណាក់កាលទាំងបីនៃអត្ថិភាព** ៖ បើតាម **គៀរគឺហ្គាដ**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អត្ថិភាពអាចចែកចេញជាបីដំណាក់កាល ៖ (១) ដំណាក់កាលសោភ័ណភាព (Le stade esthétique)៖ គឺជាដំណាក់កាលដែលជីវិតផ្ដោតទៅលើខណៈដាច់ៗពីគ្នា និងដែលគ្មានទំនាក់ទំនងជាមួយគ្នា ពោរពេញដោយការផ្លាស់ប្ដូរដ៏លើសលប់។ ដំណាក់កាលនេះ គឺជាដំណាក់កាលមួយដែលគ្មានការសន្យាអ្វីទាំងអស់ ហើយដែលពោរពេញដោយសេរីភាព (២) ដំណាក់កាលសីលធម៌(Le stade éthique) ៖ ដែលជាដំណាក់កាលផ្ទុយពីដំណាក់កាលសោភ័ណភាព ដោយវាជាដំណាក់កាលនៃការសន្យា(l'engagement) និងនៃការស្មោះត្រង់(fidélité) ដូចជាអាពាហ៍ពិពាហ៍ (៣) ដំណាក់-កាលសាសនា(Le stade religieux) ដែលមានទាំងសមាសធាតុនៃដំណាក់កាលទី១ផង និងទី២ផង។ នៅដំណាក់កាលនេះ **ពេលវេលាព្រមៗគ្នា** (l'instant) កាន់តែមានភាពស្វាហាប់ខ្លាំងឡើង រហូតដល់ភាពអមតៈ។ គេឃើញមានទំនាក់ទំនងវិចារវិទ្យារវាងពេលវេលាព្រមគ្នា និងភាពអមតៈ។

**ការសើចចំអក** (l'ironie) ៖ **គៀរគឺហ្គាដ** ប្រើវិធីសាស្ត្រសើចចំអកដើម្បីរកការពិត ឬដើម្បីកាត់បន្ថយការភូតកុហក។ ដូច្នេះហើយ ទើបគាត់សរសេរសៀវភៅដោយប្រើរហស្សនាម ឬឈ្មោះក្លែងក្លាយជាច្រើន។ មូលហេតុសំខាន់ គឺគាត់ចង់លាក់ឈ្មោះពិត ដើម្បីអាចប្រកាន់យកមតិខុសៗគ្នា។ តួនាទីជាសារវ័ន្តនៃការសើចចំអកនេះ ឬការចង់នៅឱ្យឆ្ងាយពីឈ្មោះពិត គឺដើម្បីបង្ហាញពីការពិតបាន។ **គៀរគឺហ្គាដ** យល់ឃើញថាគ្មាននរណាម្នាក់អាចជាអ្នកជឿសាសនាគ្រិស្តពិតប្រាកដឡើយ គ្មាននរណាម្នាក់អាចជឿព្រះពិតប្រាកដឡើយ ហើយក៏គ្មាននរណាម្នាក់អាចមានទស្សនៈតែមួយបានឡើយ (l'unicité subjective)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្វ្រីដ្រីច នីតស៍
## (១៨៤៤-១៩០០)

*ទស្សនវិជ្ជារបស់* **សូរ៉េន គៀរគឺហ្គាដ** *(Sören Kierkegaard) និង* **ហ្វ្រីដ្រីច នីតស៍** *(Friedrich Nietzsche) មានចំណុចដូចគ្នាច្រើនផង និងខុសគ្នាច្រើនផង។* **នីតស៍** *កើតនៅឆ្នាំ១៨៤៤ នៅក្នុងប្រទេសអាឡឺម៉ង់ ១១ឆ្នាំមុន* **គៀរគឺហ្គាដ** *ស្លាប់។ ឪពុកលោក គឺជាអាចារ្យនៃសាសនាប្រូតែស្តង់ ហើយបានទទួលមរណៈភាព នៅពេលដែលលោកមានអាយុ ៥ឆ្នាំនៅឡើយ។* **នីតស៍***បានសិក្សាអក្សរសាស្ត្រក្រិក និងជាទស្សនវិទូបុរាណនិយម។ លោកត្រូវបានគេអនុញ្ញាតឱ្យធ្វើជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Bâle មុនពេលដែលគាត់បញ្ចប់ការសិក្សាទៅទៀត។ នៅពេលដែល* **នីតស៍** *មានអាយុ ២៤ ឆ្នាំនៅឡើយ សាស្ត្រាចារ្យទស្សនវិជ្ជារបស់លោកបាននិយាយថា ៖* **នីតស៍** *គឺជាបាតុភូត គឺជាគំរូសម្រាប់យុវជនទាំងឡាយ ជាមនុស្សម្នាក់ដែលគួរឱ្យស្រឡាញ់ផង និងដែលមានអាកប្ប-កិរិយាសុភាពរម្យទមផង។ លោកបានក្លាយជាសាស្ត្រាចារ្យអក្សរសាស្ត្រក្រិកពីឆ្នាំ១៨៦៩ដល់ឆ្នាំ១៨៧៩។ ដល់ឆ្នាំ១៨៧៩ លោកចាប់ផ្តើមឈឺក្បាល ហើយត្រូវបង្ខំចិត្តបោះបង់ចោលការបង្រៀន។ ក្នុងរយៈពេល១០ឆ្នាំ* **នីតស៍** *ត្រូវផ្លាស់ប្តូរទីកន្លែងរស់នៅជាញឹកញាប់។ សំណេររបស់លោកធ្វើឱ្យគេចាប់អារម្មណ៍ តែដល់ទីចុងបំផុត គាត់ត្រូវចេញថវិកាបោះពុម្ពសៀវភៅដោយខ្លួនឯង ដោយសារសាធារណៈជនលែងចាប់អារម្មណ៍ទៅលើអ្វីដែលលោកសរសេរ។ ដល់ឆ្នាំ១៨៨៩ ជំងឺសរសៃប្រសាទចាប់ផ្តើមវាយលុកពេញបន្ទុកដែលតម្រូវឱ្យលោកចូលព្យាបាលក្នុងមន្ទីរពេទ្យ ហើយ* **នីតស៍** *ទទួលមរណភាពនៅក្នុងឆ្នាំ១៩០០។*

*យើងឃើញថា* **នីតស៍** *គឺជាទស្សនវិទូពិសេសម្នាក់ដែលរស់នៅយ៉ាង*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លំបាក ដោយសារការគំរាមកំហែងនៃជំងឺ ហើយស្ថិតនៅក្នុងស្ថានភាពមួយដែលលោកមិនដែលសប្បាយចិត្តនឹងអ្វីបន្តិចសោះឡើយ។ ពោលគឺដូចគ្នានឹងទស្សនវិទូ **គៀរគីហ្គាដ** ដែលរស់នៅក្នុងពាក់កណ្ដាលទីមួយនៃសតវត្សរ៍ទី១៩ដែរ **នីតស៍** គឺជាទស្សនវិទូមួយរូបដែលមិនចេះរៀបចំជីវិតរបស់ខ្លួនឱ្យរស់នៅបានសមរម្យឡើយ។ ចំពោះ **នីតស៍** ដែលជាមនុស្សមានជំងឺជាប់ខ្លួន និងឈឺចាប់មិនអាចទ្រាំទ្របានចំពោះគាត់ «ព្រះស្លាប់បាត់ទៅហើយ»។ តែយ៉ាងណាក្ដី គាត់ត្រូវតែរស់នៅបន្តទៀត។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**នីតស៍** គឺ «**ហ្សារ៉ាត់ជូស្ត្រានិយាយដូច្នេះ**» *(Ainsi parlait Zarathoustra)* «**មនុស្សជម៌ មនុស្សជម៌ពេក**» *(Humain, trop humain)* «**អំពើល្អ និងអំពើអាក្រក់**» *(Par-delà le bien et le mal), (La Généalogie de la morale)*។

ទស្សនវិជ្ជារបស់ **នីតស៍** ផ្ដោតលើមនុស្ស តែគឺជាមនុស្សដែលរស់នៅក្នុងស្ថានភាពដែលមិនអាចទៅរួច(subjectivité impossible) គឺជាមនុស្សដែលមានចំណុចខ្វះខាត គឺជាភាវៈដែលមានកម្រិត។ ចំពោះ **នីតស៍** មនុស្សមិនដែលមានសេរីភាពឡើយ ហើយពឹងផ្អែកជានិច្ចទៅលើជោគវាសនារបស់ខ្លួន។ មនុស្សគឺជាតំណាងឱ្យការទាមទារ និងការគ្មានអំណាចចំពោះមុខឱ្យសេរីភាព(une exigence et une impuissance de la liberté)។ ធ្វើជាមនុស្សត្រូវទទួល និងប្រឹងប្រែងជម្នះរាល់ការលំបាកជានិច្ច។ ទន្ទឹមនឹងនេះគេមិនត្រូវទទួលយកនូវអ្វីដែលស្ថិតចំពោះមុខគេឡើយ។ មនុស្សមិនមែនត្រូវស្ថិតនៅក្នុងសភាពបច្ចុប្បន្នឡើយ ហើយទទួលយកសភាពបែបនេះឡើយ។ ដូច្នេះ មនុស្សមានកាតព្វកិច្ចជម្នះរាល់ឧបសគ្គ។ ប្រសិនមនុស្សនិយាយថា ខ្ញុំកំសាក នោះមានន័យថាខ្ញុំចាប់ផ្ដើមកំចាត់ភាពកំសាកនេះចេញពីខ្លួនខ្ញុំហើយ។

**មនុស្សខ្លាំង** *(le surhomme)* ៖ **នីតស៍** យល់ឃើញថា មនុស្សខ្លាំងគឺជាមនុស្សដែលខិតខំប្រឹងប្រែងឥតឈប់ឈរ ដើម្បីកែប្រែតថភាពជាក់ស្ដែង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងកំហិតទាំងឡាយឱ្យកាន់តែប្រសើរ ដោយប្រើប្រាស់នូវថាមពលនវកម្ម ដែលមិនចេះអស់។ មនុស្សមិនមែនត្រឹមតែមនុស្សប៉ុណ្ណោះទេ ប្រសិនបើគេមិនខិតខំឱ្យក្លាយទៅជាអ្វីដែលគេមិនអាចធ្វើបាន ពោលគឺជាមនុស្សខ្លាំង។ ទស្សនាទាននេះជំរុញទៅមុខឥតឈប់ឈរ ហើយទាមទារគ្មានទីបញ្ចប់។ ពោល គឺត្រូវតែខំប្រឹងទៅឱ្យហួសពីអ្វីដែលធម្មជាតិផ្ដល់ឱ្យ និងរំដោះខ្លួនឱ្យផុតពីឧបសគ្គគ្រប់បែបយ៉ាង ដើម្បីទទួលបាននូវសេរីភាពប្រកបដោយនវកម្ម។ មនុស្ស គឺជាអ្នកសរសេរប្រវត្តិសាស្ត្រ។ មនុស្សត្រូវទាត់ចោលនូវអ្វីដែលមានរួចស្រេចហើយ។ ទស្សនាទាននេះ គឺការសំដែងនូវការមិនពេញចិត្តនឹងអ្វីដែលមនុស្សមាន ហើយត្រូវតែខិតខំសម្រេចឱ្យបានលើសពីសមិទ្ធផលដែលមានស្រាប់។ ក៏ប៉ុន្តែ នៅក្នុងប្រវត្តិសាស្ត្រគេធ្លាប់ប្រើប្រាស់ទស្សនាទាននេះខុសពីអ្វីដែល **នីតស៍** គិត។ ពួកណាហ្ស៊ីហ្វាស៊ីសបានប្រើប្រាស់នូវទស្សនាទាននេះ ដើម្បីប្រកាសថាពូជអាឡឺម៉ង់គឺជាពូជសាសន៍ដែលខ្លាំងជាងគេ។

**ឆន្ទៈរកការពិត** *(la volonté de vérité)* ៖ **នីតស៍** យល់ឃើញថា តថភាពអត្តនោម័ត ឬប្រកបដោយវិចារណញ្ញាណនៃវិទ្យាសាស្ត្រចំណុះឱ្យលក្ខខណ្ឌ ហើយមិនមែនជាតថភាពទាំងស្រុងឡើយ។ តថភាពទស្សនវិជ្ជាសំដៅលើអ្វីដែលហួសពីតថភាពសាមញ្ញដែលយើងឃើញទៅទៀត។ **នីតស៍** សង្កត់ធ្ងន់លើការបកស្រាយ។ លោកយល់ថា ជាទូទៅ គ្មានទេតថភាព មានតែការបកស្រាយនៃតថភាព និងការបកស្រាយលើការបកស្រាយប៉ុណ្ណោះ។ ដូច្នេះ ពុទ្ធិ គឺជាការបកស្រាយនៃភាវៈ ដោយកម្មវត្ថុ(sujet) ដែលមានជីវិតរស់នៅ ដែលចង់ដឹងពីភាវៈនេះ។ ក្នុងន័យនេះ តថភាពមិនអាចជាអ្វីដែលរឹង និងដែលមានឯករាជ្យពីកម្មវត្ថុ។ អ្វីដែលយើងឃើញមិនមែនជាតថភាពទេ។ យើងខិតខំចាប់តថភាពនេះដែលមិនចំណុះឱ្យយើង។ ដូច្នេះ អ្វីដែលសំខាន់ គឺគុណភាពនៃទំនាក់ទំនងរវាងកម្មវត្ថុ និងការពិត(réalité)ជាក់ស្ដែង ហើយគុណភាពនេះគឺជាធាតុផ្សំដ៏សំខាន់នៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តថភាពដែលតាមរកនេះ។

**ឆន្ទៈអំណាច** (*la volonté de puissance*) ៖ **នីតស៍** យល់ថា ពិភពលោក គឺជាជីវិត ពោលគឺមិនមែនទឹក ខ្យល់ ចំនួន ច្បាប់ ឬឆន្ទៈ ដូចទស្សនវិទូខ្លះយល់ឃើញឡើយ។ ជីវិត គឺជាឆន្ទៈអំណាច ហើយដូច្នេះ ពិភពលោក គឺជាឆន្ទៈអំណាច។ ឆន្ទៈអំណាចនេះមានន័យផ្សេងៗគ្នា ដូចជា ឆន្ទៈកំណើន ឱ្យខ្លាំងជាងមុន ឆន្ទៈប្រយុទ្ធ និងយកឈ្នះ ឆន្ទៈ យកឈ្នះលើខ្លួនឯង ធ្វើការពិសោធន៍ និងស្រាវជ្រាវ។ល។ បន្ទាប់ពីយក ឈ្នះលើខ្លួនឯងរួចមក ឆន្ទៈអំណាចនេះនាំមកនូវសេចក្តីរីករាយដល់អ្នក ដែលទទួលស្គាល់នូវភាពចាំបាច់នេះ។ ទស្សនាទាននេះផ្ទុះបញ្ចាំងពីទស្សនៈ ផ្ទុយគ្នារបស់ **នីតស៍** ។ នៅក្នុងសំណេររបស់**នីតស៍** គេតែងតែឃើញនូវ ការបកស្រាយផ្ទុយគ្នានៃទស្សនាទានរបស់គាត់។

**ព្រះស្លាប់បាត់ហើយ** (*Dieu est mort*) ៖ **នីតស៍** បានប្រយុទ្ធយ៉ាង ខ្លាំងក្លាប្រឆាំងនឹងសាសនាគ្រិស្ត។ នៅពេលខ្លះគេចាត់ទុកលោកថា ជា ទស្សនវិទូប្រឆាំងនឹងសាសនាទៀតផង។ លោកចាត់ទុកថា គ្រិស្តសាសនា គឺជាសាសនាដែលបង្កើតឡើងសម្រាប់អ្នកដែលខ្សោយ អ្នកកំសាក អ្នក ចាញ់ អ្នកដែលឈឺចាប់ និងអ្នកស្លាប់។ ក៏ប៉ុន្តែ ទន្ទឹមនឹងនោះ **នីតស៍** បាន ខិតខំបង្កើនឆន្ទៈអំណាច។ ចំពោះ **នីតស៍** មនុស្សដែលមានឆន្ទៈអំណាច នឹងមានសេរីភាពកាន់តែខ្លាំងឡើង និងមានមោទនភាពកាន់តែច្រើន។ **នីតស៍** យល់ឃើញថាព្រះយេស៊ូចងឆ្កាង គឺជានិមិត្តរូបនៃកំសោយ ការ ចុះញ៉ម ឬស្មារតីចុះចាញ់។ **នីតស៍** ប្រកាសថា ព្រះស្លាប់បាត់ទៅហើយ។ ចាប់ពីពេលនេះទៅ មនុស្សមិនត្រូវនិយាយពីព្រះ ឬពន្យល់អ្វីឱ្យព្រះស្តាប់ ឬជឿលើព្រះទៀតឡើយ។ មនុស្សត្រូវតែបង្វិចិត្តពឹងផ្អែកលើខ្លួនឯង ដោយ មិនត្រូវសង្ឃឹមលើព្រះជួយឡើយ។ មនុស្សត្រូវពឹងលើឆន្ទៈអំណាចរបស់ ខ្លួន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អេដមុន ហ៊ូស៊ែរ្យល
**(១៨៥៩-១៩៣៨)**

*បន្ទាប់ពី* **នីតស៍** *និង* **គៀរគឺហ្គាដ** *ទស្សនវិជ្ជាបានចែកចេញជាចរន្ត ចំនួនបីគឺ ៖ (១) បាតុភូតវិទ្យា (phénoménologie) ដែលបង្កើតឡើងដោយ* **អេដមុន ហ៊ូស៊ែរ្យល** *(២) ទស្សនវិជ្ជាអត្ថិភាពនិយម (existentialisme) និង (៣) ចរន្តនៃវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ។*

**អេដមុន ហ៊ូស៊ែរ្យល** *(Edmund Husserl) កើតនៅក្នុងឆ្នាំ ១៨៥៩ នៅ Mähren ប្រទេសអាឡឺម៉ង់ ក្នុងគ្រួសារពាណិជ្ជករជ្វីហ្វ។ លោកសិក្សាតារាវិទ្យា គណិតវិទ្យា និងរូបវិទ្យា តែមានចំណង់ចំណូលចិត្តពិសេសផ្នែកតក្កវិទ្យា។ នៅក្នុងឆ្នាំ១៩១៦ លោកត្រូវបានតែងតាំងជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Fribourg-en-Brisgau ដែលទស្សនវិទូម្នាក់ទៀតក៏គឺ* **ម៉ាទីន ហៃដឺហ្គ័រ** *ក៏ត្រូវបានតែងតាំងជាសាស្ត្រាចារ្យដែរ។ នៅឆ្នាំ១៩៣៣ អ៊ីត្លែរឡើងកាន់អំណាច ហើយបានហាមឃាត់មិនឱ្យជនជាតិជ្វីហ្វចូលសាកលវិទ្យាល័យ និងបណ្ណាល័យ។ ដូច្នេះ* **អេដមុន ហ៊ូស៊ែរ្យល** *ត្រូវបានគេបញ្ឈប់ពីតំណែងសាស្ត្រាចារ្យ តែគាត់បដិសេធមិនព្រមភៀសខ្លួនទៅបរទេស។ លោកទទួលមរណភាពនៅក្នុងឆ្នាំ១៩៣៨។*

**ស្នាដៃសំខាន់** *៖ ស្នាដៃសំខាន់របស់***ហ៊ូស៊ែរ្យល** *គឺ «***ទស្សនវិជ្ជានៃលេខាគណិត***» (Philosophie de l'arithmatique) «***តក្កវិទ្យាសុទ្ធ***» Pure logic។*

*ទស្សនវិជ្ជារបស់* **អេដមុន ហ៊ូស៊ែរ្យល** *ផ្តោតលើការសិក្សាស្រាវជ្រាវលើវិចារណញ្ញាណ ដោយសារតែអ្វីៗដែលវិចារណញ្ញាណទទួលបានគឺតាមរយៈតែញាណប៉ុណ្ណោះ ពោលគឺតាមរយៈវិចារណញ្ញាណខ្លួនឯងតែម្តង។ ម្យ៉ាងវិញទៀត ញាណនេះអាស្រ័យលើតំបន់នៃវត្ថុដែលវិចារណ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ញ្ញាណសិក្សា។ ដូច្នេះ ទស្សនវិទូមិនត្រូវផ្ដោតលើវត្ថុនៅក្នុងពិភពលោកឡើយ តែទៅលើវិធីដែលញាណដែលទទួលវត្ថុទាំងនោះ ពោលគឺត្រូវផ្ដោតលើវត្ថុដែលជាបាតុភូត(phénomènes)។ ក្នុងន័យនេះ **ហ៊ូស្សេល** ហៅទស្សនវិជ្ជារបស់ខ្លួនថាជា **ធាតុភូតវិទ្យា** (*phénoménologie*)។

**វិធីសាស្រ្តពិចារណាយ៉ាងហ្មត់ចត់** (*la réduction*) ៖ **ហ៊ូស្សេល** ប្រើវិធីសាស្រ្តទំនួលអារម្មណ៍ដើម្បីស្វែងរកការពិត។ ពេលដែលទស្សនវិទូមើលឃើញអ្វីមួយ រូបនោះនឹងផ្ញើទៅកាន់វិចារណញ្ញាណដែលមានឥន្ទ្រីយារម្មណ៍ជាច្រើន។ ញាណដែលយើងទទួលពីពិភពលោកដែលនៅជុំវិញខ្លួន គឺតាមរយៈទំនួលអារម្មណ៍(*la preception*)។ នៅពេលដែលភ្នែកមើលឃើញប្រធានបទ គេមិនអាចពិពណ៌នាបានយ៉ាងធម្មតាពីសកម្មភាពនៃវិចារណញ្ញាណប៉ុណ្ណោះទេ។ គេត្រូវបញ្ជាក់ពីសារធាតុនៃទំនួលអារម្មណ៍នេះ ឬពីអនុស្សាវរីយ៍ ឬពីការស្រមើស្រមៃ(*imagination*) រួចបង្ហាញពីវត្ថុបំណងដែលជាគោលដៅ។ បន្ទាប់ពីបានបំភ្លឺពីសកម្មភាពនៃវិចារណ-ញ្ញាណរួចមក តាមរយៈការត្រិះរិះពិចារណា នោះទើបយើងអាចយល់បានពីខ្លឹមសារសត្យានុម័តនៃប្រធានបទនេះ។

**ការពិចារណាតាមបែបធាតុភូតវិទ្យា** (*la reduction phénoménologique*) ៖ គឺជាវិធីសាស្រ្តដែលគេត្រូវទុកតថភាពក្នុងលោកមួយអន្លើសិន(*mettre le monde entre parenthèses*) តាមរយៈការប្រើសេរីភាពដាច់ខាត ដោយមិនចាំបាច់បដិសេធ «សំបកក្រៅ» នៃបាតុភូត ពោលដោយមិនគិតពីសំបកខាងក្រៅនេះនៅក្នុងការវិភាគ។ បាតុភូតវិទូមិនអាចបដិសេធ ឬមានមន្ទិលសង្ស័យ ឬធ្វើសេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងតថភាពទាំងនេះ។ នៅពេលដែលគេទុកនិក្ខេបបទនៅមួយអន្លើរួចមក គេក៏បានរក្សាទុកមួយអន្លើនូវវិទ្យាសាស្រ្តទាក់ទងនឹងធម្មជាតិដែលបង្ហាញពីភាពពិតរបស់ចក្រ-វាល។ អ្វីដែលនៅសេសសល់បន្ទាប់ពីការពិចារណាតាមបែបបាតុភូតវិទ្យានេះ គឺវិចារណញ្ញាណ ដែលជាគោលការណ៍ គឺជាតំបន់នៃភាវៈពិសេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយដែលនឹងអាចក្លាយទៅជាវិស័យនៃវិទ្យាសាស្ត្រថ្មីមួយ គឺ**ធាតុភូតវិជ្ជា**។

**ធាតុភូតវិជ្ជា** *(phénoménologie)* ៖ គឺជាវិធីសាស្ត្រវិភាគសកម្មភាពនៃវិចារណញ្ញាណដោយមានគោលបំណងច្បាស់លាស់។ លក្ខណៈជាមូលដ្ឋាននៃវិចារណញ្ញាណ គឺវាបាញ់ផ្តោះមកខាងក្រៅ ផ្តោះទៅរកពុទ្ធិវត្ថុ(l'objet)។ វិចារណញ្ញាណប្រែរូបផ្តោះទៅរកកពុទ្ធិវត្ថុនោះ ហើយបំពេញទៅដោយសហជញ្ញាណនៃវត្ថុបំណងនេះ។ នៅពេលយើងកាន់ក្រដាសមួយសន្លឹក នៅលើក្រដាសម្ខាងមានបាតុភូតនៃបទពិសោធ ហើយនៅលើម្ខាងទៀត គឺជាបាតុភូតនៅក្នុងវិចារណញ្ញាណ។ យើងតែងតែចូលចិត្តពិចារណាក្រដាសម្ខាងៗដាច់ពីគ្នា។ បើប្រើវិធីសាស្ត្របាតុភូតវិទ្យា ត្រូវពិចារណាពីអ្វីដែលកើតមានឡើងខាងក្នុងសន្លឹកក្រដាសនេះ ពោលគឺអ្វីដែលជាទិន្នន័យនៃបាតុភូត សកម្មភាពនៃវិចារណញ្ញាណដែលតាមរយៈវិចារណញ្ញាណនេះ គេអាចទទួលបានទិន្នន័យទាំងនេះ។

**វិចារណញ្ញាណដោយចេតនា** *(la conscience intentionnelle)* ៖ គឺជាសកម្មភាពដែលវិចារណញ្ញាណមានទំនាក់ទំនងជាមួយពុទ្ធិវត្ថុដែលខ្លួនផ្តោតលើ។ ក្នុងខណៈដែល គេទុកតថភាពក្នុងលោកមួយអន្លើសិន វិចារណញ្ញាណនៅតែផ្តោតលើកម្មវត្ថុដែលកំពុងសិក្សាដដែល។ ពោលគឺវិចារណញ្ញាណនៅតែមានចេតនាផ្តោតអារម្មណ៍ពីពុទ្ធិវត្ថុនោះដដែល ដែលគេហៅថា **វិចារណញ្ញាណដោយចេតនា**។ ប្រការនេះមានន័យថា តាមរយៈ**ការពិចារណាតាមបែបធាតុភូតវិជ្ជា** គេត្រូវទុកតថភាពក្នុងលោកមួយអន្លើសិន( ទំនាក់ទំនងរវាងពុទ្ធិប្រធាន និងពុទ្ធិវត្ថុ) តែគេមិនអាចទុកចោលមួយអន្លើ **វិចារណញ្ញាណដោយចេតនា** បានឡើយ។ ឧទាហរណ៍ នៅពេលដែលយើង( ពុទ្ធិប្រធាន) មើលវត្ថុអ្វីមួយ( ពុទ្ធិវត្ថុ) យើងមើលឃើញនូវទិដ្ឋភាពផ្សេងៗខាងក្រៅនៃពុទ្ធិវត្ថុនោះ។ អ្វីដែលយើងមើលឃើញ គឺជាបទពិសោធភ្លាមៗនៃពុទ្ធិវត្ថុ។ អ្វីដែលយើងទទួលអារម្មណ៍មិនមែនជាសារធាតុសរុបនៃពុទ្ធិវត្ថុនោះឡើយ។ ដូច្នេះ គេមិនអាចជឿបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថាជាវត្ថុពិត ដោយគ្រាន់តែមើលឃើញរូបរាងពីខាងក្រៅឡើយ។ ភាវៈនៃបាតុភូត គឺជារូបរាងខាងក្រៅ។ ដូច្នេះ បទពិសោធនេះមិនគ្របដណ្តប់ឱ្យអស់នូវភាវៈនៃពុទ្ធិវត្ថុឡើយ ដោយគេអាចមើលឃើញរាល់ទិដ្ឋភាពផ្សេងៗ និងមានទស្សនៈផ្សេងៗពីពុទ្ធិវត្ថុនោះ តាមរយៈទំនួលអារម្មណ៍។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ម៉ាទីន ហៃដឺហ្គ័រ
## (១៨៨៩-១៩៧៦)

**ម៉ាទីន ហៃដឺហ្គ័រ** *(Martin Heidegger) កើតនៅប្រទេសអាឡឺម៉ង់ ភាគខាងត្បូង ក្នុងតំបន់ Forêt-Noire។ លោកបានសិក្សា ហើយត្រូវបានតែងតាំងជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Fribourg-en-Brisgau។ នៅឆ្នាំ១៩៣៣ អ៊ីត្លែរឡើងកាន់អំណាច* **ហៃដឺហ្គ័រ** *ត្រូវបានតែងតាំងជាសាកលវិទ្យាធិការ។ តែលោកសុំលាលែងពីតំណែងមួយឆ្នាំក្រោយមក រួចក៏ឈប់ចូលរួមក្នុងសកម្មភាពនយោបាយតែម្តង។ លោកទទួលមរណៈភាពនៅឆ្នាំ១៩៧៦។ ទស្សនវិទូល្បីៗ ដូចជា* **ហេហ្គែល**, **គៀរគឺហ្គាដ**, **នីតស៍** , **ហ៊ូស្សែល** *និងទស្សនវិទូក្រិក មានឥទ្ធិពលយ៉ាងខ្លាំងក្លាលើទស្សនវិជ្ជារបស់* **ហៃដឺហ្គ័រ**។

**ស្នាដៃសំខាន់** ៖ *ស្នាដៃសំខាន់របស់* **ហៃដឺហ្គ័រ** *គឺ Être et temps និង Introduction à la métaphysique។*

*ទស្សនវិជ្ជារបស់* **ហៃដឺហ្គ័រ** *ផ្តោតលើបញ្ហានៃភាវៈ(la question de l'être) និងការស្វែងរកវត្ថុដើម(la quête de l'originel)។* **ហៃដឺហ្គ័រ** *ស្វែងរក* **ភាវៈនៃអ្វីដែលមើលឃើញ** *(l'être de l'étant)។*

**ភាវៈនៃអ្វីដែលគេមើលឃើញ** *(l'être de l'étant)* ៖ **ហៃដឺហ្គ័រ** *សួរថា ហេតុអ្វីក៏មានអ្វីមួយ និងមិនមានភាពទទេ? ដូច្នេះ សំណួររបស់គាត់គឺផ្តោតលើការរក* **ភាវៈ** *(l'être) មិនមែនរក* **ឧទេ** *(le néant) ឡើយ។ នៅក្នុង «ភាវៈ»នេះ គេឃើញមាន«សកម្មភាព» ដែលតាមរយៈនេះ «អ្វីដែលគេមើលឃើញ (étant)» ក៏អាចកើតមានឡើងដែរ។ «អ្វីដែលគេមើលឃើញ» អាចមានរូបរាងបានក៏ដោយសារ«ភាវៈ»ដែរ ហើយ«ភាវៈ»គ្មានអ្វីក្រៅពី«អ្វីដែលគេមើលឃើញ»។ ក៏ប៉ុន្តែ អ្វីដែលសំខាន់ គឺ «អ្វីដែលគេមើលឃើញ»*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កប់នូវភាវៈ។ ឧទាហរណ៍ យើងមើលឃើញសៀវភៅលើតុមានពណ៌លឿង ធ្វើពីក្រដាសស ជាភាសាអង់គ្លេស រាងចតុកោណកែង។ សៀវភៅលើតុ គឺជាអ្វីដែលគេមើលឃើញ តែភាវៈមិនមែនជាក្រដាស ភាសាអង់គ្លេស ឬរាងចតុកោណកែងឡើយ ហើយក៏គេមិនអាចយកភាវៈនេះសម្រាប់អានដែរ។ ម្យ៉ាងវិញទៀត ភាវៈក៏មិនមែនអ្វីដែលនៅសល់ បើគេដកក្រដាស ភាសាអង់គ្លេស ឬរៀងចតុកោណកែងចេញដែរ។ បើគេដកក្រដាស និងគុណភាព និងសារៈប្រយោជន៍ផ្សេងទៀតរបស់សៀវភៅចេញនោះភាវៈក៏បាត់ទៅដែរ។ ដូច្នេះហើយ **ហៃដឺហ្គ័រ** យល់ថាភាវៈ គឺជាអ្វីៗផ្សេងទៀត ក្រៅពីគុណភាព និងប្រយោជន៍របស់សៀវភៅ។ ក៏ប៉ុន្តែគុណភាព និងប្រយោជន៍របស់សៀវភៅជួយបិទបាំងភាវៈ។ ប្រការនេះមានន័យថា ដើម្បីរកឱ្យឃើញនូវតថភាពនេះ គេត្រូវរកឱ្យឃើញនូវបញ្ហា**នៃភាវៈនៃអ្វីដែលគេមើលឃើញ** *(l'être de l'étant)*។

**ពន្លាត់ភាវៈ** *(le dévoilement de l'être)* ៖ ដើម្បីរកការពិត **ហៃដឺហ្គ័រ** បានប្រើវិធីសាស្ត្រពន្លាត់ភាវៈ ដោយប្រើពាក្យក្រិកថា *aletheia* ដែលមានន័យថា លែងលាក់ខ្លួន*(ce qui n'est plus caché)*។ គាត់យល់ឃើញថាតថភាពលាក់ក្នុងចក្ខុវិស័យនៃភាវៈដែលលាក់ដោយឧបករណ៍ផ្សេងៗ។ **ហៃដឺហ្គ័រ** យល់ថា ពុទ្ធិសត្យានុម័តជាទូទៅ គឺជាឧបសគ្គក្នុងការរកភាវៈ ហើយភាវៈលាក់ខ្លួននៅក្នុងល្បែងពាក្យ។ ដូច្នេះ ដើម្បីរកឱ្យឃើញនូវបញ្ហា**នៃភាវៈនៃអ្វីដែលគេមើលឃើញ** *(l'être de l'étant)* គេត្រូវធ្វើឱ្យអត្ថិភាពងើបពីដំណេក។

**អត្ថិភាព** *(l'existence)* ៖ **ហៃដឺហ្គ័រ** ពន្យល់ថា ជាបឋម អត្ថិភាពគឺជា«ការកាត់ផ្តាច់»ពីសភាពធម្មតា ពីទំនាក់ទំនងមានផលប្រយោជន៍ ពីទំនាក់ទំនងមធ្យោបាយ ពីសមត្ថភាពរបស់យើងក្នុងការបន្សាំទៅនឹងពិភពលោកដែលនៅជុំវិញខ្លួនយើង។ បន្ទាប់ពីការកាត់ផ្តាច់នេះ អត្ថិភាពនឹងបង្កលក្ខណៈឱ្យមានលទ្ធភាព។ លទ្ធភាពនេះមានសារៈសំខាន់ខ្លាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ណាស់ចំពោះ **ហៃដឺហ្គ័រ**។ នៅក្នុងអត្ថិភាពមានលទ្ធភាពនៅក្នុងវា។ អ្នកដែលមានអត្ថិភាពតែងតែមានលទ្ធភាព។ ដូច្នេះ អ្នកដែលមានអត្ថិភាពរកឃើញភាវៈរបស់ខ្លួនដែលជា **ភាវៈនៃសេចក្តីស្លាប់** (*Celui qui existe découvre son être en tant qu'«être pour la mort»*)។ ចំពោះ**ហៃដឺហ្គ័រ** សេចក្តីស្លាប់មិនមែនត្រឹមតែជាព្រឹត្តិការណ៍អនាគតប៉ុណ្ណោះឡើយ ហើយក៏មិនមែនជាអ្វីដែលរង់ចាំយើងក្នុងអនាគតកាលដែរ។ ភាវៈនៃសេចក្តីស្លាប់គឺជាអ្វីដែលគេផ្តល់ឱ្យអ្នកដែលមានអត្ថិភាពនូវលទ្ធភាពរបស់ពួកគេ។ បន្ទាប់ពីការផ្តាច់ចេញនេះ អ្នកដែលមានអត្ថិភាពរកឃើញមិនត្រឹមតែ **ភាវៈនៃសេចក្តីស្លាប់** ប៉ុណ្ណោះទេ វាថែមទាំងស្ថិតនៅក្នុងស្ថានភាពកំណត់ដ៏ពិសេសមួយ ពោលគឺស្ថិតនៅក្នុងពិភពលោក ឬភាវៈក្នុងពិភពលោក (*l'être dans le monde*)។

**ន័យនៃការពិត** (*le sens de vérité*) ៖ ដើម្បីរក **ភាវៈនៃអ្វីដែលគេមើលឃើញ** (*l'être de l'étant*) បញ្ហាសំខាន់គឺការពិត។ **ហៃដឺហ្គ័រ** យល់ឃើញថា លក្ខខណ្ឌជាមូលដ្ឋាន និងកាតព្វកិច្ចរបស់អ្នកស្រាវជ្រាវក្នុងការរកការពិត គឺត្រូវត្រៀមខ្លួនខាងក្នុងឱ្យបានល្អ ដើម្បីទទួលយកការពិតដោយឥតលំអៀង។ គេត្រូវរំដោះខ្លួនកុំឱ្យមានតណ្ហា មនោសញ្ចេតនា គំនិតអត្តនោម័ត ដើម្បីឱ្យ **ស្ថានភាពសត្យានុម័ត** លេចចេញដោយសេរី និងបើកចំហរ។ **ស្ថានភាពសត្យានុម័ត** គឺជាស្ថានភាពដែលលេចចេញឡើងក្នុងភាពជាក់ស្តែង ចំពោះមុខអ្នកដែលស្រាវជ្រាវរកតថភាព។ ប៉ុន្តែវាក៏អាចជាទិន្នន័យពីអតីតកាល សកម្មភាព និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលនៅក្នុងស្ថានភាពដូច្នេះ ទោះបីជាវាធ្វើឱ្យអ្នកស្រាវជ្រាវពេញចិត្តក្តី ឬមិនពេញចិត្តក្តី។ ដូច្នេះ ការពិត គឺ «ស្ថិតនៅចំមុខ» ការទាមទារនូវលក្ខខណ្ឌ «សត្យានុម័ត» និង«ភាពមិនលំអៀង»របស់អ្នកស្រាវជ្រាវដែលត្រូវចេះបកស្រាយ និងចេះទទួលយកការពិតនេះ ដោយគ្មានកែប្រែ និងប៉ះពាល់ដល់ការពិតនេះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# **ការល ហ្សាស្ពើរ**
## (១៨៨៣-១៩៦៩)

**ការល ហ្សាស្ពើរ** (Karl Jaspers) កើតនៅប្រទេសអាឡឺម៉ង់ភាគខាងជើង និងរស់នៅក្នុងតំបន់ Oldenbourg។ លោកបានសិក្សាច្បាប់ បន្ទាប់មកក៏បានរៀនពេទ្យ និងរៀនខាងផ្នែកចិត្តសាស្ត្រ(psychiatrie)។ គាត់មិនដែលរៀនទស្សនវិជ្ជាឡើយ។ **ការល ហ្សាស្ពើរ** បានសរសេរនិក្ខេបបទស្តីពីចិត្តសាស្ត្រ និងបានបង្រៀនចិត្តសាស្ត្រ នៅមហាវិទ្យាល័យទស្សនវិជ្ជានៃសាកលវិទ្យាល័យ Heidelberg។ នៅក្នុងឆ្នាំ១៩២១ **ការល ហ្សាស្ពើរ** ត្រូវបានគេស្នើសុំឱ្យកាន់តំណែងជាប្រធានដេប៉ាតឺម៉ង់ទស្សនវិជ្ជានៅសាកលវិទ្យាល័យ Heidelberg តែលោកយល់ថាលោកមិនទាន់សក្តិសមទទួលតំណែងនេះឡើយ។ លោកក៏សម្រេចចិត្តរៀនពីដើមមកវិញ។

នៅក្នុងឆ្នាំ១៩៣៧ រដ្ឋាភិបាលអាឡឺម៉ង់បានបញ្ឈប់មិនឱ្យលោកបង្រៀននៅសាកលវិទ្យាល័យតទៅទៀត ដោយសារការប្រកាន់ជំហរទស្សនវិជ្ជារបស់លោក និងដោយសារលោកបានរៀបការជាមួយស្ត្រីជាជនជាតិជ្វីហ្វ។ លោកត្រូវបានអនុញ្ញាតឱ្យចូលបង្រៀនវិញក្នុងឆ្នាំ១៩៤៥។ ប្រទេសអាឡឺម៉ង់ត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទី ហើយសង្គមក៏បែកបាក់។ លក្ខណៈពិសេសរបស់ **ការល ហ្សាស្ពើរ** គឺលោកសិក្សាទស្សនវិជ្ជាដោយឈរលើទស្សនវិស័យនៃវិទ្យាសាស្ត្រ ដោយលោកបានទទួលការអប់រំខាងផ្នែកវិទ្យាសាស្ត្រ។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ការល ហ្សាស្ពើរ** គឺ (Descartes et la philosophie), La foi philosophique face à la Révélation, Foi philosophique ou foi chrétienne។

ទស្សនវិជ្ជារបស់ **ការល ហ្សាស្ពើរ** ផ្តោតលើការធ្វើសមាធិប្រកបដោយវិចារណញ្ញាណដោយផ្តោតលើលក្ខខណ្ឌរបស់មនុស្ស។ ទស្សនវិជ្ជានេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្តោតលើស្ថានភាពរបស់ទស្សនវិទូនៅក្នុងពិភពលោក និងកំណត់នូវវត្ថុមានគេនៅក្នុងសហគមន៍មនុស្ស ក្នុងគោលដៅស្វែងរកសេរីភាពចំពោះមុខនៃ **ឧត្តមភាព** *(la transcendance)*។ វិចារណញ្ញាណរបស់មនុស្សភ្ញាក់ឡើង ហើយស្ថិតនៅក្នុងតថភាពជាក់ស្តែងដែលគេហៅថាពិភពលោក និងជាប្រភពមិនចេះរីងស្ងួត។ ពិភពលោកនេះ គឺជាអ្វីដែលយើងហៅថា ភាវៈដែលមិនចំណុះឱ្យមនុស្ស ពោលដែលគេហៅថា សត្យានុម័ត។ មនុស្សខិតខំប្រឹងប្រែងឈ្វេងយល់ពីភាវៈនេះជាប្រចាំ។ មនុស្សចង់ដឹងពីអ្វីៗនៅក្នុងពិភពលោកនេះ។ ជាប្រធានដែលគិត មនុស្សស្ថិតនៅចំពោះមុខនៃកម្មវត្ថុទាំងនេះ។ គេមើលឃើញនៅក្នុងពិភពលោកនូវការកាត់ផ្តាច់ដែលមិនអាចឆ្លងផុតបាន*(des ruptures insurmontables)*។ មនុស្សដែលជាប្រធានដែលគិតស្ថិតនៅខាងក្នុងនៃទំនាក់ទំនងប្រទាញប្រទង់រវាងប្រធាន-កម្មវត្ថុ។ សំណួរជាមូលដ្ឋានដែលទស្សនវិទូតែងតែចោទសួរនោះគឺ ៖ «**តើភាវៈជាអ្វី**?»។ វិទ្យាសាស្ត្រដែលសិក្សាពីភាវៈនេះមានឈ្មោះថា ontologie។

**កម្មវត្ថុនៃការសិក្សាទស្សនវិជ្ជា** ៖ នៅពេលដែលលោកត្រូវបានហាមឃាត់មិនឱ្យបង្រៀននៅសាកលវិទ្យាល័យ **ហ្សាស្ពែរ** ចាប់ផ្តើមសិក្សាពីបញ្ហាទស្សនវិជ្ជា ដោយផ្តោតលើបញ្ហានៃការពិត និងបានបង្កើតឡើងនូវ **តក្កវិទ្យាបែបទស្សនវិជ្ជា** ក្នុងគោលដៅពិនិត្យពិចារណាលើវិធីសាស្ត្រទូទៅក្នុងការគិត សម្រាប់ប្រើក្នុងទស្សនវិជ្ជា។ លោកបានបង្ហាញឱ្យឃើញនូវគំនិតផ្ទុយ*(le paradoxe)*នៃទស្សនវិជ្ជា ៖ នៅក្នុងការសិក្សាវិទ្យាសាស្ត្រគេមានកម្មវត្ថុនៃការស្រាវជ្រាវ ក៏ប៉ុន្តែនៅក្នុងការសិក្សាទស្សនវិជ្ជា គេគ្មានកម្មវត្ថុនៃការស្រាវជ្រាវឡើយ។ មូលហេតុសំខាន់គឺថា អ្វីដែលទស្សនវិជ្ជាសិក្សាស្រាវជ្រាវនោះ គឺ **ភាវៈ**។ **ហ្សាស្ពែរ** បានប្រើនូវវិធីសាស្ត្ររបស់**កង់ត៍** ក្នុង **ការបែងចែកពុទ្ធិប្រធាន-ពុទ្ធិវត្ថុ**។ ក្នុងការសិក្សាវិទ្យាសាស្ត្រ គេចែកឱ្យដាច់រវាងពុទ្ធិប្រធាន*(sujet)* និងពុទ្ធិវត្ថុ*(objet)* ៖ អ្នកស្រាវជ្រាវសិក្សាពីតថភាពដែលស្ថិតនៅចំពោះមុខគេដែលជាគោលដៅ*(objective)* សម្រាប់

គេ។ ចំណែកឯការសិក្សាទស្សនវិជ្ជាវិញ គេសួរសំណួរថា តើភាវៈជាអ្វី? ភាវៈមិនមែនជាពុទ្ធិប្រធាន ហើយក៏មិនមែនជាពុទ្ធិវត្ថុដែរ។ ពេលខ្លះភាវៈជាពុទ្ធិប្រធានផង និងជាពុទ្ធិវត្ថុផង។ ដូច្នេះ ទស្សនវិទូគ្មានពុទ្ធិវត្ថុទេ ដោយសារភាវៈគ្របដណ្តប់ទាំងពុទ្ធិប្រធាន ទាំងពុទ្ធិវត្ថុ។ ក្នុងការសិក្សាវិទ្យាសាស្ត្រ គេលើកឡើងនូវសម្មតិកម្ម រួចទើបគេធ្វើការពិនិត្យ និងបញ្ជាក់ពីសម្មតិកម្មនេះ ពោលគឺគេពិនិត្យមើលថា ភស្តុតាងនេះមានសង្គតិភាពឬទេ។ ផ្ទុយទៅវិញ នៅក្នុងការសិក្សាទស្សនវិជ្ជា ទស្សនវិទូមិនអាចបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់នូវអំណះអំណាងរបស់ខ្លួនឡើយ។ ម្យ៉ាងវិញទៀត យើងក៏សង្កេតឃើញថា សំណេររបស់ទស្សនវិទូខ្លះយើងមើលមិនយល់។ ដើម្បីឱ្យយល់បាន គេត្រូវគិតជាមួយទស្សនវិទូនោះ ដោយរក្សានូវសេរីភាពផ្ទាល់ខ្លួនក្នុងការទទួល ឬមិនទទួលទស្សនៈថ្មី។ ដូច្នេះហើយទើបនៅក្នុងប្រវត្តិទស្សនវិជ្ជា ទស្សនវិទូតែងតែជជែកវែកញែក មិនចុះសម្រុងនឹងគ្នា បញ្ចេញទស្សនៈផ្ទុយគ្នាដោយប្រើប្រាស់វិធីសាស្ត្រតក្កវិទ្យា និងប្រើអំណះអំណាងដោយឈរលើមូលដ្ឋាននៃសត្យានុម័ត និងវិចារណញ្ញាណ។ ទស្សនវិទូស្វែងរកការពិតដែលជាការពិតដាច់ខាត ដោយឈរលើមូលដ្ឋាននៃសត្យានុម័ត និងវិចារណញ្ញាណ។

**តួនាទីសាកលវិទ្យាល័យ** ៖ នៅក្នុងទស្សនវិជ្ជា ទស្សនវិទូក្រោយៗតែងតែអាចបដិសេធទ្រឹស្តីដែលទស្សនវិទូមុនៗបានលើកឡើង។ ប៉ុន្តែទោះយ៉ាងនេះក៏ដោយ ទស្សនវិជ្ជានៅតែជាមុខវិជ្ជាដ៏សំខាន់នៅក្នុងការបណ្តុះបណ្តាលបញ្ញវន្ត ដោយសារតែទស្សនវិជ្ជាបង្រៀនមនុស្សឱ្យចេះគិត ហើយទស្សនវិទូត្រូវតែបង្ហាញថាទ្រឹស្តីរបស់ខ្លួនមានលក្ខណៈតក្កវិទ្យា។ ទស្សនវិជ្ជាក៏បានចូលរួមចំណែកក្នុងការផ្តល់គំនិតសម្រាប់ការស្រាវជ្រាវខាងផ្នែកវិទ្យាសាស្ត្រផងដែរ។ សាកលវិទ្យាល័យ គឺជាថ្នាលមួយដ៏សំខាន់ក្នុងការស្រាវជ្រាវទស្សនវិជ្ជា។ សាកលវិទ្យាល័យ គឺជាស្ថាប័នដែលអ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យអាចបញ្ចេញមតិរបស់ខ្លួន និងធ្វើការស្រាវជ្រាវដោយសេរី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីឱ្យមានវឌ្ឍនភាពខាងផ្នែកវិទ្យាសាស្ត្រ។

**អត្ថិភាព** (existence)៖ អត្ថិភាព គឺជាស្ថានភាពមួយដែលពិសេស ជាក់ស្ដែង ក្នុងបរិបទដាច់ខាត និងគ្មានលក្ខខណ្ឌ។ ចំពោះ **ហ្សាស្ព័រ** គេអាចត្រឹមតែបំភ្លឺអត្ថិភាព(éclairer l'existence) តែប៉ុណ្ណោះ ពោលគឺប្រធានត្រូវខិតខំតម្រង់ខ្លួននៅក្នុងពិភពលោក ដើម្បីកំណត់កន្លែងរបស់ខ្លួន។ អត្ថិភាពនេះស្ថិតនៅក្នុងពិភពលោកនៃសេរីភាព។ ដូច្នេះ ការបំភ្លឺអត្ថិភាព គឺការលើកទឹកចិត្ត និងការវិភាគបទពិសោធន៍ ដោយឈរលើមូលដ្ឋាននៃច្បាប់ និងទ្រឹស្ដី។

**ឧត្តមភាព** (la transcendance) ៖ ឧត្តមភាព គឺជាការបំភ្លឺអត្ថិភាព ដោយធ្វើការសម្រេចចិត្តដោយសេរី ក្នុងពេលវេលា រហូតដល់អមតៈ (l'éternité)។ អមតៈនេះមិនមែនជារយៈពេលគ្មានការកំណត់ ដោយមិនគិតពីពេលវេលាឡើយ។ អមតៈនេះអាចសម្រេចបានតាមរយៈ«ការកាត់ផ្ដាច់នៃពេលវេលា» ដើម្បីឱ្យខណៈនៃអត្ថិភាព(l'instant existentiel)នេះមានទម្ងន់ធ្ងន់ដាច់ខាត។ ដូច្នេះ អត្ថិភាពត្រូវមានទំនាក់ទំនងជាមួយឧត្តមភាព ហើយឧត្តមភាពមានន័យបាន ដោយសារអត្ថិភាព។ នៅពេលខ្លះ **ការល ហ្សាស្ព័រ** ហៅឧត្តមភាពនេះ ថាជាអាទិទេព។ ឧត្តមភាពមិនមែនតែនៅក្នុងសេរីភាពឡើយ គឺតាមរយៈសេរីភាពនេះ ឧត្តមភាពនេះក៏មានវត្តមាននៅក្នុងធម្មជាតិដែរ។

**គមនាគមន៍** (communication) ៖ **ហ្សាស្ព័រ** យល់ឃើញថា ប្រសិនបើគ្មានគមនាគមន៍ នោះមិនអាចមានអត្ថិភាពបានឡើយ។ គមនាគមន៍អនុញ្ញាតឱ្យមនុស្សសម្របសម្រួលសកម្មភាពរបស់គេនៅក្នុងពិភពលោកដែលជាសមរភូមិសហប្រតិបត្តិការផង និងប្រណាំងប្រជែងនិងទំនាស់ផង។ ស្ថានភាពនេះ **ហ្សាស្ព័រ** ហៅថា Dasein( អត្ថិភាព )។ មនុស្សដែលជា Dasein ( អត្ថិភាព ) គឺជាប្រធានសំខាន់ត្រូវតែសហការ ឬតស៊ូជាមួយអ្នកដទៃទៀត ក្នុងគោលដៅការពារស្ថានភាពនៃជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ គមនាគមន៍



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គឺជាការទំនាក់ទំនងរវាងអត្ថិភាពមួយ ជាមួយអត្ថិភាពមួយទៀតដោយមិនគិតពីសត្យានុម័ត ឬភស្តុតាងយ៉ាងប្រត្យក្សឡើយ។

**ការផ្ទេរចំណេះដឹង** *(la transmission)* ៖ នៅក្នុងវិស័យវិទ្យាសាស្ត្រ គេមានដំណើរការមួយទៀតដែលហៅថាការផ្ទេរចំណេះដឹងដែលជាកន្លែងប្រមូលផ្តុំនៃ«វិចារណញ្ញាណរួម»។ «វិចារណញ្ញាណរួម» គឺជាស្ថានភាពរបស់មនុស្ស ដែលស្វែងរកការពិត តាមរយៈការគិតគូរត្រឹមត្រូវ*(la rationalité)* និងសត្យានុម័ត។ ការពិត គឺជាភស្តុតាងដែលមានលក្ខណៈចាប់បង្ខំគ្រប់ៗគ្នាឱ្យទទួលស្គាល់។ ទាំងក្នុងការផ្ទេរចំណេះដឹងជាក់ស្តែង ក្នុងជីវភាពប្រចាំថ្ងៃ ជា Dasein(អត្ថិភាព) ទាំងក្នុងការផ្ទេរចំណេះដឹងវិទ្យាសាស្ត្រក្នុងកម្រិត«វិចារណញ្ញាណរួម» គឺជាការផ្ទេរចំណេះដឹងពាក់ព័ន្ធនឹងការសង្កេតជាសត្យានុម័តដែលតម្លៃរបស់វាមិនចំណុះឱ្យមនុស្សដែលប្រធាននៃការផ្ទេរឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្សង់-ប៉ូល សាត្រ
## (១៩០៥-១៩៨០)

**ហ្សង់-ប៉ូល សាត្រ** *(Jean-Paul Sartre)»* គឺជាគំរូនៃបញ្ញវន្តដែលចូលរួមយ៉ាងសកម្មក្នុងការងារនយោបាយនៃសតវត្សរ៍ទី២០។ លោកទទួលសញ្ញាបត្របណ្ឌិត និងមហាបរិញ្ញាខាងផ្នែកទស្សនវិជ្ជាក្នុងឆ្នាំ១៩២៩។ គាត់ធ្វើជាសាស្ត្រាចារ្យទស្សនវិជ្ជា និងបានបោះពុម្ពស្នាដៃទស្សនវិជ្ជាជាច្រើន។ ជាមួយទស្សនវិទូ **មែរឡូ-ប៉ុងទី** និងបញ្ញវន្តដទៃទៀត លោកបានចូលរួមក្នុងចលនាប្រឆាំងពួកហ្វាស៊ីស តាមរយៈការបោះពុម្ពផ្សាយអត្ថបទឃោសនាសម្ងាត់។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ហ្សង់-ប៉ូល សាត្រ** គឺ «**ភាវៈនិងភាពឥតនេះ**» *(l'Être et le Néant)* បោះពុម្ពនៅក្នុងឆ្នាំ១៩៤៣ **កាំអួត** *(la nausée), L'existentialisme et un humanisme, Critique de la raison dialectique*។

ទស្សនវិជ្ជារបស់ **ហ្សង់-ប៉ូល សាត្រ** ផ្តោតលើចរន្ត **អត្ថិភាពនិយម**។ គំនិត និងស្នាដៃរបស់ **សាត្រ** និងចរន្តទស្សនវិជ្ជា **អត្ថិភាពនិយម** ល្បីសុះសាយ និងពេញនិយមក្នុងរយៈពេលក្រោយសង្គ្រាមលោកលើកទី២។ នៅក្នុងឆ្នាំ១៩៦៤ លោកត្រូវបានគណៈកម្មការណូបែលផ្តល់ពានរង្វាន់ណូបែលផ្នែកអក្សរសិល្ប៍ តែ **សាត្រ** បដិសេធមិនទទួលយកពានរង្វាន់នេះ។ លោកបានចូលរួមគាំទ្រការទាមទាររបស់និស្សិតក្នុងខែឧសភា ឆ្នាំ១៩៦៩ ដើម្បីប្រឆាំងនឹងសង្គ្រាមនៅអាល់ហ្សេរី និងនៅវៀតណាម។ មនុស្សរាប់សែននាក់ចូលរួមក្នុងការហែក្បួនសពរបស់លោកនៅទីក្រុងប៉ារីស នៅពេលដែលលោកទទួលមរណៈភាពក្នុងឆ្នាំ១៩៨០។

**ជម្រើស** *(le choix)* ៖ ជម្រើសគឺជាសារជាតុសំខាន់របស់យើង។ នៅ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រប់ពេលទាំងអស់ យើងត្រូវជ្រើសរើសថាតើយើងជានរណា ឬតើយើងចង់ក្លាយជានរណា។ នៅក្នុងតថភាពរបស់មនុស្ស ភាវៈគឺជាការជ្រើសរើស ៖ គ្មានអ្វីមួយដែលកំណត់ឱ្យមនុស្សពីខាងក្រៅ ឬពីខាងក្នុងទេ។ តថភាពរបស់មនុស្សនេះត្រូវបានគេទុកចោល ដោយគ្មាននរណាជួយ។ ដូច្នេះ មនុស្សយើងត្រូវតែកំណត់ឡើងវិញនូវភាវៈរបស់ខ្លួន។ អ្នកដទៃទៀត គឺជាឧបសគ្គដែលរារាំងអនាគតជាអមតៈរបស់យើង។

**ភាវៈ និងភាពទទេ** (l'Être et le Néant) ៖ ទស្សនាទាន «ទទេ» នេះ **សាត្រ**បានមកពី **ហេហ្គែល** និង **ហៃដឺហ្គ័រ** តែគាត់ប្រើក្នុងន័យផ្សេងៗ ទទេមិនមែនសូន្យឡើយ។ ភាពទទេគឺគេអាចបំពេញបាន និងសម្រេចតាមគោលដៅបាន។ ភាវៈ និងភាពទទេនេះ (l'Être et le Néant) **សាត្រ** ចង់បង្ហាញពី **វត្ថុក្នុងខ្លួនឯង** (la chose en-soi) និង **វត្ថុសម្រាប់ខ្លួនឯង** (la chose pour-soi) ដែលជាពាក្យដែលគាត់បានខ្ចីពី**ហេហ្គែល** តែមានន័យផ្សេងៗ **វត្ថុសម្រាប់ខ្លួនឯង** គឺជាពិភពនៃភាវៈដែលមានវិចារណញ្ញាណ និងដែលមានទំនាក់ទំនងជាមួយតថភាព ពោលគឺជាមនុស្ស។ ចំណែកឯ **វត្ថុក្នុងខ្លួនឯង** គឺជាពិភពនៃវត្ថុដែលគ្មានវិចារណញ្ញាណ និងដែលមានគុណភាព និងលក្ខណៈសំខាន់ៗរបស់ខ្លួនកំណត់រួចស្រេច ពោលគឺជាពិភពលោកដែលនៅជុំវិញមនុស្ស។

**វត្ថុក្នុងខ្លួនឯង** (la chose en-soi) និង **វត្ថុសម្រាប់ខ្លួនឯង** (la chose pour-soi) ៖ **សាត្រ** ហៅវិចារណញ្ញាណថាជា **វត្ថុសម្រាប់ខ្លួនឯង** ដែលផ្ទុយនឹង **វត្ថុក្នុងខ្លួនឯង**។ **វត្ថុក្នុងខ្លួនឯង** គឺជាកម្មវត្ថុដែលកំណត់ និងគ្មានអនាគត។ **វត្ថុសម្រាប់ខ្លួនឯង** គឺជាវិចារណញ្ញាណដែលផ្សេងៗពីគ្នា ហើយបែមុខឆ្ពោះទៅខាងក្រៅ។ ដូច្នេះ មនុស្សមិនអាចចុះសម្រុងជាមួយនឹងខ្លួនឯងបានឡើយ។ ដូច្នេះហើយទើបមនុស្សខិតខំដើរតួរបស់ខ្លួន ដោយបង្កើតជាគំរូផ្សេងមួយទៀត(stéréotype) សម្រាប់ខ្លួន ហើយទាត់ចោលនូវសេរីភាពនេះ។ **សាត្រ** ហៅបាតុភូតនេះថាជា **អសុទ្ធចិត្ត**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(mauvaise foi)។ ដើម្បីបង្ហាញឧទាហរណ៍អសុទ្ធចិត្ត **សាត្រ** បានលើកយកឧទាហរណ៍ក្មេងរត់តុ(le garcon de café) ដែលខិតខំប្រឹងប្រែងយកចិត្តអតិថិជន ដោយប្រើសម្ដីអង្វរក ឱនលំទោន ដើម្បីឱ្យភ្ញៀវអាណិតអាសូរនិងទិញកាហ្វេ។ ដូច្នេះ ក្មេងរត់តុត្រូវដើរតួម្យ៉ាងដែលក្មេងរត់តុដទៃទៀតត្រូវគ្រាប់ជាគំរូតាម (stéréotype)។ ក្នុងន័យនេះ ក្មេងរត់តុបាត់បង់នូវសេរីភាពរបស់គេ ក្នុងការធ្វើអ្វីតាមចំណង់ចំណូលចិត្ត។

**កាំអួតមនុស្ស** (la nausée) ៖ ចំពោះ **សាត្រ** មនុស្សត្រូវស្វែងរកន័យនិងកំណត់ន័យរបស់ខ្លួនម្ដងហើយម្ដងទៀត។ មនុស្សគ្មានភាវៈទេ(son être n'existe pas)។ អត្ថិភាពនៅក្នុងគ្រប់ខណៈទាំងអស់ផ្ដល់ឱ្យមនុស្សនូវឱកាសដើម្បីកំណត់ឡើងវិញ។ ដូច្នេះ អត្ថិភាពវាស្ថិតនៅមុនន័យនៃជីវិត(l'existence précède l'essence)។ ដោយសារតែគ្មានព្រះជាអ្នកបង្កើតលោក មនុស្សមិនមែនវាសនាជាអ្នកកំណត់ឱ្យទៅជាអ្នកនេះ ឬអ្នកនោះឡើយ។ មនុស្សមានសេរីភាពជានិច្ច ក្នុងការជ្រើសរើស។ សេរីភាពនេះធ្វើឱ្យមនុស្សបានយល់ដឹងពីមនោសញ្ចេតនាដែលថា ខ្លួនស្ថិតនៅទីណាមួយ ដោយគ្មានមូលហេតុ ឬដោយគ្មានគោលដៅច្បាស់លាស់។ នៅក្នុងស្នាដៃរបស់ខ្លួនដែលមានចំណងជើងថា **កាំអួត** (la nausée) **សាត្រ** បានបង្ហាញពីខណៈដែលមនុស្សយល់ថា ខ្លួនគ្មានបានការអ្វីទាំងអស់នៅក្នុងអត្ថិភាពរបស់ខ្លួន ៖ «រហូតដល់ពេលចុងក្រោយនៃជីវិត ខ្ញុំមិនដែលមានអារម្មណ៍ថា ខ្ញុំចង់មានអត្ថិភាពឡើយ។ ខ្ញុំនៅទីនោះ ដោយគ្មានកម្រើក ឡើងត្រជាក់ខ្លួនស្ពឹកស្ថិតនៅក្នុងសភាពអណ្ដែតអណ្ដូងគួរឱ្យភ័យខ្លាច។ ស្ថិតនៅក្នុងភាពអណ្ដែត-អណ្ដូងនេះ ស្រាប់តែមានអារម្មណ៍ថ្មីមួយលេចឡើង។ ខ្ញុំយល់ពីការចង់ក្អួត»។ នៅចំពោះមុខនៃភាពទទេ មនុស្សមានអារម្មណ៍ថាចង់ក្អួត។ ដូច្នេះមនុស្សត្រូវខិតខំបញ្ចេញសកម្មភាព ដើម្បីឱ្យជីវិតមានន័យ។ ដូច្នេះ មនុស្សគឺជាអ្នកទទួលខុសត្រូវនូវជោគវាសនា និងអនាគតរបស់ខ្លួន ហើយមិនអាចរង់ចាំឱកាស ឬធ្វើការផ្សងសំណាងដើម្បីដោះសាខ្លួនឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ផ្តន្ទាទោសឱ្យមានសេរីភាព** (*Condamné à être libre*) ៖ ចំពោះ **សាត្រ** មនុស្សកើតឡើង មានមុខ មានមាត់ និងឋានៈក្នុងសង្គម។ តែអ្វីៗផ្សេងទៀត មនុស្សត្រូវបង្កើតឡើងដោយខ្លួនឯង។ មនុស្សទាំងឡាយណាទាំងឈឺ ទាំងជា មានការជ្រើសរើសសម្រាប់ខ្លួន ដើម្បីសម្រេចពីជោគវាសនារបស់ខ្លួន។ អ្វីៗទាំងអស់ គឺជាការជ្រើសរើសរបស់មនុស្ស។ ក៏ប៉ុន្តែ មនុស្សមិនអាចជ្រើសរើសសេរីភាពបានឡើយ។ សេរីភាពកើតឡើងក្នុងពេលតែមួយជាមួយមនុស្ស។ សេរីភាពនេះបណ្តាលមកពីអារម្មណ៍ធុញថប់ថា តើខ្ញុំត្រូវធ្វើឱ្យជីវិតខ្ញុំទៅជាយ៉ាងណា? តើខ្ញុំត្រូវជ្រើសរើសយកអ្វី? ស្ថានភាពសម្ភារៈនៃអត្ថិភាពមិនអាចកំណត់ជីវិតមនុស្សបានឡើយ។ វាបានតែត្រឹមមានឥទ្ធិពលលើអត្ថិភាពរបស់មនុស្សប៉ុណ្ណោះ។ មនុស្ស គឺជាល្បែងលេងរបស់ប្រវត្តិសាស្ត្រ។ ក៏ប៉ុន្តែ សកម្មភាពរបស់មនុស្សអាចមានឥទ្ធិពលលើដំណើរការប្រវត្តិសាស្ត្របាន។ ដូច្នេះ មនុស្សចាំបាច់ត្រូវតែមានការប្តេជ្ញាចិត្តចូលរួមក្នុងសកម្មភាពនយោបាយ(*engagé*)។ តើធ្វើដូចម្តេចទើបអាចធ្វើសកម្មភាពដែលល្អត្រឹមត្រូវ? មានតែសីលធម៌ទេដែលអាចកំណត់ថា សកម្មភាពណាដែលត្រឹមត្រូវ សម្រាប់មនុស្សជ្រើសរើស។ មានតែការទទួលខុសត្រូវទេដែលអាចចង្អុលទិសដល់មនុស្សក្នុងការបំពេញសកម្មភាពរបស់ខ្លួន។ មនុស្សមិនត្រឹមតែមានការទទួលខុសត្រូវចំពោះខ្លួនឯងប៉ុណ្ណោះទេ តែមនុស្សត្រូវមានការទទួលខុសត្រូវចំពោះមនុស្សដទៃទៀតផងដែរ។ មនុស្សត្រូវធ្វើជាគំរូដល់មនុស្សដទៃទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហាណា អារ៉េន
## (១៩០៦-១៩៧៥)

**ហាណា អារ៉េន** *(Hannah Arendt)» កើតនៅប្រទេសអាឡឺម៉ង់ក្នុងគ្រួសារបញ្ញវន្តជ្វីហ្វ។ លោកស្រីសិក្សាទស្សនវិជ្ជា និងជាសិស្សសំណព្វចិត្តរបស់ទស្សនវិទូអាឡឺម៉ង់* **ម៉ាទីន ហៃដឺហ្គ័រ** *(Martin Heidegger)។ លោកស្រីបានការពារនិក្ខេបបទទស្សនវិជ្ជា ដោយមានទស្សនវិទូ* **កាល យ៉ាស្ព័រ** *(Karl Jaspers) ជាអ្នកដឹកនាំនិក្ខេបបទ។ ក្នុងឆ្នាំ១៩៣៣* **ហាណា អារ៉េន** *បានភៀសខ្លួនទៅនៅបារាំង រួចរត់ទៅនៅព័រទុលហ្គាល់។ នៅក្នុងឆ្នាំ១៩៤១ លោកស្រីក៏បានភៀសខ្លួនទៅនៅសហរដ្ឋអាមេរិក។*

**ស្នាដៃសំខាន់** *៖ ស្នាដៃសំខាន់របស់* **ហាណា អារ៉េន** *គឺ «***ប្រភពនៃអំណាចផ្តាច់ការ***» (Les origins du totalitarisme) 1951 «***ស្ថានភាពនៃមនុស្សសម័យថ្មី***» (Condition de l'homme modern) 1958 «***វិបត្តិវប្បធម៌***» La crise de la culture) 1961។*

*នៅពេលទៅដាន់ទឹកដីអាមេរិកដំបូង លោកស្រីធ្វើការជាអ្នកបម្រើតាមផ្ទះ។ បន្ទាប់មក លោកស្រីក៏ចាប់ផ្តើមសរសេរអត្ថបទសម្រាប់ទស្សនាវដ្តី «ការសិក្សាសង្គមជ្វីហ្វ»។* **អារ៉េន** *បានចូលសញ្ជាតិអាមេរិកក្នុងឆ្នាំ១៩៥១ និងបានបោះពុម្ពស្នាដៃដ៏សំខាន់មួយដែលមានចំណងជើងថា* **ប្រភពនៃរបបផ្តាច់ការនិយម**។ *នៅក្នុងឆ្នាំបន្តបន្ទាប់ លោកស្រីបានបោះពុម្ពផ្សាយស្នាដៃដទៃទៀត។ លោកស្រីបានក្លាយជាសាស្ត្រាចារ្យបង្រៀននៅមហាវិទ្យាល័យ និងក្លាយជាប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យឈីកាហ្គោ។*

*ទស្សនវិជ្ជារបស់* **ហាណា អារ៉េន** *ផ្តោតលើ* **មនុស្សជាតិ** *(l'humanité)។ ពេលចាប់កំណើតមក បុគ្គលមិនមែនទាន់ក្លាយខ្លួនជាមនុស្ស(être humain)*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពេញលក្ខណៈឡើយ។ ដើម្បីក្លាយជាមនុស្សពេញលក្ខណៈ បុគ្គលម្នាក់ៗ ត្រូវតែចូលរួមនៅក្នុងសកម្មភាពមនុស្សជាតិ។ គឺអ្នកដទៃ (Autrui) នេះឯង ពោលគឺក្នុងទំនាក់ទំនងជាមួយអ្នកដទៃ បុគ្គលនោះបានក្លាយជាមនុស្ស ពិតប្រាកដ តាមរយៈការចូលរួមប្រាស្រ័យក្នុងសង្គម ដែលជាទីកន្លែង សាធារណៈ។ តាមនិយមន័យរបស់ **អារីស្តូត** មនុស្សគឺជាសត្វនយោបាយ (*l'animal politique*)។ ដើម្បីឱ្យបុគ្គលម្នាក់ៗក្លាយខ្លួនជាមនុស្សពិតប្រាកដ បុគ្គលទាំងនោះត្រូវចូលរួមក្នុងសកម្មភាពរួម ហើយមិនត្រូវនៅជាឯកជន ឡើយ។ មនុស្សត្រូវមានទំនាក់ទំនងជាមួយគ្នា មានសកម្មភាពដែលប្រកប ដោយយុត្តិធម៌ ឬអយុត្តិធម៌ និងបង្កើតច្បាប់។ មានតែសកម្មភាពសង្គមទេ ដែលធ្វើឱ្យមនុស្សរីកលូតលាស់ធំធាត់បានពេញលេញ។

**ការបង្កើតទំនាក់ទំនងជាមួយមនុស្ស** (*le lien humain*) ៖ នៅក្នុងស្នាដៃរបស់លោកស្រី «**ស្ថានភាពនៃមនុស្សជំនើប**» លោកស្រី បានទិតៀនប្រព័ន្ធផលិតកម្មបែបមូលធននិយមដែលដកហូតសិទ្ធិសេរីភាព របស់មនុស្ស ដោយបង្ខំមនុស្សឱ្យធ្វើការដែលមានគោលដៅតែម្យ៉ាងគត់ គឺការផលិត និងការបែងចែកហិរញ្ញវត្ថុ។ ការផលិតទំនិញបានគ្រាន់តែ បំពេញសេចក្តីត្រូវការរបស់មនុស្សក្នុងគ្រាបន្ទាន់ប៉ុណ្ណោះ។ ក្នុងន័យនេះ មនុស្សមិនខុសពីសត្វទេ។ មនុស្សគឺជាសត្វដែលធ្វើការ(*un animal loborant*)។ នៅពេលដែលមនុស្សធ្វើស្នាដៃដែលគេអាចមើលឃើញ និងកោតសរសើរ ពេលនោះហើយទើបមនុស្សបង្កើតឡើងនូវទំនាក់ទំនងដែលជាអមតៈ។ ស្នាដៃសិល្បៈ និងប្រាសាទ និងព្រះវិហារបង្ហាញពីមនុស្សធម៌របស់មនុស្ស និងចូលរួមចំណែកក្នុងការកសាងពិភពលោកដែលបុគ្គលម្នាក់ៗជាសមាជិក។ ដូច្នេះ គេអាចកសាង និងសម្រេចបាននូវមនុស្សជាតិបាន តាមរយៈ ការកសាងអ្វីមួយដែលមានលក្ខណៈអចិន្ត្រៃយ៍ និងអមតៈជាងជីវិតមនុស្ស ទៅទៀត។

**ការចងចាំរបស់មនុស្សជាតិ** (*la mémoire*) ៖ ការចងចាំអនុញ្ញាត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យយើងកសាង និងជានាបាននូវទំនាក់ទំនងជាអមតៈជាមួយមនុស្សឯទៀត ហើយដែលអាចឱ្យគេអភិរក្សបេតិកភណ្ឌទាំងនេះសម្រាប់មនុស្សជាតិ ហើយដែលអាចផ្សាភ្ជាប់មនុស្សមួយជំនាន់ទៅមនុស្សមួយជំនាន់ទៀត។ នៅក្នុងស្នាដៃ «**វិបត្តិវប្បធម៌**» លោកស្រីបានសរសេរថា វិបត្តិវប្បធម៌គឺជាវិបត្តិនៃការចងចាំ។ សម័យទំនើបដែលមានវប្បធម៌ថ្មីៗនាំឱ្យមានវិបត្តិវប្បធម៌។ ការឱ្យតម្លៃលើអ្វីដែលថ្មី នាំឱ្យមានអំពើហិង្សា ធ្វើឱ្យបាត់បង់មត៌កមនុស្សជាតិ ការបដិសេធមិនផ្ទេរវប្បធម៌នេះដល់ជនជំនាន់ក្រោយធ្វើឱ្យបាត់បង់ទំនាក់ទំនងរវាងអតីតកាល និងអនាគតកាល រវាងមនុស្សជំនាន់មុន ជាមួយមនុស្សជំនាន់នេះ។

**អំណាចផ្តាច់ការ** *(le totalitarisme)* ៖ មនុស្សអាចបាត់បង់មនុស្សជាតិរបស់ខ្លួន ដោយសារប្រព័ន្ធផ្តាច់ការ ហើយមនុស្សក៏បាត់បង់បន្តិចម្តងៗនូវទំនាក់ទំនងជាមួយមនុស្សសង្គមមនុស្សដទៃទៀត។ មនុស្សលែងមានបុគ្គលិកលក្ខណៈជាបុគ្គល ហើយរស់នៅក្នុងហ្វូងមនុស្ស នៅក្នុងប្រព័ន្ធជំរំប្រមូលផ្តុំ*(camps de concentration)* ក្នុងគុកឥតជញ្ជាំងដែលធ្វើឱ្យការងារ និងមនុស្សក្លាយទៅជាឥតប្រយោជន៍។ នៅក្នុងស្នាដៃ «**ប្រភពនៃអំណាចផ្តាច់ការ**» **ហាណា អារ៉េន** បានវិភាគពីមូលហេតុដែលធ្វើឱ្យរបបនៃអំណាចផ្តាច់ការអាចកកើតឡើងដែលនាំឱ្យមនុស្សបាត់បង់នូវតម្លៃមនុស្សជាតិជាមនុស្ស ដោយបង្កើតឡើងនូវប្រព័ន្ធរស់នៅតាមបែបជំរំប្រមូលផ្តុំ។ មានមូលហេតុសំខាន់ពីរយ៉ាងដែលនាំឱ្យមានអំណាចផ្តាច់ការ ៖ (១) ការធ្វើឱ្យភ័យខ្លាច និង (២) មនោគមវិជ្ជា។ ការធ្វើឱ្យភ័យខ្លាចធ្វើឱ្យមនុស្សលែងមានទំនាក់ទំនងជាមួយសហគមន៍ ដោយធ្វើឱ្យមនុស្សនៅក្នុងសង្គមរស់នៅដាច់ដោយឡែកពីគ្នា ស្ថិតនៅក្នុងភាពឯកោ ដោយការភ័យខ្លាចអ្នកដទៃ។ នៅពេលដែលមនុស្សបាត់បង់នូវសេរីភាព មនុស្សស្ថិតនៅក្រោមការត្រួតត្រាទាំងស្រុងពីរដ្ឋអំណាច។ ដោយរស់នៅឯកោយ៉ាងនេះ មនុស្សចាប់ផ្តើមមានគំនិតជ្រុលនិយមតែម្តង។ មនោគមវិជ្ជា គឺជាការបង្ហាញពី

គោលបំណងរបស់អ្នកកាន់អំណាចដែលចង់ធ្វើឱ្យទ្រឹស្តីក្លាយជាការពិត។ របបផ្តាច់ការនិយមអនុវត្តនូវច្បាប់មួយដែលគេចង់ឱ្យមានសង្គមដែលគ្មានវណ្ណៈ ក្នុងប្រព័ន្ធកុំមុយនីស្ត ការបន្សុទ្ធជាតិសាសន៍ ក្នុងប្រព័ន្ធណាហ្ស៊ី ដោយគ្មានអ្នកដែលហ៊ានប្រឆាំង។ គេមិនអាចសួរថា តើរស់នៅដើម្បីអ្វីបានឡើយ។ នៅក្នុងប្រព័ន្ធនេះ រដ្ឋអំណាចប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ជាពិសេសអំពើហិង្សា ដើម្បីធានានូវនិរន្តរភាពនៃប្រព័ន្ធកុំមុយនីស្ត ឬប្រព័ន្ធណាហ្ស៊ី។

# ជំពូកទី៦
# ទស្សនវិជ្ជាចុងស.វ.ទី២០ និងដើមស.វ.ទី២១

## ទស្សនវិជ្ជាវិភាគនិយម

**ទស្សនវិជ្ជាវិភាគនិយម** (*Philosophie analytique*)» គឺជាចរន្តទស្សនវិជ្ជាដែលកើតឡើងនៅក្នុងពាក់កណ្តាលសតវត្សរ៍ទី២០ ដែលដំណាងដោយ **ហ្វ្រេគ** (*Gottlog Frege*) **រ៉ាស់សែល** (*Bertrand Russell*) និង **វីតហ្គេនស្តាញ** (*Ludwig Wittgenstein*)។ ពួកគេយល់ថា សំណួររបស់ទស្សនវិទូជាប្រពៃណីមិនអាចរកចម្លើយពេញចិត្តបានឡើយ។ ពួកគេយល់ថាត្រូវតែមានការវិភាគយ៉ាងហ្មត់ចត់។ ទស្សនវិជ្ជាវិភាគនិយមចាប់ផ្តើមពីស្នាដៃរបស់ **ហ្វ្រេគ** (១៨៤៨-១៩២៥) ដែលជា គណិតវិទូ និងទស្សនវិទូអាឡឺម៉ង់ ដែលមានគម្រោងបង្កើតភាសាមួយដែលមានតក្កវិទ្យាទាំងស្រុង ដែលហៅថា «ភាសានៃគំនិតសុទ្ធ» ក្នុងគោលដៅជៀសវាងកុំឱ្យច្រឡំជាមួយនឹងភាសាធម្មជាតិ។

ទស្សនវិទូវិភាគនិយមយល់ថាការបកស្រាយខុសៗគ្នានៃទ្រឹស្តីរបស់ទស្សនវិទូនាំឱ្យមានការមិនយល់គ្នា និងបង្កើតឡើងនូវបញ្ហាក្លែងក្លាយ។ ទស្សនវិទូ **រ៉ាស់សែល** ក៏យកចិត្តទុកដាក់បំភ្លឺន័យនៃទ្រឹស្តីទស្សនវិជ្ជា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ដើម្បីកុំឱ្យមានការយល់ច្រឡំ  គេត្រូវចាប់ផ្តើមពីសំណើសាមញ្ញ(អាតូមតក្កវិទ្យា)ដែលជាសមាសធាតុនៃពិភពលោក។ សំណើស្មុគ្រស្មាញត្រូវបានបង្កើតឡើង ដោយសំណើសាមញ្ញជាច្រើន។* **វីតហ្គេនស្តាញ** *ដែលជាសាវករបស់***រ៉ាស់សែល** *បន្តការវិភាគកំហិតនៃភាសា។*

*ទស្សនវិជ្ជានេះក៏មានការប្រែប្រួល ហើយសាខាមួយនៃទស្សនវិជ្ជានេះបានក្លាយទៅជា***ទស្សនវិជ្ជាភាសានិយម** *(Philosophie linguistique)»។ អ្នកស្រាវជ្រាវជាច្រើនបដិសេធមិនហៅចរន្តនេះ ថាជាទស្សនវិជ្ជា។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ប៊ែត្រង់ រ៉ាស់ស៊ែល
## (១៨៧២-១៩៧០)

**ប៊ែត្រង់ រ៉ាស់ស៊ែល** *(Bertrand Russell)* កើតនៅឆ្នាំ១៨៧២ នៅក្នុងគ្រួសារអភិជននៃចក្រភពអង់គ្លេស។ ជីតារបស់លោកធ្លាប់ជានាយករដ្ឋមន្ត្រីអង់គ្លេស ហើយឪពុកធម៌របស់លោក គឺទស្សនវិទូអង់គ្លេសដ៏ល្បីល្បាញ គឺ **ចន ស្ទួអាត មីល** *(John Stuart Mill)*។ លោករៀននៅសាកលវិទ្យាល័យ**ខេមប្រ៊ីជ**។ លោកគឺជាគណិតវិទូ តក្កវិទូ និងទស្សនវិទូដ៏ល្បីល្បាញម្នាក់ ដែលបានទទួលជ័យលាភីណូបែលខាងផ្នែកអក្សរសាស្ត្រក្នុងឆ្នាំ ១៩៥០ ក្នុងនាមជា «អ្នកនាំពាក្យនៃទស្សនសេរីនិយម វិចារណញ្ញាណ និងមនុស្សជាតិ»។ លោកបានបង្កើត ជាមួយនឹង Gottlob Frege នូវតក្កវិជ្ជាទំនើប និង **ចរន្តវិជ្ជាវិភាគ** ដែលមានគោលដៅពន្យល់ពីបញ្ហាទស្សនវិជ្ជា ដោយប្រើប្រាស់ការវិភាគតាមបែបតក្កវិជ្ជានៃភាសា។ **ប៊ែត្រង់ រ៉ាស់ស៊ែល** បានតស៊ូប្រឆាំងនឹងអំពើហិង្សា និងសង្គ្រាមលោកលើកទីមួយ បកអាក្រាតអាវុធបរមាណូ និងប្រឆាំងសង្គ្រាមនៅវៀតណាម។

**ស្នាដៃសំខាន់ ៖** ស្នាដៃសំខាន់របស់ **ប៊ែត្រង់ រ៉ាស់ស៊ែល** គឺ *Principia mathematica*(១៩១៣), *la Méthode scientifique en philosophie* (១៩១៤), *Notre connaissance du monde extérieure* (១៩១៤), *Vers la liberté: le socialisme, l'anarchie et le syndicalisme* (១៩១៨), *Analyse de l'esperit*(១៩២១)។

**តក្កវិជ្ជាអាតូមនិយម ៖ រ៉ាស់ស៊ែល** បានបំពេញការគណនាគណិតវិទ្យា ដើម្បីបង្កើតគោលការណ៍តក្កវិជ្ជាដ៏សាមញ្ញ ហើយបន្ទាប់មកបញ្ចូលការវិភាគនេះ ដើម្បីដោះស្រាយបញ្ហាទស្សនវិជ្ជា។ លោកបានសិក្សាយ៉ាងល្អិតល្អន់ទស្សនាទានទស្សនវិជ្ជា ជាពិសេសដោយប្រើភាសាជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឧបករណ៍ក្នុងការគិត។ លោកយល់ថា បញ្ហាទស្សនវិជ្ជានៅមិនទាន់ដោះស្រាយបាន ដោយសារតែទស្សនវិទូមិនចេះសរសេរឱ្យគេអាចយល់បាន។ តាមពិត គេអាចសរសេរទស្សនាទានទស្សនវិជ្ជា ឬពុទ្ធិ ដោយប្រើប្រាស់ភាសាសាមញ្ញងាយយល់។ **រ៉ាស់សែល** យកទ្រឹស្តីទស្សនវិជ្ជារបស់ពួកអាតូមនិយម ដោយបង្កើតជាទ្រឹស្តី «តក្កវិជ្ជាអាតូមនិយម» ថា«អាតូម គឺជាធាតុដ៏តូចបំផុតសម្រាប់ការវិភាគ» ដោយឈរលើមូលដ្ឋាននៃសំណើសាមញ្ញប្រកបដោយតក្កវិជ្ជា។ លោកចោទសួរខ្លួនឯងថា ៖ «ការព្រួយបារម្ភជាប្រចាំរបស់ខ្ញុំ គឺការរកឱ្យឃើញនូវទំហំ និងកម្រិតនៃភាពច្បាស់លាស់ដែលយើងអាចជឿជាក់លើចំណេះដឹងរបស់យើងបាន។

**ការពិសោធ និងពុទ្ធិ** ៖ **រ៉ាស់សែល** យកទ្រឹស្តីតក្កវិជ្ជាអាតូមនិយម ដើម្បីពន្យល់ពីបាតុភូតក្នុងពិភពលោក។ ពិភពលោកនេះ គឺជាបណ្តុំដ៏ស្មុគ្រស្មាញនៃព្រឹត្តិការណ៍យ៉ាងសាមញ្ញ។ ប្រសិនបើគេរៀបចំការពន្យល់ដោយប្រើភាសាសាមញ្ញ នោះព្រឹត្តិការណ៍ទាំងនេះនឹងឆ្លុះបញ្ចាំងនូវតថភាព។ តែជាបឋម គេត្រូវតែធ្វើពិសោធន៍ជាមុនសិន ដើម្បីធានាថាសំណើនេះពិតមែន។ ប្រសិនបើមនុស្សមានពុទ្ធិភ្លាមៗ(connaissance immédiate)គេអាចបញ្ជាក់ពីសំណើនេះបាន។ប្រសិនបើគេមិនអាចទទួលពុទ្ធិតាមវិធីនេះបាន គេត្រូវយកច្បាប់ទូទៅមកឆ្លុះមើលករណីពិសេស។

**ទស្សនវិជ្ជាវិភាគ** ៖ ទស្សនវិជ្ជាវិភាគរបស់ **រ៉ាស់សែល** ផ្តោតលើការប្រើពាក្យ និងន័យនៃពាក្យនេះ ដោយមិនគិតពីការបកស្រាយតាមបរមត្ថវិជ្ជា។ បញ្ហាទាំងឡាយអាចដោះស្រាយបាន ដោយប្រើការពិសោធ តែបញ្ហាខ្លះគេមិនអាចដោះស្រាយបានឡើយ។

# វីតហ្គេនស្តាញ
## (១៨៨៩-១៩៥១)

**វីតហ្គេនស្តាញ** *(Wittgenstein)* កើតនៅវីយែន ប្រទេសអូទ្រីស ក្នុងឆ្នាំ ១៨៨៩ ក្នុងគ្រួសារអ្នកមានម្នាក់។ ជីវិតរបស់លោក និងទស្សនវិជ្ជារបស់លោកបំពេញឱ្យគ្នាទៅវិញទៅមក។ លោកបានបញ្ចប់ការសិក្សាខាងផ្នែកវិស្វកម្មមេកានិចនៅទីក្រុងប៊ែរឡាំងក្នុងឆ្នាំ១៩០៦ បន្ទាប់មកក៏សិក្សាថ្នាក់បណ្ឌិតខាងផ្នែកយន្តហោះនៅសាកលវិទ្យាល័យម៉ាន់ឆែស្ទ័រ ប្រទេសអង់គ្លេស។ ដំបូងលោករៀនទស្សនវិជ្ជាជាមួយទស្សនវិទូអាឡឺម៉ង់ **ហ្វ្រេហ្គេ** *(Gottlob Frege)* តែបន្ទាប់មកក៏ទៅរៀនទស្សនវិជ្ជានៅសាកលវិទ្យាល័យខេមប្រ៊ីជជាមួយទស្សនវិទូអង់គ្លេស **រ៉ាស់ស៊ែល** *(Bertrand Russell)* ដែលជាបិតាទស្សនវិទូវិភាគ ដូច**ហ្វ្រេហ្គេ**ដែរ។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់ **វីតហ្គេនស្តាញ** គឺ«**អភិប្រាយស្តីពីតក្កវិជ្ជាទស្សនវិជ្ជា** *(Tractatus logico-philosophicus)*» ដែលបោះពុម្ពផ្សាយក្នុងឆ្នាំ១៩២១។ បន្ទាប់ពីបានធ្វើជាគ្រូបង្រៀនស្រុកស្រែអស់រយៈពេលប្រាំឆ្នាំ លោកបានត្រឡប់មកសាកលវិទ្យាល័យខេមប្រ៊ីជដើម្បីការពារនិក្ខេបបទទស្សនវិជ្ជា នៅក្នុងឆ្នាំ១៩២៩ ។ លោកបង្រៀនទស្សនវិជ្ជាអស់រយៈពេល២០ឆ្នាំនៅសាកលវិទ្យាល័យខេមប្រ៊ីជ។ នៅក្នុងរយៈពេលនេះលោកបានសរសេរស្នាដៃដ៏សំខាន់របស់លោកគឺ «**ទស្សនវិជ្ជាតាមបែបស៊ើបអង្កេត** *(Investigations philosophiques)*» នៅក្នុងឆ្នាំ ១៩៥២ មួយឆ្នាំក្រោយមរណៈភាពរបស់លោក។ ទស្សនវិជ្ជារបស់ **វីតហ្គេនស្តាញ** គឺជាទស្សនវិជ្ជានៃភាសា*(la philosophie du langage)*។ ការអង្កេតក្នុងចំណោមសាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យនៃសហរដ្ឋអាមេរិកបានចាត់ទុកសៀវភៅ «**ទស្សនវិជ្ជាតាមបែបស៊ើបអង្កេត**» ជា



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សៀវភៅទស្សនវិជ្ជាដ៏សំខាន់បំផុតនៅក្នុងសតវត្សរ៍ទី២០។

**១. «អភិប្រាយស្តីពីតក្កវិជ្ជាទស្សនវិជ្ជា»**

**វីតហ្គេនស្តាញ** សិក្សាពីទំនាក់ទំនងតក្កវិជ្ជារវាងសំណើ និងពិភពលោក ហើយយល់ឃើញថា ប្រសិនបើយកចិត្តទុកដាក់លើតក្កវិជ្ជាដែលទ្រទ្រង់ទំនាក់ទំនងនេះ គាត់អាចដោះស្រាយបាននូវរាល់បញ្ហាទាំងអស់បាន។ ដូចច្នេះហើយ ទើប**វីតហ្គេនស្តាញ** សិក្សាពីលក្ខខណ្ឌនៃការបង្កើតភាសាតក្កវិជ្ជាទំនើប និងយល់ពីភាពចាំបាច់នៃភាសាជម្មតា ក្នុងការបោះជំហានឆ្ពោះទៅរកឧត្តមគតិនេះ។ **វីតហ្គេនស្តាញ** បង្ហាញពីលទ្ធភាពដែលភាសាអាចបញ្ចេញពុទ្ធិស្តីពីតថភាព។ ទស្សនវិជ្ជានេះផ្តោតទៅលើ ៖

ទីមួយ-ក្នុងជីវន្តវិទ្យា(ontologie)បញ្ហាចម្បងបំផុតមិនមែនភាវៈ អត្ថិភាព ឬការគ្មានអត្ថិភាពទេ តែជាការបញ្ចេញគំនិត ឬការបង្ហាញតាមរយៈភាសាដែលមានន័យច្បាស់លាស់។ លក្ខណៈវិនិច្ឆ័យនៃការបញ្ចេញគំនិតនេះ គឺការកំណត់ព្រំដែនរវាងពិភពពិត និងពិភពអាចកំបាំង។

ទីពីរ-ការគិតមិនអាចកាត់ផ្តាច់ចេញពីភាសាបានឡើយ។ ការកំណត់ព្រំដែនសម្រាប់ភាសា មានន័យថា ការកំណត់ព្រំដែនសម្រាប់ការគិត។

ទីបី-ទំនាក់ទំនងរវាងពិភពលោក និងភាសា ឬទំនាក់ទំនងរវាងជីវន្តវិទ្យា និងអត្ថន័យ ឬនិយណ្ឌសាស្ត្រ(sémantique) គឺទាំងពីរនេះប្រៀបប្រដូចទៅនឹងកញ្ចក់ដែលឆ្លុះគ្នាទៅវិញទៅមក។

**ពុទ្ធិវត្ថុ** (objet) ៖ ពុទ្ធិវត្ថុ គឺជាសារធាតុ( មូលដ្ឋាននៃភាវៈ)នៃពិភពលោក។ គេអាចទទួលអារម្មណ៍ពីវត្ថុផ្សេងៗតាមរយៈញាណ តែវត្ថុមិនមែនជាសារធាតុទេ។ គេមិនអាចប្រើឥន្ទ្រីយារម្មណ៍ ដើម្បីស្គាល់កម្មវត្ថុបានឡើយ ហើយពុទ្ធិវត្ថុនេះគឺជាសណ្ឋាន(forme)យ៉ាងសាមញ្ញបំផុត ដែលជាមូលដ្ឋាននៃពិភពលោក។ ពុទ្ធិវត្ថុមានលក្ខណៈសាមញ្ញ និងមិនមានលក្ខណៈសម្បត្តិ ហើយមិនស្ថិតនៅក្នុងពិភពពិតឡើយ។ ពុទ្ធិវត្ថុមាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លក្ខណៈតក្កវិទ្យា ហើយស្ថិតនៅក្នុងលំហនៃតក្កវិទ្យា។ ក្នុងន័យនេះកម្មវត្ថុបំពេញតាមតម្រូវការនៃទ្រឹស្តីតក្កវិទ្យា និងនិយណ្ឌសាស្ត្ររបស់ **វីតហ្គេនស្តាញ** តែប៉ុណ្ណោះ ហើយកំណត់ព្រំដែននៃការវិភាគតាមបែបតក្កវិទ្យានៃសំណើ(proposition)។

**ព្រឹត្តិការណ៍ ឬស្ថានភាព** *(Évènement, État des lieux)* ៖ ព្រឹត្តិការណ៍ គឺជាសមាសធាតុមួយទៀតនៅក្នុងរចនាសម្ព័ន្ធនៃភាវៈនេះ។ ព្រឹត្តិការណ៍ជាច្រើនត្រូវបានភ្ជាប់គ្នាឱ្យស្ថិតនៅក្នុងស្ថានភាពសាមញ្ញណាមួយ។ ព្រឹត្តិការណ៍ជាច្រើនបង្កើតបានជាហេតុការណ៍(faits)។ នៅក្នុងព្រឹត្តិការណ៍កម្មវត្ថុមានទំនាក់ទំនងជាមួយគ្នា ដោយឈរលើមូលដ្ឋាន**អាតូមនិយម** ៖ ព្រឹត្តិការណ៍អាចបង្កើតបាននូវរូបរាងស្មុគ្រស្មាញ តែមានឯករាជ្យពីគ្នាទៅវិញទៅមក។

**ពិភពលោក** ៖ គេអាចបានត្រឹមតែយល់ដឹងពីសារជាតុផ្សេងនៃពិភពលោកតែប៉ុណ្ណោះ ហើយមិនអាចដឹងអស់ពីពិភពលោកទាំងស្រុងបានទេ ដោយសារតែផ្នែកខ្លះនៃពិភពលោកស្ថិតនៅក្នុងភាពអាថ៌កំបាំង។

**ទំនាក់ទំនងរវាងជីវវិទ្យា និងតថភាពភាសា** ៖ តួនាទីខាងផ្នែកអត្ថន័យនៃកម្មវត្ថុគឺជាន័យរបស់ឈ្មោះ។ ឈ្មោះគឺជាសញ្ញាដ៏សាមញ្ញគឺជាព្រំដែននៃការបែងចែកភាសា។ គេប្រើឈ្មោះដើម្បីសម្គាល់កម្មវត្ថុ។ បណ្តុំនៃឈ្មោះបង្កើតបានជាសំណើ(proposition)។ ពុទ្ធិរបស់យើងស្តីពីពិភពលោកឈរលើមូលដ្ឋាននៃសំណើសាមញ្ញ ដែលជាស្ថានភាពសាមញ្ញ ឬព្រឹត្តិការណ៍។ សំណើស្មុគ្រស្មាញ គឺជាហេតុការណ៍។

**ពុទ្ធិប្រធាន** *(sujet)* ៖ ពុទ្ធិប្រធាននេះមានលក្ខណៈជាបរមត្ថវិទ្យា និងជាឆន្ទៈ។ ពុទ្ធិប្រធានគ្មានទំនាក់ទំនងជាមួយពិភពលោកទេ ហើយមានលក្ខណៈចរិយាសាស្ត្រតែប៉ុណ្ណោះ។ ពុទ្ធិប្រធាន នេះមិនមែនជាបណ្តុំនៃគំនិត វេទនារម្មណ៍ ឬទំនួលអារម្មណ៍ឡើយ។ យើងអាចនិយាយបានថាពុទ្ធិប្រធានគឺជាផ្នែកមួយនៃកម្មវត្ថុដែលមិនមែនស្ថិតនៅក្នុងពិភពលោក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូច្នេះហើយ វាមិនអាចជាពុទ្ធិវត្ថុបានឡើយ។ **វីតហ្គេនស្តាញ** ប្រៀបប្រដូចពុទ្ធិប្រធានទៅនឹងដែនចក្ខុវិស័យ(champ de vision)ដែលភ្នែកអាចមើលឃើញ។ នៅខាងក្រៅដែនចក្ខុវិស័យនេះ ភ្នែកមិនអាចមើលឃើញឡើយ ប្រៀបបីដូចជាយើងមិនអាចមើលឃើញពុទ្ធិប្រធាននៃភាវៈដូច្នេះដែរ។ ដែនចក្ខុវិស័យនេះ កំណត់ព្រំដែនរវាងពុទ្ធិវត្ថុ និងពុទ្ធិប្រធាន។

**ផ្នែកអាថ៌កំបាំង** (Mystique) ៖ ភាសាគឺជាសូចនាករនៃព្រំដែនពិភពលោក ជាមធ្យោបាយ និងវិធីសាស្ត្រក្នុងការយល់ដឹងពីពិភពលោក ដែលបង្ហាញពីចំណុចរួមរវាងតថភាព និងអ្វីដែលអាចយល់ដឹងបាន។ អ្វីដែលស្ថិតនៅក្រៅពិភពលោក យើងមិនអាចនិយាយបានឡើយ។ អ្វីដែលស្ថិតនៅក្រៅភាសា( ពិភពហេតុការណ៍ វិទ្យាសាស្ត្រ និងតក្កវិទ្យា)គឺជាភាពគ្មានន័យ។ នេះគឺជាផ្នែកមួយនៃអត្ថិភាពនិយម អាថ៌កំបាំង ផ្នែកដែលមានតម្លៃបំផុតសម្រាប់មនុស្សលោក។ ផ្នែកអាថ៌កំបាំង មិនអាចបង្ហាញបានដោយសំណើដែលមានន័យ ដែលបង្ហាញពីហេតុការណ៍ តែផ្នែកនេះអាចបង្ហាញខ្លួនឯងបាន។ ផ្នែកអាថ៌កំបាំងនេះមាន ពុទ្ធិប្រធានអាទិទេព ចរិយាសាស្ត្រ និងសោភ័ណភាព។

## ២. «ទស្សនវិជ្ជាតាមបែបស៊ើបអង្កេត»

នៅក្នុងវណ្ណកម្មនេះ **វីតហ្គេនស្តាញ** បានផ្លាស់ប្តូរជំហរទស្សនវិជ្ជារបស់គាត់ ដោយសារតែការប្រើប្រាស់ភាសាជារៀងរាល់ថ្ងៃ។ នៅក្នុងស្នាដៃនេះ **វីតហ្គេនស្តាញ**សិក្សាអំពីវិធីសាស្ត្រក្នុងការយល់ដឹងពីពិភពលោក ពោលគឺបញ្ហាសិក្សាពីពុទ្ធិ(épistémologie)។ ចំណុចដែលខុសពីមុន គឺ **វីតហ្គេនស្តាញ**ប្រើប្រាស់ភាសា និងវេយ្យាករណ៍នៃជីវភាសា ជំនួសឱ្យតក្កវិទ្យា និងប្រើប្រាស់ទម្រង់ជីវិត ជំនួសឱ្យទម្រង់តក្កវិទ្យា។ ចំពោះ**អារីស្តូត** តក្កវិទ្យា និងវេយ្យាករណ៍មានលក្ខណៈដូចគ្នា។ តែចំពោះ**វីតហ្គេនស្តាញ** វិញ តក្កវិទ្យា និងវេយ្យាករណ៍មានលក្ខណៈមិនដូចគ្នាទេ ហើយចាត់ទុក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពិភពលោកជាបណ្ដុំនៃ «**ល្បែងភាសា**» និង «**ទម្រង់នៃជីវិត**»។ ចំពោះ **វីតហ្គេនស្តាញ** ល្បែងភាសាមានច្រើន ហើយប្រវត្តិសាស្ត្រអាចចាត់ទុកថាជាល្បែងនៃភាសាផងដែរ។ អត្ថន័យនៃជីវិតរបស់យើងអាស្រ័យទៅនឹងលទ្ធភាពក្នុងការបញ្ចេញមតិតាមរយៈភាសា។

**ល្បែងភាសា** ៖ ល្បែងភាសាមានដូចជា «ចេញបទបញ្ជា អនុវត្តតាមបញ្ជា ពិពណ៌នាពីវត្ថុអ្វីមួយ គូររូបអ្វីមួយ បង្កើតសម្មតិកម្ម និងពិនិត្យសម្មតិកម្ម បង្ហាញលទ្ធផលនៃការធ្វើពិសោធ ដោយប្រើតារាង និងដ្យាក្រាម ប្រឌិតរឿងអ្វីមួយ និងអានរឿងនេះ លេងក្នុងរឿងល្ខោន ដោះស្រាយបញ្ហាគណិតវិទ្យាអនុវត្ត បកប្រែពីភាសាមួយទៅភាសាមួយទៀត ស្នើសុំ អរគុណ ជេរប្រទេចផ្ដាសារ គោរព អង្វរក...» ទាំងអស់នេះសុទ្ធតែអាចចាត់ទុកថាជាល្បែងភាសា។ ភាសាជាប់ពាក់ព័ន្ធនឹងតួនាទី និងលទ្ធភាពនៃទស្សនវិជ្ជា។ ភារកិច្ចចម្បងនៃទស្សនវិជ្ជា គឺពិពណ៌នាអំពីល្បែងភាសា និងទម្រង់នៃជីវិត។ ក៏ប៉ុន្តែ ទស្សនវិជ្ជាមិនអាចប្រាប់យើងឱ្យបានច្រើនជាងល្បែងភាសាទាំងនេះឡើយ។ ដូច្នេះ ការយល់ដឹងពីសារជាតិនៃភាសា គំនិត និងពិភពលោក គឺស្ថិតនៅក្រៅសមត្ថកិច្ចនៃការសិក្សាទស្សនវិជ្ជា។

**ទម្រង់នៃជីវិត** ៖ ជីវិតដើរតួនាទីសំខាន់នៅក្នុងទស្សនវិជ្ជានាដំណាក់កាលចុងក្រោយរបស់**វីតហ្គេនស្តាញ**។ ទម្រង់នៃជីវិត គឺជាទំនាក់ទំនងទៅវិញទៅមករវាងសមត្ថភាពដើមពីររបស់មនុស្ស ៖ សមត្ថភាពក្នុងការបញ្ចេញសកម្មភាព និងសមត្ថភាពក្នុងការសំដែងដោយប្រើភាសា។ ទម្រង់នៃជីវិត គឺជាការប្រើប្រាស់ភាសា ឬល្បែងនៃភាសា។ ទម្រង់នៃជីវិតកំណត់នាវាជីវិតរបស់មនុស្សជារួម។

**វិធីសាស្ត្រទស្សនវិជ្ជា** ៖ ទស្សនវិជ្ជាត្រូវប្រើវិធីសាស្ត្រពិពណ៌នា។ ទស្សនវិជ្ជាមិនមែនមានគោលដៅពន្យល់ទេ តែបានត្រឹមតែពិពណ៌នាប៉ុណ្ណោះ។ ទស្សនវិជ្ជាពិពណ៌នាពីអ្វីដែលបង្ហាញឱ្យឃើញនូវអ្វីដែលលាក់បាំង ដោយប្រើប្រាស់ភាសា។ វេយ្យាករណ៍ គឺជាវេយ្យាករណ៍ស៊ីជម្រៅដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពិពណ៌នាពីអ្វីដែលសំខាន់ ដែលជាសារជាតិនៅក្នុងល្បែងភាសា ពោល គឺផ្សាភ្ជាប់ភាសាដែលជាប្រព័ន្ធនៃនិមិត្តរូបទៅនឹងជីវិត។ លទ្ធផលនៃការវិភាគវេយ្យាករណ៍ គឺជាការបកស្រាយនូវសញ្ញាណ និងទស្សនាទានផ្សេងៗ ហើយតាមរយៈនេះគេអាចបង្ហាញពីតួនាទីនៃភាសាជម្មតា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជាក្រោយវិជ្ជមាននិយម

**ទស្សនវិជ្ជាក្រោយវិជ្ជមាននិយម** (Postpositivisme) គឺជាទស្សនវិជ្ជានៅក្នុងពាក់កណ្ដាលសតវត្សរ៍ទី២០ ដែលផ្ដោតទៅលើការសិក្សាបញ្ហា**វិធីសាស្ត្រនៃវិទ្យាសាស្ត្រ** និងការទិតៀននូវទស្សនវិជ្ជាវិជ្ជមាននិយម ដោយធ្វើការពិនិត្យឡើងវិញនូវទស្សនាទានស្ដីពីវិចារណញ្ញាណ។ ទស្សនវិជ្ជាវិជ្ជមាននិយមយល់ថា គេអាចទទួលបាននូវពុទ្ធិ( ទាំងពុទ្ធិវិទ្យាសាស្ត្រ ទាំងពុទ្ធិទូទៅ)។

ប្រភពនៃទស្សនវិជ្ជាចរន្តក្រោយវិជ្ជមាននិយមកើតចេញពីគណិតវិទ្យា និងរូបវិទ្យានៅដើមសតវត្សរ៍ទី២០។ ប្រធានបទសំខាន់នៃការគិតនៅពេលនោះ គឺការបង្កើតទ្រឹស្ដីស្ដីពីទំនាក់ទំនងរវាងលំហ ពេលវេលា និងទម្ងន់(Théorie de la relativité)របស់**អាញស្តាញ** (Albert Einstein)។ ទ្រឹស្ដីនេះត្រូវបានបង្កើតឡើងក្នុងលក្ខខណ្ឌពិសេសមួយ គឺល្បឿនជិតស្មើល្បឿនពន្លឺ។ ក៏ប៉ុន្តែ ទ្រឹស្ដីនេះអនុញ្ញាតឱ្យគេអាចធ្វើការបកស្រាយតាមបែបទស្សនវិជ្ជាទូទៅយ៉ាងអស្ចារ្យ ៖ គឺទំនាក់ទំនងរវាងពេលវេលាជាមួយគ្នា អវត្តមាននៃពេលវេលាដាច់ខាត និងអវត្តមាននៃលំហដាច់ខាត និងគ្មានចលនា។ ទ្រឹស្ដីនេះដែលមិនពាក់ព័ន្ធនឹងពិភពលោកយើង តែរូបមន្តបរមត្ថវិជ្ជានៃទ្រឹស្ដីនេះបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដើម្បីពិពណ៌នាពីពិភពលោកយើងនេះ និងអាចរៀបចំជាទ្រឹស្ដីទស្សនវិជ្ជាបានយ៉ាងត្រឹមត្រូវទៀតផង។ ទំនាក់ទំនងចេញពីរូបមន្តគណិតវិទ្យាបានក្លាយជាវិធីសាស្ត្រមួយយ៉ាងល្អ។ វិធីសាស្ត្រស្ដីពីវិទ្យាសាស្ត្រ និងទស្សនាទានទស្សនវិជ្ជាដើរក្នុងទិសតែមួយ។

ឈរលើមូលដ្ឋានខាងលើ គណិតវិទូ **ពួងការ៉េ** (Pointcarré) បានលើកឡើងថា ទ្រឹស្ដីគឺជាការបង្កើតឡើងនូវប្រព័ន្ធគំនិតជាក់លាក់នៃអព្ភន្តរញាណ(intuition)ដែលមានពីមុនមក។ នៅក្នុងគណិតវិទ្យា និងតក្កវិទ្យា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេឃើញកើតឡើងនូវចលនា**អព្គន្តរញាណនិយម** ដែលគេយកទ្រឹស្តីរបស់លោក**ពួខភារ៉េ** ធ្វើជាមូលដ្ឋាន។ ដើម្បីចាត់ទុកពុទ្ធិវត្ថុ ឬសំណើមួយថាជាការពិត ទាមទារឱ្យដឹងពីទម្រង់ និងប្រភពរបស់វា។

**អព្គន្តរញាណនិយម** ខុសពីទ្រឹស្តី **វិជ្ជមាននិយមតក្កវិទ្យា** (positivisme logique) ដែលចាត់ទុកទិន្នន័យបទពិសោធ ថាជាវត្ថុទីមួយដែលត្រូវយល់ដឹង។ ដូច្នេះ វិទ្យាសាស្ត្រត្រូវតែជាបណ្តុំនៃហេតុការណ៍ត្រឹមត្រូវ។ បរមត្ថវិទ្យាលែងមានន័យទៀតហើយសម្រាប់ពួកគេ។ លក្ខណវិនិច្ឆ័យដែលកំណត់ថាទ្រឹស្តីមួយមានលក្ខណៈត្រឹមត្រូវ ទាល់តែទ្រឹស្តីនោះត្រឹមត្រូវតាមហេតុការណ៍ ដែលគេអាចបញ្ជាក់បាន អាចពិនិត្យបញ្ជាក់បាន។

ទស្សនវិទូក្រោយវិជ្ជមាននិយមមាន **ការល ប៉ប់ប៉េរ** (Karl Popper) **ថូម៉ាស គុញ** (Thomas Kuhn) **អ៊ីមរ៉េ ឡាកាតូស** (Imre Lakatos) និង **ប៉ូល ហ្វេយេរ៉ាបែនដ៍** (Paul Feyerabend) ជាដើម។

**ការល ប៉ប់ប៉េរ** (១៩០២-១៩៩៤) កើតនៅទីក្រុងវីយែន រៀនវិទ្យាសាស្ត្រ និងចិត្តវិទ្យា ចូលចិត្តតូរ្យតន្ត្រី ហើយមានបំណងធ្វើជាគ្រូបង្រៀន។ លោកចូលចិត្តទស្សនវិជ្ជាដែរ តែមិនដល់កម្រិតវិជ្ជាជីវៈឡើយ។ ទស្សនៈរបស់លោកស្តីពីពុទ្ធិវិទ្យាសាស្ត្រទទួលឥទ្ធិពលពី **ពួខភារ៉េ** ដែលយល់ឃើញថាមូលដ្ឋានគ្រឹះនៃស្នាដៃវិទ្យាសាស្ត្របណ្តាលមកពីអំពើនៃពុទ្ធិពីពេលមុន។ នៅក្នុងស្នាដៃទីមួយដែលមានចំណងជើងថា «**បញ្ហាជាមូលដ្ឋានពីរនៃទ្រឹស្តីស្តីពីពុទ្ធិ**» (Les deux problèmes fondamentaux de la théorie de la connaissance) 1932 លោក **ប៉ប់ប៉េរ**បានលើកឡើងថា ការសិក្សាពីចំណេះដឹងត្រូវឈរលើមូលដ្ឋានពីរគឺ បញ្ហាឯកសព្វវិធី(induction, problème de Hume)និងបញ្ហានៃការកំណត់ព្រំដែន(démarcation ou problème de Kant)។ លោកបានបញ្ជាក់ថា ការកំណត់ព្រំដែនគឺជាបញ្ហាដែលត្រូវចាប់អារម្មណ៍ជាងគេ ដោយសារតែវាមានអត្ថន័យមិនមែនត្រឹមតែសម្រាប់ទ្រឹស្តីនិងទស្សនវិជ្ជាប៉ុណ្ណោះទេ តែក៏មានបច្ចុប្បន្នភាពសម្រាប់វិទ្យាសាស្ត្រ ហើយជាពិសេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់អាជីពអ្នកស្រាវជ្រាវ។

លក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់ព្រំដែនរវាងវិទ្យាសាស្ត្រ និងមិនមែនវិទ្យាសាស្ត្រ គឺលទ្ធភាពក្នុងការបញ្ជាក់ បដិសេធ ឬធ្វើតេស្តសាកល្បង។ ទស្សនវិទូដែលជាសមាជិកនៃក្រុមវីយែនក៏បានប្រើវិធីសាស្ត្រពិនិត្យបញ្ជាក់ (verification)ក្នុងការកំណត់ព្រំដែន ក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងទ្រឹស្តីបរមត្ថវិទ្យាដែរ។ ពួកគេបានលើកឡើងថា ៖ ប្រសិនបើគេមិនអាចកំណត់ជាសម្មតិកម្មមួយពិត សម្មតិកម្មនេះគ្មានន័យអ្វីទាំងអស់។ ដូច្នេះ អត្ថន័យនៃសម្មតិកម្ម គឺវិធីសាស្ត្រក្នុងការពិនិត្យបញ្ជាក់ថាសម្មតិកម្មនេះត្រូវឬខុស។

លោក **ប៉ុបប៉ែរ** យល់ឃើញថា ទ្រឹស្តីជានិច្ចកាលតែងតែកើតមានមុនការសង្កេត(l'observation)។ ដូច្នេះ ដើម្បីបង្កើតទ្រឹស្តី គេត្រូវចាប់ផ្តើមពីបញ្ហាជាក់ស្តែង ឬទ្រឹស្តីដែលជួបការលំបាក ដោយសារថាការសង្កេតត្រូវធ្វើឡើងដោយឈរលើមូលដ្ឋាននៃប្រព័ន្ធរង់ចាំមួយ ដែលជាបណ្តុំពុទ្ធិមួយចំនួនដែលកើតមានពីពេលចាប់ផ្តើមមកម្ល៉េះ។ ដូច្នេះ ពុទ្ធិបានមកពីការកែឬផ្លាស់ប្តូរពុទ្ធិដែលមានពីមុន ដោយប្រើវិធីសាស្ត្រសម្មតិកម្មប្រកបដោយភាពក្លាហាន និងការខិតខំបង្ហាញថាវាមិនពិត ពោលគឺជាវិធីសាស្ត្រសាកល្បង និងលុបបំបាត់កំហុស តាមរយៈការបង្កើតជាទ្រឹស្តី ហើយយកទ្រឹស្តីនេះទៅធ្វើតេស្តសាកល្បង។

**ថូម៉ាស គុញ** (១៩២២-១៩៩៦) ជាគ្រូពេទ្យ ប្រវត្តិវិទូ និងទស្សនវិទូនៃវិទ្យាសាស្ត្រអាមេរិកដែល បានលើកឡើងពីសម្មតិកម្មស្តីពី «**ការផ្លាស់ប្តូរជាមូលដ្ឋាននៃអភិក្រមជិជសម្មតិកម្ម**» (paradigm shift) នៅក្នុងស្នាដៃរបស់លោកដែលបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៦២ ឈ្មោះ «**រចនាសម្ព័ន្ធនៃបដិវត្តវិទ្យាសាស្ត្រ**» (The Structure of Scientific Revolutions)។ លោកលើកឡើងពីទ្រឹស្តីដែលថា វឌ្ឍនភាពនៃពុទ្ធិខាងផ្នែកវិទ្យាសាស្ត្រប្រែប្រួលមិនមែនតាមផ្លូវត្រង់ និងជាបន្តបន្ទាប់ទេ តែវាប្រែប្រួលតាមបែបជា «**ការផ្លាស់ប្តូរជាមូលដ្ឋាននៃអភិក្រមជិជសម្មតិកម្ម**» (paradigm



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*shift)* ដោយទទួលយកនូវអតិក្រមថ្មីក្នុងការទទួលយកចំណេះដឹងថ្មីដែលអ្នកវិទ្យាសាស្ត្រមិនបានទាត់ចោលពីពេលមុនមក ហើយសញ្ញាណនៃការពិតក្នុងវិទ្យាសាស្ត្រមិនអាចកំណត់បាន ដោយឈរលើលក្ខណវិនិច្ឆ័យជាសត្យានុម័តបានឡើយ។ មានតែសហគមន៍អ្នកវិទ្យាសាស្ត្រប៉ុណ្ណោះដែលអាចកំណត់លក្ខណវិនិច្ឆ័យជាសត្យានុម័តនេះដោយកុងសង់ស៊ុសបាន។ ដូច្នេះហើយទើបការយល់ដឹងពីវិទ្យាសាស្ត្ររបស់មនុស្ស មិនអាចឈរលើមូលដ្ឋានគោលការណ៍សត្យានុម័តតែមួយគត់ឡើយ ដោយសារតែសេចក្តីសន្និដានជាសត្យានុម័ត ក៏ត្រូវផ្អែកលើទស្សនវិស័យជាអត្តនោម័តរបស់អ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវផងដែរ។

**ប៉ូល ហ្វេយេរ៉ាបែន** *(Paul Karl Feyerabend)* ( ១៩២៤-១៩៩៤ ) គឺជាទស្សនវិទូវិទ្យាសាស្ត្រជនជាតិដែលកើតនៅអូទ្រីស និងជាសាស្ត្រាចារ្យទស្សនវិទូនៅសាកលវិទ្យាល័យ California នៅ Berkeley។ លោកបង្រៀននៅទីនោះក្នុងរយៈពេលបីទសវត្សរ៍( ពីឆ្នាំ ១៩៥៨ ដល់ឆ្នាំ ១៩៨៩)។ ស្នាដៃសំខាន់ៗរបស់លោកគឺ ៖ *Against Method(1975), Science in a Free Society (1978)* និង *Farewell to Reason(1987)*។ លោកល្បីល្បាញដោយសារទស្សនៈគ្មានសណ្តាប់ធ្នាប់ស្តីពីវិទ្យាសាស្ត្រ និងការបដិសេធនៃវិធានវិធីសាស្ត្រសាកល និងមានឥទ្ធិពលក្នុងវិស័យសង្គមវិទ្យានៃពុទ្ធិវិទ្យាសាស្ត្រ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជារចនាសម្ព័ន្ធនិយម

**រចនាសម្ព័ន្ធនិយម** (Structuralisme) គឺជាវិធីសាស្ត្រវិភាគដែលគេយកមកប្រើប្រាស់ក្នុងវិទ្យាសាស្ត្រសង្គម ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០។ ទ្រឹស្តីនេះកើតចេញពីស្នាដៃរបស់លោក Ferdidand de Saussure ស្តីពីភាសា។ លោកយល់ថា ភាសាគឺជាប្រព័ន្ធ ដែលធាតុនីមួយៗ ឬសញ្ញាភាសា ត្រូវតែវិភាគដោយពិនិត្យមើលទំនាក់ទំនងសមមូល ឬផ្ទុយគ្នាជាមួយធាតុ ឬសញ្ញាឯទៀត ដោយសារតែធាតុ ឬសញ្ញាទាំងនោះត្រូវតែដើរតួនាទីខុសពីធាតុ ឬសញ្ញាដទៃទៀត។ សញ្ញាភាសាមានការវិវត្ត ទៅតាមវិធានដែលមិនចំណុះឱ្យអ្នកដែលសរសេរ ហើយបង្កើតបានជាប្រព័ន្ធមួយ។ ការវិភាគ**រចនាសម្ព័ន្ធនៃភាសា**អាចឱ្យគេប្រៀបធៀបភាសាផ្សេងៗ ក្នុងបរិការណ៍នៃប្រព័ន្ធបញ្ចេញសំឡេង ដោយបង្ខិតឱ្យជិត ឬដោយបង្ហាញឱ្យឃើញខុសគ្នានូវលក្ខណៈពិសេសរបស់វា។ រចនាសម្ព័ន្ធនិយមយល់ថា ទាល់តែគេប្រៀបធៀបធាតុបង្កើតប្រព័ន្ធ ទើបគេអាចយល់បាននូវតួនាទីផ្ទាល់នៃធាតុទាំងនេះ។

បន្ទាប់មក គេយកវិធីសាស្ត្រវិភាគរចនាសម្ព័ន្ធភាសារបស់លោក Ferdidand de Saussure ទៅប្រើនៅក្នុងវិទ្យាសាស្ត្រសង្គមទាំងមូលតែម្តង។ ទ្រឹស្តីនេះផ្តោតលើការប្រើប្រាស់**រចនាសម្ព័ន្ធ** ដើម្បីសិក្សាពីសង្គមមនុស្ស។ ដើម្បីយល់ពីបុគ្គលម្នាក់ៗ គេត្រូវវិភាគពីប្រព័ន្ធនៃទំនាក់ទំនងជានិមិត្តរូបដែលបុគ្គលនោះចូលរួមក្នុងប្រព័ន្ធនេះ ដោយមិនដឹងខ្លួន។ រចនាសម្ព័ន្ធនិយម គឺជាទ្រឹស្តី និងវិធីសាស្ត្រដែលផ្តោតលើការប្រៀបធៀបរូបរាង ជាជាងការប្រៀបធៀបខ្លឹមសារ។

ដោយសារតែ**រចនាសម្ព័ន្ធនិយម**នេះមិនមែនជាចរន្តទស្សនវិជ្ជា តែជាវិធីសាស្ត្រវិភាគ នោះទើបគេអាចធ្វើចំណាត់ថ្នាក់**រចនាសម្ព័ន្ធនិយម**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តាមវិស័យដូចតទៅ ៖ (១) ទស្សនវិជ្ជា ៖ លោក* **មីស្សែល ហ្វ៊ូកូល** *(Michel Foucault) និងលោក* **មីស្សែល សែរ៉េស** *(Michel Serres) (២) ភាសាវិទ្យា ៖ លោក Ferdidand de Saussure លោក Roman Jakobson លោក Georges Dumézil លោក Émile Benveniste (៣) ជាតិពន្ធុវិទ្យា ៖ លោក Claude Lévi-Strauss (៤) វិភាគចិត្តវិទ្យា(psychanalyse) ៖ លោក Jacques Lacan និង (៥) សញ្ញាសាស្ត្រ(sémiologie) ៖ លោក* **ឡូរ៉ង់ បាត្រត៍** *(Roland Barthes)។*

*ចរន្តរចនាសម្ព័ន្ធនិយមនេះយល់ថា ដំណើរការសង្គមកើតចេញពីរចនាសម្ព័ន្ធជាមូលដ្ឋានហើយបាតុភូតយ៉ាងប្រត្យក្សបង្កប់នូវរចនាសម្ព័ន្ធយ៉ាងស្មុគ្រស្មាញ ដែលបណ្ដាលឱ្យមានបាតុភូតទាំងនេះ ហើយមានតែវិធីសាស្ត្ររចនាសម្ព័ន្ធនិយមទេ ដែលអាចបកស្រាយបំភ្លឺបញ្ហានេះបាន។ លោក Claude Lévi-Strauss បានសរសេរថា ៖*

**រចនាសម្ព័ន្ធនិយម** *នៃទស្សនវិជ្ជារបស់លោក Jacques Derrida (១៩៣០-២០០៤) មិនមែនផ្ដោតលើការសិក្សាភាសាទេ តែលើការសិក្សាសំណេរ ដើម្បីបកស្រាយរចនាសម្ព័ន្ធសង្គមដែលគេមិនដឹង។ លោកទិតៀនវិធីសាស្ត្ររបស់ Saussure ក្នុងការវិភាគដោយប្រើប្រាស់ទម្រង់កិរិយាវិសេសនិងសំឡេងនៃភាសា ដោយមិនយកសំណេរមកវិភាគ។ ដូច្នេះហើយទើប Jacques Derrida បានបង្កើតទ្រឹស្ដី* ចរន្តក្រោយរចនាសម្ព័ន្ធនិយម *(le poststructuralisme)។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# មីស្សែល ហ្វូកូល
## (១៩២៦-១៩៨៤)

**មីស្សែល ហ្វូកូល** (*Michel Foucault*) *កើតនៅ Poitiers ប្រទេសបារាំងក្នុងឆ្នាំ ១៩២៦។ លោករៀនទស្សនវិជ្ជានៅសាលាគរុកោសល្យជាន់ខ្ពស់ ហើយទទួលបានសញ្ញាបត្រមហាបរិញ្ញាខាងផ្នែកទស្សនវិជ្ជាក្នុងឆ្នាំ ១៩៥១។* **ហ្វូកូល** *គឺជាបញ្ញវន្តដែលចូលរួមយ៉ាងសកម្មក្នុងការងារនយោបាយ និងសង្គម(un intellectual engagé) ដោយដើរតួនាទីជាទស្សនវិទូផង ជាប្រវត្តិវិទូផង ជាសង្គមវិទូផង ជាចិត្តវិទូផង និងជាភាសាវិទូផង។ លោកបានសរសេរនិក្ខេបបទស្តីពីការព្យាបាលមនុស្សវិកលចរិត នៅក្នុងសម័យកាលផ្សេងៗគ្នា។ នៅក្នុងឆ្នាំ ១៩៧១ លោកបានបង្កើតក្រុមការងារស្តីពីពន្ធនាគារ ដើម្បីបកអាក្រាតពីស្ថានភាពនៃពន្ធនាគារ និងដើម្បីអាចឱ្យអ្នកជាប់ពន្ធនាគារអាចបញ្ចេញមតិបាន។ លោកក៏បានសរសេរផងដែរពីប្រវត្តិនៃការរួមភេទ ហើយទទួលមរណៈភាពក្នុងឆ្នាំ ១៩៨៤ ដោយជំងឺអេដស៍។*

**ស្នាដៃសំខាន់** ៖ *ស្នាដៃសំខាន់របស់***មីស្សែល ហ្វូកូល** *គឺ* «**ការឃ្លាំមើល និងការផ្តន្ទាទោស**» និង «**ពាក្យ និងវត្ថុ**»។

*ទស្សនវិជ្ជារបស់* **មីស្សែល ហ្វូកូល** *ផ្តោតលើស្ថានភាពរបស់មនុស្សបាតសង្គម មនុស្សក្រីក្រតោកយ៉ាកក្នុងសង្គមមនុស្ស។ លោកវិភាគពីស្ថានភាពនៃអ្នករស់នៅក្នុងពន្ធនាគារ ទាំងអ្នកវិកលចរិត ទាំងឧក្រិដ្ឋជន។ លោកយល់ថា ការឃុំឃាំងអ្នកទោស គឺជាជម្រើសប្រវត្តិសាស្ត្រ និងជាការអនុវត្តក្នុងសង្គម។ គេឃុំឃាំងមនុស្សដែលគេចាត់ទុកថាជាមនុស្សមិនធម្មតា។ ដូច្នេះ ប្រព័ន្ធគំនិតរបស់* **ហ្វូកូល** *ផ្តោតលើព្រំប្រទល់រវាងមនុស្សធម្មតា និងមនុស្សមិនធម្មតា។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**គោលដៅនៃការឃុំឃាំង ៖** *នៅក្នុងស្នាដៃ «***ការឃ្លាំមើល និងការផ្តន្ទាទោស***»* **ហ្វូកូល** *បានសរសេរថា គោលដៅនៃការឃុំឃាំងឱ្យអ្នកទោស ឬអ្នកវិកលចរិតនៅដាច់ពីគេ គឺដើម្បី តាមរយៈការឃ្លាំមើលជាប្រចាំ និងការបំបាត់សេរីភាពនេះ ធ្វើឱ្យមនុស្សស្តាប់បង្គាប់ និងស្ថិតនៅក្រោមការត្រួតត្រាទាំងស្រុង។ ក៏ប៉ុន្តែ ជាក់ស្តែងពន្ធនាគារបានក្លាយជាកន្លែងដែលផលិតបទល្មើស និងតាមរយៈវិធានការតាមផ្លូវតុលាការ វិធានការឃ្លាំមើល និងការរស់នៅក្នុងមជ្ឈដ្ឋានប្រព្រឹត្តបទល្មើស ពន្ធនាគារ គឺជាកន្លែងដែលបង្កើតឱ្យមានបទល្មើសទៅវិញ។* **ហ្វូកូល** *បានសរសេរថាពន្ធនាគារបង្កើតឱ្យមានមនុស្សវិកលចរិត ឧក្រិដ្ឋករ មនុស្សស្រឡាញ់ភេទដូចគ្នាទៅវិញ។* **ហ្វូកូល** *យល់ឃើញថា ពន្ធនាគារដូចគ្នាទៅនឹងរោងចក្រ សាលារៀន និងបន្ទាយទាហាន ហើយស្ថាប័នទាំងនេះក៏ដូចគ្នាទៅនឹងពន្ធនាគារដែរ។ តាមរយៈស្ថាប័នទាំងនេះ គេបង្កើតឱ្យមានសង្គមមួយដែលមានវិន័យ ហើយមានតែរដ្ឋអំណាចទេដែលមានចំណេះដឹងគ្រប់គ្រាន់ ដើម្បីបន្តការត្រួតត្រា។*

**បុរាណវិទ្យានៃពុទ្ធិ ៖** *នៅក្នុងស្នាដៃ «***ពាក្យ និងវត្ថុ***»* **ហ្វូកូល** *វិភាគពីពាក្យពេចន៍ និងសំណេររបស់មនុស្សចាប់ពីសតវត្សរ៍ទី១៧ដល់១៩ ដែលបង្ហាញថា មនុស្សបានបង្កើតទំនាក់ទំនងរវាងខ្លួនជាមួយនឹងវត្ថុ ភាសា ការងារ និងជីវិត ហើយវត្ថុ ភាសា ការងារ និងជីវិតបានក្លាយទៅជាកម្មវត្ថុនៃពុទ្ធិ។ ពាក្យពេចន៍ និងផ្នត់គំនិតទាំងនេះវាផ្សារភ្ជាប់ទៅនឹងសម័យកាលនីមួយៗ។ ដូច្នេះហើយ ទើបគ្មានទេការពិតទូទៅដែលអាចអនុវត្តបានជាមួយមនុស្សទូទៅគ្រប់សម័យកាលបាន។ ប្រវត្តិសាស្ត្រមានឫសគល់ភ្ជាប់ជាមួយសម័យកាលកំណត់។*

**បញ្ហានៃការរួមសង្វាស ៖ ហ្វូកូល** *វិភាគពីប្រវត្តិនៃការរួមសង្វាសតាមរយៈការវិភាគពីសំណេរស្តីពីការសង្វាស ប្រភេទនៃការរួមសង្វាស និងវិធីសាស្ត្រផ្សេងៗដែលគេប្រើក្នុងការរួមសង្វាសនៅក្នុងសង្គម ដូចជាការរួមភេទរវាងមនុស្សមានភេទដូចគ្នា ការស្ទាបអង្អែល ការប្រើប្រាស់អំពើ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ហិង្សា និងវត្ថុដើម្បីធ្វើឱ្យមានចំណង់រួមសង្វាស។ តាមរយៈការវិភាគនេះ* **ហ្វូកូល** *ធ្វើសេចក្តីសន្និដ្ឋានថា ការរួមសង្វាស គឺជាមធ្យោបាយនៃការត្រួតត្រា និងឃ្លាំមើលក្នុងសង្គម ក្នុងគោលដៅរើសអើង និងដាក់ទណ្ឌកម្ម។ លោកបន្តទៀតថា រដ្ឋអំណាចប្រើប្រាស់នូវការរួមសង្វាស ដើម្បីបន្តសង្គ្រាមយ៉ាងហោចណាស់ ដើម្បីអនុវត្តនូវរបៀបរបបគ្រប់គ្រងតាមបែបយោធាជាមធ្យោបាយជាមូលដ្ឋាន ដើម្បីបញ្ចៀសចលាចលក្នុងសង្គម។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជាក្រោយទំនើបនិយម

**ទស្សនវិជ្ជាក្រោយទំនើបនិយម** (Postmodernisme) ចាប់បដិសន្ធិឡើងចេញពី«ចរន្តវប្បធម៌ក្រោយទំនើបនិយម» ដែលឈរលើមូលដ្ឋាននៃការឈ្វេងយល់លើទិដ្ឋភាពផ្សេងៗគ្នានៃពិភពលោក។ ទស្សនៈក្រោយទំនើបនិយមមានលក្ខណៈជាអន្តរវិស័យ ជាគោលការណ៍ក្នុងការស្រាវជ្រាវ និងសម្រាប់វិភាគអត្ថបទដោយប្រើប្រាស់វិធីសាស្ត្រ**បំបែកអត្ថបទ** (Deconstruction) ដែលត្រូវបានយកទៅប្រើប្រាស់ក្នុងវិស័យជាច្រើនដែលពាក់ព័ន្ធនឹងសកម្មភាពរបស់មនុស្ស ដូចជាសិល្បៈ នយោបាយ សេដ្ឋកិច្ច ទស្សនវិជ្ជា អក្សរសិល្ប៍ ចិត្តសាស្ត្រ វិទ្យាសាស្ត្រ និងក្នុងវិទ្យាសាស្ត្រដទៃទៀត។

ចលនាក្រោយទំនើបនិយម គឺជាការពិចារណាដោយទិតៀននៃវប្បធម៌ និងទស្សនវិជ្ជាសម័យទំនើប ដែលអនុញ្ញាតឱ្យគេមើលឃើញពិភពលោកតាមទិដ្ឋភាពផ្សេងៗពីគ្នា ជាពិសេសពាក់ព័ន្ធទៅនឹងវិស័យសិល្បៈ អក្សរសិល្ប៍ និងស្ថាបត្យកម្ម។ ទស្សនវិជ្ជាក្រោយទំនើបនិយម គឺជាដំណាក់កាលថ្មីមួយទៀតនៃការវិវត្តវប្បធម៌នៅអឺរ៉ុបខាងលិចក្រោយសង្គ្រាមលោកលើកទី២ ដែលអ្នកទិតៀនសិល្បៈដ៏ល្បីម្នាក់គឺ **ចេនស៍** (Charles Jencks) បានសរសេរក្នុងស្នាដៃរបស់លោកគឺ «**ភាសាស្ថាបត្យកម្មក្រោយទំនើបនិយម**» ក្នុងឆ្នាំ ១៩៧៥ ដើម្បីគាំទ្រដល់ស្ទីលនៃស្ថាបត្យកម្មថ្មីដែលប្រសូតឡើងនាចុងទសវត្សរ៍ឆ្នាំ ១៩៦០ និងដើមទសវត្សរ៍ឆ្នាំ ១៩៧០។ បន្ទាប់មក ពាក្យនេះត្រូវបានផ្សព្វផ្សាយ និងប្រើប្រាស់ក្នុងវិស័យគំនូរ ដែលផ្ទុះបញ្ចាំងពីការពិសោធក្នុងការប្រើប្រាស់ពណ៌ ទម្រង់ និងផ្នែកមួយនៃគំនូរ ហើយក៏បានជ្រាបចូលទៅក្នុងការសរសេរអត្ថបទអក្សរសិល្ប៍ ជាប្រភេទប្រលោមលោកថ្មី។

បើតាមទស្សនៈរបស់ទស្សនវិទូក្រោយទំនើបនិយម **ហ្សាក់ ដេរីដា**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេឃើញមានចលនាធ្វើវិមជ្ឈការខាងផ្នែកសង្គម និងវប្បធម៌។ លោក **ដេរីដា** ចូលចិត្តនិយាយថា «ចាប់តាំងពីសម័យបាប៊ីឡូនមក មិនដែលមានភាសាតែមួយឡើយ ហើយក៏គ្មានរបៀបសំដែងមតិរួមគ្នាតែមួយដែរ»។ លោក **រ៉ូឡង់ បារត៍** បានសរសេរថា «ចំនួនភាសា ស្មើនឹងចំនួនគោលបំណង»។ ដូច្នេះហើយ គ្មានទេរបៀប ឬ ស្ទីលតែមួយ»។ ខាងផ្នែកទស្សនវិជ្ជាវិញ គេឃើញមានការផ្លាស់ប្ដូរជាសំខាន់ ដោយគេចាប់ផ្ដើមពិនិត្យឡើងវិញនូវអភិក្រមក្នុងការវិភាគអត្ថបទ។ បញ្ហាសំខាន់គឺការវិភាគអត្ថបទ។

ជារួម ទស្សនវិជ្ជាក្រោយទំនើបនិយមផ្ដោតលើស្នាដៃនៃទស្សនវិទូបារាំងក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ ដែលអ្នកប្រាជ្ញអាមេរិកប្រសិទ្ធនាមឱ្យថាជា **ទ្រឹស្ដីបារាំង** (French Theory)។ ទស្សនវិជ្ជានេះផ្ដោតទៅលើការទិតៀនទស្សនៈប្រពៃណី និងវិចារណញ្ញាណនៃសម័យទំនើបនៃបស្ចិមប្រទេស និងស្នើឡើងនូវវិធីសាស្ត្រថ្មីក្នុងការវិភាគអត្ថបទ និងប្រវត្តិសាស្ត្រដែលទទួលឥទ្ធិពលពីលទ្ធិម៉ាក្សនិយម ការទិតៀនទស្សនវិចារណញ្ញាណរបស់ **គៀគឺហ្គាដ** និង **នីតស៍** ទស្សនបាតុភូតនិយមរបស់ **ហ្សរស៊ែល** និង **ហៃដឺហ្គ័រ** ការវិភាគចិត្តសាស្ត្ររបស់ **ហ្វ្រឹត** និង**ឡាកង់** និងទស្សនរចនាសម្ព័ន្ធនិយមរបស់ **ឡេវី-ស្ត្រោស**។ ទស្សនវិជ្ជាក្រោយទំនើបនិយមលែងផ្ដោតលើការស្រាវជ្រាវ ដើម្បីរកប្រព័ន្ធវិចារណញ្ញាណសាកលដូច **កង់ត៍** និង **ហេហ្គែល** ទៀតហើយ។ ទស្សនវិទូទាំងនេះលែងចែកបញ្ហាជាសញ្ញាណផ្ទុយគ្នាដូចនៅក្នុងបរមត្ថវិជ្ជា ៖ សច្ចធម៌ និងក្លែងក្លាយ រាង និងអាត្ម័ន សង្គម និងបុគ្គល សេរីភាព និងការកំណត់និយម វត្តមាន និងអវត្តមាន។ល។

ទស្សនវិទូក្រោយទំនើបនិយមខុសពីទស្សនវិទូរចនាសម្ព័ន្ធនិយមត្រង់វិធីសាស្ត្រ ក្នុងការវិភាគ និងស្រាវជ្រាវអត្ថបទ ដែលក្នុងន័យទូលាយ គឺការប្រើប្រាស់វិធីសាស្ត្រតាមបែប **ការរុះរើ** (Deconstruction) ហើយបើតាមន័យចង្អៀត គឺការវិភាគអត្ថបទសិល្បៈ(ដែល **សាលាយ៉េល** នៃសហរដ្ឋ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាមេរិកបង្កើតឡើង)និងការវិភាគបាតុភូតផ្សេងៗ ដូចជាអត្ថបទជាដើម ដោយប្រើប្រាស់វិធីសាស្ត្រ**ការរុះរើ**អត្ថបទរបស់លោក **ដេរីដា** *(Derrida)* ជាវិធីសាស្ត្រក្នុងការពន្យល់ន័យអត្ថបទ ដោយស្វែងរកអត្ថន័យផ្សេងទៀត និងអត្ថបទផ្សេងទៀត ដែលជាប់ពាក់ព័ន្ធនឹងអត្ថបទដែលត្រូវវិភាគនេះ។ វិធីសាស្ត្រ**ការរុះរើ**អត្ថបទរបស់ **ដេរីដា** គឺជាវិធីសាស្ត្រ អានអត្ថបទដោយវិភាគអត្ថបទដែលអាចផ្ទុយទៅនឹងរចនាសម្ព័ន្ធឯកភាព ឬន័យដើមរបស់អត្ថបទនោះ។ គោលដៅសំខាន់ គឺដើម្បីបង្ហាញថាភាសានៃអត្ថបទនេះមានលក្ខណៈស្មុគ្រស្មាញ គ្មានស្ថិរភាព និងមិនអាចយល់បាន។ តាមទស្សនៈក្រោយទំនើបនិយម ជាមួយនឹងការប្រើវិធីសាស្ត្របំបែកអត្ថបទ ដែលបង្ហាញពីសារជាតិនៃការគិតដោយឥតព្រំដែន មានលក្ខណៈជាដំណើរការ និងមានជីវភាព ទស្សនវិជ្ជាបានរកឃើញនូវឧបករណ៍គ្រប់គ្រាន់ ក្នុងការធ្វើការស្រាវជ្រាវគំនិតទស្សនវិជ្ជា។

ទស្សនវិទូក្រោយទំនើបនិយម គឺជាទស្សនវិទូដែលមាននិន្នាការជាទស្សនវិទូ នវ ឬក្រោយរចនាសម្ព័ន្ធនិយមដូចជា ៖ **មីស្សែល ហ្វូកូល** *(Michel Foucault)* (ដំណាក់កាលចុងក្រោយ) **ហ្សាក់ ដេរីដា** *(Jacques Derrida)* **រ៉ូឡង់ បារតឹ** *(Roland Barthes)* (ដំណាក់កាលចុងក្រោយ) **អេមីលឡាកង់** *(Jacques-Marie-Émile Lacan)* (ដំណាក់កាលចុងក្រោយ) **ព្យែរ-ហ្វេលិច ខ្វាតតារី** *(Pierre-Félix Guattari)* **ហ្ស៊ីល ដឺលូស្ស** *(Gilles Deleuze)*។ នៅសហរដ្ឋអាមេរិក ទស្សនវិទូក្រោយទំនើបនិយមដ៏ល្បីជាងគេគឺ **រីឆាត រ៉ូទី** *(Richard Rorty)*។

នៅក្នុងវណ្ណកម្មទស្សនវិជ្ជាសំខាន់ៗដូចជា «**រចនាសម្ព័ន្ធនៃអាកប្បកិរិយា**» *(Structure du comportement, 1942)* «**បាតុភូតនិយមនៃវេទនារម្មណ៍**» *(Phénoménologie de la perception, 1945)* «**អ្វីដែលមើលឃើញ និងអ្វីដែលមើលមិនឃើញ**» *(Le visible et l'invisible, 1961)* ទស្សនវិទូបាតុភូតនិយម និងអត្ថិភាពនិយមបារាំង **ម៉ូរីស មែរឡូ-ប៉ុងទី**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*(Maurice Merlo-Ponty)* បានបង្កើតវិធីសាស្ត្របាតុភូតនិយមដោយទិតៀនការឱ្យនិយមន័យអាត្ម័នសុទ្ធ ហើយបានបង្កើតចរន្តថ្មីនៃទស្សនវិជ្ជាអត្ថិភាពនិយម។ លោកប្រឆាំងនឹងទស្សនៈថា សតិសម្បជញ្ញៈ(conscience) គឺជាប្រភពនៃស្វ័យភាពដាច់ខាត ដែលជាគម្របឆ្លើយតបទៅនឹងតថភាពនៃពិភពលោក។ លោកយល់ថា មនុស្សតែងតែមានការប្ដេជ្ញាចិត្តខ្ពស់ នៅពេលប្រឈមមុខទៅនឹងស្ថានភាពជាក់ស្ដែង ឬប្រវត្តិសាស្ត្រអ្វីមួយ។ ន័យមានមុននឹងមនុស្សធ្វើសកម្មភាពក្នុងពិភពលោកទៅទៀត។ សេរីភាព គឺជាការដកខ្លួនដើម្បីចាប់យកន័យដែលមានរួចហើយនេះហើយផ្ដល់អត្ថន័យផ្ទាល់ខ្លួនដើម្បីឱ្យមនុស្សទទួលយកបាន។ ជម្រើសរបស់យើងក្នុងជីវិតធ្វើឡើងដោយឈរលើមូលដ្ឋាននៃព័ត៌មានមួយចំនួន។ គេមិនដែលសម្រេចអ្វីដោយអត់មានអ្វីសោះឡើយ ដោយសារតែជីវិតរបស់យើងតែងតែស្ថិតនៅក្នុងស្ថានភាពអ្វីមួយ។ ទស្សនាទានមួយទៀតរបស់ **មេរឡូ-ប៉ុងទី គឺអ្នកផ្សេង** (autri)។ នៅពេលដែលមនុស្សម្នាក់ទទួលអារម្មណ៍ពីអ្នកផ្សេងទៀត ភាសា គឺជាកម្មវត្ថុវប្បធម៌ដែលដើរតួនាទីសំខាន់។ អាកប្បកិរិយារបស់អ្នកផ្សេង និងសម្ដីរបស់អ្នកផ្សេងមិនមែនជាអ្នកផ្សេងឡើយ។ ចំពោះមុខព្រឹត្តិការណ៍អ្វីមួយ ដូចជាការកាន់ទុក្ខ ឬកំហឹងសម្រាប់អ្នកផ្សេង និងសម្រាប់ខ្ញុំមានន័យខុសពីគ្នា។ តាមរយៈស្ថានភាពផ្ទាល់ខ្លួនរបស់យើងម្នាក់ៗ មនសិការរបស់យើងបង្កើតឱ្យមានស្ថានភាពរួមមួយ តែដោយសារតែមនុស្សមានការអត្តនោម័តរៀងៗខ្លួន មនុស្សម្នាក់ៗបង្កើតបានជាពិភព «តែមួយគត់» របស់ខ្លួន។

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ ទស្សនវិទូក្រោយទំនើបនិយមបារាំងមានឥទ្ធិពលយ៉ាងខ្លាំងក្លា លើសាកលវិទ្យាល័យអាមេរិក ដែលប្រសិទ្ធនាមឱ្យចរន្តទស្សនវិជ្ជា ដែលទិតៀនទស្សនវិជ្ជាប្រពៃណីនៃបស្ចិមប្រទេសថាជា «**ទ្រឹស្ដីបារាំង** (French Theory)»។ ទស្សនវិទូបារាំងទាំងនេះបង្រៀននៅតាមសាកលវិទ្យាល័យអាមេរិក និងមានឥទ្ធិពលទៅលើការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិក្សាវប្បធម៌(ការសិក្សាអន្តរមុខវិជ្ជានៃវប្បធម៌ជនជាតិភាគតិច)ការសិក្សាយែនឌ័រ និងការសិក្សាប្រទេសក្រោយអាណានិគមនិយមជាដើម។

នៅប្រទេសបារាំង ទស្សនវិជ្ជា**ក្រោយជំនើបនិយម** និង**រចនាសម្ព័ន្ធនិយម**លែងមានប្រជាប្រិយភាព ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០មកម្ល៉េះ។ ទស្សនវិទូបារាំងបានទាត់ចោលលទ្ធិម៉ាកនិយម និងទទួលយកទស្សនវិជ្ជា**មនុស្សនិយមប្រឆាំងរបបផ្តាច់ការ** (humanisme anti-totalitaire) របស់លោក **ហង់រី-ឡេវី** (Bernard Henry-Lévy) និងលោក **អង់ឌ្រេ ឃ្លុកស្មាន់** (André Glucksmann)។

ទស្សនវិជ្ជាក្រោយទំនើបនិយមស្រដៀងគ្នាទៅនឹងទស្សនវិជ្ជារចនាសម្ព័ន្ធនិយម។ លោក **ដេរីដា** ចាប់ផ្តើមសរសេរចេញពីទស្សនៈនៃរចនា-សម្ព័ន្ធនិយម ដើម្បីឈានទៅចាប់យកទស្សនវិជ្ជាក្រោយទំនើបនិយម។ម្យ៉ាងវិញទៀត គេតែងចាត់ទុកលោក **មីស្សែល ហ្វូកូល** ជាទស្សនវិទូរចនាសម្ព័ន្ធនិយម តែខ្លួនលោកផ្ទាល់បានបដិសេធថា លោកមិនមែនជាអ្នកបញ្ញវន្តនៃចរន្តទស្សនវិជ្ជានេះទេ។

# ហ្សាក់ ដេរីដា
## (១៩៣០-២០០៤)

**ហ្សាក់ ដេរីដា** *(Jacques Derrida)* គឺជាទស្សនវិទូក្រោយជំនើបនិយមបារាំង ជានាយកខាងផ្នែកសិក្សានៃសាលាសិក្សាជាន់ខ្ពស់វិទ្យាសាស្ត្រសង្គម និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យកាលីហ្វ័រនី(Irvine)។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ដេរីដា**គឺ ៖ *La Voix et le Phénomène(1967), L'Écriture et la Différence(1967), De la grammatologie (1967)*។

លោក **ដេរីដា** យល់ឃើញថា ក្របខណ្ឌបរមត្ថវិជ្ជានៃទស្សនវិជ្ជាបស្ចិមប្រទេស ចាប់តាំងពី **ប្លាតុង** មក គឺជាទស្សនវិជ្ជាទ្វិកនិយម (le dualisme)ដែលឈរលើមូលដ្ឋាននៃការបែងចែករវាង **ឥន្ទ្រិយភព** (le monde sensible) និង**មនោភព** (le monde intelligible)។ ការគិតនៅក្នុងក្របខណ្ឌនេះត្រូវបានបែងចែកតាមសញ្ញាណផ្ទុយគ្នាគឺ ៖ អាត្មុនផ្ទុយនឹងរាងកាយ ន័យផ្ទុយនឹងសញ្ញា ខាងក្រៅផ្ទុយនឹងខាងក្នុង។ល។ បើតាមលោក **ដេរីដា** ប្រព័ន្ធទស្សនវិជ្ជាបស្ចិមប្រទេស គឺជាប្រព័ន្ធ «**គតិបណ្ឌិតមជ្ឈមណ្ឌល** (logocentrique)» ដែលក្នុងនោះ **គតិបណ្ឌិត** (logo) គឺជាប្រភព និងជាមូលដ្ឋាននៃតថភាព ហើយការគិតទាមទារឱ្យស្គាល់ខ្លួនឯង (la conscience de soi)។ ប្រព័ន្ធនេះ គឺជាប្រព័ន្ធដែលមានជាតិពន្ធុអឺរ៉ុប និងបស្ចិមប្រទេស ជាមជ្ឈមណ្ឌល(ethnocentrisme)។ ប្រព័ន្ធនេះមិនអាចឱ្យគិតពីប្រវត្តិសាស្ត្រ និងពីអត្តសញ្ញាណ ពីទស្សនវិស័យរបស់អ្នកផ្សេង (de l'autre) ភាសារបស់អ្នកផ្សេង និងវប្បធម៌របស់អ្នកផ្សេង។

លោក **ដេរីដា** យល់ឃើញថា ភារកិច្ចដ៏ចម្បងនៃកាលសម័យរបស់គាត់ គឺអនុវត្តវិធីសាស្ត្រ **ការរុះរើ** (Déconstruction) តែមិនមែនជា **ការ**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ទេចចោល (démolition) ឡើយ តែជា **ការពិនិត្យឡើងវិញនូវរបៀបរបបនៃការគិត** (désédimentation) និងអត្ថន័យនៃការគិតដែលមានប្រភពពីគតិបណ្ឌិត(logos) (Derrida(1967). De la grammatologie)។

**ការរុះរើ** (Déconstruction) ៖ ពាក្យ Destruktion (Déconstruction) នេះត្រូវបានប្រើដោយ **ហៃឌឹហ្គ័រ** (Heidegger) នៅក្នុងស្នាដៃរបស់លោក Être et Temps (1927) ដែលមានគោលដៅ ពិនិត្យឡើងវិញនូវបញ្ហាបរមត្ថ-វិជ្ជា ក្នុងគោលដៅចោទសួរនូវបញ្ហា «អត្ថន័យនៃអត្ថិភាព» នៅក្នុងគំនិតមនុស្ស។ គេអាចប្រើវិធីសាស្ត្រ **ការរុះរើ**នេះបាន ដោយសារតែ «មនុស្ស» គ្មានទំនាក់ទំនងដោយផ្ទាល់ និងជាធម្មជាតិជាមួយអត្ថិភាពរបស់ខ្លួន។ គេមិនស្គាល់ពីមនុស្ស ហើយគ្មានទំនាក់ទំនងជាមួយមនុស្ស ក្នុងន័យសត្យា-នុម័យឡើយ។ គេយល់ពីមនុស្សតាមរយៈប្រពៃណីបកស្រាយអត្ថបទ។ **ការរុះរើ**មានន័យថា ត្រូវស្វែងរកលទ្ធភាពថ្មីក្នុងការបកស្រាយសារជាថ្មីនៃស្រទាប់អត្ថបទ ហើយតាមរយៈនេះ យើងត្រូវយល់ដោយខ្លួនយើង។

**ជំពាក់ជំពិនរវាងវោហារ និងសំណេរ** (archi-écriture) ៖ តាំងពីជំនាន់**ប្លាតុង**មកម្ល៉េះ សំនួនវោហារមានអាទិភាពលើសំណេរ។ ការសរសេរតាមសំឡេង គឺជាការចម្លងតាមវោហារ។ នៅក្នុងស្នាដៃរបស់លោក Plato's Pharmacy លោកបានពិនិត្យឡើងវិញនូវពាក្យ សំនួនវោហារ និងសំណេរ។ ដោយពាក្យវោហារ និងសំណេរត្រូវប្រើការធ្វើឡើងវិញ នោះគេមិនអាចបង្ហាញពីភាពខុសគ្នាទាំងស្រុងរវាងវោហារ និងសំណេរបានឡើយ។ ឧទាហរណ៍ពាក្យក្រិកថា pharmakon មានន័យថាព្យាបាលផង និងថ្នាំពុលផង។ ពោលគឺគេអាចយកថ្នាំពុលមកព្យាបាល។ ពាក្យថា archi-écriture មានន័យថាត្រូវវិភាគឱ្យបានជ្រៅជាងការបែងចែករវាងសំណេរ និងវោហារ ដែលជាការសរសេរដែលមានមុនវោហារ និងសរសេរទៅទៀត ពោលគឺជាភាសា ដែលមានមុនពេលដែលយើងប្រើវាទៅទៀត។ គេអាចជួបប្រទះនឹងភាសារបៀបនេះក្នុងចំណោមវប្បធម៌នៃជនជាតិ ដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្មានវប្បធម៌ឬទម្លាប់សរសេរ ដែលប្រើជាសញ្ញាជាដើមដើម្បីសម្គាល់សំណេរ។

**ការពន្យាពេល** (Différance) ៖ ពាក្យនេះមានន័យថា «ទំពារឱ្យហ្មត់» ដែលជាដំណើរការបង្ហាញពីភាពខុសគ្នា អតុល្យភាព។ ពាក្យឡាតាំង differre មានន័យពីរ ៖ (១) ន័យទី១ គឺ «ពន្យាពេល» ដែលទាក់ទងនឹងពេលវេលា។ ពាក្យ Différer ក៏មានន័យថាពន្យាពេល ដើម្បីផ្លាស់ប្តូរចំណង់ ឬផ្លាស់ប្តូរឆន្ទៈ ដើម្បីកាត់បន្ថយបច្ច័យរបស់វា (២) ន័យទី២ គឺ «ខុសពីគ្នា ជាអ្វីផ្សេង»។ ចំណែកឯពាក្យ Différence មិនអាចបកប្រែថា «ពន្យាពេល»បានទេ។ ដូច្នេះ ពាក្យ "différance" មានន័យថាដំណើរការពុះជ្រៀក និងបំបែកកម្មវត្ថុនៃការវិភាគ ដើម្បីទទួលបានលទ្ធផល «ខុសពីគ្នា»។ ទ្រឹស្តីនេះបង្ហាញថា គឺជាទស្សនវិទូក្រោយរចនាសម្ព័ន្ធនិយម( ក្រោយទំនើបនិយម) ដែលផ្ទុយពីចរន្តរចនាសម្ព័ន្ធនិយម។ តាមទ្រឹស្តីរចនាសម្ព័ន្ធនិយមរបស់លោក Ferdinand de Saussure សំនួនវោហារ(le signifiant)បង្ហាញដោយត្រង់ទាំងស្រុងនូវសំណេរ(le signifié)ដែលជាទ្រឹស្តីយកវោហារជាធំ(logocentrique)មានតាំងពីជំនាន់**ប្លាតុង**មកម្ល៉េះ។ ដើម្បីប្រឆាំងនឹងបរមត្ថវិជ្ជា លោក **ដេរីដា** បង្កើតទ្រឹស្តីនៃ**ការរុះរើ** (Déconstruction) នេះឡើង ដើម្បីបង្ហាញថា រចនាសម្ព័ន្ធនៃអត្ថបទមិនមែននៅដដែលមិនប្រែប្រួលឡើយ ឬមានន័យតែមួយ(sens univoque)ឡើយ។ តាមលោក **ដេរីដា** វោហារគ្មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសំណេរឡើយ ហើយសំនួនវោហារមានន័យខុសៗគ្នាពីមួយទៅមួយ។ នៅក្នុងទស្សនវិជ្ជា បរិបទនៃការបង្កើតនិងការទទួលយកគំនិត ឬទ្រឹស្តីមាន សារៈសំខាន់ខ្លាំងណាស់។ ដើម្បីយល់ពីទស្សនវិជ្ជាក្រោយរចនាសម្ព័ននិយម គេត្រូវដឹងអំពីទស្សនវិជ្ជារចនាសម្ព័ន្ធនិយមផងដែរ។ តាមទ្រឹស្តី**ការរុះរើ**របស់**ដេរីដា** សំនួនវោហារមិនឆ្លុះបញ្ចាំងសំណេរឡើយ តែវាបណ្តាលមកពីសំនួនវោហារផ្សេងទៀត។ នៅពេលដែលយើងអានអត្ថបទ គេត្រូវធ្វើការបន្ថែមទៀត ដើម្បីរុះរើ

*(déconstruire)* ឬសាងសង់ឡើងវិញ*(reconstruire)*ក្នុងគោលដៅបកស្រាយរកអត្ថន័យ។ ក្នុងន័យនេះ ការដឹងបរិបទប្រវត្តិសាស្ត្រ និងពីអ្នកនិពន្ធមានសារសំខាន់ខ្លាំងណាស់ តែទាំងអស់នេះមិនអាចយល់អត្ថន័យទាំងស្រុងនៃអត្ថបទឡើយ។ **ការរុះរើ** គឺត្រូវវិភាគឱ្យផុតពីទស្សនាទានផ្ទុយគ្នាយ៉ាងតឹងរឹង រវាងស្រីនិងប្រុស ធម្មជាតិនិងវប្បធម៌ ប្រធានបទនិងកម្មវត្ថុ ឥន្ទ្រីយញាណ និងប្រាជ្ញាញាណ អតីតកាលនិងបច្ចុប្បន្នភាពហើយមិនត្រូវចាត់ទុកថាបញ្ញត្តិទាំងនេះខុសពីគ្នាឡើយ។ ប្រភេទនីមួយៗមានបន្សល់ទុកនូវស្នាមនៃប្រភេទផ្ទុយរបស់ខ្លួន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហ្ស៊ីល ឌើលូស្ស
## (១៩២៥-១៩៩៥)

**ហ្ស៊ីល ឌើលូស្ស** *(Gilles Deleuze)* គឺជាទស្សនវិទូក្រោយជំនើបនិយមបារាំង ដែលកើតនៅទីក្រុងបារីសក្នុងឆ្នាំ១៩២៥។ លោកបានសិក្សាទស្សនវិជ្ជានៅសាកលវិទ្យាល័យស័របោននិងបង្រៀនទស្សនវិជ្ជានៅក្នុងសាកលវិទ្យាល័យបារីស៨។ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ លោកសរសេរប្រឆាំងនឹងទស្សនវិជ្ជា**ហេហ្គែល**។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់ **ហ្ស៊ីល ឌើលូស្ស** អាចបែកចេញជាបីដំណាក់កាល ៖ (១) *(Emprisme et subjectivité, 1953), (Spinoza ou le problème de l'expression, 1968)*ដែលជាអត្ថបទដែលសរសេរពីទស្សនវិទូល្បីៗដូចជា **ហ្យូម**, **ប៊ែគសុន**, **នីតស៍** និង **កង់ត៍** (២) *(Différence et répétition, 1969), (Logique du sens, 1969)* ដែលជាស្នាដៃផ្តោតលើភាសានិងអក្សរសិល្ប៍ និង (៣)*(Anti-Œdipe, 1972)* ដែលជាស្នាដៃសរសេរជាមួយចិត្តវិទូ **ខ្វាតារី** *(Felix Guattari)*។ ស្នាដៃទាំងនេះធ្វើឱ្យលោកមានឈ្មោះបោះសំឡេង ហើយមិត្តរបស់លោក ទស្សនវិទូ **ហ្វ៊ូកូល** ថែមទាំងបាននិយាយថាសតវត្សរ៍ទី២០ គឺជាសតវត្សរ៍ **ឌើលូស្ស** ថែមទៀតផង។

**ទស្សនវិជ្ជានៃទស្សនវិជ្ជា** *(Métaphilosophie)* ៖ **ឌើលូស្ស** ចោទសួរពីគោលដៅ ដែនប្រតិបត្តិ និងវិធីសាស្ត្រក្នុងការសិក្សាទស្សនវិជ្ជា។ លោកយល់ឃើញថា ទស្សនវិជ្ជា គឺជាវណ្ណកម្ម។ តើទស្សនវិទូសរសេរស្នាដៃបែបណា? **ឌើលូស្ស** យល់ថាទស្សនវិទូជាអ្នកបង្កើតទស្សនាទាន *(concept)*។ ដូច្នេះ ដើម្បីយល់បានពីទស្សនវិជ្ជា គេត្រូវញែកទស្សនាទានដែលបង្កើតដោយទស្សនវិទូ ពីបញ្ញត្តិ*(prospect)*ដែលបង្កើតឡើងដោយអ្នកវិទ្យាសាស្ត្រ ដែលផ្តោតទៅលើស្ថានភាពនៃវត្ថុ ដែលប្រែក្លាយពី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សភាពមួយ ទៅសភាពមួយទៀត។ ពោលគឺវិទ្យាសាស្ត្រសិក្សាពីមុខងារ (fonction) ចំណែកឯទស្សនវិជ្ជាសិក្សាពីទស្សនាទាន (concept)។ នៅក្នុងស្នាដៃរបស់លោកដែលសរសេរជាមួយ* **ខ្វាតារី ឌើលូស្ស** *បានលើកពីសម្មតិកម្មថា ៖ នៅក្នុងប្រយោគមួយ ទស្សនវិជ្ជាទាញយកនូវទស្សនាទាន (concept-កុំច្រឡំជាមួយគំនិតទូទៅ ឬគំនិតអរូបី) វិទ្យាសាស្ត្រទាញយក (prospect-សូមកុំច្រឡំជាមួយការវិនិច្ឆ័យ) ហើយសិល្បៈទាញយក (percepts និង affects-សូមកុំច្រឡំជាមួយវេទនារម្មណ៍និងអារម្មណ៍)។*

**ទស្សនាទាន** *(concept) ៖ ទស្សនាទានដែលផ្តោតលើខ្លួនឯង បង្កើតឡើងពីកម្មវត្ថុដាច់ៗពីគ្នា (disjoints) ខុសៗគ្នា (fragmentaires) ហើយមិនអាចមានសុខដុមជាមួយគ្នាបានឡើយ។ ទស្សនាទានមានសមាសភាគផ្សេងៗជាច្រើន (multiplicité)។ ដូច្នេះហើយ ទើបទស្សនវិទូដូចជា* **ដេការត** *និង* **ហេហ្គែល** *តែងចាប់ផ្តើមពីទស្សនាទានផ្សេងៗពីគ្នា។ ទស្សនវិទូខ្លះដូចជា Feuerbach មិនទាំងមានចំណុចផ្តើមផង។ ទស្សនាទានទស្សនវិជ្ជាមិនផ្តោតទៅលើស្ថានភាពនៃវត្ថុទេ តែមិនផ្តោតលើអ្វីទាំងអស់ គឺផ្តោតលើខ្លួនឯង។ ទស្សនាទាន គឺជាបណ្តុំតែមួយដែលដាច់ៗពីគ្នា។ ប្រការនេះមានន័យថាគេមិនអាចផ្តុំវាឱ្យក្លាយជាសញ្ញាណរួមតែមួយ ដែលរាល់សមាសភាគទាំងអស់អាចផ្តុំជាមួយគ្នា ឱ្យទៅជាវត្ថុតែមួយស្មើសាច់គ្នាបានឡើយ។ វាបង្កើតបានជាបណ្តាញនៃទស្សនៈយ៉ាងស្មុគ្រស្មាញ។ ទស្សនាទាននេះត្រូវមានទំនាក់ទំនងជាមួយទស្សនទានផ្សេងទៀតនៅលើវាលរាប (plan) ជាមួយគ្នា។ ទស្សនាទានត្រូវផ្សាភ្ជាប់ជាមួយគ្នា គាំទ្រគ្នាទៅវិញទៅមក សម្របសម្រួលគ្នាទៅវិញទៅមក និងត្រូវស្ថិតនៅក្នុងចរន្តទស្សនវិជ្ជាដូចគ្នា។ ដើម្បីអាចឱ្យសមាសភាគផ្សេងៗនៃទស្សនាទានអាចប្រមូលផ្តុំនៅជាចង្កោមជាមួយគ្នា* **ឌើលូស្ស** *បានបង្កើតឡើងនូវទ្រឹស្តីមួយទៀតគឺ (plan d'immanence)។*

**កន្ត្រកលោកិយសច្ចៈ** *(plan d'immanence) ៖ កន្ត្រកសច្ចៈលោកិយមានគោលដៅប្រមូលផ្តុំទស្សនាទាន ឱ្យនៅក្នុងកន្ត្រកទស្សនវិជ្ជា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែមួយ ដែលពេញលេញ និងមានសង្គតិភាពហើយបង្កើតបានជាបណ្តុំតែមួយ(Omnitudo, un Un-Tout)។ លោកិយសច្ចៈ(immanence) មានន័យថា ទស្សនាទាន និងន័យរបស់វាអាចយល់បានតាមរយៈទំនាក់ទំនងរវាងទស្សនាទាននេះទៅវិញទៅមក ដោយមិនចាំបាច់យកទស្សនាទានផ្សេងខាងក្រៅពីកន្ត្រកលោកិយសច្ចៈនេះមកពន្យល់ឡើយ។ ដូច្នេះ ទស្សនវិជ្ជាខុសពីវិទ្យាសាស្ត្រត្រង់នេះតែម្តង ដោយវិទ្យាសាស្ត្រត្រូវពឹងលើ «បទពិសោធ» ដើម្បីពន្យល់ខ្លឹមសារនៃទស្សនាទានវិទ្យាសាស្ត្រ ហើយចំណែកឯសាសនាវិញត្រូវយកអាទិទេពពន្យល់ថាជាអ្នកបង្កើតលោក។ **ឌើលូស្ស** បានទាត់ចោលគំនិតចាស់គំរិលដែលថា ទស្សនវិជ្ជាត្រូវតែផ្សារភ្ជាប់ទៅនឹងអភិធម៌ ឬស្ថានលើ(transcendance)ដូចសាសនាដែរ។ ក្នុងន័យនេះ **ឌើលូស្ស** បានលើកឡើងថាទស្សនជាសកល(universaux)របស់**ប្លាតុង**, **ដេកាត**, **កង់ត៍** និង**ហ៊ុយស្សៀល** វាគ្រាន់តែជាទស្សនវិជ្ជាស្រមើស្រមៃ(illusion de la philosophie)ដែលត្រូវកំចាត់ចោលឱ្យជ្រះស្រឡះ។ **ឌើលូស្ស** បានទាត់ចោលផងដែរនូវទស្សនៈរបស់**ហេហ្គែល** ដែលថាទស្សនវិជ្ជាមានការផ្លាស់ប្តូរពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀត។ **ឌើលូស្ស** យល់ថា កន្ត្រកលោកិយសច្ចៈនេះវាអាចនៅជាមួយគ្នា ហើយពេលខ្លះនៅជាន់គ្នាបាន។ សរុបមក ទស្សនវិជ្ជា គឺជាប្រព័ន្ធគំនិត ឬទស្សនាទាន ដែលស្ថិតនៅក្នុងភាពដាច់ពីគ្នា តែចងជាបណ្តុំតែមួយជាមួយគ្នា ហើយទស្សនៈផ្សេងៗអាចនៅជាមួយគ្នា ឬនៅជាន់គ្នាបាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# រ៉ូទី
## (១៩៣១-២០០៧)

**រ៉ូទី** *(Richard Rorty)* គឺជាទស្សនវិទូអាមេរិកសម័យទំនើប ដែលតំណាងឱ្យចរន្តក្រោយទំនើបនិយម ដោយផ្តោតលើ**លទ្ធផលនិយម** *(pragmatisme)*។ លោកកើតនៅញ៉ូយ៉ក ក្នុងឆ្នាំ ១៩៣១។ បន្ទាប់ពីរៀនចប់បរិញ្ញាបត្រនៅសាកលវិទ្យាល័យឈីកាហ្គោ លោកបានទទួលសញ្ញាបត្រថ្នាក់បណ្ឌិតពីសាកលវិទ្យាល័យយ៉េល។ ក្នុងរយៈពេលជាង៤០ឆ្នាំ លោក **រ៉ូទី** បង្រៀននៅតាមសាកលវិទ្យាល័យល្បីៗនៃសហរដ្ឋអាមេរិក ដូចជា ព្រីនស្តុន វៀរហ្សីនី និងស្តែនហ្វត ជាដើម។ មុនដំបូង លោកជាទស្សនវិទូវិភាគនិយម*(philosophie analytique)*ដែលសិក្សាពីបញ្ហាភាសា។ បន្តិចម្តងៗ លោក **រ៉ូទី** បានដាកចេញពីចរន្តនេះ ហើយបានជ្រើសរើសយកទស្សនវិជ្ជាលទ្ធផលនិយម។ នៅចុងសតវត្សរ៍ទី២០ លោក **រ៉ូទី** បានក្លាយជាទស្សនវិទូដ៏ល្បីឈ្មោះមួយរូប ដោយសារតែលោកប្រកាន់ជំហរទស្សនវិជ្ជាដែលមតិភាគច្រើនអាចយល់បាន និងគ្របដណ្តប់លើប្រធានបទដ៏ទូលំទូលាយ។

**ស្នាដៃសំខាន់** ៖ សៀវភៅតែមួយគត់ដែលលោក**រ៉ូទី** សរសេរមានចំណងជើងថា «**ទស្សនវិជ្ជា និងកញ្ចក់ធម្មជាតិ**» *(Philosophy and the Mirror of Nature) 1979* ដែលពន្យល់យ៉ាងពេញលេញពីទស្សនវិជ្ជារបស់លោក។ ក្រៅពីនេះលោកបានសរសេរអត្ថបទជាច្រើន ដើម្បីបកស្រាយទ្រឹស្តីរបស់លោក។ សៀវភៅផ្សេងទៀតមាន ៖ *Consequences of Pragmatism (1982), Contingency, Irony, and Solidarity (1989)*។

**សម្ភារនិយមបំបាត់ចោល** *(Eliminative materialism or eliminativism)* ៖ សម្ភារនិយមបំបាត់ចោល គឺជាជំហរសម្ភារៈនិយមនៅក្នុងទស្សនវិជ្ជាផ្លូវមនោ។ មុនដំបូង លោកជាទស្សនវិទូវិភាគនិយម*(analytical*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*philosophy) ដែលសិក្សាពីបញ្ហាភាសា។ នៅក្នុងអំឡុងទសវត្សរ៍៦០ លោក* **រ៉ូទី** *យល់ឃើញថាលោកបានដោះស្រាយបញ្ហាទស្សនវិជ្ជាដែលចោទសួរឡើងតាំងពីជំនាន់***ឡាតុខ** *គឺទំនាក់ទំនងរវាង «ស្មារតី និងរាងកាយ» (mind-body)។ លោកគិតថាបញ្ហា «ស្មារតី និង រាងកាយ» មិនអាចរកចម្លើយដោយឈរលើមូលដ្ឋាននៃបទពិសោធឡើយ តែត្រូវរកនៅក្នុងការប្រើប្រាស់ភាសា។ ចំពោះលោក* **រ៉ូទី** *ការបែងចែករវាង «ស្មារតី» និង«ដំណើរការនៃខួរក្បាល» បានដោះស្រាយដោយប្រើប្រាស់ភាសាសរីរវិទ្យានៃប្រព័ន្ធសរសៃប្រសាទ(Neuro-physiology)ដោយពន្យល់ថា «ស្ថានភាពផ្លូវស្មារតីរបស់មនុស្សបណ្ដាលមកពីសរសៃប្រសាទ(neuron) និងការរំញោចនៃសំបកខួរក្បាលរបស់មនុស្ស» ពោលគឺដំណើរការនៃខួរក្បាលមានឥទ្ធិពលលើស្មារតីរបស់មនុស្ស។ ដូច្នេះ គ្មានទេនូវអ្វីដែលគេហៅថា* **ជំនួលអារម្មណ៍** *(sensation)។ ដូច្នេះ គេត្រូវបំភ្លេចចោលនូវទស្សនៈដែលថា នៅពេលដែលមនុស្សទទួលអារម្មណ៍ គេត្រូវទាក់ទងផ្សាភ្ជាប់ដោយត្រង់ជាមួយផ្លូវមនោផ្ទៃក្នុងរបស់ខ្លួន។ នេះគឺជាការពន្យល់ពី «ស្មារតី» តាមបែបសម្ភារៈនិយម។ ពោលគឺ* **រ៉ូទី***ប្រកាន់យកទស្សនរូបនិយម ឬសម្ភារៈនិយម ដោយទាត់ចោលនូវតួនាទីរបស់អាត្ម័ន។* **រ៉ូទី** *ប្រកាន់ជំហរនេះ ក្រោមឥទ្ធិពលរបស់គ្រូគាត់ ដែលជាទស្សនវិទូក្រោយវិជ្ជមាននិយមមាន* **ប៉ូល ហ្វេយេរ៉ាបេនដ៍** *(Paul Feyerabend) ដែលទាត់ចោលតួនាទីនៃអាត្ម័ន និងប្រកាន់យកតួនាទីនៃសរីរាង្គក្នុងការកំណត់ស្មារតី។*

**រ៉ូទី** *យល់ថាអតិក្រមទស្សនវិជ្ជាខ្លះមិនអាចនាំទៅរកចម្លើយ ដែលទទួលយកបានឡើយ។ ទស្សនវិជ្ជាលទ្ធផលនិយមផ្ដោតលើសកម្មភាព និងជានាទូវវិចារណញ្ញាណប្រកបដោយប្រសិទ្ធភាព ដើម្បីបម្រើឱ្យចរិយាធម៌ និងលទ្ធិប្រជាធិបតេយ្យ។ បេសកកម្មនៃទស្សនវិជ្ជាមិនមែនការស្វែងរកមូលដ្ឋានបរមត្ថវិទ្យា ឬវិចារណញ្ញាណដាច់ខាតឡើយ តែគឺត្រូវឆ្លើយតបយ៉ាងជាក់ស្ដែង ទៅនឹងស្មារតីសាមគ្គីភាពនៃជីវិតរួមរបស់ប្រជាពលរដ្ឋ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**លទ្ធផលនិយម** *(pragmatisme)* ៖ ជាយូរណាស់មកហើយ ទស្សនវិទូយល់ថាពុទ្ធិ គឺជាតំណាងឱ្យតថភាព។ **ដេការត** និង**កង់** បានបង្កើតទស្សនាទានទស្សនវិជ្ជាដែលផ្តោតលើតំណាងនេះ។ សំណួរដែលគេចោទសួរ គឺថាតើតំណាងនេះវាឆ្លើយតបទៅនឹងតថភាពកម្រិតណា? គ្រប់គ្រាន់ឬទេ? នាពេលបច្ចុប្បន្ននេះ គេបានបដិសេធនូវទស្សនាទានតំណាងនេះ។ ដូច្នេះ ទស្សនវិជ្ជាលទ្ធផលនិយមត្រូវពិនិត្យឡើងវិញបញ្ហានេះ។ យើងត្រូវឈប់គិតថា ទំនាក់ទំនងមនុស្សជាមួយពិភពលោកនេះ គឺជាល្បែងនៃតំណាង។ ភាសាមិនមែនជាតំណាងឱ្យគំនិតបញ្ញាឡើយ តែវាជាសមត្ថភាពរបស់មនុស្ស ដែលខុសពីសត្វមានប្រាជ្ញាដទៃទៀត ហើយអនុញ្ញាតឱ្យមនុស្សមានសកម្មភាព ដែលសត្វឯទៀតមិនអាចធ្វើបាន។ ដូច្នេះ ទស្សនវិជ្ជាលទ្ធផលនិយមចាត់ទុកភាសា ថាជាសមត្ថភាពសម្រេចបានគោលដៅឧត្តុង្គឧត្តម ដែលសត្វមិនអាចធ្វើបាន។ ក្នុងន័យនេះ ទស្សនវិជ្ជាលទ្ធផលនិយមវាផ្ទុយនឹងទស្សនវិជ្ជាមជ្ឈធាតុនិយម(scepticisme)ដែលយល់ថាគេមិនអាចរកតថភាពបាន។ ដូច្នេះ ប្រសិនបើគេនៅតែប្រកាន់យកអភិក្រមតំណាងនិយម នោះគេនៅតែយល់ថា គេមិនអាចរកការពិតបាន ព្រោះគេមិនអាចឆ្លើយនឹងសំណួរថា តើតំណាងរបស់យើងវាឆ្លើយតបទៅនឹងតថភាព ឬយ៉ាងណា។

ដំណាក់កាលបន្ទាប់នៃការបង្កើតទស្សនវិជ្ជារបស់**រ៉ូទី** គឺការបោះពុម្ពសៀវភៅ«**ទស្សនវិជ្ជា និងកញ្ចក់ធម្មជាតិ**» (១៩៧៩)។ ក្នុងសៀវភៅនោះ លោកប្រកាន់ជំហរលទ្ធផលនិយម ដោយទទួលរងឥទ្ធិពលពី **ចន ឌូវី** *(John Dewey)* **ហៃដឺហ្គ័រ** *(Heidegger)* និង **វីតហ្គែនស្តាញ** *(Ludwig Wittgenstein)*។ **រ៉ូទី** បានទាត់ចោលនូវគំនិតនៃទស្សនវិជ្ជាដែលមានពីមុនមកគឺ ៖ «ពុទ្ធិ គឺជាតំណាងដ៏ត្រឹមត្រូវ» (គឺជាកញ្ចក់ឆ្លុះធម្មជាតិ)នៃពិភពលោក ដែលស្ថិតនៅក្នុងសភាពឯករាជ្យពីការតំណាងនេះ»។ លោកយល់ថាទស្សនៈនេះខុសទាំងស្រុង ហើយប្រកាន់យកជំហរលទ្ធផលនិយម។ បើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមលទ្ធផលនិយម «អត្ថន័យនៃសំណើត្រូវតែកំណត់ដោយការប្រើប្រាស់វាក្នុងការអនុវត្តភាសា»។ បន្ទាប់មក **រ៉ូទី** បានបូកបញ្ចូលទស្សនលទ្ធផលនិយមនេះជាមួយនឹងទស្សនវិជ្ជាភាសារបស់ទស្សនវិទូ **វីតហ្គេនស្តាញ** ដែលថា៖ «អត្ថន័យ គឺជាផលិតផលសង្គម-ភាសា ហើយឃ្លាប្រយោគ មិនមែនជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងពិភពលោកឡើយ»។

នៅក្នុងស្នាដៃរបស់លោកដែលមានចំណងជើងថា «Contingency, Irony and Solidarity» លោកបានសរសេរថា៖ «ការពិតមិនអាចស្ថិតនៅទីនោះក្នុងលោក ឯករាជ្យពីផ្លូវស្មារតីរបស់មនុស្សឡើយ ដោយសារតែឃ្លាប្រយោគក៏មិនអាចស្ថិតនៅទីនោះដោយឯករាជ្យឡើយ។ ពិភពលោកស្ថិតនៅទីនោះ ក៏ប៉ុន្តែ ការពិពណ៌នាពីពិភពលោកមិននៅទីនោះទេ។ មានតែការពិពណ៌នាពីពិភពលោកទេ ដែលអាចជាការពិត ឬជាការមិនពិត។ ក៏ប៉ុន្តែ ពិភពលោកខ្លួនឯង ដែលស្ថិតនៅក្រៅការពិពណ៌នារបស់មនុស្ស មិនអាចជាការពិត ឬជាការមិនពិតបានឡើយ។

ដោយប្រកាន់យកទស្សនៈនេះ លោក **រ៉ូទី** បានចោទសួរឡើងវិញ និងពិនិត្យមើលឡើងវិញនូវសេចក្តីសន្និដ្ឋានជាមូលដ្ឋាននៃទស្សនវិជ្ជាជាច្រើន ដែលធ្វើឱ្យគេចាត់ទុកប្រព័ន្ធទស្សនវិជ្ជារបស់លោក ថាជាទស្សនវិជ្ជាបែបក្រោយទំនើបនិយម។ នៅពេលបន្ទាប់មកទៀត លោក **រ៉ូទី** បានខិតខំបង្វិតទស្សនវិជ្ជាវិភាគរបស់លោក ឱ្យស្ថិតនៅជិតទស្សនវិជ្ជាអឺរ៉ុប ដោយបញ្ជាក់ថាទស្សនវិជ្ជាវិភាគបំពេញបន្ថែមឱ្យទស្សនវិជ្ជាអឺរ៉ុប។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជាស្មារតីនិយម

**ទស្សនវិជ្ជាស្មារតីនិយម** *(Philosophy of Mind)* *គឺជាផ្នែកមួយនៃទស្សនវិជ្ជាដែលសិក្សាអំពីសារជាតុនៃស្មារតី ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹង «ស្មារតី និងរាងកាយ» ក៏ដូចជាបញ្ហាសតិសម្បជញ្ញៈ និងស្ថានភាពនៃស្មារតី និងទំនាក់ទំនងរវាងស្មារតីនិងរាងកាយ។ល។*

*ទស្សនទ្វិកនិយមបែងចែកស្មារតីពីរាងកាយមាននៅក្នុងទស្សនវិជ្ជាបុរាណឥណ្ឌា និងនៅក្នុងទស្សនវិជ្ជា* **ប្លាតុង** *តែ* **ដេការត** *បានយកទស្សនៈនេះមកបង្ហាញឱ្យកាន់តែប្រត្យក្សនៅក្នុងសតវត្សរ៍ទី១៧។ ទស្សនទ្វិកនិយមយល់ឃើញថាស្មារតី និងរូបធាតុមានលក្ខណៈសម្បត្តិខុសគ្នា។ រូបធាតុ គឺជាកម្មវត្ថុនៃការសិក្សារបស់វិទ្យាសាស្ត្ររូបវិទ្យា ចំណែកឯស្មារតីមិនមែនជារូបធាតុទេ ហើយក៏មិនមែនជាកម្មវត្ថុនៃការសិក្សារបស់វិទ្យាសាស្ត្ររូបវិទ្យាដែរ។ ស្មារតីស្ថិតនៅក្នុងខ្លួនមនុស្ស។ ទស្សនវិជ្ជាទ្វិកនិយមនេះបានក្លាយជាទ្រឹស្តីដែលគ្របដណ្តប់លើទស្សនវិជ្ជារាប់រយឆ្នាំមកហើយ។ ក៏ប៉ុន្តែ ទស្សនទ្វិកនិយមនេះមិនអាចពន្យល់បានថា តើស្មារតីមានទំនាក់ទំនងជាមួយរាងកាយ ដែលជារូបធាតុយ៉ាងដូចម្តេច។*

*ទស្សនទ្វិកនិយមនេះត្រូវបានទិតៀនដោយទស្សនៈផ្សេងទៀតដូចជាទស្សនឯកនិយម អាកប្បកិរិយានិយម(behaviorism)រូបនិយម (physicalism)។ល។*

*ទស្សនឯកនិយម ឬម៉ូនីស្ត(Monism)យល់ថា ស្មារតីនិងរាងកាយ គឺជាលក្ខណសម្បត្តិពីរនៃសារជាតុតែមួយ។*

*ទស្សនទ្វិកនិយមបង្កើតនៅក្នុងមនុស្សម្នាក់ នូវពិភពពីរខុសគ្នាគឺ ៖ ពិភពខាងក្នុង( ស្មារតី) និងពិភពខាងក្រៅ( រាងកាយ)។ ព្រឹត្តិការណ៍ខាងស្មារតីគឺជាព្រឹត្តិការណ៍ឯកជន ដែលមានតែបុគ្គលខ្លួនឯងទេដែលដឹង*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយអ្នកក្រៅមើលមិនឃើញឡើយ។ ឧទាហរណ៍ ខ្ញុំចង់លើកដៃ។ មានតែខ្ញុំខ្លួនឯងទេដែលដឹងថា ខ្ញុំចង់លើកដៃ។ ចំណែកឯអ្នកដទៃទៀតមិនដឹងពីបំណងនេះឡើយ។ ផ្ទុយទៅវិញពិកពខាងក្រៅ គឺជាព្រឹត្តិការណ៍សាធារណៈ។ នៅពេលដែលខ្ញុំលើកដៃ អ្នកក្រៅផ្សេងទៀតអាចមើលឃើញខ្ញុំលើកដៃ។

អាកប្បកិរិយានិយមយល់ឃើញថា ទស្សនាទានស្មារតីមិនមែននិយាយអំពីព្រឹត្តិការណ៍ឯកជន ដែលកើតឡើងខាងក្នុងទេ តែក៏ជាព្រឹត្តិការណ៍សាធារណៈផងដែរ។ ដូច្នេះ គេមិនចាំបាច់គិតពីអ្វីដែលយើងគិតនៅក្នុងខួរក្បាលឡើយ។ ជារួម អ្វីដែលយើងមើលឃើញ គឺសុទ្ធតែជាអាកប្បកិរិយារបស់បុគ្គល។ តាមរយៈការពន្យល់នេះ យើងលែងចាត់ទុកថា ស្មារតីជាព្រឹត្តិការណ៍ឯកជន និងនៅខាងក្នុងខ្លួនទៀតហើយ។ អាកប្ប-កិរិយា គឺជាព្រឹត្តិការណ៍ដែលគេអាចមើលឃើញជាសាធារណៈ។ អាកប្ប-កិរិយានិយមចែកជាពីរគឺ ៖ អាកប្បកិរិយានិយមវិធីសាស្ត្រ និងអាកប្ប-កិរិយានិយមតក្កវិទ្យា។

ទស្សនវិទូអាកប្បកិរិយានិយម **ហ្គីលបឺត រ៉ាយល៍** *(Gilbert Ryle)* នៅក្នុងស្នាដៃរបស់លោក «**ទស្សនាទាននៃស្មារតី**» *(The Concept of Mind)* (១៩៤៩) បានចាប់ផ្ដើមទិតៀនទស្សនទ្វិកនិយមនេះយ៉ាងខ្លាំងក្លា។ លោកចាត់ទុកថា ស្មារតីគឺជាការសំដែងយ៉ាងស្មុគ្រស្មាញ(a complexity of performance)ពោលគឺជាអាកប្បកិរិយា។ ដឹងអ្វីមួយ មិនមែនមានគំនិតលាក់ទុកក្នុងខ្លួនទេ ឬមានចំណេះដឹងខាងក្នុងខ្លួនឡើយ។ ដឹងពីអ្វីមួយ គឺអាចនិយាយពីរឿងនោះបាន និងអាចស្គាល់វា នៅពេលដែលឃើញវា។

អាកប្បកិរិយានិយមទីពីរ គឺអាកប្បកិរិយានិយមតក្កវិទ្យា(logical behaviorism)ដែលអះអាងថាគេអាចសម្គាល់អ្វីដែលមានន័យ(sense) ពីអ្វីដែលគ្មានន័យបាន(non-sense)ដោយប្រើប្រាស់គោលការណ៍ពិនិត្យបញ្ជាក់(verification)ដោយផ្ទាល់តាមរយៈបទពិសោធនៃន័យនេះ ឬដោយប្រយោល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈទំនាក់ទំនងតក្កវិទ្យារបស់ន័យនេះជាមួយនឹងពាក្យ និងទស្សនា-ទានឯទៀត។

ក៏ប៉ុន្តែ ទស្សនវិទូជាច្រើនអះអាងថា អាកប្បកិរិយានិយមមិនអាចពន្យល់ពីអារម្មណ៍របស់មនុស្ស ដូចជាការឈឺចាប់ ឱជារស ឬទំនាក់ទំនងរវាងអារម្មណ៍ទៅលើរាងកាយ ដូចជាមនុស្សមុខឡើងក្រហមនៅពេលដែលខឹង។ ព្រឹត្តិការណ៍នេះគេហៅថា សភាពនៃស្មារតី ឬqualia។

ទស្សនវិទូរូបនិយម(physicalism)អះអាងថា ស្មារតី គឺជាខួរក្បាល។ ការពិសោធបង្ហាញឱ្យឃើញថាស្មារតី និងខួរក្បាលមានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ។ ក៏ប៉ុន្តែ គេនៅតែមិនអាចពន្យល់ពីទំនាក់ទំនងនេះបានឡើយ។ ទោះបីជាសភាពនៃស្មារតី និងសភាពនៃខួរក្បាលដូចគ្នា ក៏គេមិនអាចចាត់ទុកថា ស្មារតីគឺជាខួរក្បាលបានដែរ។ គេអាចបង្កើតប្រាជ្ញាសិប្បនិមិត្ត(artificial intelligence)ឱ្យមានស្មារតីបាន តែកុំព្យូទ័រទាំងនោះមិនអាចមានខួរក្បាលបានឡើយ ដោយសារតែខួរក្បាល គឺជាសារធាតុដែលកើតឡើងពីធម្មជាតិ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ មានលេចឡើងនូវមុខវិជ្ជាមួយដែលគេហៅថា «វិទ្យាសាស្ត្រនៃការស្គាល់» (cognitive science)ដែលប្រមូលផ្តុំនូវការស្រាវជ្រាវក្នុងផ្នែកចិត្តវិទ្យា ភាសាវិទ្យា វិទ្យាសាស្ត្រកុំព្យូទ័រ វិទ្យាសាស្ត្រខួរក្បាល តក្កវិទ្យា ទស្សនវិជ្ជាភាសាជាដើម។ និន្នាការនេះនាំទៅការបង្កើតនូវចរន្ត**មុខងារនិយម** (Functionalism)។ មុខងារនិយម គឺជាចរន្តទស្សនវិជ្ជាដែលរៀនពីទ្រឹស្តី និងកំហុសមុនៗ ដើម្បីពន្យល់ពីទស្សនវិជ្ជាស្មារតីនេះ។

**មុខងារនិយម** (Functionalism) គឺជាចរន្តទស្សនវិជ្ជាដែលឈរលើមូលដ្ឋាននៃទ្វិកនិយម អាកប្បកិរិយានិយម និងរូបនិយម ដើម្បីពន្យល់ពីលទ្ធភាពក្នុងការបង្ហាញពីស្មារតីនៅក្នុងវត្ថុផ្សេងទៀតក្រៅពីខ្លួនមនុស្ស ដោយសារតែទស្សនវិទូទាំងនេះបានឃើញថាប្រាជ្ញាសិប្បនិមិត្តបានក្លាយជាតថភាពហើយ។ ទ្រឹស្តីមុខងារនិយមត្រូវបានបង្កើតឡើងដោយឈរលើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការធ្វើតេស្តរបស់គណិតវិទូ **អាឡាន់ ធូរីង** (Alan Turing) ដើម្បីបញ្ជាក់ថា ម៉ាស៊ីនក៏ចេះគិតដែរ។ នៅពេលធ្វើតេស្ត គេបញ្ចូលធាតុចូល(input) ហើយអាចបង្កើតធាតុចេញប្រកបដោយបញ្ញាញាណ(intelligent output)បាន។ មុខងារនិយមអះអាងថាស្ថានភាពស្មារតី(mental states)គឺជាទំនាក់ទំនងរវាងស្ថានភាពស្មារតីខ្លួនឯង និងជាមួយនឹងធាតុចូល និងធាតុចេញ។ ទ្រឹស្តីនេះផ្តោតទៅលើមុខងាររបស់ស្ថានភាពស្មារតីនៅក្នុងប្រព័ន្ធស្មារតីទាំងមូល។ គេអះអាងថាស្ថានភាពស្មារតី និងស្មារតី បង្កើតឡើងដោយសារធាតុខុសៗគ្នាជាច្រើន ដែលអាចជាខួរក្បាលកុំព្យូទ័រនៅក្នុងរ៉ូបូ និងសារធាតុផ្សេងៗទៀត។ ស្មារតីទៀតសោតក៏រៀបចំតាមវិធីខុសៗគ្នា និងតាមកម្រិតខុសៗគ្នាផងដែរ ដែលគេអាចសិក្សាបាននៅក្នុងមុខវិជ្ជាផ្សេងៗ ដែលយើងហៅថា «វិទ្យាសាស្ត្រនៃការស្គាល់»។

ទស្សនវិទូខ្លះអះអាងថា ប្រព័ន្ធទំនួលអារម្មណ៍គឺជាម៉ូឌុល។ នៅក្នុងទស្សនវិជ្ជាស្មារតី និងចិត្តវិទ្យាគេចាត់ទុកថាស្ថានភាពនៃស្មារតី ឬខួរក្បាលអាចមានអត្ថន័យ ឬ**ធាតុនៃស្មារតី** (mental content) ពោលគឺជំនឿថាព្រិលមានព័ណ៌ស ក្តីសង្ឃឹមថាគេនឹងសម្រេចបានដូចបំណង។ ស្ថានភាពទាំងនេះបង្កើតបានជាចេតនា(Intentionality)។

ទស្សនវិទូ **ស៊ើល** បានទិតៀនទ្រឹស្តីមុខងារនិយម ដោយប្រើប្រាស់**អំណះអំណាងបន្ទប់ចិន** (Chinese room argument)។ **ស៊ើល** បានអះអាងថា កម្មវិធីកុំព្យូទ័រមិនអាចផ្តល់ឱ្យកុំព្យូទ័រនូវ «ស្មារតី» «ការយល់» និង «សតិសម្បជញ្ញៈ»បានឡើយ ទោះបីជាកម្មវិធីនេះអាចធ្វើឱ្យកុំព្យូទ័រអាចធ្វើសកម្មភាព និងមានប្រាជ្ញាវៀងវៃដូចមនុស្សក៏ដោយ ពោលគឺកុំព្យូទ័រមិនចេះគិតទេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ដែនណេត
## (១៩៤២)

**ដែនណេត** *(Daniel Dennett)* *កើតនៅបុសស្តុន រដ្ឋម៉ាសាឈូសែត សហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៤២។ លោករៀននៅសាកលវិទ្យាល័យ Harvard ហើយទទួលបរិញ្ញាបត្រទស្សនវិជ្ជានៅក្នុងឆ្នាំ ១៩៦៣។ នៅក្នុងឆ្នាំ ១៩៦៥* **ដែនណេត** *បានការពារនិក្ខេបបទទស្សនវិជ្ជាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ Oxford ដែលមានចំណងជើងថា ៖ «The Mind and the Brain: Introspective Description in the Light of Neurological Findings; Intentionality»។ ក្នុងឆ្នាំ ២០១៧ លោកជាសហនាយកមជ្ឈមណ្ឌលវិទ្យាសាស្ត្រនៃសិក្សា(cognitive studies)និងជាសាស្ត្រាចារ្យទស្សនវិជ្ជានៅសាកលវិទ្យាល័យ Tufts។ លោកជាទស្សនវិទូ អ្នកនិពន្ធ អ្នកវិទ្យាសាស្ត្រខាងផ្នែកស្រាវជ្រាវទស្សនវិជ្ជាវិចារណញ្ញាណ ទស្សនវិជ្ជាវិទ្យាសាស្ត្រ និងទស្សនវិជ្ជាជីវវិទ្យា។*

**ស្នាដៃសំខាន់ ៖** *ស្នាដៃសំខាន់របស់***ដែនណេត** *គឺContent and Consciousness(1969), Brainstorms(1978), Elbow Room(1984), The Intentional Stance(1987), Consciousness Explained(1991), Darwin's Dangerous Idea(1995), Kinds of Minds(1996), and Brainchildren: A Collection of Essays 1984-1996 (MIT Press and Penguin, 1998), Sweet Dreams: Philosophical Obstacles to a Science of Consciousness(2005)។*

*កាលពីនៅជានិស្សិត* **ដែនណេត** *បានអានស្នាដៃ* **«ការត្រិះរិះពិចារណាស្តីពីទស្សនវិជ្ជាទីមួយ»** *របស់***ដេកាត** *ជាពិសេសទំនាក់ទំនងរវាងសម្បជញ្ញៈ(conscience) និងរាងកាយ។ ក៏ប៉ុន្តែ* **ដែនណេត** *មិនពេញចិត្តនឹងទ្វិកនិយម(dualisme)រវាងស្មារតី(esprit) និងរូបធាតុ(matière)របស់*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ដេកាត** ឡើយ។ លោកយល់ថា ស្មារតីដែលជាអាត្ម័ន ត្រូវតែបកស្រាយ យ៉ាងណា ដើម្បីកុំឱ្យបំបែកនូវឯកភាពរវាងពុទ្ធិវិទ្យាសាស្ត្រ និងសាកល កម្មនៃច្បាប់រូបវិទ្យា។ ក៏ប៉ុន្តែ គេមិនត្រូវទាត់ចោលទ្វិកនិយមនេះ ដោយ មិនគិតពីស្មារតី ហើយធ្វើពើថាអត់មានស្មារតីឡើយ។ នេះគឺជាជំហររបស់ ទស្សនវិទូអាកប្បកិរិយានិយម(behaviourism)ដូចជា Skinner និង Quine ដែលបង្រៀននៅ Harvard នៅពេលដែល**ដែនណេត**នៅជានិស្សិត។ លោកទទួលយកនិក្ខេបបទរបស់ពួកអាកប្បកិរិយានិយម ដែលថាត្រូវ សិក្សា**ស្មារតី** (psyche, mind) ពីទស្សនវិស័យនៃមនុស្សទីបី។ ក៏ប៉ុន្តែ **ដែន ណេត**យល់ថាអាចបកស្រាយឡើងវិញទស្សនាទានស្មារតី តាមរយៈកិច្ច ដំណើរការនៃប្រព័ន្ធរូបធាតុ។ លោកខិតខំបង្ហាញថា បញ្ញត្តិមួយចំនួនដូច ជា «ការឈឺ» «ចំណង់» «ការជឿជាក់» មិនមែនជាស្ថានភាពឯករាជ្យ ឬខ្លឹម សារនៃតថភាពឡើយ តែវាពាក់ព័ន្ធនឹងមុខងារណាមួយនៃខួរក្បាលរបស់ មនុស្ស។ ដូច្នេះគេឃើញមានទំនាក់ទំនងរវាងផ្លូវចិត្ត ជាមួយនឹងខួរក្បាល។

ដូច្នេះ ការបកស្រាយថាតើកិច្ចដំណើរការនៃស្មារតី ឬអាត្ម័នមាន ជាប់ពាក់ព័ន្ធនឹងអ្វីខ្លះ ត្រូវតែធ្វើដោយមានការវិភាគលក្ខណៈពិសេសនៃ អាត្ម័ន ដោយប្រើវិធីសាស្ត្រ**អត្តពិគ្រោះ** (introspection) ពោល គឺការពិនិត្យ ឬសង្កេតពីដំណើរការស្មារតី និងអារម្មណ៍របស់ខ្លួនឯង។ **ដែនណេត** យល់ថាទ្រឹស្តី**ស្មារតី** (Theory of Mind) ពេញលេញត្រូវមាន**សមាស ធាតុមុខងារ** និងទ្រឹស្តីអត្តពិគ្រោះ៖ ផ្នែកទី១ គឺជាទ្រឹស្តី**ធាតុក្នុងស្មារតី** (Theory of mental content) និងទ្រឹស្តីទី២ គឺទ្រឹស្តី**សម្បជញ្ញៈ** (Theory of consciousness)។

**ទ្រឹស្តីធាតុក្នុងស្មារតី** (mental content) ៖ **ដែនណេត**សរសេរថា លោកយកទស្សនាទាន **ចេតនា** ពីស្នាដៃរបស់ទស្សនវិទូអាឡឺម៉ង់ Brentano ដែលយល់ថា នៅពេលដែលគេពិនិត្យមើលភាពខុសគ្នារវាងបាតុភូតស្មារតី និងបាតុភូតរាងកាយ លក្ខណៈពិសេសនៃបាតុភូតស្មារតី គឺការគិតពីអ្វី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មួយជាពុទ្ធិវត្ថុ ជាវត្ថុគ្គី ឬជាគំនិតគ្គី ដែលលោកហៅថា **អវត្តមានដោយចេតនា** *(intentional inexistence)*។ *John Searle* គូសបញ្ជាក់ថា សមត្ថភាពក្នុងការព្យាករណ៍ ឬពន្យល់អាកប្បកិរិយារបស់មនុស្សត្រូវតែអាចស្គាល់អ្នកផ្សេងថាមាន**ចេតនា** *(intentional)* និងអាចបកស្រាយគំនិតអ្នកផ្សេងដែលត្រូវមាន «**ស្ថានភាពចេតនា** *(intentional states)*» (ដូចជា ជំនឿ និងចំណង់)។ ប្រព័ន្ធរូបធាតុ ដែលសកម្មភាពរបស់វាអាចបរិយាយដោយប្រើចេតនា អាចព្យាករណ៍បានដោយសារ «**ជំហរចេតនា**» *(intentional stance)*។ ជំហរចេតនានេះមិនមែនមានតែនៅក្នុងមនុស្សទេ វត្ថុដូចជាកុំព្យូទ័រក៏មានដែរ។

**ដែនណេត**បានលើកឡើងថា ប្រសិនបើគេចង់ព្យាករណ៍ពីកុំព្យូទ័រលេងអុក គេអាចធ្វើបានដោយមើលទស្សនៈក្នុងការបង្កើតវា*(design stance)* និងស្ថានភាពរូបរាង*(physical stance)*។ ក៏ប៉ុន្តែកុំព្យូទ័រនាពេលបច្ចុប្បន្នមានលក្ខណៈស្មុគ្រស្មាញណាស់។ មានតែព្យាករណ៍ដោយឈរលើមូលដ្ឋាននៃចេតនា*(Intentional stance)*ឬគោលដៅទេទើបអាចធ្វើទៅបានដោយឈរលើមូលដ្ឋាននៃស្មារតី។ ដូច្នេះ យើងអាចចាត់ទុកកុំព្យូទ័រថាជា**ប្រព័ន្ធចេតនា** *(intentional system)* ដែលមានព័ត៌មានមួយចំនួន និងមានគោលដៅច្បាស់លាស់ ហើយឈរលើមូលដ្ឋាននេះ ត្រូវព្យាករណ៍ពីសកម្មភាពសមហេតុផល និងសមស្របទាំងឡាយ។ យើងអាចចាត់ទុកថាកុំព្យូទ័រមានជំនឿ គោលដៅ និងកំណត់ចំណង់របស់ខ្លួន។ ភាពឆ្លុះគ្នានៃសកម្មភាពផ្លូវចិត្ត ដែលជាសកម្មភាពនៃខួរក្បាល និងកម្មវិធីកុំព្យូទ័រ ដែលរកឃើញនៅពេលពិនិត្យសកម្មភាពរបស់វា «ពីទស្សនវិស័យមនុស្សទី៣» អាចឱ្យ**ដាំណេត**ឱ្យនិយមន័យស្មារតីតាមន័យកុំព្យូទ័រ។ **ស្មារតី** គឺដូចជាកម្មវិធី ឬសកម្មភាពគិតលេខរបស់ខួក្បាល។ **ដែនណេត**យល់ឃើញថាក្បួនដោះស្រាយ*(algorithm)*ស្មារតីខុសពីកម្មវិធីកុំព្យូទ័រដែលមានរចនាសម្ព័ន្ធតក្កវិទ្យាជាក់ច្បាស់។ ក្បួនដោះស្រាយផ្លូវស្មារតីមិនអាចបកស្រាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានតែមួយមុខឡើយ។ ទោះបីជាខួរក្បាលមានលំនាំខ្លះក៏ដោយ ទៅតាមស្ថានភាពចេតនារបស់វា ដោយសារតែនៅក្នុងខួរក្បាលមានដំណើរការគិតគូរជាច្រើនព្រមៗគ្នា គេពិបាកសន្និដ្ឋានថា តើលំនាំអ្វីនាំឱ្យមានស្ថានភាពចេតនាណាមួយនោះ។ ដូច្នេះហើយ គេត្រូវពិនិត្យការជឿជាក់ និងចំណង់ថាជាបញ្ញត្តិអរូបី ដែលដូចគ្នាទៅនឹងមជ្ឈមណ្ឌលទំនាញផែនដី ឬវិចទ័រជាជាងស្ថានភាពនិមួយៗជាក់ស្តែង។

ទោះបីជាមានភាពខុសគ្នាក៏ដោយ ក៏នៅមានភាពដូចគ្នាជាច្រើនរវាងស្មារតី(mind) និងកម្មវិធីកុំព្យូទ័រ ៖ ដោយគោលដៅនិងទម្រង់ និងដោយមុខងារ។ មុខងាររបស់កម្មវិធី គឺសម្រេចបាននូវគោលដៅណាមួយ។ ស្មារតីក៏បម្រើនូវគោលដៅជាក់ស្តែងដែរ។ ជាការពិតកុំព្យូទ័រមាន «ចេតនាទៅតាមការបង្កើត» ពោលគឺមនុស្សជាអ្នកបញ្ចូលចេតនានេះក្នុងកុំព្យូទ័រ។ មនុស្សក៏មាន «ចេតនាទៅតាមការបង្កើត» ដែរ គឺហ្សែនរបស់មនុស្ស ដែលបន្តតាមពូជពង្សវង្សត្រកូល។

**ទ្រឹស្តីសម្បជញ្ញៈ** (consciousness) ៖ **ដែនណេត**ពន្យល់ទ្រឹស្តីនេះនៅក្នុងសៀវភៅរបស់គាត់ «Consciousness Explained» ដែលជាទ្រឹស្តីសម្បជញ្ញៈដោយចាត់ទុកស្មារតីថា ជាដំណើរការបំប្លែងព័ត៌មាន(information processing)។ លោកចាត់ទុកថា សម្បជញ្ញៈគឺជាលទ្ធផលនៃការធ្វើ មេពេគខួរក្បាលដែលអាចឱ្យប្រព័ន្ធចេតនារបស់មនុស្សសម្រេចបាននូវដំណើរការប្រកបដោយប្រសិទ្ធភាព ពីទស្សនវិស័យនៃមនុស្សទីបី។ លោកប្រកាសថា លោកប្រើទ្រឹស្តីសត្យានុម័តស្តីពីចេតនា ដើម្បីបង្ហាញថា សម្បជញ្ញៈរបស់មនុស្សកើតឡើងដូចជា «បាតុភូតឯកជនខាងក្នុងទ្រឹស្តីផ្លូវចិត្តនេះ»។ ក្នុងន័យនេះ **ដែនណេត**មិនបានកំណត់ព្រំដែនរវាងផ្នែកទី១ និងផ្នែកទី២នៃទ្រឹស្តីផ្លូវចិត្តរបស់ខ្លួនឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ចន ស៊ើល
## (១៩៣២)

**ចន ស៊ើល** *(John Rogers Searle)* កើតនៅដែនវើរ រដ្ឋកូឡូរ៉ាដូ សហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៣២។ លោករៀននៅសាកលវិទ្យាល័យ Wisconsin បន្ទាប់មកចូលរៀននៅសាកលវិទ្យាល័យ Oxford ដោយបានទទួលសញ្ញាបត្របណ្ឌិតខាងផ្នែកទស្សនវិជ្ជានៅឆ្នាំ ១៩៥៩។ លោកបានត្រឡប់មកសហរដ្ឋអាមេរិកវិញ ហើយបង្រៀនទស្សនវិជ្ជានៅសាកលវិទ្យាល័យកាលីហ្វ័រនី UC Berkeley ចាប់ពីឆ្នាំ ១៩៥៩។ លោកជាសាស្ត្រាចារ្យទស្សនវិជ្ជាស្តីពីសម្បជញ្ញៈ និងភាសា។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់ **ចន ស៊ើល** គឺ*Speech Acts: An Essay in the Philosophy of Language (1969), Intentionality: An Essay in the Philosophy of Mind (1983), The Construction of Social Reality (1995), Mind: A Brief Introduction (summary of work in philosophy of mind; 2004), Philosophy in a New Century: Selected Essays (2008), Making the Social World: The Structure of Human Civilization (2010), Seeing Things As They Are: A Theory of Perception (2015).*

កាលពីនៅជានិស្សិត **ចន ស៊ើល** ទទួលឥទ្ធិពលពី **ហ្វ្រេគ** (Frege) និង **វីតហ្គេនស្តែន** (Wittgenstein)។ ម្យ៉ាងវិញទៀត សាស្ត្រាចារ្យដឹកនាំនិក្ខេបបទរបស់គាត់នៅសាកលវិទ្យាល័យ Oxford លោកសាស្ត្រាចារ្យទស្សនវិជ្ជាភាសាអង់គ្លេស **អូស្ទីន** (Austin) មានឥទ្ធិពលយ៉ាងខ្លាំងក្លាលើ**ចន ស៊ើល**។

**ទ្រឹស្តីអំពើនិយាយ** (speech acts) ៖ លោក **អូស្ទីន** បានបង្កើត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មូលដ្ឋានគ្រឹះសម្រាប់ទ្រឹស្ដី**អំពើនិយាយ** (speech acts) នៅក្នុងឆ្នាំ ១៩៦២ ដែលក្រោយមក **សើល**បានបង្កើតជាទ្រឹស្ដីនេះឡើង។ ពាក្យដែលយើងនិយាយចេញមក មិនមែនគ្រាន់តែជាពាក្យ និងន័យរបស់ពាក្យទាំងនេះទេ។ ពាក្យដែលយើងនិយាយចេញមកអាចបំពេញកិច្ចការនិងសកម្មភាពផ្សេងៗបាន។

**អូស្ទីន** បានបែងចែកអំពើនិយាយជាបីកម្រិត ៖ (ទី១)-អត្ថន័យដែលអ្នកនិយាយចង់ប្រាប់ដល់អ្នកស្ដាប់(Illocution) (ទី២)-ពាក្យដែលអ្នកនិយាយនិយាយចេញមក(locution) និង(ទី៣)-ប្រតិកម្មរបស់អ្នកស្ដាប់ទៅនឹងសាររបស់អ្នកនិយាយ(perlocution)។ **ចន សើល** បានយកទ្រឹស្ដីនេះទៅពង្រីកថែមទៀត។

**សើល** បានធ្វើចំណាត់ថ្នាក់នៃអំពើនិយាយ ឬគោលបំណងរបស់អ្នកនិយាយ(Illocution)ជា ៖ (១) ការផ្ដល់ព័ត៌មាន(Assertive) (២) ការធ្វើសំណើ(Directive) (៣) ការប្ដេជ្ញាចិត្ត(Commissive) (៤) ការប្រកាសប្រាប់(Declaration) (៥) ការសំដែងអារម្មណ៍(Expressive)។ ពាក្យដែលនិយាយចេញមកអាចនិយាយដោយផ្ទាល់(Explicit) ឬដោយប្រយោល(Implicit)។ លោកបានគូសបញ្ជាក់ថា**អំពើនិយាយ**តែងតែមានទិដ្ឋភាពនៃការប្រាស្រ័យទាក់ទង(communication)តែត្រូវមានសមាសធាតុតំណាង(Representation)នៅក្នុងនោះ។ តំណាង(Representation) គឺជាចេតនា ហើយមានទិដ្ឋភាពពីរបែប ៖ ផ្លូវចិត្ត និងភាសា។ **សើល** យល់ឃើញថាតំណាងភាសាក៏បណ្ដាលមកពីតំណាងផ្លូវចិត្តដែរ។ ដោយឈរលើមូលដ្ឋាននៃតួនាទីរបស់ស្ថានភាពផ្លូវចិត្តក្នុងការបង្កើតអំពើនិយាយ **សើល** បានធ្វើសេចក្ដីសន្និដ្ឋានថា «**ទស្សនវិជ្ជាភាសា គឺជាផ្នែកមួយនៃទស្សនវិជ្ជាស្មារតី**»។

**ទ្រឹស្ដីចេតនា** (Intentionality) ៖ លោក **អូស្ទីន** បានចែកអំពើនិយាយជាពីផ្នែក ៖ (១) ប្រភេទ ឬគុណភាពនៃការនិយាយ និង (២) ខ្លឹមសារនៃការនិយាយ។ នៅក្នុងស្នាដៃរបស់លោក Intentionality **សើល**បាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើតទ្រឹស្តីស្តី**ចេតនា** (theory of intentionality)។ ការវិភាគភាសាបានក្លាយទៅជាការវិភាគចិត្តគំនិត(minds)។ **ចេតនា** គឺជាអានុភាពនៃស្មារតីអំពីអ្វីមួយ ឬតំណាងស្ថានភាពអ្វីមួយ។ ចេតនា គឺជាផ្នែកមួយដ៏សំខាន់នៃផ្លូវចិត្ត ឬមនសិការ។ ស្ថានភាពផ្លូវស្មារតីខ្លះជាចេតនា តែខ្លះទៀតមិនមែនជាចេតនាទេ។ ដូចជាអារម្មណ៍ថាមានសេចក្តីសប្បាយ និងភ័យខ្លាចមិនមែនជាចេតនាទេ។ ផ្ទុយទៅវិញ ជំនឿ ចំណង់ និងគោលបំណងបង្ហាញពីចេតនា។ អារម្មណ៍ទាំងនេះបង្ហាញឱ្យពិភពលោកឃើញពីចេតនាអ្វីមួយ។ ចេតនាត្រូវបានបញ្ចេញឱ្យឃើញ តាមរយៈភាសា។

បន្ទាប់មក **ស៊ើល** បង្កើតទ្រឹស្តីថ្មីស្តីពីហេតុផលនៃចេតនា ដោយឈរលើអំណះអំណាងថា ចេតនាអាចសម្រេចបាន ទាល់តែចេតនានេះនាំឱ្យមានការសម្រេចបាននូវលក្ខខណ្ឌ ទាំងអស់។ ដើម្បីសម្រេចបាននូវចេតនារបស់ខ្ញុំក្នុងការលើកដៃ ការលើកដៃរបស់ខ្ញុំមិនគ្រប់គ្រាន់ឡើយ។ ប្រការនេះទាមទារឱ្យការលើកដៃរបស់ខ្ញុំបណ្តាលមកពីចេតនាផ្ទាល់តែម្តង។ ក្នុងន័យនេះ **ស៊ើល** ប្រកាន់ជំហរដូច**អារីស្តូត** និង**ហ៊្សែរ្សល** ដែលចាត់ទុកអាកប្បកិរិយាក្នុងការនិយាយ គឺជាការឆ្លុះបញ្ចាំងនូវសកម្មភាព និងសមត្ថភាពជាមូលដ្ឋានទៅលើស្ថានភាពផ្លូវចិត្ត ជាពិសេសសមត្ថភាពនៃមនសិការក្នុងការធ្វើជាតំណាងនៃស្ថានភាពផ្លូវចិត្តទូទៅ។ ក្នុងន័យនេះ **ស៊ើល** ទទួលស្គាល់នូវឧត្តមភាពនៃមនសិការ។

**តថភាពសង្គម** (Social reality) ៖ **ស៊ើល**ប្រើទ្រឹស្តី**អំពើនិយាយ** ដើម្បីសិក្សាពីតថភាពសង្គម ដូចជាអាពាហ៍ពិពាហ៍ កម្មសិទ្ធិ ការប្រជុំរដ្ឋាភិបាល សហជីព រដ្ឋសភា ច្បាប់ ក្រុមហ៊ុន អ្នកច្បាប់ សាស្ត្រាចារ្យ ការជ្រើសរើសបុគ្គលិក។ល។ ដែលកើតឡើងតាមរយៈទំនាក់ទំនងសង្គម និងកិច្ចសន្ទនាសង្គម ហើយបង្កើតឱ្យមានតំណាងសង្គម។ តថភាពសង្គមមិនចំណុះឱ្យចេតនារបស់បុគ្គលឡើយ។ តថភាពសង្គមត្រូវបានបង្កើតឡើងតាមរយៈចេតនាសមូហភាព ដែលឆ្លុះបញ្ចាំងពីបំណងរួមនៅក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សង្គម ដែលជាលទ្ធផលនៃការវិវត្ត និងជាបាតុភូតជីវវិទ្យាជាដំបូង។ ក៏ប៉ុន្តែហ្វូងសត្វក៏មានចេតនាសមូហភាពដែរ។ តែចេតនាសមូហភាពរបស់មនុស្សខុសពីសត្វ ដោយសារមនុស្សបង្កើតឱ្យមានស្ថាប័នសង្គម។

**កុំព្យូទ័រមិនចេះគិត ឬ អំណះអំណាងបន្ទប់ចិន** *(Chinese room argument)* ៖ នៅក្នុងអត្ថបទដែលមានចំណងជើងថា «Minds, Brains, and Programs» បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៨០ **ស៊ើល**បានអះអាងថា កម្មវិធីកុំព្យូទ័រមិនអាចផ្តល់ឱ្យកុំព្យូទ័រនូវ «ស្មារតី» «ការយល់» និង «សតិសម្បជញ្ញៈ» បានឡើយ ទោះបីជាកម្មវិធីនេះអាចធ្វើឱ្យកុំព្យូទ័រអាចធ្វើសកម្មភាព និងមានប្រាជ្ញាវៀងវៃដូចមនុស្សក៏ដោយ។ **ស៊ើល**បង្កើតពិសោធខាងផ្នែកគំនិតស្តីពីប្រាជ្ញាសិប្បនិមិត្ត(Artificial intelligence-AI)។ ឧបមាថាការស្រាវជ្រាវខាងផ្នែកប្រាជ្ញាសិប្បនិមិត្តអាចផលិតកុំព្យូទ័រដែលយល់ភាសាចិន។ គេបញ្ចូលអក្សរចិនចូលក្នុងម៉ាស៊ីនជាធាតុចូល ហើយបន្ទាប់ពីអនុវត្តតាមការណែនាំនៃកម្មវិធីកុំព្យូទ័រ ផលិតបាននូវអក្សរចិនដែលជាធាតុចេញ។ ឧបមាថាម៉ាស៊ីននេះអាចធ្វើតេស្តជាប់ ហើយកុំព្យូទ័រយល់ភាសាចិន ដូចជនជាតិចិនដែរ។ យើងអាចសួរថា តើកុំព្យូទ័រយល់ភាសាចិនដែរឬទេ (**ស៊ើល**ហៅសំណើនេះថា strong AI)? ឬមួយក៏កុំព្យូទ័របានត្រឹមតែធ្វើត្រាប់តាមលទ្ធភាពក្នុងការយល់ភាសាចិន (**ស៊ើល**ហៅសំណើនេះថា weak AI)?

**ស៊ើល**បានសន្មតិថាគាត់អង្គុយនៅក្នុងបន្ទប់បិទជិត ហើយកាន់សៀវភៅកម្មវិធីកុំព្យូទ័រជាភាសាអង់គ្លេស ដោយមានក្រដាស ខ្មៅដៃ និងឯកសារផ្សេងទៀត។ លោកអាចទទួលយកធាតុចូលជាភាសាចិនតាមប្រហោងទ្វារ អនុវត្តតាមការណែនាំរបស់កម្មវិធីកុំព្យូទ័រ ហើយផលិតបាននូវភាសាចិនជាធាតុចេញ។ លោកអះអាងថា ប្រសិនបើកុំព្យូទ័រអាចធ្វើតេស្តជាប់បានតាមរបៀបនេះ គាត់ក៏អាចធ្វើតេស្តជាប់ដែរ។ **ស៊ើល**បានអះអាងថាអ្វីដែលកុំព្យូទ័រធ្វើ និងគាត់ធ្វើមិនខុសគ្នាទេ ដោយគ្រាន់តែធ្វើតាមការ

ណែនាំនៃកម្មវិធីប៉ុណ្ណោះ។ គាត់ខ្លួនឯងមិនយល់ការសន្ទនានេះ ដោយគាត់មិនចេះភាសាចិន ហើយកុំព្យូទ័រក៏មិនយល់ភាសាចិនដែរ។ ដូច្នេះ ប្រសិនបើគ្មានការយល់( ចេតនា) យើងមិនអាចនិយាយថាកុំព្យូទ័រគិតឡើយ។ ប្រសិនបើកុំព្យូទ័រមិនចេះគិត នោះកុំព្យូទ័រក៏គ្មានស្មារតីដែរ។ ដូច្នេះ អំណះអំណាងនៃប្រាជ្ញាសិប្បនិម្មិតខ្ពស់(strong AI)គឺមិនពិតទេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ភីងឃើ

**(១៩៥៤)**

**ស្ទីវិន ភីងឃើ** *(Steven Pinker) កើតនៅម៉ុនរ៉េអាល់ កាណាដា ក្នុងឆ្នាំ ១៩៥៤។ លោកមានបរិញ្ញាបត្រចិត្តសាស្ត្រពិសោធពីសាកលវិទ្យាល័យ McGill ក្នុងឆ្នាំ ១៩៧៦ និងសញ្ញាបត្របណ្ឌិតពីសាកលវិទ្យាល័យ Harvard ក្នុងឆ្នាំ ១៩៧៩។ ពីឆ្នាំ ១៩៨២ ដល់ ២០០៣ លោកបង្រៀននៅវិទ្យាស្ថានបច្ចេកវិទ្យាម៉ាស្សាឈូសែត(MIT)។ ចាប់ពីឆ្នាំ ២០០៣ មកដល់បច្ចុប្បន្ន ជាសាស្ត្រាចារ្យនៃដេប៉ាតឺម៉ង់ចិត្តសាស្ត្រនៃសាកលវិទ្យាល័យ Harvard។ នៅឆ្នាំ ២០០៤ ទស្សនាវដ្ដីថាមស៍បានចាត់ទុកលោក* **ភីងឃើ** *ក្នុងចំណោមបុគ្គលដែលមានឥទ្ធិពលជាងគេក្នុងពិភពលោក។*

*ទំនាក់ទំនងរវាងស្មារតី(Minds)ជាមួយនឹងរាងកាយ(Body)អាចចាត់ទុកថាជាផ្នែកបរមត្ថវិជ្ជានៃទស្សនវិជ្ជាស្មារតី(philosophy of mind)នាសម័យទំនើប។ ក៏ប៉ុន្តែមានទស្សនវិទូខ្លះយល់ឃើញថា ស្មារតីរបស់មនុស្ស ដែលកើតឡើងក្នុងដំណើរការជ្រើសរើសជាធម្មជាតិ(natural selection)មិនមែនមានគោលដៅដោះស្រាយបញ្ហានេះទេ។* **ភីងឃើ** *គាំទ្រជំហរនេះផងដែរ។* **ភីងឃើ** *តំណាងឱ្យចរន្តប្រឆាំងទ្រឹស្ដីម៉ាក្សនិយមក្នុងគ្រប់រូបភាពទាំងអស់ ដោយលោកមិនចាត់ទុកថា សារជាតុរបស់មនុស្សកំណត់ដោយវប្បធម៌ ឬទំនាក់ទំនងសង្គមឡើយ។ ផ្ទុយទៅវិញលោកយល់ថា ទំនាក់ទំនងសង្គមបណ្ដាលមកពីសារជាតិរបស់មនុស្ស។*

**ស្នាដៃសំខាន់** *៖ ស្នាដៃសំខាន់របស់*__ភីងឃើ__ *គឺ ៖ The Language Instinct (1994), How the Mind Works (1997), Words and Rules (2000), The Blank Slate (2002), The Stuff of Thought (2007), The Better Angels of Our Nature (2011)។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ភីងឃើ** ចាប់ផ្ដើមការងារស្រាវជ្រាវជាចិត្តវិទូពិសោធរបស់ខ្លួនដោយសិក្សាពីបញ្ហាទំនួលអារម្មណ៍តាមចក្ខុ និងការស្គាល់រាងវត្ថុ។ បន្ទាប់មកគាត់ចាប់អារម្មណ៍លើចិត្ត-ភាសាវិទ្យា(psycho- linguistics)គឺការសិក្សាកត្តាចិត្តសាស្ត្រនិងជីវវិទ្យា ដែលធ្វើឱ្យមនុស្សចេះបង្កើត ប្រើប្រាស់ និងយល់ភាសា។ លោកទទួលឥទ្ធិពលពីគំនិតរបស់អ្នកប្រាជ្ញឈ្មោះ **ណោម ឆុមស្គី** (Naom Chomsky) ដែលជាបិតានៃទស្សនវិជ្ជាវិភាគ ភាសាវិទូស្ថាបនិកម្នាក់នៃវិទ្យាសាស្ត្រសិក្សាផ្លូវចិត្ត(cognitive science) និងជាស្ថាបនិកនៃទស្សនាទាន «វេយ្យាករណ៍សាកល» (សមត្ថភាពរបស់មនុស្សក្នុងការរៀនភាសាគឺមានមកពីក្នុងតែម្ដង ដែលបណ្ដាលមកពីសារជាតិរបស់មនុស្ស និងរចនាសម្ព័ន្ធនៃវិធានដែលមាននៅក្នុងមនុស្ស ហើយគ្មានការពាក់ព័ន្ធអ្វីជាមួយនឹងឥន្ទ្រីយារម្មណ៍របស់មនុស្សពាក់ព័ន្ធនឹងការរៀនឡើយ)។ ឧទាហរណ៍ ក្មេងអាចរៀនភាសាលឿនជាងមនុស្សចាស់ ហើយឆាប់រៀនចេះវេយ្យាករណ៍លំបាកៗ និងចេះរៀបពាក្យបានយ៉ាងច្រើនទៀតផង។ ដូច្នេះ ប្រសិនបើគ្មានសមត្ថភាពពីក្នុងមក ដែលស្គាល់នូវវិធានវេយ្យាករណ៍ជារួមទេ នោះក្មេងមិនអាចរៀនភាសាចេះបានឆាប់ឡើយ ដែលលោក **ឆុមស្គី** ហៅថាវេយ្យាករណ៍សាកល។

**ភីងឃើ** មិនអស់ចិត្តនឹងការបកស្រាយរបស់លោក**ឆុមស្គី** ឡើយ។ លោកបានបោះផ្សាយនូវលទ្ធផលនៃការស្រាវជ្រាវរបស់លោកក្នុងសៀវភៅ «**ភាសា គឺជាសភាវគតិ**» (Language Instinct) 1994 ដែលក្នុងនោះលោកបានចាត់ទុកភាសា ថាជាយន្តការបន្សាំដ៏សំខាន់មួយ ដែលអនុញ្ញាតឱ្យទទួល និងចែករំលែកព័ត៌មានដែលមានសារៈសំខាន់សម្រាប់ជីវិតមនុស្ស។ បន្ទាប់ពីបានប្រើវិធីសាស្ត្រវិវត្តនិយម ដើម្បីសិក្សាពីវិចារណញ្ញាណរបស់មនុស្ស ជាពិសេសទំនួលអារម្មណ៍ និងការគិតតាមលក្ខណៈវិនិច្ឆ័យ លោកបានបោះពុម្ពផ្សាយសៀវភៅ «How the Mind Works» 1997 ដែលធ្វើឱ្យលោកល្បីល្បាញយ៉ាងខ្លាំង។ នៅក្នុងឆ្នាំ២០០២ លោកបានបោះពុម្ព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សៀវភៅ The Blank Slate ដែលក្នុងនោះលោកបានពិពណ៌នាសរុបពីសារជាតុរបស់មនុស្ស និងវិភាគពីបច្ច័យខាងផ្នែកវប្បធម៌ និងនយោបាយ។ **ភីងឃើ**អះអាងថា សម្បទារបស់មនុស្សក្នុងការរៀនភាសា គឺជាសភាវៈគតិ គឺជាអាកប្បកិរិយាពីខាងក្នុង ដែលកំណត់ដោយការជ្រើសរើសដោយធម្មជាតិ និងបន្សាំទៅនឹងតម្រូវការរបស់មនុស្សក្នុងទំនាក់ទំនង។

**សារជាតិរបស់មនុស្សតាមបែបម៉ូឌុល ៖ ភីងឃើ**ពន្យល់ពីសារជាតិរបស់មនុស្សតាមបែបស្ថាបនា(constructiviste)។ លោកបានសិក្សាពីស្មារតីរបស់មនុស្ស វិចារណញ្ញាណ ឬផ្លូវចិត្ត។ លោកចាត់ទុកថា ស្មារតី ឬផ្លូវចិត្តគឺជាលទ្ធផលនៃសកម្មភាពរបស់ខួរក្បាល។ ខួរក្បាលរបស់មនុស្ស ដែលជាសរីរាង្គដែលបង្កើតឡើងដោយសារដំណើរការវិវត្ត គឺជាឧបករណ៍ពិសេសមួយសម្រាប់វិភាគព័ត៌មាន។ ដូច្នេះ គេត្រូវចាត់ទុកស្មារតីជា «ប្រព័ន្ធនៃសរីរាង្គគិតលេខ ដែលបង្កើតឡើងដោយធម្មជាតិ ដើម្បីដោះស្រាយបញ្ហាទាំងឡាយ ដែលដូនតារបស់យើងជួបប្រទះក្នុងជីវិតរបស់ពួកគេ»។ **ភីងឃើ** មិនយល់ស្របតាមទស្សនវិទូ **ចន សៀល** ដែលបានទិតៀនទ្រឹស្តីដែលប្រៀបប្រដូចស្មារតីទៅនឹងប្រដាប់គិតលេខ។ ក៏ប៉ុន្តែ **ភីងឃើ** ក៏មិនគាំទ្រទ្រឹស្តីដែលប្រដូចស្ថានភាពអត្តនោម័តនៃស្មារតីទៅនឹងដំណើរការគិតលេខនៃខួរក្បាលដែរ។

**ភីងឃើ** យល់ថា ៖ (១) ស្មារតីរបស់មនុស្សវិវត្តដូចជាឧបករណ៍ដើម្បីធានាដល់ការរស់របស់មនុស្ស និងភាពជោគជ័យក្នុងការបន្តពូជ (២) ស្មារតីនេះមិនមែនជាឯកតាតែមួយមានសង្គតិភាពទេ តែជាម៉ូឌុលផ្សេងៗដែលទំនាក់ទំនងគ្នាក្នុងសហគមន៍តែមួយ។ ម៉ូឌុលនីមួយៗមានមុខងារផ្សេងៗគ្នា។ សរីរាង្គផ្លូវចិត្តនីមួយៗ ឬម៉ូឌុលមាននិម្មាបនកម្មខាងក្នុងពិសេស និងភារកិច្ចរបស់ខ្លួន។ តក្កវិទ្យាជាមូលដ្ឋាននៃម៉ូឌុលនីមួយៗត្រូវបានកំណត់ដោយកម្មវិធីហ្សេណេទិចរបស់យើង។ ម៉ូឌុលទាំងនេះដោះស្រាយបញ្ហាតូចៗ ដែលជាផ្នែកមួយនៃបញ្ហាធំៗ ហើយហ្សែនទាំងនេះនឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រូវផ្ទេរទៅជនជំនាន់ក្រោយ។ ដោយសារតែស្មារតីប្រៀបបីដូចជាម៉ាស៊ីនដូច្នេះ ក្នុងការសិក្សាម៉ូឌុលផ្លូវចិត្ត គេអាចដំណើរការ «ស្ពានាគិតថយក្រោយវិញ(reverse engineering)» ពោលគឺយកម៉ាស៊ីនមកដោះ ហើយរៀបឡើងវិញ ដើម្បីដឹងពីគោលដៅនៃគ្រឿងនីមួយៗ។ ពោលគឺការសិក្សាពីមនុស្សដោយឈរលើវិធីសាស្ត្រគោលដៅចុងក្រោយ (téléologique ou finalité)។

វិធីពិសោធក្នុងការកំណត់ម៉ូឌុលផ្លូវចិត្តដែលកើតពីខាងក្នុងមានលក្ខណៈដូចតទៅ ៖ ប្រសិន គេមានម៉ូឌុលដើម្បីដោះស្រាយបញ្ហាអ្វីមួយនោះវិទ្យាសាស្ត្រខួរក្បាលនឹងរកឃើញថា នៅក្នុងកោសិកាខួរក្បាល ដែលដំណើរការក្នុងការដោះស្រាយបញ្ហានោះ មានទំនាក់ទំនងសរីរាង្គដែលបង្កើតឡើងនូវប្រព័ន្ធនេះឡើង។ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យនេះ **ភីងឃើ** ជឿជាក់ថានៅក្នុងស្មារតីរបស់មនុស្សមានម៉ូឌុលជាមូលដ្ឋាន ឬ «សភាវគតិចំនួន៧» ៖ ភាសា ទំនួលអារម្មណ៍ មេកានិចអព្ភន្តរញាណជីវវិទ្យាអព្ភន្តរញាណ ចំនួន ផែនទីផ្លូវចិត្តសម្រាប់ដែនដីធំ ការជ្រើសរើសទីកន្លែងសម្រាប់រស់នៅ សភាវគតិពាក់ព័ន្ធនឹងគ្រោះថ្នាក់ អាហារ និងជំងឺការសង្កេតមើលស្ថានភាពខ្លួនឯង ចិត្តសាស្ត្រអព្ភន្តរញាណ មូលដ្ឋានទិន្នន័យសម្រាប់បុគ្គលមួយចំនួន ការស្គាល់ខ្លួនឯង យុត្តិធម៌ បងប្អូន ដៃគូរួមសង្វាស។ ម៉ូឌុលស្មារតីដែលកើតពីក្នុងនេះអាចដំណើរការបាន ដោយទាក់ទងនឹងគ្នាជាមួយនឹងមជ្ឈដ្ឋានខាងក្រៅ។ ឧទាហរណ៍ សភាវគតិនៃភាសាអាចមានសមត្ថភាពនិយាយជាភាសាបារាំង ឬអង់គ្លេស។ កោសិកាបន្តពូជរបស់មនុស្ស «បង្កើតឡើងនូវយន្តការស្មារតីខាងក្នុង» ដែលក្នុងនោះមានមុខងារក្នុងការរៀនសូត្រផងដែរ។ ដោយសារតែយន្តការនេះហើយ ទើបយើងអាចមានឧបនិស្ស័យ ទម្លាប់ ពុទ្ធិ និងតម្លៃ ដែលទាំងអស់នេះបង្កើតបានជាវប្បធម៌។ យន្តការនេះបង្កើតបានជាម៉ូឌុលស្មារតី និងវិភាគព័ត៌មានដែលទទួលបានពីមជ្ឈដ្ឋានជុំវិញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ឧស្សាហាភាពស្តីពីវប្បធម៌** ៖ ដើម្បីយល់បានពីយន្តការទាំងមូល ត្រូវតែកំណត់ពីតួនាទីនៃវប្បធម៌។ **ភីងឃើ** ទទួលស្គាល់ពីស្វ័យភាពនៃវប្បធម៌។ វប្បធម៌ គឺជាបណ្តុំនៃសមិទ្ធកម្មខាងផ្នែកបច្ចេកវិទ្យា និងសង្គម ដែលបង្កើតឡើងដោយមនុស្ស ក្នុងគោលដៅធ្វើឱ្យជីវិតមានភាពរីករាយ។ សមិទ្ធកម្មនេះស្ថិតនៅក្នុងប្រាជ្ញារបស់មនុស្ស ឬជាទម្រង់នៃសម្ភារ។ **ភីងឃើ** បង្ហាញថា «មនោសញ្ចេតនាសីលធម៌» ដែលជាបណ្តុំនៃអារម្មណ៍គិតពីអ្នកក្រៅ ដូចជាការខ្មាសអៀន ការឈឺចាប់ យុត្តិធម៌។ល។ និងសមាសធាតុផ្សេងទៀតនៃសារជាតិរបស់មនុស្ស គឺជាលទ្ធផលនៃការវិវត្ត។ ការគិតពីអ្នកដទៃ គឺជាយុទ្ធវិធីសម្រុះសម្រួល។ ក៏ប៉ុន្តែ ប្រការនេះមិនមែនមានន័យថា សីលធម៌សមមូលនឹងទម្រង់បិទបាំងនៃអត្តទត្ថបុគ្គលឡើយ។

នៅក្នុងស្នាដៃរបស់គាត់ក្រោមចំណងជើងថា The Blank Slate **ភីងឃើ** បង្ហាញឱ្យឃើញថា ការទទួលស្គាល់ថាមានសារជាតុខាងក្នុងរបស់មនុស្សមិនបានកាត់បន្ថយនូវតម្លៃ ដូចជាការផ្តល់លទ្ធភាពស្មើៗគ្នា សេរីភាពនិងយុត្តិធម៌ តែថែមទាំងពង្រឹងបញ្ញត្តិទាំងនេះថែមទៀត ដោយសារតែវាកាត់បន្ថយនូវវិបត្តិសង្គម និងវិបត្តិផ្សេងៗទៀត។ ដោយសារតែសារជាតិរបស់មនុស្សនេះ គេអាចនិយាយបានពីតម្លៃសាកល សម្រាប់មនុស្សជាតិទាំងមូល។ ការបដិសេធនូវការខិតខំរបស់មនុស្ស ឆ្ពោះទៅរកស្វ័យភាព ការសំដែងមតិ យុត្តិធម៌ និងវិបុលភាពជាដើម នឹងនាំឱ្យមានការប្រកាន់ពូជសាសន៍ និងរបបនយោបាយផ្តាច់ការ។ សមាហរណកម្មវប្បធម៌ នាំឱ្យបុគ្គលនីមួយៗមានសីលធម៌កាន់តែខ្លាំងឡើងៗ ដែលរាលដាលមិនត្រឹមតែដល់មជ្ឈដ្ឋានជុំវិញទេ តែដល់មនុស្សឯទៀតដែលរស់នៅលើគពផែនដី។ ដូច្នេះ ទស្សនវិជ្ជាអាចជួយដល់ដំណើរការទាំងនេះបាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ទស្សនវិជ្ជាលទ្ធផលនិយម

## អាផែល

(១៩២២-២០១៧)

**អាផែល** *(Karl-Otto Apel)»* (១៩២២-២០១៧) គឺជាទស្សនវិទូអាឡឺម៉ង់ និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Frankfurt។ លោកបានបង្កើតនូវចរន្តទស្សនវិជ្ជាផ្សេងមួយ ដែលមានឈ្មោះថា ឧត្តមភាពលទ្ធផលនិយម(transcendental pragmatics)។ បន្ទោះឆ្នាំ ១៩៤៥ និង ១៩៥០ **អាផែល** រៀននៅសាកលវិទ្យាល័យ Bonn ដោយជ្រើសរើសឯកទេសប្រវត្តិសាស្ត្រ តែបន្ទាប់មកបានសិក្សាទស្សនវិជ្ជា។ ក្នុងឆ្នាំ ១៩៥០ លោកទទួលសញ្ញាបត្រថ្នាក់បណ្ឌិត ដោយការពារនិក្ខេបបទស្តីពី **ហៃឌឺហ្គ័រ** (Heidegger)។

**ស្នាដៃសំខាន់ ៖ អាផែល** សរសេរពីចរិយាសាស្ត្រ ទស្សនវិជ្ជាភាសា និងវិទ្យាសាស្ត្រមនុស្សសាស្ត្រ។ ស្នាដៃរបស់លោកមាន ៖ *Analytic Philosophy of Language and the Geisteswissenschaften (1967), Towards a Transformation of Philosophy (1980 & 1998), Understanding and Explanation: A Transcendental-Pragmatic Perspective (1984), Ethics and the Theory of Rationality: Selected Essays (1996)*។

**ទស្សនវិជ្ជាសញ្ញាប្រកបដោយឧត្តមភាព ៖ អាផែល** ដាក់ចេញនូវគោលដៅដើម្បីបង្កើតឡើងនូវប្រព័ន្ធទស្សនវិជ្ជាថ្មី ដោយធ្វើការកែប្រែមុខមាត់(transformation)នូវទស្សនវិជ្ជារបស់**កង់ត៍** ហើយបង្កើតឡើងនូវ**ទស្សនវិជ្ជាសញ្ញាប្រកបដោយឧត្តមភាព** (Transcendental Semiotics) ដែលគ្របដណ្តប់ទស្សនវិជ្ជាភាសា និងសញ្ញាដទៃទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោកចាប់ផ្តើមពីការពិភាក្សានូវនិក្ខេបបទរបស់ Charles Sanders Peirce (១៨៣៩-១៩១៤) ដែលលើកឡើងថា តួនាទីនៃសញ្ញា(semiosis) គឺជាការបង្ហាញនូវទំនាក់ទំនងត្រីភាគី ពោលគឺសញ្ញា ឬតំណាង មានន័យសម្រាប់នរណាម្នាក់ ដើម្បីសម្គាល់អ្វីមួយ។ និយមន័យនេះគឺជាមូលដ្ឋាននៃអត្ថន័យរវាងសញ្ញា និងកម្មវត្ថុរបស់វា និងទំនាក់ទំនងរវាងសញ្ញានិងអ្នកបកប្រែសញ្ញានេះក្នុងក្របខណ្ឌនៃប្រព័ន្ធសញ្ញា ឬភាសា។ ក្នុងន័យនេះ សញ្ញាបង្ហាញនូវអត្ថន័យរបស់វា។

ដើម្បីយល់ពីសញ្ញា មនុស្សត្រូវព្រមព្រៀងគ្នាជាមុនពីអត្ថន័យរបស់វា។ គេអាចព្រមព្រៀងគ្នាពីអត្ថន័យរបស់សញ្ញា ដោយប្រើប្រាស់សញ្ញាផ្សេងទៀត ដែលគេត្រូវព្រមព្រៀងគ្នាពីអត្ថន័យនៃសញ្ញាផ្សេងទៀតនេះ។ ចលនានៃការពន្យល់អត្ថន័យនៃសញ្ញា ដោយប្រើសញ្ញាផ្សេងទៀតមកជំនួសនេះនឹងនាំឱ្យគេអាចកាន់តែយល់គ្នាបានល្អប្រសើរ។ ការបកស្រាយសញ្ញា ដោយមានការព្រមព្រៀងគ្នា និងមានការឯកភាពគ្នានេះ មានន័យថា គេសម្រេចបាននូវការយល់គ្នាយ៉ាងពេញលេញ តាមរយៈការប្រើប្រាស់សញ្ញាដែលគេអាចហៅបានថា ៖ «សហគមន៍ប្រាស្រ័យទាក់ទងប្រកបដោយឧត្តមគតិ(Ideal communication community)»។ មនោនិយមមានន័យថា គេអាចសម្រេចបាននូវសហគមន៍នេះ តាមរយៈដំណើរការប្រាស្រ័យទាក់ទង ដោយគ្មានទីបញ្ចប់ ហើយនៅក្នុងសហគមន៍នេះ សញ្ញានិងមនុស្សទាំងអស់អាចយល់គ្នាបានទាំងស្រុង តាមរយៈការបកស្រាយសញ្ញាដោយមានការឯកភាពគ្នាទាំងស្រុង។

**«សហគមន៍ប្រាស្រ័យប្រកបដោយឧត្តមគតិ» ៖ អាប៉ែល** ប្រើនូវទស្សនាទានខាងលើ ដើម្បីយកទៅធ្វើកំណែទម្រង់នៃទស្សនវិជ្ជាឧត្តមភាព(philosophie transcendentale)របស់**កង់** ដោយផ្លាស់ប្តូរបញ្ញត្តិរបស់**កង់**ស្តីពីវត្ថុក្នុងខ្លួន(chose en soi) និងឯកភាពក្នុងឧត្តមភាពនៃទំនួលអារម្មណ៍(unité transcendentale de l'apperception)ដែលជាការធានានូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការឯកភាពនៃពិសោធន៍។ **អារ៉ែល** ចាប់ផ្តើមផ្លាស់ប្តូរបញ្ញត្តិ «ឧត្តមភាពទំនួលអារម្មណ៍» ដោយទស្សនាទានស្តីពី«**សហគមន៍ប្រាស្រ័យទាក់ទងប្រកបដោយឧត្តមគតិ**» ដោយសារតែទស្សនាទាននេះធានានូវឯកភាពនៃពិសោធន៍ តាមរយៈការបកស្រាយសញ្ញាដោយឯកភាពគ្នា។ ចំណែកឯបញ្ញត្តិ «វត្ថុក្នុងខ្លួន» ក៏គេអាចដូរបានដែរ។ នៅក្នុង«សហគមន៍ប្រាស្រ័យទាក់ទងប្រកបដោយឧត្តមគតិប្រកបដោយឧត្តមគតិ» សញ្ញាលែងលាក់បាំងតថភាពទៀតហើយ។ ផ្ទុយទៅវិញ សញ្ញាបង្ហាញពីតថភាពនេះ។ «វត្ថុក្នុងខ្លួន» គឺជាតថភាពជាក់ស្តែង ដោយមិនចំណុះឱ្យបុគ្គលិកលក្ខណៈជាសត្យានុម័តនៃបុគ្គលដែលសិក្សាពីវា។ នៅក្នុង«សហគមន៍ប្រាស្រ័យទាក់ទងប្រកបដោយឧត្តមគតិ» ទស្សនៈរបស់មនុស្សទៅលើតថភាពមិនពាក់ព័ន្ធទៅនឹងបុគ្គលិកលក្ខណៈជាសត្យានុម័តនៃបុគ្គលឡើយ។ នរណាក៏ដោយក៏មើលឃើញដូចៗគ្នា ពោលគឺគេមើលឃើញតថភាពដោយខ្លួនឯង។

ក្នុងន័យខាងលើនេះ នៅក្នុង«សហគមន៍ប្រាស្រ័យទាក់ទងប្រកបដោយឧត្តមគតិ» ត្រូវមានវត្ថុមុនពិសោធន៍(a priori)របស់ខ្លួន។ ដើម្បីរកវាឱ្យឃើញ គេត្រូវវិភាគលក្ខខណ្ឌ និងបុព្វបទនៃការប្រាស្រ័យទាក់ទង។ ឧបមាថាយើងមានបំណងធ្វើប្រាស្រ័យទាក់ទង។ ប្រការនេះមានន័យថាយើងមានបំណងឱ្យមានការយល់គ្នា។ ពីដំបូង គ្មានការយល់គ្នាឡើយ។ តែបន្ទាប់ពីបានបញ្ជាក់ពីដំហររឿងខ្លួន តាមរយៈនិក្ខេបបទ ការផ្តល់ទឡ្ហីករណ៍ ការពិនិត្យសំណើ គេក៏ចាប់ផ្តើមយល់ពីគ្នា ដោយបដិសេធសំណើមិនត្រឹមត្រូវ និងទទួលយកសំណើដែលត្រឹមត្រូវ។ ដូច្នេះ ចំណុចចាប់ផ្តើមក្នុងការធ្វើគមនាគមន៍ គឺការតម្រង់អ្នកចូលរួម ឱ្យចូលក្នុងការប្រើប្រាស់ដូចគ្នានូវវិចារណញ្ញាណ។

**ចរិយាធម៌ ៖** ការយល់ដឹងពីលក្ខខណ្ឌដំបូងនៃការប្រាស្រ័យទាក់ទងអនុញ្ញាតឱ្យគេចងស្ពានមេត្រីរវាងវិស័យផ្សេងៗដែលពីពេលមុនស្ថិតនៅដាច់ពីគ្នា ដូចជាភាពខុសគ្នារវាង «ភាពចាំបាច់និងខ្លឹមសារ» រវាងវិទ្យា

សាស្ត្រពីធម្មជាតិ(science naturelle) និងវិទ្យាសាស្ត្រពីអាត្ម័ន(science de l'esprit)ជាដើម។ «សហគមន៍ប្រាស្រ័យទាក់ទងប្រកបដោយឧត្តមគតិ» មុនពិសោធន៍(a priori)អាចឱ្យគេឈានពីពុទ្ធិឆ្ពោះទៅរកចរិយាធម៌ តាមរយៈការប្រាស្រ័យទាក់ទង។ ការប្រាស្រ័យទាក់ទងអាចដំណើរការទៅបាន ទាល់តែគេប្រើប្រាស់ឱ្យឯកភាពគ្នានូវស្មារតី(mind)។ ប្រសិនបើមនុស្សចង់ប្រាស្រ័យទាក់ទង គេត្រូវតែប្រើប្រាស់នូវស្មារតីខ្លួនឱ្យឯកភាពគ្នា ពោលគឺត្រូវតែគួរឱ្យទុកចិត្តបាន និងមិនត្រូវរើសអើងជាមួយបុគ្គលផ្សេងទៀតឡើយ។ ទាំងនេះគឺជាការទាមទារនៃចរិយាធម៌។ ការមិនរើសអើងជាមួយបុគ្គលផ្សេងទៀតមានន័យថា ត្រូវទទួលស្គាល់ថា អ្នកផ្សេងទៀតក៏មានសិទ្ធិក្នុងការបំពេញសេចក្តីត្រូវការរបស់ពួកគេ ដូចខ្ញុំដែរ។ ដូច្នេះ ខ្ញុំមិនត្រឹមតែជួយឱ្យគេអាចបំពេញតាមសេចក្តីត្រូវការនេះប៉ុណ្ណោះទេ ថែមទាំងត្រូវការពារឱ្យគេអាចបំពេញសេចក្តីត្រូវការថែមទៀត។ ក៏ប៉ុន្តែ ជាក់ស្តែងជីវិតប្រចាំថ្ងៃមិនមែនដូចអ្វីដែលយើងចង់បានឡើយ ពោលគឺយើងត្រូវរស់នៅក្នុង «សហគមន៍ប្រាស្រ័យទាក់ទងជាក់ស្តែង»។

**សហគមន៍ប្រាស្រ័យទាក់ទងជាក់ស្តែង ៖** នៅក្នុង «សហគមន៍ប្រាស្រ័យទាក់ទងជាក់ស្តែង» មនុស្សរស់នៅមានខ្ពស់ មានទាប និងស្ថិតនៅក្នុងស្ថានភាពវប្បធម៌ខុសៗគ្នា។ ឧទាហរណ៍ មនុស្សរស់នៅក្នុងវណ្ណៈនិងស្រទាប់សង្គមខុសៗគ្នា។ ដូច្នេះ ពួកគេមានសិទ្ធិផ្សេងៗគ្នា អាចធ្វើអំពើខុសៗគ្នា មិនដូចការរស់នៅក្នុង«សហគមន៍ប្រាស្រ័យទាក់ទងមនោនិយម» ឡើយ។ ប្រការនេះមានបច្ច័យដូចតទៅ ៖ (១) ដូច្នេះគេមិនអាចតម្រូវឱ្យបុគ្គលទាំងនោះមានកាតព្វកិច្ចខាងផ្នែកចរិយាធម៌ដូចៗគ្នាឡើយ (២) ចាំបាច់ត្រូវបង្កើត «ចរិយាធម៌ពិភាក្សា» ៖ ពោលគឺត្រូវមានការទាមទាររួមខាងផ្នែកចរិយាធម៌ចំពោះសមាជិកសហគមន៍ទាំងអស់ តែត្រូវគិតគូរផងដែរពីលក្ខខណ្ឌពិសេសរបស់បុគ្គលម្នាក់ៗ។ «ចរិយាធម៌ពិភាក្សា» មិនអាចបង្ហាញផ្លូវដើរសម្រាប់គ្រប់ស្ថានភាពបានឡើយ តែត្រូវមានដំណោះស្រាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះស្ថានភាពដែល «គ្មានការពិភាក្សា» ឬស្ថានភាពអត្តិភាពនិយម នៅពេលដែលមនុស្សត្រូវសម្រេចចិត្តខាងផ្នែកចរិយាធម៌ក្នុងស្ថានភាពពិសេសដោយសារតែលក្ខខណ្ឌពិសេស។ ក្នុងស្ថានភាពនេះ គេត្រូវពិចារណាផងដែរពីការទិតៀនពី «សហគមន៍ប្រាស្រ័យទាក់ទង»។ ដូច្នេះ យើងអាចធ្វើសេចក្ដីសន្និដ្ឋានពីភាពខុសគ្នារវាង «សហគមន៍ប្រាស្រ័យទាក់ទងប្រកបដោយឧត្តមគតិ» និង«សហគមន៍ប្រាស្រ័យទាក់ទងជាក់ស្ដែង» ៖ នៅក្នុងជីវិតជាក់ស្ដែង គេត្រូវគោរពតាមគោលការណ៍ធ្វើការទាមទារឱ្យស្មើៗគ្នាចំពោះមនុស្សទាំងអស់។ ទោះបីជាមានវិសមភាពជាក់ស្ដែងក៏ដោយ ក៏យើងត្រូវខិតខំយ៉ាងណា ដើម្បីសម្រេចឱ្យបាននូវសមភាពជាក់ស្ដែង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ហាបឺរម៉ាស
## (១៩២៩)

**ហាបឺរម៉ាស** *(Jürgen Habermas)* កើតនៅ Düsseldorf ប្រទេសអាឡឺម៉ង់ក្នុងឆ្នាំ ១៩២៩។ តុលាការនៃទីក្រុង Nuremberg បានក្លាយជាសក្ខីកម្មដែលបង្ហាញពីបរាជ័យខាងផ្នែកសីលធម៌ និងនយោបាយរបស់ប្រទេសអាឡឺម៉ង់ក្នុងរបបសង្គមនិយមជាតិនិយម។ នៅពេលដែលនៅជានិស្សិត លោកបានចាប់អារម្មណ៍លើទស្សនវិជ្ជាអត្ថិភាពនិយមរបស់ Heidegger។ **ហាបឺរម៉ាស** ត្រូវបានគេចាត់ទុកថាស្ថិតនៅក្នុងចំណោមទស្សនវិទូដែលមានឥទ្ធិពលជាងគេក្នុងពិភពលោក។ ទស្សនវិទូ**ហាបឺរម៉ាស**បញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតនៅក្នុងឆ្នាំ ១៩៥៤ នៅសកលវិទ្យាល័យ Bonnដោយសរសេរពីទំនាស់រវាងបញ្ញត្តិដាច់ខាត និងប្រវត្តិសាស្ត្រនៅក្នុងទស្សនៈរបស់ Schelling។ លោកចាប់ផ្តើមល្បីល្បាញបន្ទាប់ពីបានបោះពុម្ពផ្សាយស្នាដៃទីមួយនៅក្នុងឆ្នាំ ១៩៦២ ក្រោមចំណងជើងថា ៖ «Structural Transformation of the Public Sphere» (English ed., 1989) ដែលរៀបរាប់ពីប្រវត្តិសាស្ត្រនៃវិស័យសាធារណៈវណ្ណៈអភិជនចាប់ពីដើមកំណើតនៃការបង្កើតសាឡុង នៅក្នុងសតវត្សរ៍ទី១៨ រហូតដល់ការប្រែក្លាយវាក្រោមឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយ។

**ស្នាដៃសំខាន់** ៖ ស្នាដៃសំខាន់របស់**ហាបឺរម៉ាស** អាចចែកចេញជាពីរផ្នែក ៖ (១) បញ្ហានយោបាយ និង(២) បញ្ហាវិចារណញ្ញាណ គមនាគមន៍ និងពុទ្ធិ។ ស្នាដៃសំខាន់របស់លោកគឺ ៖ «**ការផ្លាស់ប្តូររចនាសម្ព័ន្ធនៃសហគមន៍**» (១៩៦២) «**ទ្រឹស្តីសកម្មភាពច្រាស្រ័យទាក់ទង**» (១៩៨១)។

លក្ខណៈពិសេសនៃទស្សនវិជ្ជារបស់**ហាបឺរម៉ាស** គឺលោកខិតខំធ្វើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សំយោគគំនិតផ្សេងៗគ្នា។ ក្នុងន័យនេះ លោកមានទស្សនៈស្រដៀងនឹងទស្សនវិទូ **គីឌិនស៍** ដែរ ដែលជាតំណាងនៃចរន្តគំនិតសំយោគថ្មីៗ។ គំនិតរបស់លោកមានឥទ្ធិពលទៅលើមិនត្រឹមតែទស្សនវិជ្ជាទេ តែក៏មានឥទ្ធិពលលើគំនិតនយោបាយ ច្បាប់ សង្គមវិជ្ជា ការប្រាស្រ័យទាក់ទង វោហាសាស្ត្រ ចិត្តវិទ្យា និងសាសនាវិជ្ជាផងដែរ។ ទ្រឹស្ដីរបស់**ហាបឺរម៉ាស** មានគោលដៅបង្កើតប្រព័ន្ធទស្សនវិជ្ជា «សកម្មភាពប្រាស្រ័យទាក់ទង» ឬដែលពីមុនលោកហៅថា «សហគមន៍» ឬ«សាធារណៈ»។ ទស្សនវិជ្ជានេះក៏ជាប្រធានបទនៃលទ្ធិម៉ាក្សនិយមដែរ ហើយទន្ទឹមនឹងនេះ គេអាចឃើញនូវទស្សនវិជ្ជារបស់**កង់ត៍** និងទស្សនវិជ្ជាវិភាគលាយឡំផងដែរ។ គំនិតស្ដីពីគមនាគមន៍របស់ **ហាបឺរម៉ាស** ទទួលឥទ្ធិពលពី **អារ៉ែល** ដែលជាទស្សនវិទូដ៏ធំមួយនាចុងសតវត្សរ៍ទី២០ និងដើមសតវត្សរ៍ទី២១។

**ទ្រឹស្ដីស្ដីពីសកម្មភាពប្រាស្រ័យទាក់ទង** (The Theory of Communicative Action) ៖ លោក**ហាបឺរម៉ាស**យល់ថាទស្សនវិទូត្រូវសហការជាមួយអ្នកវិទ្យាសាស្ត្រសង្គម ក្នុងបរិបទនៃសង្គមសម័យទំនើប ដែលមានសមាហរណកម្មនៃប្រព័ន្ធសង្គមជាច្រើន។ **ហាបឺរម៉ាស** ធ្វើការវិភាគពីទ្រឹស្ដីសម្ភារនិយមប្រវត្តិសាស្ត្ររបស់ម៉ាក្ស និងទ្រឹស្ដីម៉ាក្រូសង្គម និងប្រវត្តិសាស្ត្រធំៗ ដែលជាទ្រឹស្ដីចម្បងៗដែលមានគោលដៅពន្យល់ពីវិទ្យាសាស្ត្រសង្គម។ ក៏ប៉ុន្តែ ទ្រឹស្ដីទាំងនេះមានចំណុចខ្វះខាតពីយ៉ាងគឺ ៖ (១) គេមិនអាចពន្យល់ឱ្យបានក្បោះក្បាយ និងបរិបូណ៌នូវទ្រឹស្ដីដែលមានលក្ខណៈពេលលេញបានឡើយ (២) បើគេពិនិត្យការបកស្រាយវិញ ទ្រឹស្ដីមនោគមវិជ្ជាបង្ហាញថាការពន្យល់ទាំងនេះត្រូវពឹងផ្អែកលើទ្រឹស្ដីសង្គមជាច្រើនទៀត។

**ហាបឺរម៉ាស** ធ្វើការទិតៀនសង្គមទំនើប ដោយពន្យល់ពីទំនាក់ទំនងរវាងទ្រឹស្ដីពីដែលផ្សេងគ្នា ៖ ទ្រឹស្ដីមីក្រូស្ដីពីវិចារណញ្ញាណដែលឈរលើមូលដ្ឋាននៃការសម្របសម្រួលខាងផ្នែកប្រាស្រ័យទាក់ទង និងទ្រឹស្ដី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ម៉ាក្រូស្តីពីសមាហរណកម្មជាប្រព័ន្ធនៃសង្គមសម័យទំនើប តាមរយៈយន្តការផ្សេងៗដូចជាទីផ្សារជាដើម។ ប្រការនេះមានន័យថា **ហាបើរម៉ាស** បង្កើតទ្រឹស្តីសង្គមដែលមានពីរជាន់ដែលមាន (១) ការវិភាគនៃវិចារណញ្ញាណខាងផ្នែកប្រាស្រ័យទាក់ទង សក្តានុពលវិចារណញ្ញាណដែលមាននៅក្នុងការនិយាយប្រចាំថ្ងៃ និង (២) ទ្រឹស្តីនៃសង្គមទំនើប និងទំនើបភាវូបនីយកម្ម។ ដោយឈរលើមូលដ្ឋាននៃទ្រឹស្តីនេះ **ហាបើរម៉ាស** សង្ឃឹមថាគាត់អាចវាយតម្លៃពីចំណុចវិជ្ជមាន និងចំណុចខ្វះខាតនៃទំនើបភាវូប-នីយកម្ម និងអាចជៀសផុតពីទ្រឹស្តីមិនគ្រប់ជ្រុងជ្រោយនៃវិចារណញ្ញាណនិយម។

**ហាបើរម៉ាស** យល់ថា ភាសាគឺជាមធ្យោបាយមួយដ៏សំខាន់ ក្នុងការសម្របសម្រួលសកម្មភាព។ រូបភាពដ៏សំខាន់ក្នុងការសម្របសម្រួលដោយប្រើភាសាទាមទារឱ្យអ្នកនិយាយប្រកាន់យកជំហរជាក់ស្តែងនិយមដែលមានគោលដៅសម្រេចបាននូវការយល់គ្នា ដែលជាគោលដៅនៃការនិយាយ។ នៅពេលដែលគូសន្ទនានិយាយទៅគ្នាទៅវិញទៅមក ដោយប្រកាន់យកអាកប្បកិរិយានេះ ពួកគេចូលរួមក្នុងអ្វីដែលលោក**ហាបើរម៉ាស**ហៅថា «សកម្មភាពប្រាស្រ័យទាក់ទង» ដែលមានលក្ខណៈខុសពីទម្រង់យុទ្ធសាស្ត្រនៃសកម្មភាពសង្គម។ នៅក្នុងសកម្មភាពយុទ្ធសាស្ត្រ គូសន្ទនាមិនចាប់អារម្មណ៍ខ្លាំងទៅលើការយល់គ្នាទៅវិញទៅមកទេ ដោយពួកគេមានបំណងសម្រេចបាននូវគោលដៅផ្ទាល់ខ្លួនរបស់ពួកគេ។ គូសន្ទនា **ក** ឆ្លើយតបទៅនឹងបំណង និងការភិតភ័យរបស់ គូសន្ទនា **ខ** ក្នុងគោលដៅមានឥទ្ធិពលលើអាកប្បកិរិយារបស់ **ខ** យ៉ាងដូចម្តេច ដើម្បីធានាឱ្យបានជោគជ័យសម្រាប់ **ក**។ ដើម្បីធានានូវសហប្រតិបត្តិការពី **ខ** ចំណង់ចំណូលចិត្ត និងការភិតភ័យរបស់ **ខ** ត្រូវឆ្លើយតបទៅនឹងគោលដៅរបស់ **ក** ប៉ុណ្ណោះ។ **ខ** សហការជាមួយ **ក** មិនមែនដោយសារតែ **ខ** យល់ឃើញថាគម្រោងរបស់ **ក** គួរឱ្យចាប់អារម្មណ៍ ឬល្អ តែដោយសារតែ **ខ** គ្មានជម្រើស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ល្អជាងនេះ ៖ ដោយត្រូវជៀសវាងនូវការគម្រាមកំហែងរបស់ **ក** ឬទទួលយកអ្វីជាសំណាងពី **ក**។

ផ្ទុយទៅវិញ នៅក្នុង «សកម្មភាពប្រាស្រ័យទាក់ទង» វិញ គូសន្ទនាសម្របសម្រួលសកម្មភាពរបស់គេ និងខិតខំសម្រេចនូវគោលដៅផ្ទាល់ខ្លួនដោយឈរលើមូលដ្ឋាននៃការយល់គ្នាទៅវិញទៅមកថា គោលដៅរបស់ពួកគេមានហេតុផល និងមានប្រយោជន៍សម្រាប់ទាំងអស់គ្នា។ ដូច្នេះ នៅក្នុង «សកម្មភាពប្រាស្រ័យទាក់ទង» គូសន្ទនាសម្រេចបាននូវគោលដៅរៀងៗខ្លួន ដោយសារតែពួកគេឯកភាពគ្នាដោយសេរីថា គោលដៅរួមរបស់ពួកគេមានហេតុផល និងសមស្របទៅនឹងអាកប្បកិរិយាសហប្រតិបត្តិការ។ ដូច្នេះ សកម្មភាពប្រាស្រ័យទាក់ទង គឺជាទម្រង់កុងសង់ស៊ុសនៃការសម្របសម្រួលសង្គម ដែលក្នុងនោះតួអង្គកៀរគរសក្តានុពលដើម្បីវិចារណញ្ញាណដោយប្រើប្រាស់ភាសាយ៉ាងសាមញ្ញ។

ដើម្បីគាំទ្រទស្សនាទាននៃសកម្មភាពប្រាស្រ័យទាក់ទង **ហាបឺរម៉ាស** បង្កើតយន្តការ ក្នុងការបង្កើតកិច្ចព្រមព្រៀងប្រកបដោយវិចារណញ្ញាណដោយប្រើទ្រឹស្តីអត្ថន័យ។ ដោយអនុលោមតាមទ្រឹស្តីរបស់គាត់ «យើងយល់ពីសម្តី(speech acts)នៅពេលដែលយើងដឹងពីមូលហេតុរបស់អ្នកនិយាយដើម្បីបញ្ចុះបញ្ចូលអ្នកស្តាប់ ថាគាត់មានសិទ្ធិក្នុងលក្ខខណ្ឌនេះ ថាតើត្រូវធ្វើដូចម្តេចដើម្បីឱ្យគេទទួលយកសម្តីនេះបាន។ ដូច្នេះ **ហាបឺរម៉ាស**ភ្ជាប់អត្ថន័យនៃសម្តី ទៅនឹងការផ្តល់មូលហេតុ ៖ សម្តីគឺត្រូវផ្តល់នូវមូលហេតុនៃការនិយាយ ដែលបើកឱ្យមានការរិះគន់ និងបញ្ជាក់ពីមូលហេតុ គាំទ្រសម្តីនេះ។ នៅក្នុងការនិយាយជារៀងរាល់ថ្ងៃ អ្នកនិយាយព្រមព្រៀងប្រកបដោយតុណ្ហីភាព ដើម្បីពន្យល់ និងផ្តល់ហេតុផលគាំទ្រសម្តីនេះ។ ដើម្បីយល់ថាតើត្រូវនិយាយយ៉ាងដូចម្តេច គេត្រូវដឹងពីចម្លើយដែលផ្តល់ហេតុផលសមស្របដើម្បីគាំទ្រសម្តីនេះ។ សម្តីអាចទទួលបានជោគជ័យ ក្នុងការធានានូវការយោគយល់គ្នា នៅពេលដែលអ្នកស្តាប់ប្រកាន់យកជំហរវិជ្ជមាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីឆ្លើយទៅនឹងជំហរដែលអ្នកនិយាយបានលើកឡើង។ ដូច្នេះ អ្នកស្ដាប់សន្និដ្ឋានថាអំណះអំណាងក្នុងសម្ដី អាចគាំទ្រដោយមូលហេតុត្រឹមត្រូវ។ នៅពេលដែលសំណើរបស់អ្នកនិយាយមិនបានការ នោះអ្នកនិយាយ និងអ្នកស្ដាប់អាចផ្លាស់ប្ដូរកម្រិតនៃការពិចារណា ពីសម្ដីធម្មតា ទៅកម្រិត «សុន្ទរកថា» ដែលមានអំណះអំណាង និងការសន្ទនា ដែលក្នុងនោះអំណះអំណាងនៅក្នុងសម្ដីនឹងត្រូវផ្ទៀងផ្ទាត់ថាពិត ត្រឹមត្រូវ ឬដូចដើម (authentique)។ ដូច្នេះ វិចារណញ្ញាណនៃសកម្មភាពប្រាស្រ័យទាក់ទងត្រូវភ្ជាប់ទៅនឹងវិចារណញ្ញាណនៃសុន្ទរកថា។

# ទស្សនវិជ្ជាចរិយាធម៌និយម

## ស៊ីងហ្គ័រ

(១៩៤៦)

**ភីធើ ស៊ីងហ្គ័រ** *(Peter Singer) កើតនៅម៉ែលប៊ិន ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៤៦។ ឪពុកម្ដាយលោកភៀសខ្លួនមកពីទីក្រុងវីយែន ប្រទេសអូទ្រីស ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៣០ ដើម្បីគេចពីពួកណាហ្ស៊ី។ លោករៀននៅសាសកលវិទ្យាល័យ Melbourne ដោយទទួលបានបរិញ្ញាបត្រខាងផ្នែកនីតិសាស្ត្រ ប្រវត្តិសាស្ត្រ និងទស្សនវិជ្ជានៅក្នុងឆ្នាំ១៩៤៦ និងបរិញ្ញាបត្រជាន់ខ្ពស់ក្នុងឆ្នាំ១៩៦៩។ បន្ទាប់មកបានបន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ Oxford ក្នុងឆ្នាំ១៩៧១។ ក្នុងឆ្នាំ១៩៧៧ លោកត្រូវបានតែងតាំងជាប្រធានដេប៉ាតឺម៉ង់ទស្សនវិជ្ជា នៅសាកលវិទ្យាល័យ ហើយបន្ទាប់មកត្រូវបានតែងតាំងជាប្រធានមជ្ឈមណ្ឌលជីវចរិយាសាស្ត្រមនុស្ស។*

**ស្នាដៃសំខាន់** ៖ *ស្នាដៃសំខាន់របស់* **ស៊ីងហ្គ័រ** *គឺនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោកក្រោមចំណងជើងថា «Democracy and Disobedience» ដែលបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៧៣។ ក្នុងឆ្នាំ ២០០០ លោកបោះពុម្ពផ្សាយ «សំណេរស្ដីពីចរិយាសាស្ត្រ»ដែលបានលើកឡើងពីស្នាដៃដែលលោកបានបោះពុម្ពផ្សាយមុនៗ ដូចជា* «**ការរំដោះសត្វ**» (១៩៧៥) «**ចរិយាសាស្ត្រជាក់ស្ដែង**» (១៩៧៥) «**តើយើងត្រូវរស់នៅដូចម្ដេច**» (១៩៩៣)។

*ស្នាដៃរបស់លោក* **ស៊ីងហ្គ័រ** *បានលើកឡើងពីភាពចាំបាច់ក្នុងការធ្វើកំណែទម្រង់ចរិយាធម៌បុរាណនិយម និងការពិនិត្យឡើងវិញនូវប្រព័ន្ធតម្លៃ។ ស្នាដៃទាំងនេះបានធ្វើឱ្យមានការទិតៀនពាក់ព័ន្ធនឹងរឿងចម្រូងចម្រាស់ ដូចជាការរំលោភសិទ្ធិរបស់សត្វ ការរួមសង្វាសរវាងមនុស្សនិងសត្វ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការសម្លាប់ក្មេងពិការ ការរំលូតកូន ដោយសារបញ្ហាចរិយាធម៌ជាដើម។ ស្នាដៃរបស់លោកខ្លះត្រូវបានហាមឃាត់នៅក្នុងសាកលវិទ្យាល័យអាឡឺម៉ង់។ នៅពេលដែលត្រូវបានតែងតាំងជាសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យ Princeton សហគមន៍ទីនោះបានធ្វើការប្រឆាំងតវ៉ាចំពោះការតែងតាំងរូបលោក។ តែនៅឆ្នាំ ១៩៩៩ លោកនៅតែត្រូវបានតែងតាំងជាសាស្ត្រាចារ្យនៅ Princeton។

**ទស្សនវិទូជាជំនាញការ** ៖ លោក **ស៊ីងហ្គ័រ** បានស្នើសុំធ្វើ «បដិវត្តន៍»ខាងផ្នែកចរិយាធម៌ ដោយកម្ទេចចោលនូវមូលដ្ឋាននៃចរិយាធម៌ចាស់ និងបង្កើតឡើងនូវក្រមចរិយាធម៌ថ្មី។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ លោកបានសរសេរថា ទស្សនវិជ្ជាសីលធម៌មិនត្រូវធ្វើការវិភាគត្រឹមតែទស្សនាទានចរិយាធម៌ដែលមានស្រាប់ឡើយ។ ទស្សនវិទូអាចក្លាយជាអ្នកឯកទេសខាងផ្នែកបញ្ហាសីលធម៌ និងកំណត់និយាមសីលធម៌ ពោលគឺកំណត់អ្វីជាអំពើល្អ និងអ្វីជាអំពើអាក្រក់។ លោកយល់ឃើញថា ក្រមសីលធម៌ចាស់មិនឆ្លុះបញ្ចាំងតថភាពសង្គមដែលចេះតែវិវត្តទៅមុខ។ ទោះបីជាយើងទទួលស្គាល់ថាក្រមសីលធម៌ចាស់នៅមានន័យ តែឥទ្ធិពលរបស់វាលើឆន្ទៈមនុស្សត្រូវឆ្លងកាត់ការត្រិះរិះពិចារណាថា តើបុគ្គលម្នាក់ៗត្រូវប្រកាន់ជំហរអ្វីមួយចំពោះមុខស្ថានភាពជាក់ស្តែង។ ការត្រិះរិះពិចារណាគឺជាសកម្មភាពដែលទាមទារឱ្យមានទម្លាប់។ ម្យ៉ាងវិញទៀត ការត្រិះរិះពិចារណានេះត្រូវការនូវព័ត៌មានពេញលេញពីស្ថានភាពជាក់ស្តែងទាំងនោះ។ ដូច្នេះ គេត្រូវចេះប្រមូលព័ត៌មាន និងវិភាគព័ត៌មានទាំងនេះ ប្រកបដោយប្រសិទ្ធភាព។ ដោយសារតែគ្មាននរណាម្នាក់អាចធ្វើការងារទាំងនេះបាន មានតែទស្សនវិទូទេដែលត្រូវគិតគូរពីបញ្ហាចរិយាធម៌។

**ធម្មជាតិនៃចរិយាធម៌** ៖ មុននឹងដោះស្រាយបញ្ហាជាក់ស្តែង គេត្រូវកំណត់ពីធម្មជាតិនៃចរិយាធម៌សិន។ ស្ថានភាពចរិយាធម៌កើតមានឡើង នៅពេលដែលគេត្រូវធ្វើការជ្រើសរើសប្រកបដោយវិចារណញ្ញាណ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នូវសកម្មភាពអ្វីមួយ ឬរបៀបរបបរស់នៅអ្វីមួយ។ ពោលគឺជាការជ្រើសរើស រវាងស្ថានភាពពីរ។ ម្យ៉ាងវិញទៀត ការជ្រើសរើសអាចចាត់ទុកថាមាន សីលធម៌ ប្រសិនបើការជ្រើសរើសនេះមានគោលដៅធ្វើឱ្យសម្រេចបាន នូវផលប្រយោជន៍ខាងផ្នែកចរិយាធម៌របស់អ្នកដែលធ្វើការជ្រើសរើស។ ពោលគឺមិនមែនជាការធ្វើឱ្យសម្រេចនូវផលប្រយោជន៍របស់អ្នកផ្សេង។

ចំពោះ **ស៊ីចហ្គ័រ** បរិបទសីលធម៌ គឺជាបរិបទចរិយាធម៌ ដែលជា បរិបទដែលមានលក្ខណៈសាកល ដែលគេមិនអាចកំណត់នូវភាពខុសរវាង ផលប្រយោជន៍របស់ខ្លួនឯង និងផលប្រយោជន៍របស់អ្នកដទៃ។ ប្រការនេះ មានន័យថា បរិបទដែលមានចរិយាធម៌ គឺត្រូវគិតពីផលប្រយោជន៍អ្នកដទៃ ដូចជាគិតពីផលប្រយោជន៍របស់ខ្លួនឯង។ ដូច្នេះ មនុស្សដែលមានសីល ធម៌ គឺជាមនុស្សដែលជ្រើសរើសយកជីវិត ដែលគាត់ត្រូវខិតខំប្រឹងប្រែង សម្រេចឱ្យបានជាអតិបរមា មិនមែនតែផលប្រយោជន៍របស់ខ្លួនឯងទេ តែ ត្រូវគិតពីផលប្រយោជន៍អ្នកដទៃផងដែរ។ ដូច្នេះ អំពើប្រកបដោយចរិយា ធម៌ គឺជាអំពើដែលនាំទៅរកការសម្រេចបាននូវផលប្រយោជន៍របស់ទាំង អស់គ្នា។ ប្រការនេះមានន័យថា អំពើមួយជាអំពើសីលធម៌ត្រូវតែវាយតម្លៃ តាមរយៈលទ្ធផល និងផលវិបាករបស់វា។ **ស៊ីចហ្គ័រ** បានប្រកាសថា លោក គឺជាអ្នកគាំទ្រនូវទ្រឹស្តីនៃចរិយាធម៌ប្រយោជន៍និយម(Utilitarian ethics)។

**កម្មវិត្តនៃចរិយាធម៌** ៖ មនុស្សដែលមានសីលធម៌ គឺជាមនុស្ស ដែលខិតខំប្រឹងប្រែងសម្រេចឱ្យបានជាអតិបរមានូវផលប្រយោជន៍របស់ ទាំងអស់គ្នា។ ប្រយោជន៍ទាំងនេះខុសៗគ្នា តែផលប្រយោជន៍ជាមូលដ្ឋាន គឺបំណងកុំឱ្យមានទុក្ខវេទនា។ មនុស្សដែលមានសីលធម៌តែងតែខិតខំប្រឹង ប្រែងធ្វើយ៉ាងណា ដើម្បីកាត់បន្ថយទុក្ខលំបាករបស់អ្នកដទៃ។ តើអ្នកដទៃ នេះជានរណា? ទំនាក់ទំនងប្រកបដោយចរិយាធម៌ពាក់ព័ន្ធជាមួយគ្រប់ បុគ្គលទាំងអស់ ដែលអាចមានទុក្ខ។ បុគ្គលទាំងនេះមិនមែនសំដៅតែលើ មនុស្សឡើយ។ នេះគឺជាការទិតៀនដំបូងបំផុតចំពោះចរិយាធម៌ប្រពៃណី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលបែងចែករវាងមនុស្ស និងសត្វ។ **ស៊ីងហ្គ័រ** បានបង្ហាញថាការបែងចែកនេះមិនត្រឹមត្រូវទេ ដែលអាចចាត់ទុកថាជាការរើសអើង ដូចគ្នានឹងការប្រកាន់ពូជសាសន៍ផងដែរ។

មនុស្សមិនត្រូវរើសអើងចំពោះសត្វ ដែលជាវត្ថុមានជីវិតដូចមនុស្សដែរ។ អំពើដែលនាំឱ្យធ្វើទុក្ខបុកម្នេញដល់សត្វ ដូចជាយកសត្វទៅធ្វើការពិសោធវិទ្យាសាស្ត្រ ឬចិញ្ចឹមសត្វនៅក្នុងទ្រុង ត្រូវចាត់ទុកថា ជាអំពើអសីលធម៌ ប្រសិនបើគេមិនអាចបង្ហាញថា អំពើទាំងនេះមិនសំដៅដល់ការសម្រេចបាននូវគោលដៅចម្បង ពោលគឺការរំដោះសត្វលោកឱ្យចាកផុតពីទុក្ខវេទនា។ **ស៊ីងហ្គ័រ** បានចាត់ទុកការប្រើប្រាស់សាច់សត្វជាចំណីអាហារ ថាជាអំពើអសីលធម៌។ តក្កវិជ្ជារបស់គាត់ គឺអំពើដែលអសីលធម៌គឺជាអំពើណាដែលនាំឱ្យមានទុក្ខវេទនាខ្លាំងជាងគេ បើប្រៀបធៀបទៅនឹងអំពើដែលផ្ទុយពីអំពើនេះ។ នាពេលបច្ចុប្បន្ននេះ គ្រប់គ្នាទទួលស្គាល់ថា ការមិនបរិភោគសាច់មិននាំឱ្យប៉ះពាល់ដល់សុខភាពមនុស្សឡើយ។ ផ្ទុយទៅវិញ ការបរិភោគសាច់សត្វនាំមកនូវទុក្ខវេទនាដល់ជីវិតសត្វ។ ដូច្នេះមនុស្សមានសីលធម៌សម័យទំនើបមិនត្រូវបរិភោគសាច់សត្វឡើយ ហើយត្រូវបរិភោគតែបន្លែប៉ុណ្ណោះ។

**បដិវត្តន៍ចរិយាធម៌** ៖ មនុស្សសម័យឥឡូវលែងមានទំនាក់ទំនងចរិយាធម៌ទៀតហើយ។កាលពីពេលមុនមនុស្សនៅបស្ចិមប្រទេសស្ថិតនៅចំកណ្ដាលនៃចរិយាធម៌ ដោយសារតែគ្រិស្តសាសនា។ ថ្វីត្បិតតែវិហារគ្រិស្តនៅតែមានប្រយោជន៍ តែទ្រឹស្ដីសាសនាមិនអាចបកស្រាយបាន ដោយប្រើវិចារណញ្ញាណបានឡើយ។ អ្នកជឿសាសនាគ្រិស្តបានសម្លាប់សត្វជាច្រើនលានក្បាល។ ដូច្នេះ សីលធម៌បែបប្រពៃណីដែលឈរលើមូលដ្ឋានសាសនាបាននាំមកនូវលទ្ធផលប្រកបដោយគ្រោះថ្នាក់។ សីលធម៌បែបនេះបានដាក់សីលធម៌ស្មើនឹងការហាមឃាត់ខាងផ្នែករួមភេទប៉ុណ្ណោះ។ នៅពេលដែលគេនិយាយពីសីលធម៌ធ្លាក់ចុះ នោះគេមិនដែលនិយាយពីមរណភាព

កុមារ ឬបញ្ហាសំខាន់ៗឯទៀតឡើយ។ គេនិយាយពីសីលធម៌ធ្លាក់ចុះដែលបណ្ដាលមកពីការចែកចាយយ៉ាងទូលំទូលាយនៃរូបអាសអាភាស ឬអ្នកស្រឡាញ់ភេទដូចគ្នាប៉ុណ្ណោះ។ បញ្ហាទាំងនេះ តាមពិតគ្មានសារៈសំខាន់ខាងផ្នែកចរិយាធម៌អ្វីទាំងអស់។

**ចរិយាធម៌អនុវត្ត** (Practical ethics) ៖ **សីងហ្គ័រ** បានទាត់ចោលនូវខ្លឹមសារនៃចរិយាធម៌បែបប្រពៃណី ៖ បញ្ហារួមភេទបានក្លាយជាបញ្ហាបន្ទាប់បន្សំនៃចរិយាធម៌។ ដូច្នេះ មនុស្សដែលជាកម្មវត្ថុនៃទំនាក់ទំនងចរិយាធម៌នេះ លែងមានបញ្ហាស្នូលនៃចរិយាធម៌ទៀតហើយ។ ប្រការនេះមានន័យថា សត្វក៏ត្រូវតែស្ថិតនៅជាស្នូលនៃចរិយាធម៌ ហើយម្យ៉ាងវិញទៀត ជីវិតមនុស្សលែងមានន័យទៀតហើយ។ មានតែបុគ្គលពេញលក្ខណៈ(personality)ទេដែលនៅមានចរិយាធម៌ ពោលគឺមនុស្សដែលមិនត្រឹមតែចេះឈឺចាប់ រីករាយប៉ុណ្ណោះទេ។ គេត្រូវស្គាល់ពីស្ថានភាពរបស់ខ្លួន អតីតកាល និងអនាគតកាលរបស់ខ្លួន។ ជាការពិត បុគ្គលពេញលក្ខណៈមានសិទ្ធិក្នុងការរស់នៅ ហើយគ្មាននរណាម្នាក់អាចដកហូតសិទ្ធិនេះបានឡើយ។ សត្វក៏ចេះឈឺចាប់ និងចេះសប្បាយរីករាយដែរ តែសត្វភាគច្រើនមិនមែនជាបុគ្គលពេញលក្ខណៈឡើយ។ ដូច្នេះហើយ ទើបគេអាចប្រើវានៅក្នុងពិសោធន៍វិទ្យាសាស្ត្រ ប្រសិនបើគេអាចកាត់បន្ថយនូវការឈឺចាប់របស់សត្វទាំងនោះបាន។ គេអាចប្រើប្រាស់បុគ្គលពេញលក្ខណៈក្នុងពិសោធន៍បាន លុះត្រាតែមានការយល់ព្រមពីសាមីខ្លួន។ ក្នុងករណីដែលមនុស្សឈឺព្យាបាលមិនជា ហើយសុំបញ្ចប់ជីវិតខ្លួនដោយប្រើក្បួនពេទ្យ(euthanasie) នោះសីលធម៌តម្រូវឱ្យធ្វើតាមសំណូមពររបស់អ្នកជំងឺ។

ក៏ប៉ុន្តែ បញ្ហាសំខាន់ គឺបើគិតតាមទស្សនវិស័យជីវសាស្ត្រវិញ មនុស្សទាំងអស់មិនមែនសុទ្ធតែបុគ្គលពេញលក្ខណៈឡើយ។ កូនដែលទើបតែកកើតនៅក្នុងផ្ទៃពោះ(embryon) មនុស្សដែលស្ថិតនៅក្នុងស្ថានភាពសន្លប់ឥតដឹងខ្លួន មិនមែនជាបុគ្គលពេញលក្ខណៈឡើយ (**សីងហ្គ័រ** ចាត់ទុកថា


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការរំលូតកូននៅក្នុងដំណាក់កាលដើមដំបូង មិនប៉ះពាល់ដល់ចរិយាធម៌ទេ)។ នៅក្នុងបរិបទនេះ ក្នុងលក្ខខណ្ឌពិសេសណាមួយ គេអាចបញ្ចប់ជីវិតមនុស្សបាន ដោយមិនប៉ះពាល់ដល់សីលធម៌ឡើយ។ គេសង្កេតឃើញស្ថានភាពដូច្នេះនាពេលបច្ចុប្បន្ននេះ។ ក្នុងករណីដែលមនុស្សឈឺមើលមិនជា មិនជួយព្យាបាលមានសីលធម៌ជាង បញ្ចប់ជីវិតខ្លួនដោយប្រើក្បួនពេទ្យ ហើយគេអាចសន្សំថវិកាដើម្បីជួយដល់អ្នកដែលត្រូវការ។ ជំហររបស់**ស៊ីងហ្គ័រ** នេះបានធ្វើឱ្យមានការតវ៉ាពាសពេញពិភពលោក។ ក្នុងករណីដែលពេទ្យមិនអាចព្យាបាលបុគ្គលដែលមិនពេញលក្ខណៈបាន នោះបញ្ចប់ជីវិតពួកគេមិនចាត់ទុកថាជាអំពើអសីលធម៌ឡើយ។

**ស៊ីងហ្គ័រ** បានចាត់ទុកថា អំពើពីរយ៉ាងមានបញ្ហាសីលធម៌ដូចគ្នា ប្រសិនបើផលវិបាករបស់វាដូចគ្នា៖ (១) ធ្វើអន្តរាគមន៍នៅពេលដែលមានព្រឹត្តិការណ៍កើតឡើង និង (២) មិនធ្វើអ្វីទាំងអស់។ ឧទាហរណ៍ ប្រសិនបើមនុស្សម្នាក់មិនបានជួយជីវិតក្មេងតូចមួយ ទោះបីគាត់អាចជួយបានយ៉ាងស្រួលក៏ដោយ ស្ថានភាពនេះស្មើនឹងមនុស្សម្នាក់នោះសម្លាប់ក្មេងនោះដូច្នេះដែរ។

**សារជាតិរបស់មនុស្ស ៖ ស៊ីងហ្គ័រ** យល់ឃើញថាសារជាតិរបស់មនុស្សធ្វើឱ្យយើងគ្មានសីលធម៌។ បញ្ញត្តិសីលធម៌មានការវិវត្តផងដែរ ដែលពេលដំបូងអារម្មណ៍នេះមានតែចំពោះសាច់ញាតិជិតស្និទ្ធរបស់ខ្លួនតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ វិចារណញ្ញាណ សមត្ថភាពពិចារណាពីទស្សនវិស័យសាកលបានពង្រីកដែនអនុវត្តសីលធម៌ឱ្យបានដល់មនុស្សគ្រប់រូប ហើយបន្ទាប់មកដល់សត្វមានជីវិតទាំងអស់។ ក៏ប៉ុន្តែ សារជាតិរបស់មនុស្សគិតតែប្រយោជន៍ផ្ទាល់ខ្លួនមិនអាចដូចបានឡើយ។ ដូច្នេះ មិនត្រូវរង់ចាំដល់ពេលដែលអាកប្បកិរិយាសីលធម៌ ដែលគិតប្រយោជន៍អ្នកដទៃទទួលជោគជ័យបានឡើយ។ ក៏ប៉ុន្តែ គេអាចដូរសារជាតិរបស់មនុស្សបាន។ តែការដូរនេះ មិនមែនដោយវិធីបដិវត្តន៍សង្គមឡើយ តែដោយធ្វើតាមរយៈការបង្ហាត់

ពូជ។ ដូច្នេះ នាពេលអនាគត យើងនឹងមានសេរីភាពថ្មីមួយ គឺសេរីភាពក្នុងការកែប្រែហ្សែនរបស់មនុស្ស។

# វាក្យស័ព្ទទស្សនវិជ្ជា

| បារាំង | អង់គ្លេស | ខ្មែរ |
|---|---|---|
| *Apeiron* | | អនន្ត |
| *Âme* | | អាត្ម័ន |
| *Arithmatique* | | លេខាគណិត |
| *Atomisme* | | អាតូមនិយម |
| *Autri* | | អ្នកផ្សេង |
| *Bien* | | គុណធម៌ |
| *Bonne volonté* | | សុឆន្ទៈ |
| *Cause de soi* | | មូលហេតុនៃខ្លួនឯង |
| *Cause en soi* | | មូលហេតុក្នុងខ្លួនឯង |
| *Cause efficiente* | | មូលហេតុប្រសិទ្ធផល |
| *Cause finale* | | មូលគោលដៅ |
| *Cause formelle* | | មូលហេតុរាងសណ្ឋាន |
| *Cause matérielle* | | មូលហេតុរូបធាតុ |
| *Cause par soi* | | មូលហេតុដោយខ្លួនឯង |
| *Changement* | | ការផ្លាស់ប្ដូរ |
| *Concept* | | ទស្សនាទាន |
| *Connaissance* | | ពុទ្ធិ ចំណេះដឹង |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| *Conscience* | *Mind* | សម្បជញ្ញៈ |
| *Conscience morale* | | មនសិការ |
| *Contradiction* | | បដិវាទកម្ម |
| *Corp* | *Body* | ពង្សកាយ |
| *Dasein* | | តថភាពនៃមនុស្សលោក<br>អត្ថិភាព |
| *Déduction* | | សព្វឯកវិធី |
| *Devenir* | | ការផ្លាស់ប្តូរ |
| *Dialectique* | | វិចារវិទ្យា |
| *Dieu transcendant* | | អាទិទេពនៅឋានខ្ពស់ |
| *Discours* | | សិក្សាកថា |
| *Doute méthodique* | | វិធីសាស្ត្រសង្ស័យរកការពិត |
| *Dualisme* | | ទស្សនវិជ្ជាទ្វិកនិយម |
| *Ecclésiastique* | | ប្រឆាំងសាសនាកាតូលិក |
| *Empiricisme* | *Empiricism* | ពិសោធនិយម |
| *Entendement* | | វិមំសា |
| *Éphémère* | | បណ្តោះអាសន្ន |
| *Épistémologie* | | ការសិក្សាពីពុទ្ធិ |
| *Esprit* | *Mind* | ស្មារតី  វិញ្ញាណ |
| *Essence* | | សារជាតិ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| *Éthique* | | ចរិយាសាស្ត្រ |
| *Être* | | ភាវៈ ជីវន្ត(ភាព) |
| *Être en soi* | | ភាវៈនៅក្នុងខ្លួនឯង |
| *Être en tant qu'être* | | ភាវៈជាភាវៈ |
| *Évidence* | | សក្ខីកម្ម |
| *Existence* | | អត្ថិភាព ជីវិត |
| *Existencialisme* | | អត្ថិភាពនិយម ជីវិតនិយម |
| *Forme* | | រាង សណ្ឋាន |
| *Général* | | សព្វ |
| *Idéal* | | ឧត្តមគតិ |
| *Idéalisme* | | មនោនិយម |
| *Immanence* | | លោកិយសច្ចៈ |
| *Impulsion* | | និច្ឆន្ទៈ |
| *Inconscient* | | អញ្ញាណសតិ |
| *Induction* | | ឯកសព្វវិធី |
| *Instinct* | | សភាវគតិ |
| *Intelligence* | | បញ្ញា ប្រាជ្ញា |
| *Intuition* | | អព្ភន្តរញាណ សហជញ្ញាណ |
| *Ironie socratique* | | ការចំអកបែបសូក្រាត |
| *Logique* | | តក្កវិជ្ជា |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| Ligicien | | តក្កវិទូ |
| Mal | | អំពើអាក្រក់ |
| Maïeutique | | វិធីបង្កើតកូន |
| Matière | | រូបធាតុ |
| Métaphysique | | បរមត្ថវិទ្យា |
| Monade | | ឯកញាណ សុក្រឹតញាណ |
| Monde intelligible | | មនោភព បញ្ញាញាណ |
| Monde sensible | | ឥន្ទ្រីយភព |
| Néant | | ទទេ សូន្យ |
| Néo- | | នវ |
| Non-être | | អភាវៈ |
| Non-savoir | | អពុទ្ធិ |
| Non-soi | | មិនមែនខ្លួន |
| Noumènes | | បញ្ញាភូតិ |
| Ontologie | | ជីវន្តវិទ្យា |
| Panthéisme | | អាទិទេពជាអ្វីៗទាំងអស់ |
| Particulier | | ឯក |
| Pensée | | គំនិត ពិចារណាគតិ |
| Perception | | ទំនួលអារម្មណ៍ ញាណកម្ម |
| Permanent | | អចិន្ត្រៃយ៍ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| *Philosophie matérialiste* | | ទស្សនវិជ្ជារូបធាតុនិយម ឬ សម្ភារនិយម |
| *Philosophie transcendantale* | | ទស្សនវិជ្ជាអស្តិរូប |
| *Pragmatisme* | | លទ្ធផលនិយម |
| *Pour-soi* | | ជីវិតដើម្បីខ្លួនឯង |
| *Préjudice* | | បុរេវិនិច្ឆ័យ |
| *Propriété* | | គុណជាតុ  លក្ខណៈសម្បត្តិ |
| *Proposition* | | សំណើ |
| *Puissance* | | អានុភាព |
| *Raison* | | វិចារណញ្ញាណ |
| *Réalité* | | តថភាព |
| *Réminiscence* | | អនុស្សារណៈ |
| *Renaissance* | | បុនរុត្ថិសម័យ |
| *Révélation* | | វិវរណៈ |
| *Sagesse* | | គតិបណ្ឌិត |
| *Savoir* | | ពុទ្ធិ |
| *Scepticisme* | | មជ្ឈជាតុនិយម  មិនអាចរកការពិត |
| *Sémantique* | | អត្ថន័យ ឬនិយណ្តសាស្ត្រ |
| *Sensation* | | ឥន្ទ្រីយារម្មណ៍  វេទនារម្មណ៍ |
| *Substance* | | សារជាតុ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| *Stoïciens* | | ខន្តីនិយម មិនត្អូញត្អែរ |
| *Syllogisme* | | ត្រ័យវាទនិយម |
| *Temps* | | កាល |
| *Traité* | | អភិប្រាយ |
| *Transcendant* | | ឧត្តមភាព ឋានលើ ហួសពីលោកិយសច្ចៈ |
| *Vérification* | | ពិនិត្យបញ្ជាក់ |
| *Vérité* | | សច្ចធម៌ |
| *Utopiste* | | អចិន្តបុគ្គល |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# គន្ថនិទ្ទេស


១-ឯកសារជាខេមរភាសា ៖

**ខ្មៅ សាវន, ប៉ាន់ វុត្ថា, ឈត ប៊ុនថន, ឈុន ផារ៉េន, អ៊ុន លាង,** ២០០៨ «មូលដ្ឋានរបស់ទស្សនវិជ្ជា» ភ្នំពេញ

**ខ្លូត ធីតា** ២០០៦ «មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជា» *Fundamental of Philosophy,* រាជបណ្ឌិត្យសភាកម្ពុជា

ព្រះមហាវិរិយបណ្ឌិតោ **ប៉ាង ខាត់** (១៩៦៩) «ទស្សនវិជ្ជាពុទ្ធសាសនា» ទស្សនាវដ្ដី កម្ពុជសុរិយា

**រស់ ចន្ទ្រាបុត្រ** ១៩៧២ «សូក្រាត»

**វ៉ាន់ឌី កាអុន** ២០១៣ «ពិជ្ជកាពខ្លះៗនៃទស្សនវិជ្ជា» *Vandy Kaon. Quelques aspects de la philosophie du Vie siècle av. J.-C. à nos jours.*

**សរ សារុន** ១៩៧៤ «អត្ថាធិប្បាយទស្សនវិជ្ជា» *La Dissertation philosophique.* សម្រាប់ថ្នាក់ទីបញ្ចប់ និងថ្នាក់ឧត្តមសិក្សា

**ស៊ិន សុវណ្ណនិ** ២០១២ «អភិទស្សនវិជ្ជារបស់ព្រះពុទ្ធ»

**សុខ សុត្ថាល** ២០១៥ «ទស្សនវិជ្ជា៖ សំណួរ ចម្លើយ អត្ថាធិប្បាយ»

**សុខ សូផាត** ២០១០ «ជីវិតចុងក្រោយរបស់សូក្រាត» *The Last Days of Socrates.*

**អេវ៉ាន អាស្លី** ២០១២ «អំណាចទស្សនវិជ្ជាពីលោកបុរាណ ទៅលោកម៉ាក្ស» សាកលវិទ្យាល័យភ្នំពេញ មហាវិទ្យាល័យទស្សនវិជ្ជា បោះពុម្ពលើកទី៤




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២-ឯកសារជាភាសាបរទេស៖


Alain (1928). *Propos sur le bonheur*. Paris: Gallimard.

Alain (1940). *Éléments de philosophie*. Paris: Gallimard.

Annas, J. (2000). *Ancient Philosophy: A Very Short Introduction*. Oxford: Oxford University Press.

Apel, K.-O. (1998). *From a Transcendental-Semiotic Point of View*. Manchester: Manchester University Press.

Arendt, H. (2002). *Le système totalitaire*. Paris: Seuil.

Arendt, H. et Jaspers, K. (2006). *La philosophie n'est pas tout à fait innocente*. Paris: Payot & Rivages.

Beaney, M. (2017). *Analytic Philosophy: A Very Short Introduction*. Oxford: Oxford University Press.

Belsey, C. (2002). *Poststructuralism: A Very Short Introduction*. Oxford: Oxford University Press.

Craig, E. (2002). *Philosophy: A Very Short Introduction*. Oxford: Oxford University Press.

Collette, J. (1999). *L'existentialisme. Troisième edition corrigée*. Paris: Press universitaire de France.

Colebrook, C. (2002). *Gilles Deleuze*. New York: Routledge.

Compte, A. (1830-1842). *Cours de philosophie positive*. Paris: Larousse.

Deleuze, G. (1988). *Spinoza: Practical Philosophy*. San Francisco: City Lights Books.

Dennett, D. C. (1969). *Content and Consciousness*. Boston: Brill Academic Publishers.




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

-------(1981). *Brainstorms: Philosophical Essays on Mind and Psychology*. Cambridge: MIT Press.

-------(2003). *Freedom Evolves*. New York: Viking Adult.

-------(2017). *From Bacteria to Back and Back. The Evolution of Minds*. New York:  Norton & Company.

Durant, W. (1961). *The Story of Philosophy*. New York: Simon & Schuster Paperbacks.

Gottlieb, A. (2016). *The Dream of Enlightenment. The Rise of Modern Philosophy*. London: Penguin Books.

Hadot, P. (1995). *Qu'est-ce que la philosophie antique?* Paris: Gallimard.

Harwood, J. (2010). *Philosophy. A Beginner's Guide to the Ideas of 100 Great Thinkers*. London: Quercus.

Honderich, T. (eds) (2015). *Philosophers of Our Times*. New York: Oxford University Press.

Huisman, D. (1984). *Dictionnaire des philosophes*. Paris: Presses Universitaires de France.

Jaspers, K. (1962). *Socrates, Buddha, Confucius, Jesus. The Paradigmatic Individuals.* San Diego: Harcourt

Kant, E. (1954). *La raison pure*. Paris: Presses Universitaires de France.

Kant, E. (1956). *La raison pratique*. Paris: Presses Universitaires de France.

Kierkegaard (1949). *Traité du désespoir*. Paris: Gallimard.

Kuhn, Thomas (1962) *The Structure of Scientific Revolutions*.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Chicago: University of Chicago Press.

Lefranc, J. (1998). *La philosophie en France au XIXè siècle.* Paris: Presses Universitaires de France.

Livingston, P. & Cutrofello, A. (2015). *The Problems of Contemporary Philosophy*. London: Polity.

Matsas, N. (1983). *Les mémoires de Socrate d'après le manuscrit d'Athènes*. Paris: Les belles lettres.

McGinn, C. (2015). *Philosophy of Language: The Classics Explained*. Cambridge: The MIT Press.

McGinn, M. (2013). *The Routledge Guidebook to Wittgenstein's Philosophical Investigations*. London: Routledge.

Nietzsche, F. (1994). *Premiers écrits : "Le monde te prend tel que tu te donnes"*. Paris: Le Cherche-Midi.

-------(1995). *Humain, trop humain*. Paris: Le livre de poche.

-------(2000). *Par-delà le bien et le mal*. Paris: Le livre de poche.

-------(2000). *La Généalogie de la morale*. Paris: Le livre de poche.

Pinker, S. (1997). *How the Mind Works*. New York: W. W. Norton Company

-------(2002). *The Blank Slate. The Modern Denial of Human Nature*. New York: Viking Adult.

Popkin, R. (ed.) (1966). *The Philosophy of the 16th and 17th Centuries*. New York: The Free Press.

Popper, K. (1963) *Conjectures and Refutations: The Growth of Scientific Knowledge*. New York: Basic Books.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Rorty, R. (1978). Philosophy and the Mirror of Nature. Princeton University Press. Princeton and Oxford.

-------(1979). *Philosophy and the Mirror of Nature*. Princeton: Princeton University Press.

-------(1982). *Consequences of Pracmatism: Essays 1972-1980*. Minneapolis: University of Minnesota Press.

Russell, B. (2010). *History of Western Philosophy*. London: Routledge.

Ryle, G. & Dennett. D. (1949). *The Concept of Mind*. London: Penguin Books.

Scruton, R. (2016). *Philosophy: Principles and Problems*. London: Bloomsbury.

Searle, J. R. (1969). *Speech Acts: An Essay in the Philosophy of Language*. Cambridge: Cambridge University Press.

-------(1983). *Intentionality: An Essay in the Philosophy of Mind*. Cambridge: Cambridge University Press.

-------(2004). *Mind: A Brief Introduction*. New York: Oxford University Press.

-------(2010). *Making the Social World: The Structure of Human Civilization*. Oxford: Oxford University Press.

-------(2015). *Seeing Things As They Are*. Oxford: Oxford University Press.

Singer, P. (1993). *How Are We to Live? Ethics in an Age of Self-Interest*. Melbourne: Random House Australia.

-------(2002). *One World: Ethics and Globalization*. New Haven:



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Yale University Press.

Singer, P. (2015). *The Most Good You Can Do: : How Effective Altruism Is Changing Ideas About Living Ethically*. New Haven: Yale University Press.

Soumet, H. & Kerdraon, A., et al. (2013). *Le Petit Larousse des Grands Philosophes*. Paris: Larousse.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៥នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរ-ជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកជានារ៉ាប់រងពីវិទ្យាស្ថានជានារ៉ាប់រង(CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានជានារ៉ាប់រងម៉ាឡេស៊ី(MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គ-លេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះលោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋា-ភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសិទអន្តរជាតិ ដូចជាមហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ក្រោមចំណងជើងថា «Cambodian Economy: Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះ-ពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ «Series of Lectures in Public International Law»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្នាដៃរបស់អ្នកនិពន្ធ

១- *L'Économie du Cambodge : La lutte pour le développement, 2005*

២- *Essais économiques, 2007*

៣- *Les finances publiques du Cambodge, 2007*

៤- *Cambodia: Recent Macroeconomic and Financial Sector Development, 2008*

៥- *Three Essays on Macroeconomic Management of Cambodia, 2008*

៦- *Introduction to Insurance, 2008*

៧- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩

៨- *Public Finance in Cambodia, 2009*

៩- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩

១០- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩

១១- *Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009*

១២- *L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010*

១៣- *Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012*

១៤- ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣

១៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖
មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦

១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍ ឆ្នាំ១៩៨០) - ឆ្នាំ២០១៧

១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧

១៩- *Series of Lectures in Public International Law, 2018*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia